## រឿង

# អំបែងអណ្តែត


និពន្ធ គូរគំនូរ និង រចនាក្របដោយ

*អ្នកស្រី កែវ ចន្ទបូរណ៍*

P.O.Box 600279
Saint Paul, MN 55119
USA
khmervissal @ yahoo.com



ជំនួយការពិសេស

*សាស្ត្រាចារ្យ យូ សុភា*

មជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម



ទាក់ទងទូទៅ

016-318-023
012-774-751



ខែតុលា ២០០៦



រក្សាសិទ្ធិគ្រប់យ៉ាង

CHANBOKEO.COM

# ស្នាដៃខ្លះៗរបស់អ្នកស្រីកែវចន្ទ័បូរណ៌

១- រឿង សំនៀងស្នេហ៍កវី
២- រឿង និស្ស័យស្នេហ៍
៣- រឿង ផ្កាយវង្វេងមេឃ
៤- រឿង ស្នាមញញឹម
៥- រឿង កុលាបស្មឹងខៀវ
៦- រឿង ក្លិនផ្កាមាលតី
៧- រឿង លិខិតមរតកសម្ងាត់
៨- រឿង បំណុលជីវិត
៩- រឿង ចរណៃដួងទ័យា
១០- រឿង អំបែងអណ្តែត
១១- រឿង ស្នេកចាកផុតទៅ
១២- រឿង តន្ត្រីបេះដូង
១៣- រឿង សារាណីយមាតា
១៤- រឿង ទារុណដួងចិត្ត
១៥- រឿង បើសិននៅមានថ្ងៃស្នេក
១៦- រឿង លំអងផ្កាស្នេហ៍
១៧- រឿង ត្រៃមិត្ររតននារី
១៨- រឿង ខ្មើយវាសនា
១៩- រឿង បើសិនអាចបង្វិលផែនដី
២០- រឿង សីវបុរេកាល
២១- រឿង មេឃដ៏សក្តិសិទ្ធិ
២២- រឿង មួយពាន់ទំព័រ
២៣- រឿង អាមេរិកដែនដីមាស
២៤- រឿង អាធ្រាតថ្ងៃរះ
២៥- រឿង បក្សីសួនសុបិន
២៦- រឿង ម្លប់អសោក
២៧- រឿង ពិជេដ្ឋភានុមា
២៨- រឿង ផ្ការីកក្រៅសួន
២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ
៣០- រឿង អនង្គលាភា
៣១- រឿង ពណ្ណរាយពេជ្រ
៣២- រឿង សារិកា
៣៣- រឿង ផ្ការាជបឹងរាំង
៣៤- រឿង នភាមណី
៣៥- រឿង ស្រីនាថភ្លួងមាលា
៣៦- រឿង វាយោដួងចិត្ត

CHANBOKEO.COM

October 2006

ISBN: 99950-79-01-1

9 789995 079017

# សូមឧទ្ទិសស្នាដៃនេះប្រគេននិងជូនចំពោះ

- ព្រះគ្រូ សេងប៊ុនសង ព្រះគ្រូចៅអធិការ ម៉ឹងសាង ភិក្ខុ វុមភិរម្យ ភិក្ខុ គិមសុវត្ថិ ភិក្ខុ ជុំ វិចិត្រ ភិក្ខុ គង់សុជា វត្តមិនីសូតារាម រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

- លោក មេងសួងសុវណ្ណធី ជាស្វាមី និង កុមារី សុវណ្ណធីធម្មិកាបារមីបុណ្យជាបុត្រី

- លោកឪពុក ប៊ុនថង អ្នកម្តាយ កែវយឿង និងប្អូនទាំងប្អូនព្រមទាំងក្រុមគ្រួសារ

- លោកឪពុកក្មេក មេងសួង និងអ្នកម្តាយក្មេក កូវសារ៉ាន់ ព្រមទាំងកូនចៅ

- សាស្ត្រាចារ្យគិមមាសកួយ រស់សាន់ អួនឡើង និង ចាន់សុខា បណ្ឌិតឃូគិមទូយ

-អ្នកស្រីនៅសារិម វិទ្យុសម្លេងសហរដ្ឋអាមេរិក វីអូអេ

- លោក លីតាយហុង អ្នកគ្រូ ទូចសារៀង អ្នកគ្រូ កែវសុផុន លោករីនេរស់ អ្នកស្រីប៉ក់ដារិនី - អ្នកគ្រូមៀចសុខារី វិទ្យាល័យនេតយ៉ង់ បាត់ដំបង ។

- លោកអ៊ិមសុនាថ លោកជិនសោរិន លោកជាសយនា សារពតិមានកោះសន្តិភាព

- លោកខូតារាឫទ្ធិ នាយកកម្មវិធីសម្ភូហកម្មអក្សរសិល្ប៍ខ្មែរហាច ភ្នំពេញ

CH .COM



អ្នកស្រី កែវ ចន្ទ័បូរណ៍

# វាចាអ្នកនិពន្ធ

ដោយហេតុថានាងខ្ញុំបានសំណូមពរពីអ្នកអានសូមអោយនាងខ្ញុំ សរសេរចងក្រងរឿងជីវិតរបស់កម្មករកម្មការិនីទុរគតក្រីក្រ និង រឿងរបស់គ្រួសារដែលរងគ្រោះ ដោយជម្ងឺអេដស៍ នាបច្ចុប្បន្ននេះ នាងខ្ញុំក៏សំរេចចិត្តនិពន្ធរឿងនេះឡើង ដើម្បីជូនជាការលើកកម្លាំង ចិត្តដល់ខេមរញាតិ ដែលរងគ្រោះ ដោយគ្មៀបអ្នកមានទុច្ចរិត ជាពិសេសទៅទៀត គឺដើម្បីឆ្លើយតបទៅនឹងគុណធម៌របស់អ្នកអាន ទាំងឡាយ ដែលមានចិត្តអាណិតអាសូរ និងជួយឧបត្ថម្ភដល់ជន ទីទ័លច្រកដោះស្រាយជីវិតដោយសន្តានចិត្តសប្បុរសធម៌ ។

សូមអោយអ្នកអានទាំងឡាយ បានទទួលនូវរសជាតិជីវិតនៃ ការតស៊ូព្យាយាមរបស់អ្នកក្រីក្រ ក្នុងការស្វែងរកអនាគតភ្លឺស្វាង នៅក្នុងប្រលោមលោកមនោសញ្ចេតនា "អំបែងអណ្តែត" នេះ កុំបីខាន ។

នាងខ្ញុំអ្នកនិពន្ធ សូមទទួលនូវមតិយោបល់ពីប្រិយមិត្តអ្នកអាន តាមរយៈ អស័យដ្ឋានដូចខាងក្រោមនេះ :


Pannalai Khmer Vissal
`P.O.Box 600279
Saint Paul, MN 55119, USA
Khmervissal@yahoo.com


ខែសីហា២០០៦
អ្នកស្រី កែវ ចន្ទ័បូរណ៍
មិនីសូតា សហរដ្ឋអាមេរិក

CHANBOKEO.COM

# កំណាព្យ

==========================================

## មុននឹងអស់សង្ខ័យ....

កើតចាស់ឈឺស្លាប់ច្បាប់ធម្មជាតិ មនុស្សមិនអាចឃ្លាតអាចបំពាន
តែនៅអាចជ្រើសជីវិតបាន ពេលរស់គ្រប់ប្រាណសាងក្តីល្អ ។
ទាន់មានជីវិតគិតវៀងវៃ សាងខ្លួនប្រពៃក្នុងសីលធម៌
ប្រព្រឹត្តសុចរិតក្រិត្យបវរ ធ្វើអំពើល្អចំពោះញាតិ ។
នៅក្មេងបណ្តុះសព្វវិជ្ជា ជំនាញសាស្ត្រាមិនរវាត
ធំឡើងធ្វើការស្វែងអស់ស្បៀត ចិញ្ចឹមផៅញាតិចាកអត្តខាត់ ។
មិនខ្ជិលទំរន់ទន់រាងកាយ ងើបឡើងធ្វើហើយយ៉ាងប្រយត្ន័
ពាក្យម៉ែឪផ្តាំចាំគ្រប់ម៉ាត់ ប្រព្រឹត្តមធ្យ័តជាគំរូ ។
ដល់ចាស់ពេញវ័យស្តីពិរោះ ស្រឡាញ់ស្នេហ៍ស្មោះថែធួនគ្រួ
អប់រំកូនចៅដោយគុណធម៌ មិនជោរប្ញកជួរឆ្មើងកន្រ្ទើង ។
ធ្វើខ្លួនជាទីហៅស្រឡាញ់ ញាតិផងត្របាញ់ស្កាត់រកយើង
ផ្តល់គំនិតខ្ពស់រស់ថ្កុំថ្កើង ថែធួនស្រុកយើងរស់សប្បាយ ។
នោះដល់យើងស្លាប់បិទភ្នែកជិត ត្បិតព្រោះជីវិតសុក្រិតក្រៃ
សាងនូវក្តីល្អសព្វវិស័យ គំរូប្រពៃនៃកូនចៅ...

CHANBOKEO.COM

# ក្បួនប្រល័យខ្មែរដោយចំហ

ក្បួនប្រល័យខ្មែរមានងាយៗ តែគួរអោយស្តាយយើងភ្លេចគិត
ល្បិចបំផ្លាញខ្មែរស្រួលអស់ចិត្ត បណ្តោយវិបរិតខ្មែរងាប់ឯង ។
កលប្រល័យខ្មែរមានអវិជ្ជា ខ្មែរល្ងង់វេទនារស់ចំបែង
មិនចូលរៀនសូត្រខ្លួនវង្វេង ខ្មែរឆោតបែរឆ្វេងលែងស្គាល់ល្អ ។
កលមួយបណ្តោយឱ្យខ្មែរងោះ មិនស្គាល់ត្រូវខុស ខ្មៅ ឬ ស
គិតតែកាប់ចាក់ពេញនគរ លែងមានសីលធមិចំពោះគ្នា ។
កលមួយទុកអោយខ្មែរកម្លៅ ចិត្តខ្មៅបង្កភ្លើងទោសា
ជាន់កក្តាឯងឥតមេត្តា រួចឱនសិរសាជូនជាតិគេ ។
តាំងពីចំរៀងរឿងស្លៀកពាក់ សក់លឿងលាបល័ក្សឥតគ្នាន់គ្នេរ
បើប្រពៃណីស្រែកថាទេ រត់រេះគេចបែរបាត់រាប់យោជន៏ ។
បើឆ្កួតផឹកស៊ីច្រៀងធុងបាស បោកកែវឈ្លោះណាស់ឥតប្រដូច
យាយីខ្ទែរឯងមុខសំពោច ងាប់បោសដៃរួចដើរចូលគុក ។
លើថ្នល់រចល់ដោយយន្តយាន គ្មានអធ្យាស្រ័យសាងក្តីសុខ
ខឹងគ្នាត្រង់ណាបរដេញបុក បាញ់រះសំរុកយកឈ្នះដៃ ។
កវីឃើញហើយគិតសង្វេគ អាណិតជាតិពេកតឹងទ្រូងក្រៃ
យើងធ្វើយ៉ាងណាជួយជាថ្មី ស្រង់ខ្មែរផុតភ័យល្បិចបំផ្លាញ ។

CHANBOKEO.COM

# បំណាច់នឹង...

បំណាច់នឹងរៀនរៀនអោយចេះ　　　ក្បូង់យកតម្រេះជួយខ្លួនឯង
បំណាច់នឹងសេពគួរគិតឈ្វេង　　　សេពប្រាជ្ញជាក់ស្តែងស្រង់វិជ្ជា ។
បំណាច់នឹងមានអោយមានសីល　　　ជ្រះអស់មន្ទិលពៀរវេរា
មិនសាងទុច្ចរិតលើ "ខ្មែរអ៊ា"　　　មាននេះល្អជានាមាខ្ពស់ ។
បំណាច់ស្រដីស្តីសមហេតុ　　　ស្តីនូវប្រភេទនាំអត្ថរស
អ្នកផងបានស្តាប់គាប់គ្មានទាស់　　　ស្តីពាក្យពិរោះរសខ្លឹមសារ ។
បំណាច់នឹងហុចកុំសូញសាញ　　　ហុចហើយកុំទាញស្រង់ចុងការ
ហុចនេះមិនហៅមានសទ្ធា　　　ចំពោះញាតិការដោយស្មោះស្ម័គ្រ ។
បំណាច់ចង់ល្អអោយល្អចិត្ត　　　បេះដូងសុក្រិតឥតអប្បលក្ខណ៍
បំណាច់នៅស្ងៀមចេះស្តាប់ជាក់　　　ពិចារណ៍ជ្រៅរាក់ដឹងសេចក្តី ។
បំណាច់នឹងក្រអោយចេះស៊ូ　　　ព្យាយាមផ្តាច់ប្តូរចាកអវិថី
ក្រព្រោះសុចរិតព្រះប្រណី　　　អ្នកស្រុកប្រុសស្រីគង់យល់ហេតុ ។
បំណាច់នឹងចេះអោយគេកោត　　　ចែកការពិសោធន៏គ្រប់ប្រភេទ
ចេះរៀនចេះស្តាប់ចេះសង្កេត　　　ចេះដឹងច្រៀកហែកចែកគ្នារៀន ។
បំណាច់ប្រព្រឹត្តអោយសុចរិត　　　រក្សាសុក្រិតមិនបំពាន
គន្លងសីលធមិជាធរមាន　　　ជីវិតច្បាស់មានសុភមង្គល ។

CHANBOKEO.COM

# អវិជ្ជានិងកម្លៅ

អវិជ្ជាមានន័យថាល្ងិតល្ងង់ ចង់ភ្លឺរៀនឡើងអោយជ្រះស្វាង
សាងខ្លួនខ្ពង់ខ្ពស់មានសំណាង ធ្វើមេចាងហ្វាងគ្រប់គ្រងការ ។
អវិជ្ជាមានន័យថាមិនចេះ ស្រវាតម្រេះត្រេងសិក្សា
បណ្តុះខ្លួនឡើងយសភ្លឺថ្លា ក្លាយជាបញ្ញាជនគំរូ ។
រីឯកម្លៅមានន័យផ្សេង ជាអ្នកចេះដឹងប្រឹងគឃូរ
វាយឫកអញចេះគ្មានអ្នកប្តូរ កុំជោរកែកុនអោយយោបល់ ។
កម្លៅសំដៅអ្នកដឹងចេះ មានចិត្តមានះមិនរវល់
ពុំស្តាប់គតិយោងហេតុផល ច្រានចោលយោបល់រិះគន់ខ្លួន ។
ជងឺពីរនេះឈឺខុសគ្នា ឈឺអវិជ្ជាពេទ្យអាចស្ទួន
តែឈឺកម្លៅគ្មានទេក្បួន ពេទ្យអាចថៃធួនជាងាយឡើយ ។

# អណ្តូតអភិវឌ្ឍន៍

អណ្តូតឥតឆ្អឹងរលាស់សែនស្រួល　　　អណ្តូតរមួលបានគ្រប់ភាសា
អណ្តូតក្រឡេវគ្រលាស់វាចា　　　សុខទុក្ខយ៉ាងណាពឹងលើអណ្តូត ។
បើដឹងដូច្នោះយើងរៀនបញ្ញា　　　អណ្តូតមានងារចចារឆ្លៀវឆ្លាត
គ្រលាស់រកផលប្រយោជន៍ជូនជាតិ　　　មិនអោយឃ្លាឃ្លាតចាកអំពើល្អ ។
បំណាច់គ្រលាស់សូមច្បាស់ភាសា　　　អណ្តូតវោហារសាស្ត្រាគុណធមិ
រលាស់នាំផលជូនញាតិបវរ　　　ខេមរាបែរល្អតាមរសអណ្តូត ។
នោះទើបហៅល្បីអណ្តូតមាសប្រាក់　　　គ្រលាស់កៀវឆ្លាក់ប៉ាក់ខ្មែរឱ្យស្អាត
នគរថ្កុំថ្កើងរុងរឿងស្រុកជាតិ　　　អណ្តូតមានស្នៀតនាំអភិវឌ្ឍន៍ ។

CHANBOKEO . COM

# បើចង់សម្លឹងឱ្យបានឆ្ងាយ

បើកភ្នែកមើលឃើញត្រឹមជើងមេឃ　　　បិទវិញឃើញប្លែកឆ្លងពិភព
ឆ្លងយុគសម័យឆ្លងជាតិគ្រប់　　　ឃើញក្រៅក្នុងសព្វមិនខ្វះអ្វី ។
និពន្ធសំណេរស្នេរសំណៅ　　　សង្កេតរាងរៅត្រឹមភ្នែកវៃ
យល់ត្រឹមសំបកខ្វះខ្លឹមន័យ　　　ចង់ជ្រៅសេចក្ដីបិទភ្នែកគិត ។
បើកភ្នែកឃើញតូចបិទក្លាយធំ　　　ប្រមូលអារម្មណ៍មកពិនិត្យ
សម្លឹងអ្វីៗដោយគំនិត　　　វិភាគល្អិតល្អិតក្រិត្យអត្ថរស ។
កុំមើលដោយភ្នែកវាយសំបក　　　ឃើងច្បាស់ប្រែខកដឹងមិនអស់
បិទភ្នែកគិតវិញមើលខ្លឹមយស　　　ពិចារណ៍អត្ថរសច្រោះល្អិតល្អន់ ។
នោះឃើងនឹងឃើញជ្រៅវែងឆ្ងាយ　　　ឃើញទាំងរូបកាយមិនមានអន់
ទាំងដួងព្រលឹងវិញ្ញាណក្ខន្ធ　　　ខ្លឹមរសសំខាន់អស់សេចក្ដី ។

CHANBOKEO.COM

# ខ្សិប

មិនអោយគេឮខំឈ្ងោកខ្សិប          បបូរមាត់ខ្ចិបសៀងខ្សោយៗ
ខ្សិបតែមួយពាក្យបែកមួយរយ          បង្ហើរឆ្ងាយហើយដល់ជើងមេឃ ។
ម្នាក់ខ្សិបម្នាក់ស្តាប់ម្នាក់លួចផ្ទៀង          ម្នាក់ទៀតមិចមៀងពួនត្រងត្រេក
ចង់ដឹងគេខ្សិបរឿងចម្លែក          ម្នាក់ទៀតកេះញែកសុំដឹងផង ។
ខ្សិបរឿងក្អែកមួយជួយកើនដប់          ខ្សិបផ្សាយឆ្ងាយសព្វដល់ប្អូនបង
នាំគ្នាខ្សិបតលាន់រំពង          ខ្សិបឮឆ្ងាយហោងមិនបាច់ប្រឹង ។
ថ្ងៃមានរឿងអ្វីកុំឡូឡា          រឿងតូចក្រួចឆ្មារចង់ពង្រីង
យើងខ្សិបគ្នាវិញរឿងទាំងហ្នឹង          តូចក្លាយជង្គ្រឹងរឹងមិនលែង ។
ខ្សិបរឿងថៃជាតិថៃសាសនា          រឿងប្រៀនសាស្ត្រាល្អចិញ្ចែង
ប្រដៅខ្សិបៗថ្នមសម្លេង          កុំជ្រុលកំហែងគំហកខ្លាំង ។
ថ្នមពាក្យសំដីពេលស្តីប្រាប់          កូនច្បាស់ប្រឹងស្តាប់ពេញកម្លាំង
កុំធ្លោយឡូឡាលាន់ក្ខុងក្ខាំង          ក្រែងកូនប្រឆាំងស្អប់លែងបៀត ។
ខ្សិបដោយស្រទន់យន់កាយកល          ខ្សិបពាក្យនិមលល្អវរនាថ
ខ្សិបរឿងចំរើនកើនមិនឃ្លាត          ផ្សាយដល់ផៅញាតិពេញកម្ពុជា ។

CHANBOKEO.COM

# សំដី

សំដីមួយម៉ាត់មានន័យរាប់ម៉ែត្រ ប្រាប់អស់រឿងហេតុ នាំនូវដំណឹង
សំដីនិយាយប្រាយមិនបាច់ប្រឹង ន័យលាតសន្ធឹងឆ្ងាយដល់ជើងមេឃ ។
សំដីស្តីល្អជាតិចរចំរើន សំដីខ្លៅច្រើននាំនូវសង្វេគ
សំដីអសុរសនាំមោហ៍អនេក សំដីអួតប្លែកញាតិរេរកចំអក ។
បំណាច់នឹងហារ ស្វែងពាក្យពិរោះ មានន័យអត្ថរសកុំអោយស្តីខក
អាណិតមុខមាត់អ្នកស្តីស្តាយត្រក សំដីហួសខកបាក់មុខនរណា?
សំដីជាម៉ែត្រនៃការចេះដឹង បំណាច់នឹងប្រឹងស្រដីវាចា
និយាយពាក្យថ្លៃន័យវិញ្ញូពិស្តារ ញាតិស្តាប់កាលណាបានសារប្រយោជន៍ ។

CHANBOKEO . COM

# ទាបនិងតឿ

ទាបៗមានន័យថាមិនខ្ពស់ តែអាចលូតលាស់ខ្ពស់ទៀតបាន
ឃើញឈើនៅទាបស្រោចកុំខាន យូរគង់លូតថ្កានខ្ពស់ជាងមុន ។
ទាបទន់វិជ្ជាអាចរៀនសូត្រ ប្រឹងដកពន្លូតមិនមានស៊ុន
ទាបមានឱកាសខ្ពស់ទៀតគ្រាន់ មិនភន្ត័នឹងថ្កល់មួយកន្លែង ។
ចំណែកតឿវិញពិបាកកែ មនុស្សសត្វឈើដែរសែនចំបែង
តឿពិបាកកែបែររអែង លូតយ៉ាកក្រៃលែងងើបមិនបាន ។
ដូចគំនិតតឿយ៉ាប់នឹងជួយ អោយលូតលាស់ត្រួយខ្ពស់ថ្កើងថ្កាន
ឯវិជ្ជាតឿពិតរំខាន ទៅមុខមិនបានខ្ពស់មិនរួច ។
ទាបមានន័យថាមានឱកាស កែឆ្នៃប្តូរផ្លាស់លូតមិនខូច
ប៉ុន្តែតឿវិញគ្មានអ្វីដូច លូតទៅមិនរួចតឿណាំងៗ ។

CHANBOKEO.COM

# "មិនដល់អញ!"

អស្មិមានះចរិតខ្មែរ (ខ្លះ១) តែងគិតថាគេមិនដល់អញ
ចេះមួយសៀវភៅអួតត្របាញ់ ស្ដីក្លាមុខខ្លាញ់ឆ្វាញ់អំនួត ។
សីលប្រាំចាំបានគ្មានចន្លោះ ស្រណោះប្រព្រឹត្តខុស ខុសត្រួត
មាត់វិញក្មេងក្មាងចាងភរភូត ដឹងមួយពន្លួតអួតដឹងដប់ ។
ហុតទឹកខំប្រឹងសម្លឹងកាក ហុចមួយចង់ផាកបកត្រឡប់
រកលាភចូលវិញទ្វេជាដប់ ស្រវាឆក់ទ្រព្យមិនដល់អញ ។
កុំជេរមកប្រាប់ថាអញខ្វះ អញមានខ្លាំងណាស់គួរស្រឡាញ់
មុខដូចអ្នកវិញមិនដល់អញ កុំខ្ចាញ់មកបៀតឆ្មៀតប្រាប់អី ។
នេះហើយចរិតពិតបច្ចុប្បន្ន ខ្មែរយន់គំនិតគិតអប្រិយ
មិនចេះយោគយល់អធ្យាស្រ័យ អញនេះសែនល្បី មិនបាច់កែ ។

CHANBOKEO.COM

# សន្សំនិងកំណាញ់

សន្សំមានន័យថាសំចៃ　　　តិចតួចលកលៃ កុំអោយខ្វះ
ក្រែងថ្ងៃមួយដាច់ធ្វើមុខក្រាស់　　　ផ្ដេសផ្ដាសដើរខ្ចីអស់ផងញាតិ ។
កំណាញ់មានន័យថាមិនអោយ　　　មើលបំណាំហើយប្រឹងត្បិតត្បៀត
ឃើញក្រឃើញខ្វះមិនហុចញាតិ　　　ចិត្តឃ្លាតសប្បុរសអស់សទ្ធា ។
សន្សំគឺលៃសំចៃធន　　　ទុកគ្រាន់ប្រើប្រាស់ក្នុងគ្រួសារ
មានភាគរំលែកចែកញាតិការ　　　មួយភាគវត្តវ៉ាធ្វើបុណ្យទាន ។
កំណាញ់ស្រោបចិត្តគិតឱបប្រាក់　　　ទូលរែកទុកដាក់ក្នុងវិមាន
ដេករាប់ខ្លាចអស់ពន់ប្រមាណ　　　ស៊ូឃ្លាតសន្ដានកុំឃ្លាតប្រាក់ ។
ពីរម៉ាត់មានន័យយ៉ាងធំធេង　　　ជាក់ស្ដែងខុសគ្នាយ៉ាងប្រត្យ័ក្ស
សន្សំមានញាតិរាប់ឥតអាក់　　　កំណាញ់វិញស្លាក់អត់ញាតិក្បែរ ។

CHANBOKEO.COM

# ខ្មែរបីកំណាត់

ខ្មែរលើខ្មែរក្រោមខ្មែរកណ្ដាល នាំគ្នាអុជអាលបំបាត់ឈ្មោះ
ខ្មែរមួយអួតអាងប្រឹងឱ្យខ្ពស់ ខ្មែរមួយឱបយសរស់ម្នាក់ឯង ។
ខ្មែរក្រោមកំសត់អស់ទឹកដី ដេកគិតភិតភ័យយំក្តែង១
ខ្មែរនៅកណ្ដាលច្រៀងឥតក្រែង កាត់ជើងដៃឯងសល់តែខ្លួន ។
បដិសេធខ្មែរលើថាជាថៃ ថាខ្មែរក្រោមក្ដីជាសាសន៍យួន
អ្នកនៅកណ្ដាលទើបសមសួន ថាខ្លួនគ្រប់គ្រាន់គ្រប់លក្ខណៈ ។
តើគ្រប់ម្ដេចទៅខ្មែរកណ្ដាល ប្រមាថពាសវាលឥតបណ្ដាក់
កាត់ខ្មែរលើក្រោមចោលឥតអាក់ ជើងដាច់ក្បាលបាត់នៅតែខ្លួន ។
លួតលាស់ម្ដេចកើតបើយើងកាត់ ខ្មែរបីកំណាត់មួយចែកយួន
មួយទៀតចែកសៀមច្រើនចំនួន រួចហើយអួតខ្លួនជាខ្មែរសុទ្ធ ។
អនិច្ចាខ្មែរណាស់មិនស្គាល់ខ្មែរ ចែកកេរ្ដិ៍ជូនតាមិនតក់ស្លុត
កាត់លើឱ្យសៀមមិនឱ្យភ្លាត់ ក្រោមឱ្យយួនបាត់សល់កណ្ដាល ។
ពេលណាទើបយើងប្រមូលគ្នា ជុំជាគ្រួសារយ៉ាងវិសាល
ខ្មែរលើខ្មែរក្រោមខ្មែរកណ្ដាល ជាថ្នាលកម្ពុជាជាតិតែមួយ?

CHANBOKEO.COM

# ថ្នាំគ្រុនចាញ់

គ្រុនចាញ់ពេទ្យប្រាប់លេបគីនីន　　　　រសជាតិសែនល្វីងខ្លឹមណាស់វើុយ
ទោះបីយល់ថាលេបហើយស្បើយ　　　　ក៏ចិត្តនៅឡើយខ្ពើមជាតិថ្នាំ ។
លុះបែរប្រទះផ្លែស្វាយទុំ　　　　ទន្ទេញរងំទាររកញ៉ាំ
បានមួយចំណិតសុំថែមប្រាំ　　　　លេបផុតលែងទ្រាំគ្រុនជាថ្មី ។
គីនីនដូចពាក្យម៉ែប្រដៅ　　　　ស្តាប់ទៅទាស់ចិត្តត្បិតល្វីងប្រៃ
ពាក្យម៉ែនាំល្អតែមិនខ្ចី　　　　ស៊ូគ្រុនអោបដៃញ័ររញ្ជាក់ប្រាណ ។
ឯស្វាយទុំផ្អែមជាតិពិសពុល　　　　កូនគ្រុនដេកឈ្ងុលពន់ប្រមាណ
បែរធ្មេចមិនជឿពាក្យទូន្មាន　　　　មិនផឹកទេថ្នាំញ៉ាំស្វាយវិញ ។
ជីវិតឈាមរាវដូចជាតិស្វាយ　　　　ក្រេបផ្អែមសប្បាយឥតទោម្ទេញ
ទោះបីដឹងថាស្វាយនោះមិញ　　　　នាំរូបអ្នកវិញគ្រុនមិនជា ។
ថ្វីបើគីនីនល្វីងយ៉ាកផឹក　　　　បើកូនបែរនឹកតាមមាតា
ម្ល៉េះសមកូនចាកអស់រោគា　　　　ផុតឈឺអង្គានិងអន្តរាយ!!!

*អ្នកស្រី កែវ ចន្ទ័បូរណ៍*

អ្នកនិពន្ធ

CHANBOKEO.COM

# វគ្គទីមួយ
# បងស្រី

ម៉ោងប្រហែលបួនរសៀល លើដងផ្លូវ កាត់ភូមិព្រៃកូនខ្លា...

រថយន្តឡានគ្រួសារដ៏ថ្មីស្រឡាងមួយបោះពួយយ៉ាងលឿនស្លេវ ពីក្រុងបាត់ដំបងសំដៅទៅរកទិសភ្នំសំពៅ ហាក់កំពុងសំញែងឫក អង្គបង្អួតថាលើផ្លូវនេះមានតែអញ ស្រាប់តែភ្លាត់ស្នៀតបរចៀស គោដាច់កន្លះមួយរត់មកពីណាមិនដឹង រត់កាត់ទទឹងផ្ទាល់ បណ្តាលឲ្យ ម្ចាស់រថយន្តជ្រុលចង្កូតចុះពីផ្លូវ ធ្លាក់ចុះទៅក្នុងប្រឡាយស្នាមភ្លោះ គ្រាំៗ អូសទៅឆ្ងាយពីដីគោកប្រហែលជិត៨ម៉ែត្រ ស្ទុះកង់ក្នុងភក់ វិលទៅមុខលែងរួចតែម្តង ។ នោះសំណាងល្អ ហើយដែលរដូវនេះ ជារដូវវស្សា មានទឹកភ្លៀងដក់តាមប្រឡាយសងខាងផ្លូវ កុំអីមិន ដឹងជាគ្រោះថ្នាក់ដល់ផ្ទះអ្នកស្រុក តាមបណ្តោយផ្លូវនេះអស់ប៉ុន្មាន ខ្នងទៅហើយទេ ។

ចៃដន្យ រថយន្តនោះមានផ្ទុកបុរសតែម្នាក់ កុំអីអ្នកជិះជាមួយ នោះមិនដឹងជាភ័យលោះព្រលឹងរត់ដល់ក្រហែងណាទៅហើយក៏មិន ដឹង ។ បុរសអ្នកបើកបរនោះ មួលកញ្ចក់បង្អួចចុះហើយស្រែកហៅ អ្នកស្រុកថា ៖

- ឪ៊ុយ! អាណាគេនៅម្តុំនេះ មកជួយអញបន្តិចឪ៊ុយ!

យី! សំដីគ្រោតគ្រាតណាស់តើហ៎! អ្នកស្រុកម្តុំនោះឈរមើល រហង់ តែគ្មាននរណាគេនឹកនាមកជិតបុរសនោះម្នាក់សោះ ។

- យី! អញហៅអោយជួយអញផង មិនឮទេ? ឃើញទេ? ឡាន អញវាជាប់ផុង ទៅណាមិនរួច ។

CHANBOKEO.COM

អ្នកស្រុកទាំងនោះជ្រួញចិញ្ចើមដាក់គ្នា ។ ដំបូងៗ គេនាំគ្នារត់ស្ទុះស្ទាបំរុងថាទៅរកជួយទៅហើយ ទទួលឮពាក្យគ្រោតគ្រាតរបស់ បុរសនោះក៏អស់ទឹកចិត្តលែងចង់ជួយតែម្តង ។ តាចាស់ម្នាក់មាន ប្រសាសន៍ឡើងថា ៖

- បុរសហ្នឹងប្រហែលជាស្រវឹងហើយទើបងោកងាកមិនដឹងអីនូច្នេះ កុំទៅរវល់នឹងគេអី! ទុកអោយគេថមថយការស្រវឹងពីខ្លួនសិនទៅ ចាំយើងគិតទៀត ។ បើយើងទៅជួយនៅពេលនេះគុណច្បាស់ ក្លាយជាទោសមិនខាន ។

អ្នកស្រុកបួនដប់នាក់នោះ ក៏បំបែកជួរអស់ទៅ មិនមាននរណា ហុចដៃជួយបុរសយើងទេ ។

- ទ្វីយ! អាក្មេងក្មាងម្តុំនេះ មានអាណាមានដៃមានជើងខ្លះទេ? មកជួយអញម៉ាភ្លែត! ចាំអញអោយពីរបីម៉ឺនចាយ...

បុរសនោះបើកទ្វាររថយន្តស្រែកមករកអ្នកស្រុក ដោយមាន ទាំងធ្វើមុខខ្ញើមរអើមទឹកភក់ដែលនៅពីក្រោមរថយន្តនោះផង ។ ការពិត រថយន្តកប់ក្នុងទឹកប្រឡាយយ៉ាងឆ្ងាយពីផ្លូវថ្នល់ជំរៅងល់ ជង្គង់ ។ ចៃដន្យរថយន្តនោះទ្រង់ខ្ពស់បន្តិច កុំអីម្ចាស់ឡានត្រូវជ្រមុលជ្រមកជ្រកក្នុងទឹកល្បក់ខ្លះមិនខាន ។ ឯអ្នកបើកបរនោះវិញ មានវ័យប្រមាណសែបួយស្លៀកខោអាវឡូយឆាយ តែគ្មានស្ទូហ្វ័រ
បើកជូនលោកសោះ មិនដឹងថាមកពីហេតុអីទេ ។

គ្រាន់តែឮសូរថាបានលុយចាយពីរបីម៉ឺន ក្មេងប្រុសពីរនាក់ អាយុប្រហែល១០ឆ្នាំរត់ស្ទាទៅជួយ ។

- ងាប់ហើយ ពួកឯងល្អិតៗណាស់ សែងអញមិនរួចទេ! ទៅហៅ ពួកអាធំៗជាងហ្នឹងបានទេ?

- ងាប់ហើយពូអើយ! នៅម្តុំនេះ គ្មានពួកអាធំៗដែលពូឯងស្រែក រកនោះឡើយ (ក្មេងម្នាក់ឆ្លើយឡើង)

- អូហ៍ ហើយពួកវាទៅណាអស់ហើយ?

- ទៅរកស៊ីនោះអី នៅសល់តែអាល្អិតៗនេះឯង ឥលូវ ទៅឬ មិនទៅ? បើទៅយើងជួយសែងពូទៅដាក់លើគោក ។ បើមិន ទៅទេ នៅចាំមនុស្សធំគេមកជួយពូឯងទៀតទៅ ។

បុរសនោះសម្លឹងក្មេងៗ ឃើញតូចៗពេក មិនហ៊ានអោយវា ជួយសែងគាត់ទេ ក្រែងដួលធ្លាក់ទឹកប្រឡាក់ខោអាវថ្មីរបស់គាត់ ៖

- អញមិនទៅទេ ចាំម៉ាសន្ទុះទៀតក៏បានដែរ ។

CHIANBOKEO.COM

ក្មេងពីរនាក់ក៏រត់ចេញទៅ ។ ស្រាប់តែមានយុវជនម្នាក់មាឌធំខ្ពស់គួរសមគ្រាន់តែរាងស្គមបន្តិច អាយុប្រហែល១៧ឆ្នាំ ដើរមកពី ខាងណាមិនដឹងក៏មកដល់ទីនោះដែរ ។

- នែ៎វ៉ើយ! មកជួយអញបន្តិចវ៉ើយ!

យុវជននោះបែរមើលបុរសចំណាស់ ហើយក៏ជ្រួញចិញ្ចើម ៖

- ពូឯង ហៅនរណាគេ វ៉ើយៗ ?

- គឺហៅឯងហ្នឹងណា៎!

- ខ្ញុំមិនមែនឈ្មោះវ៉ើយទេ ហើយក៏មិនមែនកូនចៅរបស់ពូឯងដែររឿងអីដែលខ្ញុំត្រូវទៅជួយពូឯងផង ?

- យី! ក្មេងនេះ អត់ចិត្តមែនវ៉ី!

- ពូឯងក៏អត់យ៉ាប់ដូចតែគ្នាហ្នឹង ចាស់ហើយនិយាយស្តីពិបាកស្តាប់ គួរអោយខ្មាស់ក្មេងណាស់ ។

- យើ! ឯងមានមុខស្ទី មកហ៊ានស្តីអោយអញ ?

- ទៅអត់ស្ទីម៉ាអាមុខនោះ ? មុខអ្នកក្រសំបូរជាងអ្នកមានទៅ ទៀត មានតាំងពីមុខឆ្កែ មុខស្វា មុខសំពោចអីក៏មានដែរ ។ ពួក អ្នកមានតើហ៎ដែលវាអត់ ព្រោះវាមានតែមុខដូចយក្សតែម្យ៉ាង មិន គួរអោយរាប់ជាគ្នាទេ ព្រោះពួកអាមុខយក្សអស់នេះវាចូលចិត្តក្រញីក្បាលសត្វស៊ីជាចំណីណាស់ ។ ដូច្នេះ អាមុខសត្វដូចយើង មិនគួរនៅបៀតទេខ្លាចពួកអាមុខយក្សវាខាំស៊ី!!

ថាហើយ យុវជននោះក៏ដើរប្រុយទៅ លែងអើពើ ធ្វើអោយ បុរសនោះមួម៉ៅតែម្តងតែក៏មិនអាចធ្វើអីបានឡើយ ៖

- យីអើ! អាអ្នកស្រុកម្តុំនេះ អីក៏អត់ចិត្តម៉េះវ៉ី ? គ្មានអាណាគេ ចង់បានលុយទេហ្អី បានជាមិនឃើញមកជួយអញម្នាក់យ៉ាងហ្នឹង ?

បុរសនោះរអ៊ូឡូងៗ ធ្វើមើលតែប្រាក់របស់គាត់ជាអាទិទេពដ៏ អស្ចារ្យអញ្ចឹង មិនដឹងថាមារយាទនិងសំដីរបស់គាត់នោះ វាយ៉ាប់ ដល់ណាហើយទេ រហូតដល់អ្នកស្រុកម្តុំនោះអស់ទឹកចិត្តនឹងមកជួយ គាត់អស់រលីង ។ រីឯរថយន្តរបស់គាត់ក៏ឈ្លក់ទឹករលត់ម៉ាស៊ីនឈឹង រួចហើយក៏កប់ផុងក្នុងទឹកប្រឡាយឆ្ងាយពីចញ្ចើមថ្នល់ដល់ទៅជិត ៨ម៉ែត្រ ។ បើនឹងអោយចុះដើរ គាត់ទៅមិនរួចទេ ព្រោះទឹកនៅក្នុងប្រឡាយនោះក្រខ្វក់ណាស់ ម្យ៉ាងគាត់កំពុងតែខ្លើមភក់ស្រាប់ ផង ។ ម្តុំនោះ

CHANBOKEO.COM

មានផ្ទះអ្នកស្រុកច្រើនគួរសមដែរ ប៉ុន្តែទំនងជាអ្នក គ្រាន់បើបន្តិចផង មិនសូវជាអត្តខាត់ប៉ុន្មានទេ ព្រោះផ្ទះគេមួយៗ ជាផ្ទះឈើ ឬផ្ទះឥដ្ឋមានលក្ខណៈសមសួន ។ ប្រហែលជាឆ្លូច្ចេះទេ នឹង បានជាគេមិនរវីរវល់ហ្នឹងប្រាក់របស់ថៅកែម្នាក់ហ្នឹង ។

មួយស្របក់ក្រោយមក មានមាណវីអាយុប្រមាណ១៩ឆ្នាំស្លៀកខោអាវប្រុស ជិះកង់ដឹកចេកពីរបីស្ទង កាត់តាមនោះ ។

- អឺ! មីនាង! (បុរសនោះស្រែកហៅ)

មាណវីក៏ឈប់កង់អែបខាង សួរថា ៖

- ហើយពូអផ្សុកខ្លាំងណាស់ទៅហ្អី បានជាបើកឡានចុះទៅលេង ទឹកប្រឡាយ ? នឹងទេ ថានោះជាកន្លែងខ្ញុំចិញ្ចឹមកូនត្រីក្រឹមលក់ ?

- ហ្អ៎ស ? អាណាគេថាទឹកប្រឡាយនេះជាបរិវេណដីរបស់នាង ?

- មាននរណាថា ? គឺខ្ញុំនេះអីថា... សងលុយភ្លាមមក៎!

- ចុមយក្ស! ឃើញមុខទារលុយមើលតែទារតុងទីន ។ នែ៎ បើ នាងចង់បានមែន ទៅជួយយកឈើមកដាក់កល់បន្តធ្វើស្ពានអោយ យើងដើរឆ្លងបន្តិចមក យើងមានការប្រញាប់ ។

- យី! ងាប់ត្រីក្រឹមរបស់ខ្ញុំទាំងហ្វូង មិនទាន់អោយលុយផង មក រកប្រើស្អី ? នែ៎ ពូ! បើចង់ប្រើអោយខ្ញុំជួយចម្លងពូទៅដាក់ដី គោកនោះ ទាល់តែគិតលុយរឿងត្រីក្រឹមសិន ។

- ហើយឯងមានគ្នាប្រុសៗមាឌធំៗខ្លះទេ ?

- មិនអត់ទេ តែពូត្រូវការគេធ្វើអី ?

- គឺអោយគេជួយសែងអញដាក់លើគោក ។

- ម៉ាអារឿងប៉ុនហ្នឹងមានទៅពិបាកស្អី ?

- អញ្ចឹង ទៅហៅអោយបន្តិចមក៏!

ស្រាប់តែមាណវីនោះលាតដៃបក់ម្រាមរវិចៗ ទំនងទារលុយ ៖

- ចុះឯណាថ្លៃត្រីក្រឹម... នឹងថ្លៃរត់ការ ?

- យី! គ្រាន់តែឲ្យទៅហៅមនុស្សមកជួយក៏ទារលុយដែរវ៉ី ?

- នេះសម័យជឿនលឿនរបស់ប្រទេសយើងណា៎ពូ រត់ការស្អីក៏គេ ទារលុយថ្លៃទឹកតែដែរ ពូមិនដឹងទេហ៎ ?

ដោយទាល់ច្រក បុរសនោះក៏ទាញកាបូបលុយចេញមក ។

- អញគ្មានរាយទេ មីនាង! មានតែក្រដាសមួយរយដុល្លារ ។

CHANBOKEO.COM

- អញ្ចឹង ជង្គង់ខ្ញុំក៏គ្មានកម្លាំងនឹងដើរធ្វើការដែរ!

នាងក៏ហក់ឡើងជិះកង់វិញ ។ ស្រាប់តែបុរសចំណាស់ឃាត់ ៖

- នែ៎... ឈប់សិន! និយាយគ្នាមិនទាន់ចប់ឯណា? មកនេះ! យកលុយនេះទៅដូរទៅ ហើយកាច់យកបីដុល្លារទៅ សល់ប៉ុន្មាន យកមកអោយអញវិញ ។

ធិតានោះបញ្ឈរកង់ទុក រួចក៏ដើរលុយទឹកទៅទទួលលុយនោះ ស្រាប់តែជ្រួញចិញ្ចើមនឹកឃើញអ្វីម្យ៉ាង ក៏សួរថា ៖

- ហេតុអ្វីពូចិត្តល្អម្ល៉េះ អោយលុយខ្ញុំកាន់ដល់ទៅមួយរយដុល្លារ? មិនខ្លាចខ្ញុំយកហើយរត់បាត់ទេហ៎?
- អឺណ៎! ទៅគិតអីច្រើនម៉េះ? នែ៎ អញទុកចិត្តមីនាងឯង ឆាប់ទៅហៅមនុស្សអោយមកជួយយើងភ្លាមមក!
- ហើយពូឯងមិនមានទូរសព្ទដៃហៅជំនួយទេហ៎ បានជា...?
- ថីក៏មិនមាន... តែអញហៅគេម៉ាសន្ទុះហើយមិនទាន់ឃើញមាន អាណាគេអើតក្បាលមកសោះ ។

ធិតានោះក៏លាតប្រាក់ឡើងយកមកមើល ហើយយក មកឈ្លី... ឈ្លីហើយជ្រលក់ទឹកប្រឡាយទៀត ។

- នែ៎ មីនាង! យកលុយអញទៅធ្វើអីហ្នឹង?
- ពិសោធន៍មើលក្រែងដុល្លារក្លែងក្លាយ ។
- គឺវាមិនក្លែងក្លាយទេ ពិសោធន៍ធ្វើអី?

រំពេចនោះ នាងលើកក្រដាសបញ្ចាំងទៅមេឃ ស្រាប់តែឈ្លីវា ហើយគប់ចំទ្រូងបុរសចំណាស់នោះផាច់ ព្រមទាំងស្រដីថា ៖

- លុយក្លែងក្លាយអញ្ចឹងតើហ៎ បានជាចិត្តល្អម្ល៉េះ? ពូបោកខ្ញុំមិនបានទេ! ហ៊ឺះ! ព្រោះតែពូមានចិត្តទុច្ចរិតអញ្ចឹងទេដឹង ទើបទេវតាដាក់ទោសអោយធ្លាក់ប្រឡាយថ្ងៃនេះ ដោយគ្មាននរណាម្នាក់ មានចិត្តមកជួយសោះ!!

ថាហើយ នាងក៏លុយទឹកគ្រាំៗត្រឡប់ទៅវិញ ។

- នែ៎ មីនាង ឈប់សិន! អញសាកចិត្តឯងលេងតើហ៎ ។ ត្រឡប់ មកវិញវើយ! នេះចាំអញអោយអាលុយមែនទែន ។

CHANBOKEO.COM

ម្តងនេះ មាណវីត្រឡប់មកវិញ តែមិនព្រមយកលុយទេ បែរ ជាចង្អុលមុខបុរសនោះទៅវិញ ៖

- នែ៎ពូ! បើសិនជានិយាយអោយពិរោះជាងនេះបន្តិច ខ្ញុំនឹងទៅ រកគេជួយលីពូដាក់ដីគោក ដោយមិនគិតថ្លៃទឹកតែ ។ តែបើពូស្រដី អញឯង ដូចពួកអាបងធំបងតូចនោះ ពូឯងដេកចាំឡានប៉ូលីសគេ មកសង្គ្រោះទៅ ។ ទីនេះ ញាតិជិតខាងគេរវល់ចេញទៅរកស៊ីអស់ ហើយ គ្មាននរណាគេទំនេរមកជួយពូឯងទេ ។ បើសំបូរលុយណាស់ លើកក្រោយជួលតែកុងឡានមួយឲ្យជួយបរទៅ កុំបរខ្លួនឯងទៀត ក្រែងដល់ពេលមានអាសន្នលើកក្រោយ មានតែកុងបង្អោបកពូ ឯងដាក់ដីគោកវិញ ដើម្បីកុំអោយប្រឡាក់ជើងផង ។
- យី! ធ្វើឫកគ្រាន់បើមិនព្រមទទួលលុយផងហ្អ៎ស ? ក្រមែន តែវាយឫកណាស់ នាងឯងនេះ ។

បុរសនោះរអ៊ូ តែម្តងនេះ មិនហ៊ានរអ៊ូរ៉ូងរ៉ាំងដូចមុនទេ ។ គាត់អង្គុយអេះក្បាលសម្លឹងមុខធិតាមួយស្របក់ ក៏និយាយថា ៖

- នែ៎ មីនាង! អញនិយាយលេងទេវើយ! ម៉ោះ! ជួយអញ បន្តិចសិនមក៎!!

កាលបើឮដូច្នោះ ធិតាក៏តបវិញ ៖

- គិតម៉ត់ចត់មែនទែនហើយហ្អ៎ស ពូ ?

បុរសនោះក៏ដក២០ដុល្លារហុចអោយ ៖

- នេះយក២០ដុល្លារទៅ ហើយលីអញដាក់ដីគោកបន្តិចមក!
- ពុទ្ធោ ? អោយខ្ញុំហ្នឹង លីពូដាក់ដីគោក ?
- អើហ៎!

មាណវីបើកភ្នែកធំៗ មួយស្របក់មកក៏សើចខឹកៗតែម្តង ៖

- លីក៏លី... តែសុំប្រាំសន្លឹកបានទេ ?
- ថ្លៃម៉េះវ៉ើយ! ស្រីការ៉ាអូខេ អោយតែ១០ដុល្លារ បំរើដល់មួយ យប់ឯណោះ ។ នេះគ្រាន់តែលីអញប្អូនដប់ជំហាន ទារដល់ទៅ មួយរយដុល្លារ ?
- នោះស្រីការ៉ាអូខេ! នេះស្រីលក់ផ្លែឈើ! វាខុសគ្នាណា៎ពូ!ម៉េច អោយឬមិនអោយ ?

ស្រាប់តែបុរសនោះញញឹម ហើយដកហុចអោយនារីភ្លាម ថែម ទាំងញាក់ចិញ្ចើមព្រិតៗ ទំនងសប្បាយចិត្តដែលបានស្រីក្មេងឲ្យ គាត់អោបកពីក្រោយ ដើម្បីឆ្លងទឹក ។

CHANBOKEO.COM

មាណវីយើងទទួលលុយ ហើយក៏លើកយកពិនិត្យមើលថាជាលុយពិតប្រាកដ ហើយក៏រត់ទៅយកបាវមួយពីក្រោយកង់មកទ្រាប់ខ្នង មុននឹងអោយបុរសចាស់នោះឡើងទំបង្អោប់កលើខ្នងរបស់នាង ។
- នែ៎! យកបាវមកទ្រាប់ខ្នងធ្វើអី ? (បុរសចំណាស់សួរ)
- គឺ.. ការពារកុំអោយឆ្លងរោគ ។
- តែអញគ្មានរោគឆ្លងទេ វើ៎យ!
- ពូមិនមាន តែខ្ញុំមាន!
- អូហ៍ ហើយមីនាងឯងកើតរោគអី ?
- កើតអេដស៍នោះអី!
- ងាប់បាត់! ឯងកើតរោគអេដស៍ ម៉េចមិនប្រាប់អញមុន ?
- ហើយ ចុះម៉េចពូឯងមិនសួរ ?
- ហ៊ឺះ! នែ៎ អោយលុយអញមក... អញទុកពឹងអ្នកផ្សេងវិញ ។
- យី! ពូចាស់នេះបោកក្មេងតើហ៎!
- នរណាថា ? ឯងតើហ៎ដែលបោកអញ!
- គឺពូឯងហ្នឹង មិនធ្វើតាមសន្យា!
- ព្រោះឯងកើតអេដស៍ មិនប្រាប់អញមុន ។
- យើងមិនបានកុងត្រាឯណាថា ខ្ញុំកើតអេដស៍ បង្អោបកពូឯងមិន បាន ? គ្រាន់តែថាអោយនាំទៅដាក់ដីគោកតែប៉ុនហ្នឹងឯង ។

បុរសនោះនិយាយមិនឈ្នះ ក៏បាត់មាត់ ។ រំពេចនោះ យុវជនជំទង់ដែលដើរកាត់ទីនេះមុននឹងបន្តិច ក៏មកដល់ ។ នាវីក្រឡេកក៏ ស្រែកហៅ ៖
- រក្សា! មកនេះជួយបងម៉ាភ្លែត!
- មិនជួយទេ (រក្សាឆ្លើយ) ទាល់តែមានថ្លៃកម្លាំងបាយ ។
- អឺ! ចាំដល់ផ្ទះ បងអោយ តែពេលនេះ ជួយបន្តិចសិនមក៍ ។

រក្សាបែរសម្លឹងមុខបងស្រី ហើយសម្លឹងបុរសនោះ តែក៏មិន ប្រកែកអ្វីដែរ ។ នរៈក៏ដើរលុយទឹកមកអោបកបុរសចំណាស់ចេញ ពីឡានទៅដាក់នៅដីគោក ។ គ្រាន់តែទំលាក់ខ្លួនដល់ដីភ្លាម បុរស នោះក៏យកដៃរឹតដើមទ្រូង ហើយស្រដីថា ៖
- វើ៎យ ធូរពោះបន្តិច ដោយមិនបានឆ្លងអេដស៍!

- ឆ្លងអេដស៍រឿងអីទៅ ពូ ? (រក្សាសួរ)
- អើហ៎ មីនាងខាងនេះវាកើតអេដស៍ បានជាអញមិនអោយវាឱប កទៅដាក់លើគោក ជួនឯងមកដល់ ក៏បានឯងជួយអញផុតគ្រោះ ។
- ហើយចុះនរណាថាពូឯងរួចខ្លួន ?
- ហ៊្នាស ថាម៉េច ? នែ៎! កុំប្រាប់ណា៎ ថាឯងក៏កើតអេដស៍ដែរ ?
- ចុះនរណាគេប្រាប់ពូ ថាអត់ ? ឪពុកខ្ញុំទើបតែស្លាប់ដោយសារ អេដស៍កាលពីពីរឆ្នាំមុន ហើយម្តាយខ្ញុំស្លាប់ឆ្នាំទៅមិញជាមួយកូន ប្រុសម្នាក់ ។
រីឯកូនៗនៅសល់កំពុងតម្រង់ជួរទៅតាមពីក្រោយហើយ...
- អូហ៎ ពុទ្ធោពុទ្ធំ! ងាប់អញបាត់...! អាលីងឆេង!!

តែពីរនាក់បងប្អូននោះមិនខ្វល់ទេ បែរជាកៀកកគ្នាដើរចេញ ទៅ ទុកឲ្យបុរសនោះឈរអេះក្បាលតែម្នាក់ឯងយ៉ាងញាប់ញ័រ ។ រំពេចនោះ មានរថយន្តមួយទៀតបរនាំបុរសពីរបីនាក់មកដល់ ។ បុរសស្ទូហ្វ័រឡានបើកទ្វារឡានចុះ មកទទួលបុរសចំណាស់ម្នាក់នោះ ចេញទៅ ។ ឯបុរសឯទៀត ក៏រៀបចំយកឡានមួយទៀតមក សណ្តោងអូសឡានគ្រូស័រចេញពីប្រឡាយស្នាមភ្លោះ ។

តាមផ្លូវ រក្សាដើរកង់របស់បងស្រី ដើរដៃកគ្នាពីនាក់នាង ត្រឡប់ចូលផ្ទះដែលនៅមិនឆ្ងាយពីទីនោះប៉ុន្មានឡើយ ។
- បងរាសី! កៀបតាចាស់ម្នាក់នោះបានប៉ុន្មានដែរ ? មើលទៅ មុខគាត់ ស្ទិតដល់ស្ទូរហើយ បងអើយ...!
- ស្ទិតយ៉ាងណា ក៏រាសីបូតទាល់តែបានខ្លះហ្នឹង ។ ពួកអ្នកមានឬក ពាអន់ៗបែបហ្នឹង ច្បាស់ពួករកស៊ីផ្លូវកាត់មិនខានឡើយ ។

បន្តិចមក គេក៏មកដល់លំនៅតូចមួយ នៅក្នុងដីចំការដំណាំតូច មួយតាមដងផ្លូវ ។ នោះគ្រាន់តែជាកូនផ្ទះឈើតូចមួយ សង់ខ្ពស់ ពីដីប្រហែលមួយម៉ែត្រ ។ ភ្លាមនោះ ស្រាប់តែពួកគេភ្ញាក់ព្រើត ព្រោះឃើញរថយន្តថ្មីស្រឡាងមួយ ដែលដឹកបុរសចំណាស់អំបាញ មិញនោះ បានមកសំចតនៅមុខផ្ទះរបស់គេ ដោយមានស្ទូហ្វ័រឡាន ឈរចាំផង ។ អ្នកទាំងពីរបែរមើលមុខគ្នាធ្វើភាំង ។ លុះគេនាំគ្នា ស្ទុះឡើងលើផ្ទះ ក៏ប្រទះឃើញបុរសចំណាស់ដដែលនោះនៅអង្គុយ

CHANBOKEO.COM

លើកនេ្ទលក្រហមមួយចំកណ្តាលផ្ទះ ព្រមទាំងមានឆវីសោភាម្នាក់ អាយុប្រហែល១៦ឆ្នាំ កំពុងបំរើទឹកភេសជ្ជៈជូនគាត់ផង ។

- រស្មី ? ភ្ញៀវម្នាក់នេះជានរណា ?

រាសីសួររស្មីជាប្អូនស្រីរបស់នាង ដែលកំពុងលើកថាសភេសជ្ជៈ នោះ ។ កាលបើឃើញបងស្រីបងប្រុសដើរចូលមក នាងក៏ញញឹម ហើយឆ្លើយថា ៖

- បងរាសី! នេះថៅកែ ឌាំង! គាត់ជាថៅកែធំម្នាក់នៅភ្នំពេញ មានសាខាជំនួញតាមខេត្តច្រើនទៀតរួមទាំងបាត់ដំបងផង ។ គាត់ ចិត្តល្អណាស់ ហើយបានសុំខ្ញុំធ្វើកូនធម៌ទៀតផង ។

រាសីបើកភ្នែកធំៗដោយការភ្ញាក់ផ្អើល ។ នាងមិនរវល់នឹងគួរសមជាមួយបុរសចំណាស់ម្នាក់នោះទេ បែរជាមកសួរប្អូនស្រីថា ៖

- ហើយចុះឯងទៅស្គាល់គេពីអង្កាល់ ?

- គឺ... កាល... ពួកម៉ាកខ្ញុំ គេណែនាំអោយស្គាល់...

ស្រាប់តែបុរសនោះសើចក្អឹកៗហើយឆ្លើយជំនួសថា ៖

- ម៉េចក៏រស្មីមិនប្រាប់ទៅថា នាងបានជួបប៉ា ពេលទៅសុំការធ្វើ នៅហាងការ៉ាអូខេ ?

រាសីរិតតែភ្ញាក់ផ្អើលឡើង រួចឧទានថា ៖

- រស្មី! បងអោយប្អូនទៅរៀន ប៉ុន្តែហេតុអ្វីបែរជាទៅរកការធ្វើនៅហាងការ៉ាអូខេទៅវិញអញ្ចឹង ?

- គឺខ្ញុំរៀនមិនចូលនោះអី ? រៀនធ្វើអី កាលបើរៀនចប់ ក៏ប្រឡង មិនជាប់ដដែល បើគ្មានលុយស៊កហោប៉ៅគេ ?

រាសីខកចិត្តណាស់ ក៏ច្រានទ្រូងប្អូនស្រីសឹងធ្លាក់ក្រោយ ៖

- ហើយអារបររកស៊ីជាស្រីការ៉ាអូខេនោះ មានអនាគតអីដែរទៅ ?

- មានឬមិនមាន ក៏គង់រកលុយបាន មានការសប្បាយបំភ្លេចទុក្ខ ម៉ាគ្រាៗ គ្រាន់បើជាងជីវិតសព្វថ្ងៃដែលខំរកស៊ីសុចរិតសព្វយ៉ាង តែក៏នៅតែក្រីក្រខ្វះមុខខ្វះក្រោយ...មិនឃើញចំរុងចំរើនឯណា ?

- តែសំបុកដែលឯងដើរចូលនោះជារង្វង់ដែលនាំឯងធ្លាក់អវិថី បើមិនស្លាប់ដោយញៀនស្រា ញៀនថ្នាំញៀន ក៏នឹងស្លាប់ដោយរោគ អេដស៍មុនអាយុ!

(រាសីគំហក)

CHANBOKEO.COM

- ចុះម៉ែយើងវិញនោះ ? ម៉ែមិនដែលចូលកន្លែងអស់ហ្នឹងផង ហេតុអ្វីក៏កើតរោគអេដស៍ស្លាប់នឹងគេដែរ ?
- គឺមកពីឪពុកយើងនោះអី ! ឪពុករបស់យើងបានប្រព្រឹត្តបាបកម្ម ហើយក៏នាំជម្ងឺទម្លាក់ដល់ម៉ាក់រួចឥឡូវនេះទៀត ចរិតវង្វេងរបស់
គាត់ក៏បានជ្រួតជ្រាបជាំជាប់នឹងខ្លួនរបស់ឯងជាកូនទៀតហើយ ឯង ឃើញហើយនៅ ?
- តែខ្ញុំមិនខ្វល់ ! បងចង់រស់អាយុវែងនៅឯណាក៏ទៅរស់ទៅ ! ខ្ញុំ នឹងទៅរស់នៅដោយខ្លួនឯង មិនចាំបាច់ចាំបងធ្វើឫកជាឈឺឆ្អាល ចំពោះជីវិតរបស់ខ្ញុំតទៅទៀតទេ ។
ការដែលត្រឹមផ្គត់ផ្គង់ត្រឹមបាយ កកស្ករផែនបែបនេះ ខ្ញុំមិនត្រេកត្រអាលឡើយ ហើយកុំសង្ឃឹមថា អាចធ្វើអោយខ្ញុំរំភើបចិត្តចំពោះទង្វើដ៏ល្ងង់របស់បង ដែលមិនចេះ រកលុយ
ចេះត្រឹមតែលក់ផ្លែឈើនោះ ! ជីវិតកណ្តាច់កណ្តោចបែប នេះ
គ្មានតម្លៃគួរឲ្យខ្ញុំមានមោទនភាពជាមួយទេ... វេទនាណាស់ !

ថាហើយ នាងក៏លូកចាប់ដៃបុរសចំណាស់នោះដើបដើរចេញ ទៅក្រៅយ៉ាងលឿន ៖
- តោះប៉ា ! យកខ្ញុំចេញពីទីនេះភ្លាមទៅ ! ខ្ញុំមិនចង់នៅឃើញមុខ
មនុស្សដែលពាក់មុខបិសាចដាក់ខ្ញុំដូច្នេះតទៅទៀតឡើយ ។

រស្មីងាកមកសម្លក់បងស្រីរបស់ខ្លួន ហើយក៏អូសដៃថៅកែខាំង
នោះចេញទៅ ធ្វើអោយរស្មីខកចិត្ត ស្រឡាំងកាំងនិយាយលែងរួច តែម្តង ។
នាងក៏រត់យ៉ាងលឿនទៅអូសដៃប្អូនស្រីមកវិញ ៖
- អត់ទេ រស្មី ! បងមិនអោយប្អូនទៅទេ ! ទៅមិនបានទេ !
- លែងខ្ញុំ បងរាសី ! បើបងគ្រាន់បើពិតមែន បងបង្ហាញខ្ញុំមកថា ជីវិតបងនឹងគ្រាន់បើជាងរូបខ្ញុំនៅរវាងពីរបីឆ្នាំទៀត ចាំមើលថា តើអ្នកលក់ផ្លែឈើដូចបង និងនារីកាវ៉ាអូខេដូចខ្ញុំនេះ
តើនរណាមាន ជីវិតប្រសើរជាងនរណា !

ថាហើយ រស្មីរលាស់ដៃពីបងស្រី ហក់ឡើងរថយន្តដ៏ស្រឡាង
ជាមួយថៅកែខាំងនោះយ៉ាងរហ័ស ។ រថយន្តក៏បរចេញទៅ... ទុក
អោយរាសីរត់តាមពីក្រោយស្រែកយំហៅប្អូនល្វើយៗ ៖
- អត់ទេ ! រស្មី ! កុំទៅអី ! ត្រឡប់មកផ្ទះវិញអូន ! កុំចាញ់បោក គេណ៎ា រស្មី !.... រស្មី !

អនិច្ចា ! រថយន្តបរចេញទៅឆ្ងាយហើយ នៅសល់តែដីហុយ ទ្រលោមពីក្រោយប៉ុណ្ណោះ ។ រាសីទុចដំណើរដ៏ក់ ព្រោះដឹងថានាង មិនអាចរត់ទាន់រថយន្តឡើយ ។ រំពេចនោះ

CHANBOKEO.COM

រាសីដាក់ភ្នែកទៅម្ខាង ឃើញបុរសម្នាក់ពាក់មួយកន្តិប ពាក់អាវពណ៌ប្រផេះ កំពុងជួយ
អូសឡានរបស់បុរសចាស់នោះឡើងដល់លើគោក ដោយមានជំនួយ
ពីរថយន្តធំមួយទៀតនិងកម្មករពីរបីនាក់ ។ បុរសនោះបានចោល កន្ទុយភ្នែកមើលនាងភ្លៀកៗ ។
ធិតាចាប់ភ្លឹកភ្លាម ហើយក៏គំហក ឡើងទៅមាណពនោះ ទាំងទឹកភ្នែកពេញមុខ ថា ៖

- នែ៎! លួចសម្លឹងមើលស្អី ? សប្បាយចិត្តណាស់មែនទេ ដែល ចៅកែរបស់អ្នក
ដើរទាក់ក្មេងស្រីដាក់ហាងការ៉ាអូខេដូច្នេះ ?

បុរសនោះនៅស្ងៀមមិនតបទេ តែបែរទាញមួកបន្ទាបលិចមុខ
ថែមទៀតរួចក៏ឈ្ងោកមុខគេចចេញ ។ រាសីសម្លក់បុរសនោះហើយ ក៏សម្លក់បុរសទាំងអស់
ដែលកំពុងរៀបរថយន្តសណ្តោងអូសឡាន ឡើងពីភក់មក រួចហើយក៏ស្រែកអោយពួកគេថា ៖

- ឲ្យអ្នកទាំងអស់សើចយំខ្ញុំសិនចុះ! ថ្ងៃណាមួយរាសីខ្ញុំអណ្តែត ខ្ពស់ដល់មេឃ
ខ្ញុំនឹងអូសអ្នកចេញពីការបំរើជនពាលឧក្រិដ្ឋមុខ ខ្លាញ់នេះឲ្យអស់
មិនឲ្យស៊ីប្រាក់ខែពួកទុច្ចរិតទៅទៀតឡើយ ។

រាសីខាំធ្មេញក្រឹតៗ យកដៃជូតទឹកភ្នែក រួចនិយាយបន្តថា ៖

- ថ្ងៃណាមួយ កំទេចអំបែងដូចជាយើងនឹងអណ្តែតឡើងផុតផ្ទៃទឹក
អោយអ្នករាល់គ្នាដែលមានបេះដូងឧក្រិដ្ឋទាំងឡាយ លោះព្រលឹង មិនខាន! ចាំតែមើលចុះ!

ថាហើយ រាសីក៏បែរដើរត្រឡប់ក្រោយទៅផ្ទះវិញ ទុកអោយ
បុរសមួយរូបនោះលួចឈរគន់មើលនាង យ៉ាងភ្លន់ភ្លឹកពីក្រោយ
ដោយកិរិយាស្ងាត់ស្ងៀមតែម្នាក់ឯង ។

- បងរាសី... (រក្សាដើរមកដល់ជិត ហៅបងស្រីតិចៗ)

- បងមិននឹកស្មានសោះ រក្សា... ថាប្អូនស្រីរបស់បងហ៊ានប្រមាថ
មាក់ងាយទឹកចិត្តបងស្រីរបស់គេដល់ម្លឹង ?... (រាសីយកដៃផ្ទិតទឹក
ភ្នែកដែលកំពុងតែស្រក់ចុះមកលើផ្ទៃមុខរបស់នាងជាថ្មី)

- រស្មីគេមិនយល់មែន... តែរក្សាយល់ចិត្តបងណាស់!

ឮប្រយោគនេះភ្លាម រាសីក៏ងើបមុខឡើង ៖

- បងអរគុណណាស់ រក្សា! ទោះបីជាយ៉ាងណា បងក៏នៅតែបារម្ភ ពីសុខទុក្ខរបស់រស្មីជានិច្ច
ព្រោះគេនៅក្មេង ពិតជាហក់លោតតាម ល្បិចចាស់ទុច្ចរិតមិនទាន់ឡើយ ។

CHANBOKEO.COM

- តែរស្មីគេបានជ្រើសរើសយកផ្លូវជីវិតបែបនោះ រួចទៅហើយ ដូច្នេះនាងត្រូវតែហ៊ានទទួលយកនូវលទ្ធផលចុងក្រោយ របស់ជីវិត បែបនោះ ដោយមិនអាចប្រកែកបានទេ ។

បន្តិចមក រាសីកាន់ដៃប្អូនប្រុសដើរចូលទៅក្នុងផ្ទះវិញវែករាំង ននចូលទៅក្នុងបន្ទប់ ក៏ប្រទះនឹងកុមារជំទង់មួយអាយុប្រហែល ១០ឆ្នាំ រាងស្គាំងស្គមស្លេកស្លាំង កំពុងតែគេងឈឺលើកន្ទេល...

- រតនា! ប្អូនបានធូរស្រាលគ្រាន់បើខ្លះ ថ្ងៃនេះ ?

នោះគឺជារតនាជាប្អូនបន្ទាប់ពៅ ។ ការពិត រាសីមានបងប្អូន ដល់ទៅប្រាំមួយនាក់ ។ ឪពុករបស់នាងបានស្លាប់ទៅដោយជំងឺ អេដស៍ហើយបានចម្លងមកដល់ម្តាយរបស់នាង ។ ចំណែកប្អូនពៅ វិញបានឈឺស្លាប់ នៅអាទិត្យជាមួយគ្នានឹងម្តាយរបស់នាងដែរ ។ តាមការពិតគ្មាននរណាដឹងថា ប្អូនពៅរបស់នាងស្លាប់ព្រោះអេសដ៍ ឬជំងឺអ្វីដទៃទៀតឡើយ ត្បិតគេស្លាប់ទាន់ហន់ពេក ។ ម្យ៉ាងទៀត កាលនោះ ពេលប្អូនដេកឈឺ រាសីគ្មានលុយយកគេទៅពេទ្យពិនិត្យ ជម្ងឺរបស់ប្អូនអោយបានត្រឹមត្រូវផង ។ មិនទាន់បានប៉ុន្មានផង រតនាជាប្អូនបន្ទាប់ពៅ ក៏ធ្លាក់ខ្លួនឈឺជាបន្តបន្ទាប់ទៀត ។ ឯគ្រួសាររបស់រាសីដែលធ្លាប់ជាមនុស្សមានទ្រព្យធនមធ្យមមួយ ក៏បានក្លាយ ធ្លាក់ខ្លួនជាជនទុរគត ព្រោះត្រូវលក់ដីលក់ផ្ទះរកលុយព្យាបាលជំងឺ របស់ឪពុកម្តាយនាង ។ សព្វថ្ងៃនេះ គ្មាននរណាគេទៅមករាប់រក ក្រុមគ្រួសាររបស់រាសីឡើយ ព្រោះគេខ្លាចត្រូវស្លាប់ដោយការឆ្លងមេរោគអេដស៍ពីគ្រួសារនេះ ។ កាលពីមុនគ្រួសារគេរស់នៅឯផ្សារ ណាត់ ។ បន្ទាប់ពីលក់ផ្ទះសងបំណុលគេមក រាសីក៏នាំប្អូនរត់មក នៅផ្ទះចាស់របស់គេ នៅម្តុំព្រៃកូនខ្លា លាក់ខ្លួនពួនអាត្មា មិនអោយ មានគេស្គាល់ថា សមាជិកគ្រួសាររបស់នាង មានជំងឺអេដស៍ទេ ។ រាសីក៏បានឈប់រៀនពីវិទ្យាល័យមុនីវង្ស ហើយប្រកបរបរជួញផ្លែឈើពីចំការយកទៅបោះនៅផ្សារផង ជួនធ្វើនំលក់ផង ដើម្បីចិញ្ចឹម ប្អូនៗ ។ ឯរក្សាវិញត្រូវប្រឡងបញ្ចប់មធ្យមសិក្សាឆ្នាំនេះ ។ ស្តាយ តែរស្មីទេដែលបែកគំនិតផ្តេសផ្តាសតាំងពីម្តាយនាងស្លាប់ទៅព្រោះ រស្មីមិនអាចទ្រាំទ្រទទួលជីវិតដ៏ក្រីក្រអត្តខាត់បាន ។ រដ្ឋាជាកូនទី៤ អាយុ១៤ឆ្នាំ ចេញដើរបាត់ៗ ឃើញៗ តាមតែដំណើរ ជួនមកផ្ទះ ជួនបាត់បួនដប់ថ្ងៃទើបអើតមុខមកផ្ទះម្តង ។ គេក៏គេចសាលាមិន ខុសពីរស្មីបងស្រីរបស់គេឡើយ ។ សល់តែរតនាជាប្អូនពៅ កំពុង

CHANBOKEO.COM

ចាប់មានជំងឺទៀតហើយ... គ្រប់គ្នាគិតថា គេប្រហែលជាកំពុង
ទទួលជាការទន្ទ្រានរបស់ជំងឺអេដស៍បន្តពីឪពុកម្ដាយហើយ ។

ឃើញរាសីនិងរក្សាដើរចូលមក រតនាបែរនិយាយខ្សាវៗដាក់ បងស្រីនិងបងប្រុសរបស់ខ្លួន ៖

- ខ្ញុំជិតស្លាប់ហើយមែនទេ បងរាសី បងរក្សា ? ខ្ញុំខ្លាចណាស់... ខ្ញុំមិនចង់ស្លាប់ទេ...ថ្ងៃនេះ... ខ្ញុំហេងហោងក្នុងខ្លួនណាស់...

រតនាស្រដីផងរលីងរលោងទឹកភ្នែកផង ។ រាសីដាក់ខ្លួនអង្គុយ ជិតប្អូនហើយយកដៃអង្អែលក្បាលកុមារដោយក្ដីអាណិតអាសូរ ៖

- រតនាមិនទៅណាចោលបងទេ! ប្អូនគ្រាន់តែគ្រុនក្ដៅប៉ុណ្ណោះ ។ ប្អូនញ៉ាំថ្នាំសំរាកតែពីរបីថ្ងៃទៀតជាវិញហើយ ។
- បងនិយាយពិត ឬក៏គ្រាន់តែលួងចិត្តប្អូនទេ បងរាសី ? ខ្ញុំពិតជា មិនទាន់ចង់ស្លាប់ទៅតាមប៉ាម៉ាក់និងប្អូនពៅទេ ។ ខ្ញុំខ្លាច...

រាសីលើកប្អូនមកអោបយ៉ាងណែន ៖

- ប្អូនកុំខ្លាចអី... បន្តិចទៀតប្អូនជាវិញហើយណា៎...!

រំពេចនោះ រតនាក៏ត្រឡប់ភ្នែកឡើងដង្ហក់ខ្យល់ ៖

- បង... រាសី... បង...រក្សា....

ស្រាប់តែនាយធ្វើភ្នែកខៀវទៅៗ រួចហើយក៏បាក់ករងៀកទៅ ក្រោយដកចង្កាមាន់មួយរំពេច ។

- រតនា! ប្អូនសម្លាញ់របស់បង..!

រាសីទ្រហោរយំផង អោបប្អូនផង ទាំងក្ដីរន្ធត់តក់ស្លុតក្នុងចិត្ត ឥតឧបមា ។ រក្សាក៏ទប់ចិត្តមិនបានក៏ស្រក់ទឹកភ្នែកតាមដែរ... នេះ ហើយឬវិបត្តិនៃជំងឺអេដស៍ ? ឪពុកភ្លើតភ្លើនទៅសប្បាយនៅក្រៅ ដោយមិនគិត តែអ្នកទទួលរងគ្រោះវិញនោះ បែរក្លាយមកជា ប្រពន្ធកូនដែលមិនបានដឹងនូវអំពើឧក្រិដ្ឋរបស់ឪពុកនោះទៅវិញ ?

រាសីបីសពប្អូននៅក្នុងដៃជ្រួញចិញ្ចើមគិតមិនអស់មិនហើយ ។ មើលចុះ! គេនៅក្មេងណាស់! គេទើបតែមានអាយុ១០ឆ្នាំ មាន វ័យស្រស់ថ្លាដែលគួរណាស់តែបានទទួលអនាគតល្អ តែបែរជាមក រលត់សង្ខារទាំងក្មេងដោយសារភាពរាយមាយរបស់ឪពុកគេ... ឱ! លោកឪពុកអើយ! បើសិនមានឱកាសនៅគិតបាន តើលោកគួរ គិតយ៉ាងណាវិញ ដើម្បីអោយកូនមានអនាគតឆ្ងាយ ជាជាងឲ្យគ្នា មកបញ្ចប់សង្ខារដោយឥតន័យយ៉ាងនេះ ? តើលោកឪពុកគួរក្លាយ ខ្លួនជាឃាដករសម្លាប់កូនប្រពន្ធតាមវិធីបែបនេះទេ ?.... តើឯណា

CHANBOKEO . COM

ទៅក្ដីស្រឡាញ់ដែលលោកឪពុកគួរផ្ដល់ចំពោះកូនប្រពន្ធ ? លោកឪពុកជាអ្នកមានគុណយ៉ាងធ្ងន់ចំពោះកូន... ប៉ុន្ដែ រឿងដែលលោក ឪពុកធ្វើឲ្យកូនរបស់លោកស្លាប់ទៅដោយការប្រព្រឹត្ដឧក្រិដ្ឋរបស់ លោកឪពុករបៀបនេះ តើគួរឲ្យកូនគិតថាលោកឪពុកជាអ្នកមាន គុណ ឬក៏ជាឃាដករសម្លាប់កូន សម្លាប់ប្រពន្ធរបស់ខ្លួន ? តើគុណនិងទោសអាចសងគ្នារួចទេ ចំពោះករណីខាងលើនេះ ?

នៅចំពោះមុខចេតិយមួយនៅវត្ដកំផែង...

រក្សានិងរាសីឈរស្ងើងស្ងាធយ៉ាងយូរ ។ បន្ទាប់មក រាសីក៏ស្រដី ថា ៖

- ម៉ាក់! រតនា! ពៅ! សូមអោយវិញ្ញាណក្ខន្ធ័របស់អ្នកទាំងបី បានទៅដល់ស្ថានសុគតិភពកុំបីខាន ។

រក្សាភ្ញាក់ព្រើត នឹកចម្លែកក្នុងចិត្ដដែលគេមិនបានឮរាសីហៅរកវិញ្ញាណក្ខន្ធ័របស់ឪពុកសោះ ។ ប៉ុន្ដែ គេមិនស្រដីអ្វីទេ ។ គេនៅតែស្ងៀមតាមទម្លាប់របស់គេដែលគោរពបងស្រីបំផុត ។

បន្ដិចមក រក្សាក៏ឡើងធាក់កង់ឌុបបងស្រីត្រឡប់ទៅផ្ទះវិញ ។ ស្រាប់តែគេប្រទះនឹងក្មេងជំទង់បីបួននាក់កំពុងវាយគ្នានៅក្បែរដង ទង់វត្ដកណ្ដាលទីធ្លាសួនច្បារដែលមានរូបចម្លាក់ស្អាតៗជាច្រើន ។

- នែ៎! ពួកឯងឈប់វាយគ្នា! ទីនេះជាវត្ដអារាមមិនមែនសង្វៀន ប្រដាល់សេរីទេ ។

រក្សាស្រែកឃាត់ ។ ស្រាប់តែ... ខ្វាប់ៗ ក្មេងម្នាក់យារដាវគ្រវី កាប់ឆិតៗក្បាលរក្សា ។ យុវជនយើងហក់ចុះពីកង់ គ្រវីខ្លួនខ្វាល់ គេចផ្លែដាវសាម៉ូរ៉ៃ ហើយព្រលែងជើងព្រលែងដៃយ៉ាងអស់ក្បាច់ ព្រលំក្មេងៗទាំងនេះដួលត្រោលៗ ។ រាសីឃើញហើយក៏ស្ទុះហក់រឹង ទៅក្របួចក្មេងម្នាក់ក្នុងចំណោមបួននាក់នោះឡើង ៖

- គឺឯងទេ រដ្ឋា ? ឥឡូវធ្លាក់ខ្លួនដល់ថ្នាក់នេះហើយ ប្អូនសម្លាញ់ ? ឥឡូវនេះ ឯងជក់ថ្នាំញៀនរហូតក្លាយជាអ្នកលេងកាប់ដាវផង មែនទេ ?

មែនហើយ នោះគឺរដ្ឋា ប្អូនប្រុសរបស់អ្នកទាំងពីរ ។ គ្រាន់តែ ឃើញមុខបងប្រុសបងស្រីភ្លាម គេក៏ធ្វើមុខស្លេកតែម្ដង ។ រំពេច នោះ ក្មេងពីរនាក់បានដាក់មេផាយទៅបាត់ស្រមោល សល់តែក្មេង ប្រុសម្នាក់ដែលរក្សាចាប់បាន ដោះយកអាវមកចងដៃ ។ បន្ដិចមក ព្រះសង្ឃព្រមទាំងអាចារ្យវត្ដនិងអ្នកស្រុកចំណុះជើងវត្ដ

CHANBOKEO.COM

ក៏បានមក ដល់ ។ គេក៏ចាប់កុមារជំទង់ម្នាក់នោះចេញទៅ ។ ចំណែករដ្ឋាបាន
ត្រូវបងប្រុសបងស្រីចាប់ប្រគល់អោយទៅព្រះគ្រូអធិការ ។
- លោកតា! តើអាចទទួលយកក្មេងមួយនេះ អោយជ្រកម្លប់ព្រះ
ធម៌ផងបានទេ? (រាសីក្រាបបង្គំសុំព្រះគ្រូចៅអធិការ)
- អត់ទេ! ខ្ញុំមិនចង់បួសទេ (រដ្ឋាស្រែកកាត់) ខ្ញុំមិនចូលចិត្តធ្វើ
ខ្លួនជាលោកសង្ឃអត់បាយល្ងាចនោះទេ ។
- ឈប់មាត់! (រក្សាគំហកតិចៗ) ទីនេះជាវត្តអារាម ប្អូនត្រូវរៀប
ចំតិរិយាបថអោយសមរម្យបន្តិចផង ។

ភ្លាមនោះ ព្រះគ្រូមានដីការឡើងថា ៖

- នឹងអោយគេបួសតែម្តងនោះមិនបានទេ ព្រោះគេនៅមានជាតិ ញៀនក្នុងខ្លួនប្រាណគេនៅឡើយ
តែលោកតាសុំបិណ្ឌបាតយកគេ អោយនៅបំរើជាកូនសិស្សនៅទីនេះសិនចុះ ។

រាសីក្រាបបង្គំព្រះគ្រូ ៖

- អរគុណលោកតាណាស់ ដែលជួយយិតយោងសត្វលង់ទឹកដូចជា រូបគេ ។
ចំពោះខ្ញុំករុណាដែលជាបងទាំងពីរនាក់ ពេលនេះ គ្មាន សមត្ថភាពអ្វីនឹងជួយគេបានទេ
មើលទៅមានតែពឹងលើព្រះគ្រូ ជា អ្នកតម្រែតម្រង់ហើយ ។
- មិនអីទេ! ទុកអោយលោកតាជួយទទួលខុសត្រូវចុះ ។
- អត់ទេ! ខ្ញុំចង់ទៅផ្ទះវិញ! ខ្ញុំមិនចង់នៅវត្តទេ (រដ្ឋាស្រែក)

ស្រាប់តែរាសីពោលឡើងថា ៖

- កុំប្រឹងភូតបងអី រដ្ឋា! ឯងឯណាដែលចង់ទៅផ្ទះ នៅផ្ទះជាមួយ ពួកយើង?
យើងបានចាប់ប្អូនមកផ្ទះច្រើនដងហើយ តែប្អូនបែរ ជារត់ពីផ្ទះរាល់លើក ។ លើកនេះ
បងមិនយកឯងទៅផ្ទះទេ ព្រោះ ឯងបានវាយតប់គ្នា ធ្វើអោយខូចបែកបាក់ទ្រព្យសម្បត្តិរបស់វត្ត
អារាម ដូចនេះ ឯងត្រូវតែធ្វើការបំរើ ជាសំណងដល់ការខូចខាត ទាំងនោះ ។ បើមិនសុខចិត្តទេ
បងនឹងចាប់ប្អូនបញ្ជូនអោយអង្គការ កែក្មេងញៀនគ្រឿងញៀនអោយគេអប់រំឯងហើយ ។
ឥឡូវជ្រើស
រើសមួយទៅ តើឯងចង់យកផ្លូវមួយណា?

ដោយទាល់ច្រក រដ្ឋាក៏ឈ្ងោកមុខនៅស្ងៀម ។

CHANBOKEO.COM

ក្រោយពីប្រគល់ប្អូនប្រុសទៅលោកតាអនិការហើយ រក្សាក៏ឱប បងស្រីត្រឡប់មកផ្ទះវិញ ។ យប់នោះ រាសីនៅអង្គុយសំកុកមាត់ ជណ្តើរ អង្គុយមើលមេឃ មិនព្រមចូលគេងសោះ ។ រក្សាឃើញ ហើយក៏លូនចូលមកជិត ហើយនិយាយថា ៖

- បងរាសី! យប់ហើយណា! មិនចូលគេងទេ ?
- បងមិនទាន់ងុយទេ រក្សា! ប្អូនចូលគេងមុនទៅ ។
- ប៉ុន្តែ បងក៏ត្រូវចូលគេងដែរ កុំអត់ងងុយច្រើនពេក តិចលោ ឈឺម្នាក់ទៀតទៅ ។
- ទោះជាបងប្រឹងគេង ក៏មិនលក់ដែររក្សា... ព្រោះបងកំពុងគិតពី ថ្ងៃស្អែករបស់យើង...
- រស់តាមតែដំណើរសិនទៅបង! ទោះបីជាគិត ក៏យើងមិនអាច ដោះស្រាយអ្វីបានដែរ មានតែឈានដើរទៅមុខបន្តទៅទៀតតែ ប៉ុណ្ណោះ ។
- រក្សានិយាយត្រូវហើយ! យើងត្រូវបោះជំហានទៅមុខ ប៉ុន្តែបង មិនដឹងថា ត្រូវបោះជំហានខាងណា ដើម្បីកុំឲ្យធ្លាក់ជ្រោះដូចជីវិត ប៉ាម៉ាក់របស់យើង ។ រក្សានឹងប្រឡងបញ្ចប់ការសិក្សាឆ្នាំនេះហើយ ប្អូននឹងត្រូវបន្តការសិក្សាទៅមុខទៀត... តើបងត្រូវធ្វើការអ្វីដើម្បី យកប្រាក់មកបង់សាលាអោយរក្សា រួចជួយផ្គត់ផ្គង់ដល់រង្គាផង ?

រក្សាញញឹមហើយស្រដីថា ៖

- ជំហានទីមួយនោះ គឺ បងនិងខ្ញុំត្រូវទៅរកពេទ្យដោះឈាមមើល ហើយ ខ្លាចយើងមានចម្លងមេរោគអេដស៍ពីសមាជិកក្រុមគ្រួសារ របស់យើង ។
- បងថា យើងមិនបានឆ្លងអេដស៍ទេ ។ ប្អូនរបស់យើងពីរនាក់ ដែលស្លាប់ អាចស្លាប់មកពីជំងឺផ្សេងទៀតក៏បានដែរ មិនមែនឲ្យ តែស្លាប់ ក៏សុទ្ធតែមកពីអេដស៍ទាំងអស់នោះទេ ។
- តែក៏វាអាចទៅរួចណាបង ព្រោះយើងរស់នៅជាមួយគ្នាជិតដិត អាចឆ្លងមេរោគតាមស្បែក ដែលមុតចំហាមុខក៏មានដែរ ។
- អឺ! បងជឿតាមឯងចុះ ។ អញ្ចឹងយើងទៅរកពេទ្យដោះឈាម រួចហើយ យើងនឹកមកដេកគិតគ្នា ថាធ្វើដូចម្តេចទៀត ដើម្បីរក លុយបង់សាលាអោយឯងរៀន ។ បងចង់អោយរក្សារៀនបានឆ្ងាយ កុំអោយដូចបងដែលត្រូវបង្ខំចិត្តលាសាលាទាំងក្មេង ដើម្បីមកថៃ ទាំប៉ាម៉ាក់នោះឡើយ ។
- ប៉ុន្តែបងបានធ្វើល្អបំផុត ចំពោះក្រុមគ្រួសារយើងហើយ ។ បើកុំ តែមានរូបបង មិនដឹងថា ពួកយើងរស់នៅយ៉ាងណាទេ ជាពិសេស តាំងពីប៉ាម៉ាក់គាត់ចែកស្ថានទៅ ។

CHANBOKEO.COM

- ហ៊ឺ! បងប្រឹងអស់សមត្ថភាពហើយ រក្សា តែបងនៅតែមិនអាច
គ្រប់គ្រងប្អូនអោយបានល្អដូចចិត្តបងប៉ងប្រាថ្នាទេ ។ ប្អូនមិនឃើញ ទេ ?
ប្អូនយើងខ្លះប្រមាថសមត្ថភាពបងណាស់ដែលបងមិនអាចរក
ប្រាក់ផ្គត់ផ្គង់រូបគេអោយរស់នៅស្រណុកសុខស្រួលបាន... នេះគឺ មកពីបងរៀនមិនចប់
ទើបបងគ្មានសមត្ថភាពអ្វីនឹងរកការងារធ្វើ ឲ្យប្រសើរជាងនេះបាន
បានត្រឹមតែជាឈ្មួញលើកផ្លែឈើលើកបន្លែ លក់ដុំនៅផ្សារ និងធ្វើនំ ធ្វើបង្អែមលក់
តាមដែលធ្វើបានតែ ប៉ុណ្ណោះ ។
- បងកុំពិបាកចិត្តអី! រក្សាក៏មានសាច់ដុំគួរសមដែរ អាចជួយជា ដៃជើងបានខ្លះ
មិនអោយបងនឿយតែម្នាក់ឯងនោះទេ ។

រាសីឮដូច្នោះ ក៏យកដៃអង្អែលស្មាប្អូនដែលអង្គុយទន្ទឹមនឹង
នាងនៅមាត់ជណ្ដើរផ្ទះ ហើយញញឹមឡើង ៖
- ពេលនេះ បងសប្បាយចិត្តវិញហើយ ដែលហោចណាស់ បង
នៅមានប្អូនប្រុសយ៉ាងល្អម្នាក់ ដែលមិនបណ្ដោយអោយបងស្រក់ ទឹកភ្នែកអាសារឥតការ ។
- គឺមកពីយើងជាបងប្អូនដែលស្រឡាញ់គ្នាបំផុតនោះអី ។

អ្នកទាំងពីរក៏ញញឹមដាក់គ្នាឡើង ទាំងដួងចិត្តពោរពេញដោយ ក្ដីសង្ឃឹមជាថ្មី
ថ្វីបើក្នុងបេះដូងរបស់គេពោរពេញទៅដោយកង្វល់ នឹកគិតទៅដល់រស្មី ប្អូនស្រីរបស់គេ
ដែលរត់តាមបុរសចំណាស់ កំពូលខិលនោះទៅ កាលពីប៉ុន្មានថ្ងៃមុន រួចហើយក៏បារម្ភដល់រដ្ឋា
ដែលកំពុងតែញៀនគ្រឿងញៀន មិនដឹងថាលោកគ្រូអធិការអាច
រំលត់ភាពញៀននិងមារយាទព្រហើនរាយមាយរបស់នាយបានដែរ ឬក៏យ៉ាងណា...

ទោះបីជាយ៉ាងណា គេមិនលះបង់សេចក្ដីសង្ឃឹមរបស់គេទេ
ហើយគេទាំងពីរបានស្រោក់ដៃសន្យាគ្នា ថានឹងពុះពារតទៅទៀត
ដើម្បីដើរឆ្ពោះទៅរកអនាគតមួយដែលគ្រប់ៗគ្នាគិតថា គេទាំងពីរ
នាក់នោះពិតជាមិនអាចមានសមត្ថភាពដើរទៅដល់ឡើយ ក្នុងមួយ ជីវិតរបស់គេនេះ...

តើគេអាចធ្វើបានសំរេចដូចបំណងឬក៏យ៉ាងណា ?

*oooooooooooooooooooo*

*oooooo*

CHANBOKEO.COM

# វគ្គទីពីរ
# រាសីថ្មី

នៅភោជនីយដ្ឋានមនោរម្យមួយ លើផងផ្លូវទៅព្រៃកលាប...

បុរសសង្ហាមួយរូបពាក់វ៉ែនតាខ្មៅដែលមានវ័យប្រមាណ៣០ឆ្នាំ ដើរចុះពីរថយន្តតែម្នាក់ឯង ដើរសំដៅចូលទៅក្នុង ដោយឫកពា ឆ្មើងឆ្មៃ ។ រំពេចនោះ អ្នកបំរើបាននាំគេមកដល់តុដ៏ស្អាតមួយនៅ លើរានហាលបែរទៅទន្លេ ឆ្ងាយពីវេទិកាចម្រៀងសម័យបន្តិច មិន សូវជាថ្លង់ត្រចៀកខ្លាំងពេកទេ ។ មាណពមិនទាន់ទាំងដាក់ខ្លួនអង្គុយ ស្រួលបួលផង ស្រាប់តែស្រីៗឡង់សេមួយហ្វូងរត់ជាន់កងណ្ដើមគ្នា យករូបស្រាបៀរមកហុចជូនបុរសសង្ហានោះជ្រើសរើស តែបុរស បែរជាយកដៃគៀសចេញ ហើយស្រដីថា ៖

- សុំចៀសឆ្ងាយៗបន្តិចមើល៍! បើចោមរោមអ៊ូអរ ជាន់កខ្ញុំតត របៀបយ៉ាងនេះ ខ្ញុំច្បាស់ជាខ្យល់គ មិនខានទេ ។

គេសម្លក់ពួកស្រីអស់នោះ ធ្វើឫកហាក់ដូចជាមិនពេញចិត្តនឹង កិរិយារបស់នាងៗ ដែលមានចរិតជ្រួលច្រាល គ្មានសណ្ដាប់ធ្នាប់ គ្មានសុជីវធម៌ទន់ភ្លន់ចំពោះភ្ញៀវ ។ រំពេចនោះ សូរទូរស័ព្ទលាន់ ឡើង ។ បុរសសង្ហាក៏លើកឆ្លើយតបយ៉ាងរហ័ស ៖

- បងមកដល់ហើយតើហ៎! កំពុងរង់ចាំអូននេះអី... តុងដែល!

CHANBOKEO.COM

រំពេចនោះ នារីសោភាមួយរូបអាយុប្រហែល២៥ឆ្នាំ ផាត់មុខលាមក្រែមម្សៅយ៉ាងឆើតសិចស៊ីស្រស់អស្ចារ្យ លេចឆ្លោឡើងមក ពីក្រោយខ្នងនរៈ ហើយយកទូរស័ព្ទចុចស្មារបស់គេ ៖

- សួស្តី ជិនហួ!
- សាវីរី! (បុរសឧទានហៅឈ្មោះនាងទាំងមុខញញឹម)
- បែកគ្នាពីរបីថ្ងៃ មាននឹកសាវីរីដែរទេបង ?
- នរណាថាជិនហួមិននឹកនោះ សង្សារមួយទាំងមូលទៅហើយ ?
- ហើយបើនឹកមែន ម៉េចក៏មិនឃើញទូរស័ព្ទមកអូនបន្តិចសោះ ?
- ដកឃ្លាពីការងារមិនរួចនោះអី ? សព្វថ្ងៃនេះ យើងមានកុងត្រាត្រូវដឹកឥវ៉ាន់ចេញទៅក្រៅប្រទេសច្រើនជាងមុន ដូច្នេះ បងត្រូវមើលចាត់ចែងអោយផលិតផលដឹកចេញទៀងទាត់ តាមកុងត្រា កុំអោយខូចមុខមាត់រោងចក្ររបស់យើង បើមិនដូច្នោះទេ លោកប៉ារបស់អូនមុខជាយិតបងស្លាប់ហើយ ។
- យី! ឥឡូវនេះ បងនិយាយខ្មែរបានឡូយណាស់តើហ៏ ? រៀនតែ បីបួនឆ្នាំសោះ និយាយរត់មាត់ច្រឡំនឹងខ្មែរស្រុកយើងនេះដែរ ។
- មកពីបងធ្វើការជាមួយខ្មែររាល់ថ្ងៃ ហើយមានសង្សារជាខ្មែរផង ទើបបងចេះច្រើនដល់ម្លឹងនោះ ។

បន្តិចមក គេក៏ហៅអាហារបរិភោគ ។ បុរសនោះមានឫកឆ្មើង ឆ្មៃ ក៏ពិតមែន តែចំពោះនារីសោភាដូចសាវីរី គេបែរជាបន្ទន់ ឥរិយាដាក់នាងយ៉ាងទន់ភ្លន់ទៅវិញ ។

- ចុះខាងសណ្ឋាគាររបស់អូនវិញ មានដំណើរការយ៉ាងណាដែរ ?

ជិនហួសួរសង្សារ ។

- ដូចជាចេះតែទៅមុខធម្មតាទេនឹង ? សាវីរីមិនសូវដឹងទេ ព្រោះ មិនដែលទៅ ។ នោះជាកិច្ចការរបស់លោកប៉ានិងបងប្រុស សាវីរី មិនចង់ដឹងឮទេ ។
- ហើយចុះអូនមិនទៅជួយធ្វើការលោកប៉ាខ្លះទេហ៏ ?
- មានលុយចាយមិនអស់ទៅហើយ អោយសាវីរីទៅធ្វើការធ្វើអី ? សាវីរីចង់មានពេលជាមួយបងជាជាង ។

CHANBOKEO.COM

- តែបងក៏មិនទំនេរដូចគ្នាដែរណា៎ ត្រូវធ្វើការដូចតែលោកប៉ានិង បងប្រុសរបស់សាវរីអញ្ចឹង
មិនដូចសាវរីដែលមិនចាំបាច់ធ្វើការអ្វីក៏ បានដែរ
ព្រោះមានលោកប៉ានិងបងប្រុសជាបង្អែកធំនោះ ។
- គឺមកពីអូនជាស្រីស្អាត...តើនរណាគេចង់ប្រើអូនដែរទៅ ?

សាវរីធ្វើឫកខ្មិកខ្មក់ដាក់ជិនហួភ្លាម ។ បុរសក៏បាត់មាត់ដូចគេ ចុក
កាលបើនាងម្ញិកម្ញក់អោយបុរសកើតក្តីស្រម័យស្រើបស្រាល
នៅក្នុងអារម្មណ៍របស់គេយ៉ាងភ្លើតភ្លើនស្ទើរទប់ចិត្តមិនបាន ។

- ជិនហួ! ថ្ងៃនេះ យើងមានពេលយូរទេ ?
- មានប្រហែលជាមួយម៉ោង... អូនចង់ទៅណា ?
- ទៅរកជួលអូប៉័រជិះដើរលេង...
- នេះក្បែរព្រលប់ហើយ... ទៅជិះអូប៉័រយ៉ាងម៉េចនឹងកើត ?
- អញ្ចឹងទៅមើលកុនទេ ? សាវរីចង់មានពេលវេលាខ្លះៗជាមួយ បង ។
យើងជាសង្សារនឹងគ្នាពិតមែន ប៉ុន្តែបែរជាមានឱកាសជួប គ្នា ដូចជាអំពិលអំពែកអញ្ចឹង ។
- ចាំថ្ងៃក្រោយទៅនឹង ព្រោះបងត្រូវត្រឡប់ទៅរោងចក្រវិញទាំង យប់
ដើម្បីទទួលភ្ញៀវបរទេស ដែលមកសន្ទនាទាក់ទងការនាំ ផលិតផលចេញក្រៅ ។

សាវរីធ្វើមុខស្មើក ព្រោះមិនសមបំណង ។ ការពិត អ្នកទាំង
ពីរស្គាល់គ្នាតាមរយៈការងាររកស៊ីរបស់គេ ។ ជិនហួជាជាតិចិន មក
ធ្វើវិនិយោគទុននៅភ្នំពេញដោយការបើករោងចក្រកាត់ដេរដើម្បីនាំ
ផលិតផលបំរើសេវាក្នុងប្រទេសផង ទៅក្រៅប្រទេសផង ។ ឪពុក
របស់គេជាពាណិជ្ជករអភិជនដ៏ល្បីម្នាក់ នៅក្វាងទុងប្រទេសចិន ។
រីឯសាវរីជាកូនមហាសេដ្ឋីម្ចាស់សណ្ឋាគារផ្កាយប្រាំនៅភ្នំពេញ ដែល
មានភាគហ៊ុនពាក់កណ្តាលក្នុងរោងចក្រជិនហួ ។ នរៈនារីទាំងពីរក៏ បានត្រូវណែនាំអោយស្គាល់គ្នា
តាំងពីជិនហួបានមកដល់ដីខ្មែរដំបូង កាលពីជាងបីឆ្នាំមុន ។ រីឯបងប្រុសសាវរី ឈ្មោះសារៈ
បានត្រូវ តែងតាំងជានាយចំណាត់ការរបស់រោងចក្រជិនហួអិលធីឌី ។

ព្រលប់នោះ ធិតាធ្វើមុខហាក់ដូចមិនស្រួលក្នុងចិត្តដែលជិនហួ
មិនមានពេលវេលាសំរាប់នាងដូចដែលនាងទាមទារ ។ ក្រោយពី បរិភោគរួចហើយ
គេក៏បែកគ្នាសាជាថ្មី ។

CHANBOKEO.COM

- យើងជួបគ្នាជាថ្មីទៀត នៅថ្ងៃណាដែរ ជិនហួ ?

- ប្រហែលជាថ្ងៃអាទិត្យ បងនឹងមានពេលពេញមួយថ្ងៃ... ចាំបងនាំអូនទៅលេងឆ្នេរកំពង់សោមម្តង ។

គ្រាន់តែឮថាឆ្នេរកំពង់សោម សាវីញញឹមពព្រាយភ្លាមតែម្តង ដោយមិនបាច់ប្រឹង ៖

- អញ្ចឹង អូនរង់ចាំបងទៅទទួលណា៎ !

- បាទ !

អ្នកទាំងពីរក៏បែកផ្លូវគ្នា ។ ជិនហួក៏បររថយន្តសំដៅទៅឫស្សីកែវដែលជាទីតាំងរោងចក្ររបស់ឪពុកនរៈមួយកន្លែង ។ តាមដង ផ្លូវនោះ មានចរាចរណែនណាន់ខ្តាន់ខ្តាប់ មានអ្នកស្រុកលក់ដូរតាម ដងផ្លូវ និងមានកម្មកររោងចក្រដើរច្រវាត់ច្រវែងមិនដឹងជាទៅ ណា មកណាខ្លះទេ ។ លុះនរៈបរមកដល់ជិតមាត់ទ្វាររោងចក្រ ស្រាប់តែ មានរថយន្តធំមួយ បរដឹកឥវ៉ាន់លើសចំណុះ បែកកង់ផ្ទុង វែចង្កូត ធ្លាក់គន្លុកដីធំមួយ ផ្អៀងតួឡានជ្រុះធ្លាក់ឥវ៉ាន់ប្រាវ មកលើតួរថយន្តដ៏សង្ហារបស់បុរសជាតិចិននោះ ដណ្តប់ចង់ជិតអស់តួឡាន ថែមទាំងសង្កត់លើរ៉ឺម៉កម៉ូតូដឹកមនុស្សមួយចំនួនទៀត កប់បាត់អ្នក ដំណើរ មិនដឹងជាស្លាប់រស់ឬរបួសអស់ប៉ុន្មាននាក់ទេ ។ អ្នកស្រុក ក៏ផ្អើលជ្រួលច្រាលឡើងអ៊ូអរ ស្ទុះចរាចរកកគាំងលែងទៅណារួចតែ ម្តង ។ សូហ្វ័រឡានធំនោះភិតភ័យណាស់ ក៏រត់ចុះពីឡានរត់ត្រុយ បន្លំខ្លួនបាត់ទៅក្នុងចំណោមមនុស្សរយពាន់នោះបាត់ទៅ ។ ចំណែកអ្នករងគ្រោះក៏ត្រូវគេសង្គ្រោះចេញម្តងមួយៗ ។ ចៃដន្យអី នៅ ពេលគេកាយយកឥវ៉ាន់ចេញពីតួឡានរបស់ជិនហួរួច គេឃើញនរៈ ត្រូវអំបែងកញ្ចក់មុតឈាមពេញខ្លួន ។ ស្រាប់តែពួកហ្វូងកម្មករ ដែលរត់មកជួយទាំងនោះ បែរជានាំគ្នាដើរថយក្រោយក្រាកៗ មិន ព្រមចូលជិតទៅសួរអ្វីជាមួយបុរសនោះឡើយ ។ រំពេចនោះ មាន នារីមួយរូបក្នុងវ័យប្រហែល២០ឆ្នាំ ស្ពាយសាក់កាដូមួយនៅលើស្មា បានឧទានឡើងថា ៖

- ហេតុអ្វីហ្នឹ៎ ឃើញមនុស្សរបួសហើយមិនជួយដូច្នេះ ?

មាណវីក៏ស្ទុះទៅជិត ជួយបើកទ្វារឡាន តែបើកមិនចេញ ត្បិត ទ្វារនោះត្រូវរបស់របរធ្លាក់សង្កត់កំពិតរួញចូលក្នុង ។ នាងក៏ស្ទុះរត់ ទៅបើកនៅទ្វារម្ខាងទៀត ស្រាប់តែមានកម្មការិនីមួយរូបទាញដៃ នាងទៅឱ្យបប្រាប់ថា ៖

CHANBOKEO.COM

- កុំទៅចង់ធ្វើបុណ្យជាមួយពួកអាថៅកែអ្នកមានអស់ហ្នឹង! វាមិន
ចេះស្គាល់បុណ្យគុណទោសអីទេ ។ វាចេះតែហុតឈាមអ្នកក្រតែ ម្យ៉ាងប៉ុណ្ណោះ ។
អោយឈាមអាក្រក់វាហូរចេញខ្លះក៏ល្អហើយ នោះ វានឹងបានដឹងថា ហុតឈាមអ្នកក្រលើសចំណុះ
នរកវាតាមទារវិញ យ៉ាងងាយៗ ដូច្នេះឯង ។

តែមាណវីជួញចិញ្ចើម មិនយល់ថាគេនិយាយនោះ សំដៅ បុរសនោះតែម្តង
ឬក៏គ្រាន់តែជាភាសាដែលអ្នកក្រស្អប់អ្នកមានជា ទូទៅព្រោះអ្នកមានចូលចិត្តជិះជាន់អ្នកក្រ ?
នាងឃើញអ្នករបួស នោះទន់ករងាក ក៏ស្រដីថា ៖

- ឃើញមនុស្សទុរន់ទុរាហើយ មិនជួយក៏មិនកើត តែបើជួយទៅ ខ្លាចប៉ះមនុស្សមិនល្អ
តើធ្វើម៉េចទៅហ្ន៎ ?

មនុស្សម្នាចោមជិតឡាន តែគ្មាននរណាឈឺឆ្អាលជួយបើកទ្វារ
ដោះយកបុរសនោះចេញមកក្រៅទេ ។ មើលទៅគេ ទំនងដូចជា ត្រូវក្បាលយ៉ាងដំណំហើយ
ទើបឃើញទន់ខ្លួនធ្វើងីងើនិយាយអ្វីមិន រួចដូច្នេះ ។ ទ្រាំមើលនឹងភ្នែកមិនបាន
ធិតាម្នួយរូបនោះក៏អើតតាម ចន្លោះបង្អួចម្ខាងទៀត សួរថា ៖

- នែ៎! អ្នកម្ចាស់ឡាន! ដឹងខ្លួនទេ ? អាចព្រមៀលខ្លួនចេញខាង នេះបានទេ ?
ចាំខ្ញុំនឹងបើកទ្វារខាងនេះអោយចេញ ។

បុរសនោះប្រឹងបែកភ្នែកទាំងឈឺចាប់ ។ ឯឈាមក៏ហូរពីក្បាល
ស្រក់មកលើផ្ទៃមុខជិតពេញស្ទើរលែងឃើញមុខទៅហើយ ។ កាល
បើបែរឃើញនារីយេិងបើកទ្វាររថយន្តម្ខាងទៀតអោយ គេក៏រំកិល ខ្លួនទាំងទុរន់ទុរាចេញមក ។
មើលទៅគេក៏មានរបួសគួរសមដែរ សុទ្ធតែអំបែងកញ្ចក់មុតពេញខ្លួន
តែប្រហែលជាមិនដល់ថ្នាក់បាក់ ឆ្អឹងបាក់ឆ្អែងនោះទេ ព្រោះគេនៅកំរើកខ្លួនបានតាមសម្រួល ។

រំពេចនោះ ធិតាក៏សួរបុរសម្នាក់អាយុប្រមាណប្រហែល៣០ឆ្នាំ
កំពុងជិះម៉ូតូដៃកឈប់គាំងស្ទះក្នុងចរាចរម្តុំៗនោះដែរ ៖

- ល្បឹងៗ! ជួយឌុបគាត់នោះទៅពេទ្យបន្តិចបានទេ ?

បុរសនោះសម្លឹងមុខនារីធ្វើភាំង មិនឃើញឆ្លើយទេ ។ នាងក៏ សួរទៀតថា ៖

- បងរត់ម៉ូតូឌុបទេ ? បើរត់ ដឹកគេនេះទៅពេទ្យបន្តិចទៅ ឃើញ មនុស្សរបួសហើយមិនជួយ
ដូចជាអត់ចិត្តពេកណាស់ ។

អ្នកស្រុកឈរមើលម្តុំនោះក៏ធ្វើមុខភាំងដូចគ្នា ។ ស្រាប់តែមាន មនុស្សម្នាក់លាន់មាត់ថា ៖

CHANBOKEO.COM

- នាងប្រហែលជាអ្នកចម្ងាយហើយ បានជាមានកិរិយានិងសំដីខុស គេយ៉ាងនេះ ។ បើសិនជាអ្នកស្រុកម្តុំនេះវិញ គេទុកកិច្ចការនោះឲ្យ ប៉ូលីសធ្វើការហើយ ព្រោះអ្នកស្រុកយើងមិនចូលចិត្តលូកលាន់រឿង រ៉ាវរបស់ពួកអ្នកមាន នាំតែជ័រភ្លៅស្អិតជាប់ឃ្លៀកទទេៗនោះទេ ។ ពួកអ្នកមានវាមិនដែលស្គាល់គុណស្រ័យ និងសមានចិត្តរបស់អ្នក ក្រដូចពួកយើងនេះ ម្តងណាឡើយ ។

នារីនោះឮហើយក៏ស្រដីខ្សិបៗក្នុងមាត់តែម្នាក់ឯងថា ៖

- នរណាថាខ្ញុំជួយដោយមិនគិតសគុណ ? ពុទ្ធោ...! នរណាមិន ស្គាល់ ?... រាសីស្មោះ ! មិនអោយរបូតងាយៗឡើយ ព្រះអង្គ!

អូហ៍! ការពិតគឺរាសីរបស់យើងទេតើហ៍! ចុះហេតុអ្វីមកដល់ ភ្នំពេញនេះទៅវិញ ?

បុរសជិះម៉ូតូនោះមិនឆ្លើយនឹងនារីយើងថាយ៉ាងណាទេ គ្រាន់ តែសម្លឹងមុខនាង ហាក់ដូចជាចាប់អារម្មណ៍រឿងអ្វីម្យ៉ាង រួចហើយ គេក៏ឈប់ម៉ូតូជួយទប់ជិនហួ អោយឡើងអោបចង្កេះរបស់គេពីខាង ក្រោយ ដើម្បីដឹកយកទៅមន្ទីរពេទ្យ ។

- ជួយយកកាតាបដាក់ឯកសារពីឡានអោយខ្ញុំផង! (ជិនហួស្រដី ពឹងនារីយើង រួចហើយក៏លើកទូរសព្ទ័ហៅគ្នីគ្នា)

រាសីក៏ស្ទុះទៅបើកទ្វារឡាន ស្រវាកាតាបខ្មៅដាក់ឯកសាររបស់ ជិនហួចេញមក ស្រាប់តែភ្លាត់ដៃជ្រុះកាតាបនោះកំពប់លើពូកឡាន ចេញឯកសារព្រោងព្រាត ។ នាងដាក់ភ្នែកទៅឃើញក្រដាសមួយ សំណុំកិបជាប់គ្នា មានបោះត្រាពណ៌ក្រហមថា ឯកសារសម្ងាត់ ។ នាងភ្ញាក់ព្រើតលួចចោលកន្ទុយភ្នែកសម្លឹងទៅម្ចាស់រថយន្ត ឃើញ គេកំពុងយកដៃជូតឈាមដែលហូរពីក្បាលចូលភ្នែក ។ នាងក៏ស្រវា ប្រមូលក្រដាសឯកសារទាំងនោះទុកវិញជាប្រញាប់ រួចបិទកាតាប យួរចេញមក ។ បុរសម៉ូតូក៏រោទិ៍ម៉ាស៊ីន ម៉ូតូបំរុងចេញទៅ ។

- ឈប់សិន! កុំលឿនពេក! ខ្ញុំទៅដែរ ។

រាសីនិយាយហើយ ក៏ហក់ឡើងជិះច្រកកៀរពីក្រោយបុរសទាំង ពីរយ៉ាងរហ័ស ធ្វើឲ្យមនុស្សឈរម្តុំនោះ គេមើលច្រូងច្រាងព្រោះ ចម្លែកចិត្ត ដែលឃើញមនុស្សស្រីស្លៀកខោអាវប្រុស សំដីក្លាហាន មានចរិតដូចប្រុសយ៉ាងដូច្នោះ ។ ភ្លាមនោះ ប៉ូលីសមួយហ្វូងបាន មកដល់កន្លែងកើតហេតុដែរ ។ ចៃដន្យ ជិនហួបានចេញបាត់ពីម្តុំ នោះបាត់ទៅហើយ ។

CHANBOKEO.COM

បុរសម៉ូតូឌុបដឹកអ្នករបួសនិងរាសី មកដល់គ្លីនិកមួយមិនឆ្ងាយ ប៉ុន្មានពីទីគ្រោះថ្នាក់នោះទេ ។ តែដោយភាពអ៊ូអរ និងការស្ទះ ចរាចរ គេចំណាយពេលជិតកន្លះម៉ោង ទំរាំនាំជិនហួមកដល់គ្លីនិកនោះ ។ លោកគ្រូពេទ្យប្រចាំគ្លីនិកក៏រត់ចេញមកទទួលយកអ្នករបួស ចូលភ្លាម ។ រាសីអង្គុយលើកៅអី យកដៃគោះកាតាបដាក់ឯកសារ របស់ជិនហួប៉ិកប៉ក់ៗ នៅខាងក្រៅក្បែរមាត់ទ្វារគ្លីនិក ។ ចំណែក បុរសម៉ូតូឌុបចេះតែលួចសម្លឹងមុខនារីភ្លៀកៗ មិនព្រមដាក់ភ្នែក សោះ មិនដឹងថាគេកំពុងគិតអ្វីពីនាងទេ ៖

- នែ៎! កុំសូវមើលមុខខ្ញុំពេកមើល៏! (រាសីគំហកអោយ) ម៉េច ខ្លាចខ្ញុំមិនមានលុយអោយថ្លៃម៉ូតូ ហីយ៉ាំងម៉េច បានជាមើលមុខខ្ញុំ មិនព្រមឈប់យ៉ាំងនេះ ?

បុរសនោះឮវាចារបស់នាងភ្លាម ក៏ញញឹម ហើយបែរទៅម្ខាង នៅស្ងៀម មិនតបមិនស្រដីអ្វីទៅនាងវិញទេ ។ បន្តិចមក គេក៏លួចចោលកន្ទុយភ្នែកលួចមើលធិតាទៀតសាជាថ្មីដដែល ។ ឃើញ ដូច្នោះ រាសីក៏ដោះម្ជុកហើយដើរទៅជិត រួចស្រដីសួរនាយម៉ូតូឌុប បន្តទៀតថា ៖

- នែ៎ល្បែងម៉ូតូឌុប! មានកាម៉ារ៉ាថតរូបទេ ?

បុរសនោះភ្ញាក់ព្រើត គ្រវីក្បាល តបវិញថា ៖

- បាទ! អត់មានទេ! អ្នកនាងត្រូវការយកទៅថតកន្លែងកើត ហេតុមែនទេ ?
- នរណាថា ? ខ្ញុំចង់បានកាម៉ារ៉ា យកមកអោយល្បែងឯងជួយថត រូបខ្ញុំ ប្អូនដប់ប៉ុស្តិ៍លេង ។
- អូហ៍ អ្នកនាងថតរូបយកទៅចុះឈ្មោះធ្វើការនៅឯណាមែនទេ ?
- អត់ទេ! គឺចង់ថតអោយល្បែងឯងយករូបខ្ញុំទៅផ្ទះ ដេកមើល អោយណាណីតែម្តងទៅ កុំអោយពិបាកចោលកន្ទុយភ្នែកលួចមើល ខ្ញុំ ឡើងស្រឡេវភ្នែកបែបនេះច្រើនពេក ។ ខ្ញុំខ្លាចល្បែងឯងក្លាយ ជាជនស្រឡេវតេវ កែលែងឡើង!

បុរសនោះហាក់ដូចរអៀសខ្លួនបន្តិចដែលនាងនិយាយចំៗ តែ ក៏លួចញញឹមក្រញួចមាត់ ចង់សើចបន្តិច ខ្មាស់បន្តិច ព្រោះមាណវី មានសំដីរួសរាយគួរអោយចូលចិត្ត ។ រំពេចនោះ បុរសយកដៃខ្ទប់ ដើមទ្រូងឆ្វេងរបស់ខ្លួន ហើយស្រដីថា ៖

- តែ...កាម៉ារ៉ាពិសេសក្នុងទ្រូងឆ្វេងរបស់ខ្ញុំនេះបានថតរូបអ្នកនាង ទុកហើយ ។ ចាំយប់នេះ ខ្ញុំនឹងយកហ្វិលមកចាក់សាថ្មី គេងមើល អោយពេញម៉ាយប់ ទាល់តែអស់ចិត្តខ្ញុំតែម្តង ។

ស្រាប់តែនាងសើចខឹកៗឡើង ឆ្លើយថា ៖

CHANBOKEO.COM

- យ៉ាងណា សូមមេត្តាកុំតែធ្លាក់ពីលើគ្រែបានហើយណា៎!

- បើសិនខ្ញុំធ្លាក់ពីលើគ្រែមែន តើមាននរណាគេទៅហ្ន៎ មកជួយ យកអាសារ លើកខ្ញុំដាក់ចូលក្នុងមុងលើគ្រែវិញ ?

- ខ្ញុំថាប្រហែលជាមូសហើយមើលទៅដែលចិត្តល្អជាងគេនោះ ។

បុរសនោះអត់មិនបានក៏លាន់សំណើចខឹកៗឡើង ។ ពេលនោះ រាសីសង្កេតឃើញថា នរៈក៏ហាក់ដូចជាមានចិត្តចង់និយាយជាមួយ នាងច្រើន គ្រាន់តែគេមិនដឹងថាត្រូវចាប់ផ្តើមការសន្ទនាយ៉ាងណា ទើបគេយកកន្ទុយភ្នែកជាគោលសញ្ញា អោយនាងចាប់អារម្មណ៍ថា គេកំពុងតែចង់ប្រស្រ័យសន្ទនាជាមួយនាង ។ ចៃដន្យ រាសីមិនមែនជានារីអៀនប្រៀនខ្មៀនកៀនជញ្ជាំងនោះទេ ។ នាងជាមនុស្ស ក្លាហាន បានមាត់បានកតាំងតែពីដើមមក មិនសូវចេះតមមាត់រឿង អ្វីឡើយ ។ ពេលនោះ អ្នកទាំងពីរក៏ចាប់ផ្តើមមានរឿងជជែកឆ្លោះ ឆ្លងគ្នាទៅវិញទៅមក យ៉ាងសប្បាយសើចកក្អឹកតែម្តង ។

បន្តិចមក លោកគ្រូពេទ្យនាំជិនហួចេញមកវិញ ។

- លោកអោយថ្លៃព្យាបាលគេហើយមែនទេ ? (រាសីសួរ)

ជិនហួងក់ក្បាល លួចសម្លឹងមុខនារីយើងភ្លៀកៗ ។ ភ្លាមនោះ រាសីក៏សួរជិនហួទៀតថា ៖

- ចង់អោយខ្ញុំជូនទៅផ្ទះទេ ?

ជិនហួសម្លឹងមុខនាងមួយស្របក់ ក៏ងក់ក្បាល ហើយស្រដីតប ទាំងទឹកមុខនៅឈឺចាប់ដោយសាររបួសនៅឡើយ ថា ៖

- បាទ! គឺសូមជូនខ្ញុំទៅរោងចក្រជិនហួ អិលធីឌី ផង ។

បន្តិចក្រោយមក បុរសម៉ូតូឌុបបាននាំជិនហួនិងរាសីមកដល់ មុខរោងចក្រ ដែលមានឆ្មាំពីររូបឈរចាំយាមឆែកឆេរ ។ ជិនហួចុះ ពីម៉ូតូហើយក៏ស្រដីថា ៖

- អរគុណអ្នកទាំងពីរដែលមកជួយខ្ញុំថ្ងៃនេះ ។

គ្រាន់តែក្រឡេកឃើញវត្តមានជិនហួភ្លាម ឆ្មាំទាំងពីរស្ទុះរឹងមក ទទួលស្វាគមន៍ ៖

- ជំរាបសួរលោកជិនហួ!

រាសីភ្ញាក់ព្រើត នឹកក្នុងចិត្តថា ៖

- លោកជិនហួ ?...ជាថៅកែរបស់រោងចក្រជិនហួអិលធីឌីតើហ៎!

ជិនហួរៀបនឹងដើរចូលទៅក្នុងរបងរោងចក្រទៅហើយ ស្រាប់តែរាសីស្រែកឡើងពីក្រោយ ថា ៖

- ថៅដន្យ យើងជាអ្នកក្រ មានសមានចិត្តជួយលោកពិតមែន តែកុំភ្លេចថ្លៃលើកទឹកចិត្តអ្នកក្រផង ដើម្បីអោយសមនឹងមុខមាត់របស់ ថៅកែរោងចក្រទាំងមូល... សូមមេត្តាកុំដើរបែរខ្នងចេញដោយមិន បានបង្ហាញសមានចិត្តតបយើងវិញ ចំពោះការដែលយើងបានធ្វើ ចំពោះលោកនៅថ្ងៃនេះ ព្រោះថា បើធ្វើដូច្នោះមែន គឺហាក់ដូចជាបង្ហាញនូវភាពអាត្មានិយមរបស់អភិជនពាន់ពេកណាស់ ។

ជិនហួភ្ញាក់ព្រើតបែរក្រោយសម្លឹងមុខយុវនារីយើងយ៉ាងរហ័ស តែម្តង ។ មែនហើយ! អំបាញមិញ គេរវល់តែនឹកគិតដល់រឿង ជំនួបជាមួយពាណិជ្ជធំៗ មកពីបរទេសក្នុងរោងចក្ររបស់គេ នា ព្រលប់នេះ ម្ល៉ោះហើយ គេក៏ភ្លេចអោយឈឹងរឿងថ្លៃម៉ូតូឌុបនិងថ្លៃលើកទឹកចិត្តនារីអស់រលីង ។ ណាមួយ គេធ្លាប់ធ្វើតែជាថៅកែ វាយឫកឆ្មើងឆ្មៃ មានអ្នកបំរើឆ្វេងស្តាំ ហុចនេះហុចនោះតាមតែគេ ត្រូវការ មិនចាំបាច់នឹកគិតថាត្រូវសម្តែងសទ្ធាលើកទឹកចិត្តដល់ នរណាម្នាក់នៅក្នុងរោងចក្រសោះឡើយ ។ លុះដល់គេមកប្រទះឧប្បត្តិហេតុថ្ងៃនេះ គេក៏ភ្លេចខ្លួនថា គេកំពុងជំពាក់សមានចិត្តរបស់អ្នកស្រុកដែលមិនមែនជាកម្មករស៊ីប្រាក់ខែរបស់រោងចក្រ ។ កាលបើឮសំដីផ្លែផ្ការបស់មាណវីយើង គេក៏ភ្ញាក់ខ្លួនក្រញាង នឹកខ្មាសឆ្មាំ ទ្វារពីរនាក់នោះដល់ស្ទូរហើយ ត្បិតឆវីយើងស្រដីឮខ្លាំងៗ មិនមាន នឹកក្រែងរអែងចិត្ត ។

ជិនហួដកដង្ហើមបន្ធូរទ្រូងមួយ រួចក៏ទាញកាបូបដកលុយពីរបី សន្លឹកហុចអោយនារីដែលកំពុងឈរច្រត់ចង្កេះចាំទទួលក្បែរនាយ ម៉ូតូឌុប ។ ធិតាទទួលយកមកលាតមើលស្រាប់តែភ្ញាក់ព្រើត ត្បិត
នោះជាប្រាក់បីដុល្លារតែប៉ុណ្ណោះ ៖

- ពុទ្ធោអើយ! យើងខំប្រឹងជួយលោកម៉ាដៃ បានត្រឹមតែបីដុល្លារ ប៉ុនហ្នឹងទេហ៍? អីក៏ចិត្តល្អម្ល៉េះលោកអ្នកមាន?

ជិនហួជ្រួញចិញ្ចើមហើយស្រដីតបថា ៖

- ថៅដន្យ ខ្ញុំមានរាយតែប៉ុនហ្នឹងឯង ។ ថ្លៃម៉ូតូឌុបតែប្រាំកាក់ទេ ដូច្នេះចំណែកពីរដុល្លារកន្លះដែលនៅសល់ គឺជារបស់នាងហើយ ។ ប៉ុនហ្នឹងហាក់ដូចជាច្រើនពេកផង សំរាប់ការងារដែលនាងធ្វើជាង ពីរម៉ោងកន្លងមក ។

CHANBOKEO.COM

បើនាងធ្វើកម្មកររោងចក្រវិញ ប្រាក់ការងារ ៨ម៉ោងបានតែមួយដុល្លារកន្លះទេ ក្នុងមួយថ្ងៃ ។ ដូច្នេះ អ្វីដែល នាងបានទទួលឥឡូវនេះ គឺលើសចំនួនពីប្រក្រតីហើយតើហ៎!!

ថាហើយ ជិនហ្វដើរចូលទៅក្នុងរោងចក្រធ្វើមិននឹង ហាក់ដូចជាមិនខ្វល់នឹងអារម្មណ៍របស់នរណាឡើយ ។ រាសីក៏កើតចិត្តមោហោ ភ្លាម ហើយក៏ខាំធ្មេញក្រឹតៗ ស្រដីខ្សឹបៗតែក្នុងមាត់ពីក្រោយខ្នង ជិនហ្វ ថា ៖

- ស្មានថាអ្នករួចខ្លួនហើយហ្នឹង លោកចៅកែ ? យើ! កុំច្រឡំ ស្មានថារួចខ្លួនអោយសោះ... រាសីមិនអោយអ្នកដើរខ្សែលើងាយៗ ដូចអ្នកបានគិតនោះឡើយ... បន្តិចទៀត អ្នកគង់តែមករកខ្ញុំវិញ ដើម្បីទទួចអង្វររាសីយើងជាក់ជាមិនខាន ។

ថាហើយ នាងក៏ហុចពីរដុល្លារអោយទៅបុរសម៉ូតូឌុប ៖

- នេះ ថ្លៃសាំងម៉ូតូរបស់ល្បង! យកទៅ!

បុរសនោះសម្លឹងមុខនារី រួចលូកដៃទទួលយកប្រាក់ បន្តិចមក ក៏អាប់អោយធិតាវិញ ពីរពាន់រៀល (ប្រាំកាក់) ៖

- នេះ យើងចែកគ្នាម្នាក់ពាក់កណ្តាលចុះណ៎ា យ៉ាងម៉េចដែរ ?
- អត់ទេ! (រាសីតប) ល្បងចេញថ្លៃសាំងម៉ូតូ ចំណែកខ្ញុំមិនមាន ចំណាយអ្វីទេ គ្រាន់តែហត់មាត់ប៉ុនហ្នឹង មិនគួរយកច្រើនជាងល្បងឯងទេ ត្បិតហាក់ដូចជាប្រមាថកម្លាំងអ្នកក្រគ្នាឯងណាស់ ។ ខ្ញុំយកតែមួយដុល្លារសមរម្យហើយ ។

ដោយឃើញមានសមានចិត្តចំពោះខ្លួនដូច្នោះ គេក៏សួរថា ៖

- ចង់អោយខ្ញុំជូនអ្នកនាងទៅខាងណាទេ ឥឡូវនេះ ? ខ្ញុំសូមជូនមួយជើងដោយឥតគិតថ្លៃឈ្នួលទៅចុះ គិតថា ខ្ញុំជូនជាសមានចិត្តដែលអ្នកនាងជួយរកម៉ូយម៉ូតូឌុបថ្ងៃនេះមកអោយខ្ញុំ រហូតដល់បាន ប្រាក់ពីរដុល្លារឯណោះ ។

រាសីឈរអោបដៃធ្វើម៉ក់មួយស្របក់ទើបនិយាយថា ៖

- ការពិត រាសីខ្ញុំនេះគ្មានផ្ទះដែលត្រូវទៅទេ ព្រោះទើបធ្វើដំណើរ មកពីបាត់ដំបង ដល់ភ្នំពេញប៉ុន្មានម៉ោងមុននេះឯង ។
- អូហ៍! អញ្ចឹងអ្នកនាងនឹងទៅស្នាក់នៅឯណាទៅ ?
- មិនទាន់ដឹងទេ ចាំរក្សាប្អូនប្រុសខ្ញុំ គេត្រឡប់មកពីរកជួលបន្ទប់ ស្នាក់នៅសិន ។ ពេលនេះមិនដឹងថារកបានឬក៏យ៉ាងណាទេ ព្រោះយើងកំពុងនាំគ្នាមករកការធ្វើនៅភ្នំពេញនេះ ។

CHANBOKEO.COM

- ហើយចុះអ្នកនាងត្រូវទៅជួបប្អូនប្រុសវិញ នៅឯណាដែរ ?

- គឺនៅម្តុំៗគល់ចាមរីមួយក្បែរកន្លែងកើតហេតុអំបាញមិញ...

- អញ្ចឹង ឡើងម៉ូតូមក ខ្ញុំជូនត្រឡប់ទៅវិញ ។

រាសីក៏ហាក់ផ្លាញ ឡើងច្រកកៀវលើម៉ូតូតោងចង្កេះបុរសយើង ចេញទៅភ្លាម ។ រីឯនរៈវិញ ហាក់ដូចជាលួចញញឹមតែម្នាក់ឯង លាក់គំនួចតែក្នុងចិត្ត ដោយបាននារីជិះតោងចង្កេះ ។ គេក៏បរម៉ូតូ យឺតៗកាត់ចរាចរដ៏ណែនណាន់ខ្ពាន់ខ្ពាប់ដូចត្រីពុលទឹក តម្រង់ទៅ រកទីចាស់ ។

មួយសន្ទុះមក គេក៏រករក្សាឃើញ ។ រក្សាក៏ប្រាប់បងស្រីថា ៖

- រកបន្ទប់ជួលបានហើយបង! មួយខែដល់ទៅ១០ដុល្លារឯណោះ គ្រាន់តែជាកូនផ្ទះឈើមួយមានចែកបន្ទប់ៗ ហើយខ្ញុំកក់គេយក បន្ទប់មួយហើយ នៅជិតរោងចក្រជិនហួអិលធីឌី ។

គ្រាន់តែឮឈ្មោះនេះភ្លាម រាសីភ្ញាក់ព្រើតបើកភ្នែកធំៗ នឹកក្នុង ចិត្តតែម្នាក់ឯង ៖

- តើរាសីយើងនេះមានជាប់ជំពាក់និស្ស័យអ្វីជាមួយម្ចាស់រោងចក្រ នេះទេដឹង បានជាមានហេតុការណ៍នាំគន្លងអោយយើងដើរប្រទាក់ ក្រឡាជីវិតគ្នារបៀបនេះ ?

ភ្លាមនោះ បុរសម៉ូតូឌុបស្រដីថា ៖

- តើអ្នកទាំងពីរចង់អោយខ្ញុំជូនទៅដល់ផ្ទះជួលនោះដែរទេ ?

- គឺ... មិនបាច់ទេដឹង នាំតែរំខានដល់ពេលវេលារកស៊ីរបស់ល្បង ទេ ណាមួយយើងក៏មិនជាសំបូរប្រាក់បង់ថ្លៃម៉ូតូឌុបផង ។

- មិនអីទេ! ចាត់ទុកថាជាសមានចិត្តនៃការរាប់អានរវាងយើង ទាំងបីនាក់ចុះណា៎! ខ្ញុំមិនគិតគួរថ្លៃឈ្នួលទេ ។

បុរសម៉ូតូឌុបក៏បរជូនអ្នកទាំងពីរទៅរកផ្ទះជួលនោះដល់កន្លែង ត្រឹមត្រូវ ទើបគេបែកផ្លូវត្រឡប់ទៅវិញ ។

នៅព្រលប់ដដែលនោះ...

- រក្សា! ស្អែកនេះប្អូនទៅរកសាលាចុះឈ្មោះចូលរៀន ។ ចំណែក បងវិញ គិតដើររកការធ្វើម្តុំៗនេះចុះ ។

- តើបងសង្ឃឹមទេ ថានឹងបានការធ្វើឆាប់ៗ ?

- បងមិនដឹងទេ! បើយើងព្យាយាម គង់តែបានសំរេចទេ រក្សា!

CHANBOKEO.COM

- នៅភ្នំពេញនេះ បើគ្មានការធ្វើ យើងច្បាស់ជាដាច់ពោះហើយ កុំថាឡើយដល់ទៅមានលុយបង់សាលានោះ ។

- មិនទាន់ចូលសង្វៀនប្រយុទ្ធផង ម៉េចក៏រៀបចិត្តបំរុងទទួលការ ចុះចាញ់ទៅហើយ ? បងគិតថា យើងនឹងមានលាភឆាប់ៗនេះ !

- អូហ៍... អ្វីទៅដែលនាំអោយបងមានជំនឿដល់ម្លឹងនោះ ?

- គឺប្រាជ្ញរបស់បងនោះអី... វានឹងប្រមូលលាភដល់បងនិងរក្សា ជាមិនខាន មិនយូរមិនឆាប់ ចាំមើលចុះ !

រក្សាញញឹមហើយក៏ទំរេតក្បាលលើខ្នើយសំងំគេង ទុកឲ្យរាសី អង្គុយផ្ទៀងក ពិនិត្យក្រដាសប្អូនដប់សន្លឹកតែម្នាក់ឯង ។

តុក ! តុក ! តុក ! សូរគោះទ្វារ ។

- នរណាហ្នឹង ? (រាសីសួរពីខាងក្នុងបន្ទប់ទៅ)

- គឺខ្ញុំ សយនា ! (សម្លេងបុរសម្នាក់ឆ្លើយ)

- ខ្ញុំគ្មានញាតិឈ្មោះហ្នឹងទេ ! អ្នកមករកបងប្អូនច្រឡំបន្ទប់ហើយ !

- មិនច្រឡំទេ... គឺត្រូវបន្ទប់ហើយ បើកទ្វារអោយបន្តិចមក ។

រាសីពិភាល់ក្នុងចិត្តណាស់ មិនហ៊ានបើកទ្វារបន្ទប់អោយមនុស្ស ចម្លែកទេ មិនដឹងថាគេមានបំណងអ្វីទាំងយប់ ។ តែលុះឮសូរគោះ ច្រើនដងពេក ខ្លាចរំខានដល់អ្នកជាប់បន្ទប់ រាសីក៏ដើបទៅបើកទ្វារ ឡើង ស្រាប់តែប្រទះនឹងបុរសម៉ូតូឌុបដែលនាងជួបពីថ្ងៃមិញនោះ កំពុងឈរសើចញញឹមដាក់នាង ព្រមទាំងមានយួរឥវ៉ាន់មួយស្បោង មកជាមួយផង ។

- អូហ៍ ! ល្បងឈ្មោះសយនាតើហ៍ ?

សយនាញញឹមឡើងកាលបើឃើញធិតាបើកទ្វារអោយ ៖

- សួស្តីរាសី ! នៅចាំមុខខ្ញុំបានដែរមែនទេ ?

មាណវីភ្ញាក់ព្រើត ឆ្លើយឡើង ៖

- ហេតុអ្វីល្បងស្គាល់ឈ្មោះខ្ញុំដែរ ? ហើយមានការអ្វីទៅទាំងយប់ ព្រលប់យ៉ាងនេះ ?

នរៈញញឹមមិនឆ្លើយទេ ត្បិតធីរីបានភ្លេចទៅហើយថានាងធ្លាប់ ហៅខ្លួននាងថា រាសី នៅចំពោះមុខបុរសយើង ។ គេបែរជាសួរ ត្រឡប់ទៅនាងវិញថា ៖

CHANBOKEO.COM

- ចុះបើខ្ញុំមានចំណីបន្តិចបន្តួច យកមកផ្ញើ ដើម្បីបរិភោគជុំគ្នានៅ ទីនេះ តើរាសីអនុញ្ញាតដែរទេ ?

- គឺ... ខ្ញុំនឹងរក្សាបានបរិភោគបន្តិចបន្តួចរួចហើយ !

- អញ្ជើញ មកទទួលទានជាមួយខ្ញុំម្តងទៀតទៅណា៎ ព្រោះខ្ញុំមិនចង់ បរិភោគតែម្នាក់ឯងទេ ព្រោះដូចជាត្រមង់ត្រមោចណាស់ ។

- ចុះល្បងគ្មានប្រពន្ធកូនឬក្រុមគ្រួសារអ្វីទេ បានជា... ?

ភ្លាមនោះ សយនាបែរជានិយាយកាត់ភ្លាមថា ៖

- ម៉ោះ ! នេះត្រីអាំងជក់ត្រសក់លាយសណ្តែក ហើយនឹងស្ងោរ ម្រះ ។ ឯណាចាន ?

ការពិត រាសីនិងរក្សាបានបរិភោគបាយសម្រួបដែលគេលក់នៅ មាត់ផ្លូវអស់ម្នាក់មួយចានរួចទៅហើយមែន ប៉ុន្តែគ្រាន់តែបានមួយ សំរន់តែប៉ុណ្ណោះមិនជាបានឆ្អែតពេញពោះទេ ត្បិតគេចង់សំចៃ ប្រាក់មិនអោយចាយអស់មុនពេលដែលគេរកការធ្វើបាន ។

កាលបើឃើញអាហារមកដល់ទំនងដូចឆ្ងាញ់ រាសីរកប្រកែក មិនរួចសោះ ។ នាងក៏ដាក់សន្លឹកក្រដាសទាំងនោះចុះទៅម្ខាង រួច ក៏ស្រវាចានមកចាប់អាហារចែកគ្នាបរិភោគ ។ ចៃដន្យ រក្សាមិន ព្រមដើបមកទេ បែរជាឆ្លើយថាងងុយគេងណាស់ ។ រាសីក៏នៅ អង្គុយបរិភោគជាមួយនរៈយើងតែពីរនាក់ ។ បន្តិចមក នារីក៏លើក យកចានទៅលាង ។ សយនាអង្គុយស្ងៀមតាមសម្លឹងមាណវី មិន ដាច់ក្រសែភ្នែក ហើយលួចញញឹមតែម្នាក់ឯង ហាក់ដូចជារីករាយ ក្នុងចិត្ត ដែលគេបានបរិភោគបាយជាមួយនាង ។ រំពេចនោះ មាណពដាក់ភ្នែកចុះទៅចំក្រដាសបួនដប់សន្លឹកដែលរាសីដាក់ចោល ក្បែរនោះ ។ គេក៏លើកឡើងយកមកអាន ស្រាប់តែបើកភ្នែកធំៗ តែម្តង ។ លុះឮសូរសម្រិបជើងរាសីដើរចូលមកក្នុងបន្ទប់វិញ នរៈ យើងក៏ប្រញឹបប្រញាប់ទម្លាក់ក្រដាសចុះយ៉ាងរហ័ស មិនអោយធិតា ចាប់ធ្នាក់បានថានាយលួចអានសំណៅផ្ទាល់ខ្លួនរបស់នារីទេ រួច ហើយក៏រៀបឫកពារបស់ខ្លួនដូចប្រក្រតីវិញ ។

រាសីឃើញសយនាអង្គុយស្ងៀមស្ងាត់ ក៏សួរនរៈថា ៖

- ល្បងជាអ្នកភ្នំពេញនេះមែនទេ ?

CHIANBOKEO.COM

- បាទ! ហើយចុះរាសីវិញ ជាស្រី ជាប្រុស ឬក៏ខ្មើយ ? ហៅខ្ញុំ សុទ្ធតែ ល្បងៗ
មើលតែខ្លួនហ្នឹងជាប្រុសអញ្ចឹង!
- យី! ល្បងនិយាយអីអញ្ចឹងទេ ពិបាកស្ដាប់ដល់ហើយ!
- ម៉េចក៏ថាពិបាក ? គឺខ្ញុំចង់នឹង ដើម្បីនឹងអាលរៀបឥរិយាបថ អោយសមរម្យ
ចំពោះគ្នានោះអី ។
- អីយ៉ា! ល្បងមានបំណងអ្វីហ្នឹង ?
- គ្មានអ្វីទេ គឺគ្រាន់តែសុំជាមិត្តប៉ុនហ្នឹងតើហ៍ ?
- ទើបតែស្គាល់គ្នាមិនបានមួយថ្ងៃផង មករកចងមេត្រីជាមិត្តជាបង ប្អូនទៅហើយ...
ដូចជារហ័សពេកទេនឹង ល្បង ? ការពិត ខ្ញុំមិន ទាំងស្គាល់ល្បងផងថាជានរណាផង!
ជាមនុស្សអាក្រក់ល្អយ៉ាងណា ក៏មិននឹង ? វីវរ ល្បងទើបតែរត់ចេញពីគុក ប៉ូលីសកំពុងតាមរក
មុខ  នោះមិនស័យមិត្តភាពរបស់ខ្ញុំស្លាប់ហើយទេ ?
- អញ្ចឹង រាសីរៀនស្គាល់ខ្ញុំអោយជិតដិតទៅ...  ប្អូននឹងបាននឹង ដោយខ្លួនឯង
ដោយមិនបាច់ខ្ញុំរៀបរាប់បរិយាយប្រាប់ច្រើនផង កុំ អោយថា ខ្ញុំចេះតែកាន់ជើងខ្លួនឯង ។

រាសីលួចសម្លឹងមុខនរៈ ឃើញគេមានវ័យចាស់ជាងនាងច្រើន
យ៉ាងហោចណាស់ក៏ដប់ឆ្នាំដែរ ។ មើលទៅគេ ទំនងជាមនុស្សគិត ច្រើនហើយធ្វើការច្រើន
ព្រោះឃើញគេលួចចងចញ្ចើមញឹកញាប់
ថ្វីបើគេតែងតែញញឹមយ៉ាងស្រស់ចំពោះរូបនាងនៅរៀងរាល់ពេល ដែលគេជួបនាងក៏ដោយ ។
បន្ទាប់មក នាងក៏ស្រដីថា ៖
- រាសីមិនខ្លាចនឹងរាប់ញាតិទេ តែបើញាតិហ៊ានលូកថ្លើមរាសីវិញ
នោះរាសីក៏មិនទុកមុខមាត់អោយឡើយ ល្បងនឹងហើយឬនៅ ?
- ដូច្នោះ ល្អណាស់ ដែលរាសីជាមនុស្សស្រវាស្រទេញរកមិត្តភឿន ល្អៗសេពគប់ជាគ្នា ។
សយនាក៏នឹងមានគ្នីគ្នាល្អនឹងហៅរកផងដែរ កុំអោយកណ្ដោចកណ្ដែងពេក ។ អញ្ចឹងថ្ងៃក្រោយ
បើខ្ញុំមកលេង ទៀត រាសីរាប់រកខ្ញុំផងណា៎!
- ហើយចុះនៅភ្នំពេញនោះ ល្បងគ្មានញាតិមិត្តទេ ?
- មានម្នាក់ពីរដែរ! ប៉ុន្តែ អ្នកភ្នំពេញ ភាគច្រើនគេរាប់មនុស្ស នឹងសន្លឹកដុល្លារ
មិនមែនរាប់គ្នាដោយសារទឹកចិត្តរវាងគ្នានឹងគ្នា ដូចអ្នករស់នៅតាមស្រុកភូមិជនបទនោះទេណា៎ ។
- អូហ៍! ហេតុអ្វីដល់ថ្នាក់ហ្នឹងផង ?

CHANBOKEO.COM

- ជីវិតនៅទីក្រុងធំ គឺឯូច្ចេះឯង ។ ញាតិជិតខាងផ្ទះមិនស្គាល់គ្នា ឃើញញាតិហើយ មិនហ៊ានរាប់ ព្រោះមិនដឹងថា នរណាអាក្រក់ នរណាល្អ... ម្នាក់ៗស្រវាស្រទេញរករស់តែរៀងៗខ្លួន គ្មាននរណាមានពេលគួរសមនឹងនរណាឡើយ ។
- បើឯូច្ចេះ រាសីត្រូវរៀនតាមចរិតអ្នកទីក្រុងហើយ កុំអោយមាន សន្តានចិត្តពេកក្រែងច្រឡំយកដំរភ្លៅត្បៀតភ្លៀក ។

បន្តិចមក សយនាក៏លារាសីចេញទៅវិញ ទាំងទឹកមុខញញឹម រីករាយចំពោះចំណងមិត្តភាពថ្មីរបស់គេ ។

នៅក្នុងបន្ទប់ជួល រាសីផ្ដេកក្បាលទៅលើខ្នើយ នឹកគិតក្នុងចិត្ត តែម្នាក់ឯងថា ៖
- តើបុរសនេះជានរណា ? ហេតុអ្វីគេចង់មកចងនិស្ស័យ ជាមិត្តជាមួយយើងដែលជាមនុស្សចំណូលថ្មីទីនេះ ? តើគេមានគោល បំណងអាក្រក់ឬល្អមកលើយើង ?... ដើម្បីប្រយោជន៍អ្វីដែរទៅ កាលបើគេឃើញហើយតើថាយើងជាមនុស្សទីទ័លអត្តខាត់បំផុត នោះ ?

oooooooooooooooooo

ooooo

o

CHANBOKEO.COM

# វគ្គទី៣
# ឯកសារ១០សន្លឹក

ព្រឹកស្អែកឡើង...

រក្សាឡើងម៉ូតូឌុបចេញទៅរកមហាវិទ្យាល័យ ដើម្បីចុះឈ្មោះត្រៀមខ្លួនសំរាប់ចូលរៀនឆ្នាំសិក្សា ដែលកំពុងតែបោះជំហានចូល មក ។ រាសីស្លៀកខោអាវរបស់ឪពុកនាង រាងស៊ុលយុលបន្តិចតែក៏ អាចស្លៀកជិតខ្លួនសមសួន ព្រោះនាងអាល័យសន្សំលុយមើលជំងឺ ម្តាយនឹងប្អូន មិនបានទិញខោអាវស្លៀកអោយត្រឹមត្រូវពីរបីឆ្នាំ មកហើយ ហើយខោអាវរបស់នាងសោតក៏ចាស់ៗ ហើយចង្អៀត ពាក់មិនត្រូវផង ។ ចំណែកខោអាវម្តាយរបស់នាងវិញ បានត្រូវ រដ្ឋាប្អូនប្រុសរបស់នាងលួចយកទៅលក់អោយញាតិថោកៗ យក លុយទិញថ្នាំញៀនអស់ ។ ការពិតទ្រព្យធនរបស់គ្រួសារនាងបាន របេះរបោចគ្មានសល់អ្វីទេ ។ ទ្រព្យចុងក្រោយគឺកូនដីមួយជ្រុងនៅព្រៃកូនខ្លាដែលរាសីនិងរក្សាត្រូវបង្ខំចិត្តលក់ចោលដើម្បីសងបំណុល គេផង និងដើម្បីធ្វើទុនមករកការធ្វើនៅភ្នំពេញផង ។

លុះដើរមកដល់មុខរោងចក្រជិនហួ រាសីឃើញមនុស្សម្នាឈរចោមមើលការដាក់ផ្សាយរកកម្មករថ្មីបន្ថែមទៀត ហើយឃើញគេនាំគ្នាតម្រង់ជួរដាក់ពាក្យសុំចូលសម្ភាសន៍ធ្វើការ ។ នាងក៏ដើរត្រុយ ចូលទៅជិត ស្រាប់តែរារែកចង់ចូលបន្តិច មិនចង់បន្តិចទៅវិញ ត្បិតស្អប់មុខថៅកែចិនមហាគីរិះម៉ៅស៊ិតដែលនាងបានជួបកាលពី ម្សិលមិញនោះណាស់ ឃើញឫកហើយ មិនចង់បៀតឡើយ កុំថាឡើយចង់ទៅធ្វើការអោយ ។ តែលុះនឹកឃើញដល់រក្សា ដែលត្រូវ ការលុយបង់សាលាមាណវីក៏សំរេចចិត្តដើរចូលទៅតម្រង់ជួរនឹង គេដែរ ។ ទទួលពេលនោះ

CHANBOKEO.COM

ឆ្មាំទ្វារពីរនាក់ដែលនាងប្រទះកាលពី ម្សិល បានដាក់ភ្នែកឃើញនាងមកដល់ ក៏ញាក់មុខឡើងហៅគ្នីគ្នា បន្ថែមមកដល់ភ្លែត ចំពោះមុខនារី តម្កង់ពទ្ធ័ជុំវិញរូបនាង ។ រាសី ភ្ញាក់ព្រើត ស្រដីឡើងថា ៖

- នេះ ពូៗ បងៗទាំងអស់មកពទ្ធ័ខ្ញុំយ៉ាងនេះ មានការអ្វីហ្នឹង ?

ស្រាប់តែឆ្មាំម្នាក់សួរនាងវិញថា ៖

- តើនាងជានារី ដែលនាំលោកជិនហ្ស៊ូចេញពីកន្លែងគ្រោះថ្នាក់ឡាន កាលពីម្សិលមិញទៅគ្លីនិក មែនទេ ?

- មែនហើយ! ហើយពូសួរមានការអ្វីដែរ ?

- គឺលោកនាយជិនហ្ស៊ូ កំពុងរង់ចាំ ចង់អោយអ្នកនាងទៅជួបនៅ ការិយាល័យរបស់លោក ឯខាងក្នុងម៉ាភ្លែត ។

- យីអើ! លោកជិនហ្ស៊ូនោះមានភ្នែកស្រឡៅតាំងពីអង្កាល់បានជា មកសម្លឹងនារីអង្កាច់អង្កោចដូចខ្ញុំនេះផង ?

- នែ៎នាង! កុំទាន់អាលអួតខ្លួនអី! លោកជិនហ្ស៊ូមិនមានទម្លាក់ខ្លួន មកសម្លឹងនារីសាបៗ ស្រីមិនស្រី ប្រុសមិនប្រុស សក់ក្បាលកន្ទ្រីង កន្ទ្រើង មុខមើលមិនបានដូចនាងនោះទេ ។

- អូហ៍បើដូច្នេះមែន ម៉េចក៏លោកជិនហ្ស៊ូចាំបាច់អី បញ្ជូនពូៗបងៗ ទាំងហ្វូង មកហែហមទទួលរូបខ្ញុំបែបនេះធ្វើអី ? នេះមិនមែនជា ការសម្តែងចំណាប់អារម្មណ៍យ៉ាងពិសេសមកលើរូបខ្ញុំទេហ៍ ? ឬក៏ ចង់ប្រកែកថាមិនមែនទៀត ?

ឆ្មាំទាំងឡាយនោះ មើលមុខគ្នាព្រាតតែម្តង ។ មែនហើយ! តើ ហេតុអ្វីទៅដែលជិនហ្ស៊ូដាក់បញ្ជាតឹងរឹងអោយគេមកចោមពទ្ធ័ទទួល រាសីយ៉ាងច្រើនដូចស្រមោចយ៉ាងនេះ រហូតដល់មនុស្សម្នាដែល តម្រង់ជួរចុះឈ្មោះសុំចូលធ្វើការនៅទីនោះទាំងឡាយ ក៏នឹកឆ្ងល់ ដូចគ្នាដែរថាតើហេតុអ្វី នារីយើងបានទទួលការស្វាគមន៍ជាពិសេស ពីពពួកឆ្មាំយាមជាច្រើននាក់នោះ ?

- យើងមិនដឹងថាលោកជិនហ្ស៊ូមានការអ្វីទេ តែលោកសុំអោយ អញ្ជើញនាងចូលទៅជួបលោកឥឡូវនេះជាប្រញាប់ ។

- ពុទ្ធោ! ប្រហែលជាដេកគិតមួយយប់ ទើបតែនឹកឃើញថា ត្រូវ សងគុណរាសីបែបណាហើយ ទើបអោយកូនចៅមកតាមហៅអស់ ម៉ារោងចក្របែបនេះ! (រាសីលាន់មាត់)

- កុំនិយាយច្រើន! ប្រញាប់ឡើងទៅជួបលោកភ្លាមទៅ ។

CHANBOKEO .COM

នាយឆ្មាំម្នាក់លូកដៃបំរុងចាប់អូសដៃរាសីចូលទៅក្នុងរោងចក្រ ស្រាប់តែនារីរលាស់ខ្លួនភិលថយក្រោយបីជំហាន ហើយស្រដីថា ៖

- យី! ហេតុអ្វីចង់ប្រើកម្លាំងបាយ ចាប់នារីភេទជូនលោក ដល់ ការិយាល័យបែបនេះ ? ក្រែងនេះជារោងចក្រ មិនមែនទេ ? ហេតុអ្វីក៏មិនអោយខ្ញុំឈរតម្រង់ជួរចូលសម្ភាសន៍ដូចគេឯងតចឹង ?

- នែ៎ ស្រីល្អ! លោកគ្រាន់តែចង់មានប្រសាសន៍ពីរបីម៉ាត់សួរនាង ប៉ុនហ្នឹងឯង... កុំប្រញាប់វាយឫកធ្វើគ្រាន់បើអី!

- មកពីខ្ញុំខ្លាចធ្លាក់ក្នុងអន្ទាក់ល្បិចអ្នកមាន ទើបត្រូវប្រយ័ត្នខ្លួនខ្លះ ទើបបាន ។ បើលោកជិនហួពិតជាចង់ជួបខ្ញុំមែន អោយគេមកជួប ខ្ញុំទីនេះដោយខ្លួនឯងទៅ ។ ខ្ញុំមិនចូលចិត្តជួបលោកតែពីរនាក់ក្នុង បន្ទប់ផ្ទាល់ខ្លួនពិសេសទេ ។

មើលទៅរាសី មាត់បាន ប្រាជ្ញបានណាស់ ។ បុរសដែលជាឆ្មាំ មួយហ្វូងនោះនិយាយមិនឈ្នះ ក៏បង្គាប់អោយឆ្មាំមួយរូបទៅជំរាប លោកជិនហួ ហើយធ្វើសញ្ញាអោយប្អូនដប់នាក់ទៀត ចាប់ដៃចាប់ ជើងសែងរាសីចូលទៅក្នុងរបងរោងចក្រភ្លាម ធ្វើអោយមនុស្សទី នោះឆ្ងើលឆោឡោឡើងដោយសម្រែកនារីដែលស្រែកឡើងថា ៖

- ជួយផងៗ! គេចាប់ខ្ញុំយកទៅអោយថៅកែ! ជួយផងៗ...ទីនេះ មិនមែនជារោងចក្រទេ តែជាកន្លែងប្រើកម្លាំងបាយចាប់ស្រីជូន លោក...

មនុស្សម្នាក៏បែកហ្វូងអ៊ូអរភ្លាមមួយរំពេច ។ រាសីប្រឹងបម្រះ ផង ស្រែកផង តែក៏មិនឈ្នះកម្លាំងឆ្មាំប្អូនដប់នាក់នោះ ដែលសែង នាងឡើងរហូតដល់ជាន់ទីពីរនៃអាគារថ្មីធំមួយ ។ មកដល់បន្ទប់ ការិយាល័យមួយយ៉ាងធំស្រឡះ ហើយមានការរៀបចំយ៉ាងស្អាត ស៊ីវិល័យ មានតាំងពីម៉ាស៊ីនកុំព្យូទ័រ ឥន្ទ្រីធិត និងសេនាសនភណ្ឌ តម្លៃរាប់ពាន់រាប់ម៉ឺនដុល្លារ ពួកគេក៏ទម្លាក់នាងទៅក្នុងសាឡុងដ៏ ទំនើបមួយ រួចហើយក៏ទាញទ្វារបិទ ។ រាសីស្ទុះដើបទៅមួលគន្លឹះ ទ្វារ រករត់ត្រឡប់ក្រោយវិញ ស្រាប់តែ...

- នាងទៅណាមិនបានទេ! យើងមាននរឿងនិយាយគ្នាបន្តិច!

រាសីភ្ញាក់ព្រើតបែរក្រោយរឹង ឃើញលោកជិនហួឈរនៅក្បែរ ទ្វារមួយទៀត ទើបតែចូលមកដល់ ។ នៅលើមុខមាត់របស់គេ មានស្នាមដេរជាច្រើនកន្លែង ដោយសារគ្រោះថ្នាក់ចរាចរកាលពី ម្សិលមិញ ។

- តើយើងមានរឿងអ្វីទៅ ដែលត្រូវនិយាយគ្នានោះ ? (រាសីសួរ)

CHANBOKEO.COM

ជិនហួសម្លឹងមុខធិតា ដោយក្រសែភ្នែកយ៉ាងមុត ប៉ុន្តែរាសីមិន ព្រឺ មិនញោចទេ ។ នាងបែរជាញាក់មុខហើយសួរថែមថា ៖

- ក្រែងពេលវេលារបស់លោកមានតម្លៃណាស់មែនទេ ? ហេតុអ្វីក៏មកឈរស្ទៀមបង្ហើរពេលវេលាដោយអាសារបង់យ៉ាងនេះ ?

ជិនហួឮដូច្នោះ ក៏ស្រដីរឹងយ៉ាងប្រញាប់ថា ៖

- ខ្ញុំបាត់ក្រដាសសំណៅឯកសារពីកាតាបខ្មៅដែលនាងកាន់កាលពី ម្សិលនោះទៅចំនួន១០សន្លឹក តើនាងមានឃើញទេ ?

- អីយ៉ា! សំណៅឯកសារស្អីទៅ លោកជិនហួ ? អ្នកជនបទឡើកឺ មិនគ្រប់ដប់ដូចខ្ញុំនេះ ទៅចេះដឹងស្អី ពីឯកសារ១០សន្លឹករបស់ លោកនោះកើត លោកអើយ!...

- តែនោះជា brief case របស់ខ្ញុំប្រើផ្ទាល់តែម្នាក់ឯង គ្មាននរណា កាន់ទេ ក្រៅពីនាងម្នាក់កាលពីម្សិលមិញនេះ ។

- យើ! ជួយកាន់អោយម៉ាដើ អោយបីដុល្លាររួមទាំងថ្លៃម៉ូតូឌុបផង ថ្ងៃនេះ មករករឿងខ្ញុំ ចង់រកទារបីដុល្លារនោះវិញមែនទេ ? នេះ បានហៅថាថៅកែមហាគីរិះ មហាល្បិច មែនតែម្តង!

- នែ៎! យើងមិនបានគិតអាបីដុល្លារហ្នឹងទេ ព្រោះក្រដាសឯកសារ ១០សន្លឹកនោះមានតម្លៃធំធេងណាស់ សំរាប់រោងចក្ររបស់យើង ទាំងមូល ។

- បើដូច្នោះ ខ្ញុំជួយលោកមិនបានទេ ។ អ្នកក្រល្ងិតល្ងង់ដូចខ្ញុំនេះ ត្រូវការតែលុយប៉ុណ្ណោះ ។ អារឿងក្រដាសក្រដោញស្អីហ្នឹង ខ្ញុំមិន ដឹង មិនស្គាល់អ្វីឡើយ ។ អស់ការហើយមែនទេ នឹងអាលខ្ញុំត្រឡប់ ទៅវិញ ។ លោករំខានខ្ញុំយូរ ខ្ញុំច្បាស់ជាគ្មានពេលរកការធ្វើទេ ហើយពេលនោះ តើខ្ញុំបានអ្វីចិញ្ចឹមពោះទៅ ?

- នាងកំពុងរកការធ្វើមែនទេ ? បាន! ចាំខ្ញុំអោយកិច្ចការនាងធ្វើ ជាកម្មកររោងចក្រនេះ តែនាងត្រូវតែសងក្រដាស១០សន្លឹកនោះ មកវិញសិន ។

- យី! លោកនេះ ស្តាប់មិនខ្មែរមិនយល់ ឬក៏ធ្វើពើមិនយល់ ? ខ្ញុំ បានប្រាប់ហើយតើហ៎ថា ខ្ញុំគ្មានក្រដាសនោះទេ ។

ថាហើយ នាងស្ទុះបើកទ្វារចេញទៅ ដោយមិនចាំអោយជិនហួ អនុញ្ញាត្តិទេ ។ លុះទ្វាររបើកឡើង រាសីក៏ប្រទះបុរសមាឌធំៗបី នាក់នៅឈរខាំងមាត់ទ្វារខាងក្រៅស្រេច ។ រាសីភ្ញាក់ព្រើត នឹក ភ័យខ្លាក ប្រហោងពោះធ្លុងតែម្តង ។ នាងក៏បែរក្រោយហើយស្រដី ខឹងឯងឡើងថា ៖

CHANBOKEO.COM

- ពុទ្ធោ! ជាបុរសហើយជាថៅកែទៀត តែហេតុអ្វីបានជាខ្លាចអ្នក តូចតាចដូចខ្ញុំ
រហូតដល់បញ្ជាអោយឆ្មាំគ្រាក់ៗ ឲ្យជួយយាមលោក ដូច្នេះអញ្ចឹង ? ម៉េច ?
ខ្លាចខ្ញុំរំលោភលោករួចទាមទារជំងឺចិត្តរាប់ ពាន់រាប់ម៉ឺនដុល្លារហើយយ៉ាងម៉េច
បានជាប្រុងប្រយត្ន័ដល់ម្លឹង ?
- នែ៎! កុំនិយាយច្រើនពេក (ជិនហួគំហក) ក្រែងនាងនិយាយថា ចង់មានការធ្វើមែនទេ ?
ឥឡូវ ខ្ញុំអោយការនាងធ្វើចាប់ពីពេលនេះ តទៅ
តែនាងចាំបាច់ត្រូវតែរកក្រដាស១០សន្លឹកនោះមកសងយើង វិញអោយបាន ឮហើយនៅ ?
- ចុះបើខ្ញុំមិនដឹងថា ក្រដាសនោះនៅឯណាផង តើអោយខ្ញុំតាមរក វានៅឯណាទើបឃើញ ?
លោកកំពុងតែចាប់ច្របាច់កខ្ញុំឲ្យស្លាប់ ដោយមូលហេតុមិនជាប់ជំពាក់គ្នាសោះហើយនេះ !
- បើនាងពិតជាមិនបានដៃស្ទិត លួចយកឯកសារពីកាតាបធ្វើការ យើងមែន
នាងត្រូវតែបង្ហាញមក នូវភាពបរិសុទ្ធរបស់នាង ។
- ជិនហួ! លោកចង់ធ្វើយ៉ាងម៉េចហ្នឹង ?
- គឺជាកិច្ចការងាយមួយតើហ៍ ។

ជិនហួនិយាយហើយ ក៏បញ្ជាទៅអង្គរក្សម្នាក់ថា ៖

- នាយសៀក! ជូននាងទៅផ្ទះ ជួយរើតវាន់ផ្ទះនាងបន្តិចមើល៍
ថាតើនាងមានច្រឡំដៃយកសំណៅរបស់យើងនោះដែរឬក៏អត់!
- បាទទាន!
- អេហ៍! លោកធ្វើអញ្ចឹងមិនបានទេ លោកជិនហួ! នោះគឺជាការ
រំលោភសិទ្ធរបស់អ្នកស្រុកស្លូតត្រង់ហើយ (រាសីលាន់មាត់)
- យើងមិនខ្វល់ទេ ។ រញ៉ើរញ៉ៃច្រើន ប្រយត្ន័យើងឃុំអោយនាង
ដេកអត់បាយទីនេះពីរបីថ្ងៃខ្ញុំឥឡូវហ្នឹង! នាយសៀកចាត់ការ!

នាយសៀកនិងអង្គរក្ស័ពីររូបទៀត ក៏ក្រៀកនាំខ្លួនរាសីចេញពី
បន្ទប់ការិយាល័យរបស់ជិនហួ ។

- នែ៎! ពួកឯងចាស់ៗហើយ! កុំបន្លំធ្វើជាប៉ះខ្លួនស្រីក្មេងដូចជាខ្ញុំ នេះពេកមើល!
តិចលោពួកឯងព្រឺសម្បុរលួចស្រឡាញ់ខ្ញុំ ហើយរត់ ចោលប្រពន្ធកូនទៅ (រាសីចាក់ផ្លែផ្កា)

នាយសៀកអស់សំណើចខឹកៗតែម្តង កាលបើឮដូច្នោះ ៖

CHANBOKEO.COM

- នែ៎នាងច្រមក់! មុខមាត់ប្រុសមិនប្រុស ស្រីមិនស្រី ស្រមេក ស្រមកដូចនាងនេះ មិនបាននឹងអ្នកបំរើជូតផ្ទះអោយគេផង កុំមក ជោរនឹងខ្លួននាងពេកមើល៍.. ថ្លង់ណាស់!

- បើពូៗនឹងអញ្ជឹងដែរ សូមមេត្តា ដកឃ្លាដៃជើងនិងខ្លួនរបស់ពូ អោយវាឆ្ងាយពីខ្ញុំបន្តិចទៅអញ្ជឹង ក្រែងលោវាជាប់ក្លិនមនុស្ស ស្រមេកស្រមក នាំតែប្រពន្ធនៅផ្ទះប្រចណ្ឌខុសរឿង ។

ដោយនិយាយមិនឈ្នះក្មេងស្រី នាយសៀកស៊ីញ៉ូអោយឆ្នាំពីរ នាក់ទៀតនោះដកខ្លួនថយបន្តិច ដើម្បីឲ្យធិតាដើរតាមសម្រួល ។ លុះឆវីនាំបុរសទាំងនោះមកដល់បន្ទប់ជួល នរណាៗដែលរស់នៅម្តុំៗនោះ ក៏បែរសម្លឹងមើលមុខនាងធ្វើឡឹងឡង់ៗ ដែលសុខៗ ស្រាប់តែនាងមានអង្គរក្សដើរហែហមដល់ទៅបីនាក់យ៉ាងគ្រាក់ៗ ។ មិនតែប៉ុណ្ណោះ លោកជិនហ្វួ ថៅកែរោងចក្រដ៏សែនឆ្មើងឆ្មៃ មិន ដែលបន្ទាបខ្លួន ដើម្បីនរណាម្នាក់សោះ ថៃដន្យអីថ្ងៃនេះ គេបែរជា ដើរតាមពីក្រោយស្រីក្មេងមួយរូប ខោមិនខោ អាវមិនអាវ អោយ តត្រុក ដោយឥតស្រដីគំហក ឬវាយឬកន្តើមរអើមដូចទម្លាប់របស់ គេ ពីមុនៗមកនោះឡើយ ។

លុះមកដល់បន្ទប់ដ៏តូចចង្អៀត ដែលរាសីនិងរក្សាទើបជួលនៅ កាលពីម្សិលនោះ ជិនហ្វួហក់រឹងចូលទៅក្នុង បែរមើលជុំវិញក្នុង បន្ទប់ មិនឃើញមានអ្វីទេ ក្រៅពីកូនសាក់កាដូដាក់ខោអាវពីរ កន្ទេលចាស់មួយ ខ្នើយពីរមុងមួយ និងចានក្បានពីរបីប៉ុណ្ណោះ ។ ក្រៅពីនោះគឺស្រឡះឆេងតែម្តង ។ នៅលើជញ្ជាំង មានរូបថតអ្នកចំរៀងព្រាបសុវត្ថិ តារាភាពយន្ត កែវពេជ្រពិសី វេតរតនា ដាញ់ម៉ូនិកា អេងឬទ្ធី ទេពរិនដារ៉ូ និង អ្នកចំរៀងដូចជា ឈឿន ឧត្តម អឿនស្រីមុំ យន់សុភាពជាដើម ជាក្រដាសហែកពីទស្សនាវដ្តីចាស់ៗ យកមកបិទពាសពេញជញ្ជាំង មើលទៅ ហាក់ ដូចជាចង់យករូបតួតារាស្អាតៗ មកបិទស្មាមជញ្ជាំងកំពុកនោះ ហើយ ។ ជិនហ្វួញាក់ភ្នែកស៊ីញ៉ូអោយនាយសៀកឆែកសាក់កាដូ ។ ស្រាប់តែរាសីស្ទុះទៅខ្ទប់ជាប់ ៖

- នែ៎ នេះជាសំពៀតដាក់តវ៉ាន់ផ្ទាល់ខ្លួនស្រីៗ ។ លោកមិនគួរនឹង ឆែកឆេរសោះ...!

តែនាយសៀកមិនស្តាប់ឡើយ ។ គេឆក់សំពៀតពីដៃនាង រួច ច្រាននាងផ្ងាកក្រោយផ្ទប់និងជញ្ជាំង បន្ទាប់មកក៏រលាក់តវ៉ាន់ចេញ ពីសំពៀត ។ ថៃដន្យ គេមិនបានឃើញអ្វីទេ ក្រៅពីខោអាវចាស់ៗ ប៉ុណ្ណោះ ។ គេក៏រលាក់ខោអាវរក្សាចេញពីសំពៀតទីពីរ តែក៏មិន ឃើញអ្វីដូចគ្នា ។

CHANBOKEO.COM

ចំណែករាសីដែលកំពុងតែទល់ផ្អកបន្ទាប់ពីត្រូវ នាយឆ្មាំច្រាននាងផ្ទប់ជញ្ជាំងនោះ ផិតាក៏នៅអង្គុយស្ងៀមលែង និយាយអ្វីរួចតទៅទៀត ព្រោះឈឺផ្អិតក្នុងខ្លួនខ្លាំងពេក ។

បន្តិចមក នាយឆ្មាំនោះក៏ចាប់រលាក់ខ្មើយច្របាច់មើលទៀត ប៉ុន្តែ ក៏នៅអាសារឥតការដដែល ។ នាយសៀកបែរមើលជិនហួ ហើយគ្រវីក្បាល ៖

- មិនឃើញមានស្អីទេ ទាន!

ជិនហួនៅទីនោះ ឃើញសកម្មភាពឆែកឆេរទាំងអស់ហើយ ក៏នៅស្ងៀម ។ រាសីឃើញដូច្នោះ ក៏គំហកចំអកអោយថា ៖

- ការដែលលោករំលោភចូលផ្ទះនារីម្នាក់ ដល់បន្ទប់របស់នាង តើ លោកគិតថា ខ្ញុំគួរចុះកាសែតផ្សាយទំព័រទីមួយ ថាម៉េចដែរ ?

ជិនហួនៅស្ងៀម ។ នេះជាលើកទីមួយដែលគេធ្វើការបរាជ័យ តាំងពីគេមកដល់ស្រុកខ្មែរនេះ ។ រាសីសម្លឹងមុខនរៈដោយក្រសែ ភ្នែកយ៉ាងមុត រហូតដល់បុរសនោះមានអារម្មណ៍ ថា នាងកំពុងរក វិធីបំបាក់មុខរបស់នាយវិញហើយ ។ គេក៏បន្ធូរបរិយាកាសវិញ ដោយលួងលោមមាណវីថា ៖

- ណ្ហើយចុះ! ថ្ងៃនេះ ចាត់ទុកថា ខ្ញុំចោទនាងខុសចុះទៅចុះ! ប៉ុន្តែកុំទាន់អាលអន់ចិត្តអី ។ ចាំខ្ញុំប្រាប់រោងចក្រអោយទទួលនាង ធ្វើការនៅទីនោះ ដូច្នេះនាងមិនបាច់ដើររកការធ្វើឯណាទៀតទេ ។

ថាហើយ ជិនហួក៏ប្រាប់ទៅនាយសៀកអោយជួយសំរួលកិច្ចការ ដល់នាង ហើយគេក៏ដើរចេញទៅទាំងទឹកមុខសោះកក្រោះ ។ រាសី ក៏រអ៊ូឡើងតែម្នាក់ឯង ក្រោយពីពួកគេចេញទៅអស់ ថា ៖

- ពួកអ្នកមានតែប៉ុណ្ណឹងឯង! រំលោភសិទ្ធិគេដោយមិនដឹងរឿង ក៏នៅតែប្រឹងខំរំលោភទាំងមុខខ្លាញ់... គួរឲ្យខ្ពើមមារយាទណាស់! ធ្វើបែបនេះ ស្មានថាឈ្នះអ្នកក្រគ្រប់ពេលហើយឬ ? នរណាមិន ដឹង រាសីស្មោះ! គឺមិនងាយចុះចាញ់អ្នកងាយៗទេ លោកជិនហួ! កុំថាឡើយអ្នកជាជាតិបរទេសរៀនខ្ពស់ត្រឹមណា មានលុយ មាន អំណាចត្រឹមណា... ពេលនេះ រាសីក៏ចង់ដឹងដែរថា ប្រាជ្ញក្មេងខ្មែរ ជនបទដូចជាយើង តើអាចប្រដេញប្រាជ្ញាមនុស្សដូចអ្នកបានដែរ ឬទេ ? នៅវេលាយើងរាប់លទ្ធផលចុងក្រោយ តើនរណានឹងគ្រាន់ បើជាងនរណា ?

ព្រលប់ថ្ងៃដដែល...

CHANBOKEO.COM

រក្សាមកដល់ផ្ទះវិញដោយទិញបាយពីរកញ្ចប់មកផង ។

- បងរាសី! ខ្ញុំបានចូលរៀនហើយបង!

រក្សានិយាយប្រាប់បងដោយត្រេកអរ ។

- បងក៏បានការធ្វើដែរនៅរោងចក្រជិនហ្វូអិលធីឌី ជិតផ្ទះយើង នេះតែម្តង ដូច្នេះបងមិនបាច់ដើរឆ្ងាយទេ ។

- មែនឬបងរាសី ? ហេងអស្ចារ្យណាស់ ។

ថាហើយ គេក៏លាតបាយកញ្ចប់ចែកគ្នាបរិភោគ ស្រាប់តែ...

- មានចំណែករបស់បងដែរឬទេ រក្សា ?

អ្នកទាំងពីរក៏ងាកមើល ឃើញបុរសម្នាក់កាន់អាហារមួយកញ្ចប់ មកដល់ដែរ ។

- បងសយនា! (រក្សាលាន់មាត់) មកទាន់ពេលបាយល្មមតែម្តង!

រាសីលួចមើលសយនា នឹកចម្លែកចិត្តដែលបុរសម្នាក់នោះមក ផ្ទះនាងរាល់ល្ងាចដូច្នោះ ។ ការពិត នាងមិនទុកចិត្តបុរសនេះទេ ។ នៅទីក្រុង មនុស្សល្អនិងមិនល្អលាយគ្នាច្របូកច្របល់ តើទុកចិត្ត ម្តេចបាន ជាពិសេស គឺមនុស្សដែលនាងមិនស្គាល់ប្រវត្តិពីមុនមក សោះ... មិនដឹងថាគេមកស្និទ្ធស្នាលជាមួយនាងនិងប្អូនដើម្បីអ្វី ?

ឃើញរាសីបរិភោគស្ងៀមស្ងាត់ មិននិយាយស្តីជាមួយខ្លួន នរៈ ក៏ស្រដីឡើងថា ៖

- មិនពេញចិត្តនឹងវត្តមានរបស់បងមែនទេ រាសី ? បើប្អូនទើស ទាល់ ប្រាប់បងណា៎! កុំធ្វើមុខក្រញូវអញ្ចឹង បាត់សោភ័ណនារីអស់ ហើយ ។ បើសិនបងមានអ្វីធ្វើអោយប្អូនទើសទាល់មែន បងក៏មិន ហ៊ាននៅរំខានប្អូនទៀតដែរ... បងទៅផ្ទះវិញហើយណា៎!

សយនាក៏យកចានបាយទៅលាង ហើយក៏លើកដៃបក់បោយ លាអ្នកទាំងពីរចេញទៅ ។

- បងរាសី! ម៉េចបងមិននិយាយរកបងសយនាអញ្ចឹង ? ក្រែង បងទាំងពីរទើបតែចាប់ដៃធ្វើមិត្តនឹងគ្នាហ្អែស ?

- នរណាថា ? បងមិនស្គាល់គេផង ទើបតែជួបម្សិលមិញនេះតើហ៍ ម្ល៉ោះហើយទើបបងមិនមានអារម្មណ៍ថាទុកចិត្តគាត់អ្វីបន្តិចទេ ។

- តែអាកប្បកិរិយាតោះតើយរបស់បង ហាក់ដូចជាបណ្តេញគាត់ឲ្យ ចេញទៅអញ្ចឹង ។ តិចលោគាត់ជាមនុស្សល្អវិញទៅ បងមិនបាត់ បង់មិត្តម្នាក់ដ៏ល្អទៅហើយទេហ្អែស ?

CHANBOKEO.COM

- ប្រយត្ន័ ក៏គង់គ្រាន់ជាងអោយគេមកលូកថ្លើមថ្ងៃក្រោយដែរណា៎ រក្សា ។
កុំអាលទុកចិត្តបុរសចម្លែកអី មិនដឹងថាគេជាមេធ្លាក់ទាក់ ស្រីៗយកទៅលក់
ជាបុរសដើរពង្រាយស្នេហ៍ ឬក៏គេជាមនុស្សល្អ ក៏មិនដឹង...យើងកុំស្និទ្ធស្នាលនឹងគេពេកអី ។

- តែបើបងមិនរាក់ទាក់ស្និទ្ធស្នាលនឹងគាត់ ធ្វើម៉េចនឹងអាចឲ្យបង បានដឹងកើតថា
គាត់ជាមនុស្សយ៉ាងណា ?

ការពិត ថ្ងៃនេះ រាសីមិនសូវស្រួលខ្លួនសោះ ត្បិតពីព្រឹកមិញ
នាងត្រូវនាយសៀកប្រេចានដួលអុកខ្លួននឹងជញ្ជាំង ។ ពេលនេះ នាងហាក់ដូចជាឈឺសព្វរាងកាយ
ហាក់ដូចជាចង់គ្រុន ទើបគ្មាន អារម្មណ៍ថាចង់គួរសមនឹងនរណា សូម្បីតែជាមួយសយនាដែលជា
មិត្តដំបូងរបស់នាង ក៏គ្មានចេតនានឹងរាក់ទាក់ដែរ ។

- រក្សា! ទៅមាត់ផ្លូវ ទិញថ្នាំអោយបងបន្តិចបានទេ ?

ឃើញបងស្រីមិនស្រួល រក្សាក៏ហក់ប្រុយទៅរកទិញថ្នាំឲ្យនាង ភ្លាម ។
រាសីក៏ទំរេតខ្លួនឆ្មេចសំងំយកកម្លាំង ស្រាប់តែមានដៃមួយ ហុចកែវទឹក ហុចថ្នាំមកអោយនាង
ហើយស្រដីថា ៖

- លេបពីរគ្រាប់នេះសិនទៅ ក្រែងលោបានស្រួលខ្លួនជាងមុន ។

រាសីបើកភ្នែកឡើង ឃើញសយនាដាក់ខ្លួនអង្គុយចុះជិតនាង
ក្នុងបន្ទប់តូចរបស់នាងនឹងរក្សា ។ នាងស្ទុះងើបឡើង ៖

- ល្បងសយនា ?
- គឺ... បងសយនា! មិនមែនល្បងសយនាទេ ។
- កុំចេះ! គេហៅយ៉ាងម៉េចស្រេចតែគេ ។
- អូហ៍ អ្នកឈឺអី មាត់រឹងម្លេះ ? ស្អែកទៅធ្វើការកើតទេ ?
- យី! ម៉េចបានដឹងថា ខ្ញុំបានការធ្វើ ?
- គឺរក្សាគេប្រាប់បងអំបាញមិញនោះអី ។ អញ្ចឹងតើហ៍ បានថ្ងៃនេះ
រាសីវាយឫកលែងស្គាល់បងអស់រលីង!
- និយាយតែផ្តាស! គឺមកពីខ្ញុំត្រូវពួកអាមាឌធំៗនោះវាច្រានខ្ញុំផ្ទប់ ជញ្ជាំងតើហ៍...
- អូហ៍ មានរឿងអីហ្នែស ?
- គឺ... ទោះខ្ញុំប្រាប់ល្បងក៏ល្បងមិនយល់ដែរ ។ ថ្ងៃនេះ រាសីមិន ស្រួលខ្លួន ។
ស្អែកចាំនិយាយគ្នាទៀតណា៎!

CHANBOKEO.COM

- មានន័យថា នៅថ្ងៃស្អែក បងអាចមកទីនេះបាន មែនទេ ?

រាសីងាកសម្លក់សយនាភ្លាម ។

- ស្រេចតែគិតទេ! (រាសីឆ្លើយអត់ឈ្មោះ)

មាណពញញឹមដាក់នាង ហើយក៏ដើរចេញពីបន្ទប់ទៅទុកអោយ រក្សាជាអ្នកបិទទ្វារ ។ រក្សាវិញក៏លួចញញឹមដាក់បងស្រីដែលស្រដី ង៉ោកង៉ាក លាក់បាំងចិត្តទន់ខ្សោយរបស់នាងចំពោះបុរសមួយរូប នោះ ។ នាយហាក់ដូចជាយល់បន្តិចៗហើយ ថាហេតុអ្វីសយនា មកអើតរាសី បងស្រីរបស់គេញឹកញាប់យ៉ាងនេះ ។

ស្អែកឡើង...

រក្សាចេញទៅរកការធ្វើ ។ ចំណែករាសីវិញ បានមកបង្ហាញ ខ្លួននៅការិយាល័យរោងចក្រ ដើម្បីបំពេញលក្ខណ្ឌការងារ មុននឹង អាចចូលធ្វើការបាន ។ នាងត្រូវបានទទួលប្រាក់ខែ៨៥ដុល្លារ ធ្វើ ការ៨ម៉ោងក្នុងមួយថ្ងៃ សំរាកតែថ្ងៃអាទិត្យមួយថ្ងៃ រួចហើយគេនឹង គិតថ្លៃម៉ោងបន្ថែម បើសិនជានាងត្រូវធ្វើការលើសម៉ោង ។ ចៃដន្យ ធិតាមិនទាន់បានចូលធ្វើការផង នាងបានជំពាក់គេអស់ប្រាក់ខែពាក់ កណ្ដាលខែបាត់ទៅហើយព្រោះគេកាត់ថ្លៃសម្លៀកឯកសណ្ឋានកម្មករ របស់រោងចក្រ ។ នេះជាការតម្រូវពីរោងចក្រ ដោយមិនអាចតវ៉ា ប្រកែកបាន ។ ដោយទើសទាល់ រាសីត្រូវស៊ីញ៉េជំពាក់គេ២០ដុល្លារ ដើម្បីសងថ្លៃឯកសណ្ឋានពីរសម្រាប់នោះ ។ នាងក៏ត្រូវបានគេចាត់ តាំងអោយធ្វើការកន្លែងដំឡេវលើខោអាវដែលដេររួចហើយ ។

បួនម៉ោងពេញកន្លងទៅ ធិតាធ្វើការបែកញើសសស្រាក់ដោយ មិនបានសំរាកសោះ ។ ថ្ងៃត្រង់ នាឡិកាពោទិ៍ឡើង... កម្មករសំរាក បរិភោគបាយ ។ រាសីសង្កេតឃើញថា កម្មករប្រុសស្រីទាំងនោះ ម្នាក់ៗ ហាក់ដូចជាគ្មានឱកាសនិយាយគ្នាអ្វីទេ ព្រោះពេលសំរាក បរិភោគបាយខ្លីពេក ។ ខ្លះខ្ចប់បាយយកមកពីផ្ទះ ។ ខ្លះដើរចេញ ទៅច្រកមាត់ផ្លូវទិញបាយសម្រួបឆី ។ ប៉ុន្តែមិនទាន់បរិភោគអស់ពី ចានផង ស្នូរនាឡិការពោទិ៍ឡើងដាស់ហៅពួកគេ អោយចូលជួរវិញ ទៀតហើយ ។ ឯរាសីវិញក៏មិនខុសពីពួកគេប៉ុន្មានដែរ ។ ចៃដន្យ ជីវភាពក្រខ្សត់របស់នាងនៅឯស្រុកបានលត់ដំជីវិតរបស់នាងរួចខ្លះ មកហើយ ម្ល៉ោះហើយ នាងមិនសូវជាពិបាកបត់បែនខ្លួនប៉ុន្មានទេ ចំពោះការនឿយហត់ទាំងឡាយនោះ ។

CHANBOKEO.COM

នៅក្នុងផ្ទៃដីរោងចក្រដ៏សែនធំទូលាយ មានកម្មកររាប់រយរាប់ ពាន់នាក់ ធ្វើការតាមផ្នែកៗ ក្នុងរោងផ្សេងៗគ្នា ។ រាសីធ្វើការ បណ្តើរ លួចសង្កេតមើលបរិយាកាសជុំវិញខ្លួនបណ្តើរ ។ ក្នុងរោង ចក្រនោះ អាកាសអួរអាប់ណាស់ គ្មានខ្យល់ផ្លាស់ប្តូរគ្រប់គ្រាន់ទេ ។ រំពេចនោះ ស្រាប់តែ...

- ជួយផង! មានកម្មការិនីម្នាក់ខ្យល់គ!

រាសីលួចចោលកន្ទុយភ្នែកមើលទៅឃើញ អ្នកធ្វើការជិតគ្នា នោះស្រែកឡើង ប៉ុន្តែគ្មាននរណាហើបគូចទៅជួយអ្នករងគ្រោះ ម្នាក់នោះសោះ បែរជាគិតតែពីប្រឹងធ្វើមុខការរបស់ខ្លួនញាប់ដៃបន្ត ទៅទៀត ។ ស្រាប់តែ..

- ជួយផង! មានមនុស្សដួលម្នាក់ទៀតហើយ!

មែន! មនុស្សស្រែកហៅជំនួយបន្តៗ ដោយឃើញកម្មការិនី បីបួននាក់ដួលគ្រេងៗ បន្តកន្ទុយគ្នាដោយមិនដឹងរឿង ។ ចម្លែក ណាស់ ពេលកម្មករស្រីប្រុសខ្លះមានចិត្តដើបទៅជួយយកអាសារគ្នា ពពួកឆ្មាំតម្រួតដែលទើបចូលមកដល់ បែរជាសម្លុតថា ៖

- នែ៎ ! ធ្វើតែកិច្ចការរបស់ខ្លួនអោយតែហើយៗទៅ ប្រយត្ន័អត់ ការធ្វើ ពេលអ្នកធ្វើមិនបានទៀងទាត់តាមដែលរោងចក្រកំណត់ ។ ចំណែកពួកស្រីដេកដួលឈឺទាំងនេះ ទុកអោយពួកយើងចាត់ការ ។

ពួកគេក៏អូសស្រីៗទាំងនោះចេញទៅ មិនដឹងថាគេនឹងជួយ សង្គ្រោះនាងៗដោយវិធីបែបណាទេ ព្រោះគេមិនបណ្តោយអោយ កម្មករគ្នាឯងជួយលូកដៃយកអាសារសោះឡើយ ។ រាសីឃើញភ្លាម ក៏លួចសួរនារីមួយរូបឈ្មោះសុផាដែលធ្វើការជិតនាង ៖

- បងសុផា! នៅក្នុងរោងចក្រនេះ មានពេទ្យប្រចាំការដែរ ?

- នរណាថាមាន ? (សុផាឆ្លើយ) ការពិត គេយកពួកនៅទៅដាក់ អោយដេកមួយកន្លែងតែប៉ុនហ្នឹង ។ ពេលដឹងខ្លួនហើយ ពួកគេត្រូវ ត្រឡប់មកធ្វើការវិញ ហើយបើធ្វើមិនបានគ្រប់ចំនួនដែលយើង បានស៊ីញ៉េកុងត្រាឲ្យគេនោះទេ គេនឹងកាត់ប្រាក់ខែហើយ ។ ជួន កាល គេបញ្ឈប់យើងអោយឈប់ធ្វើការក៏មានដែរ ។

- ពុទ្ធោ! ហេតុអ្វីក៏តឹងតែង គ្មានមនុស្សធម៌អីសោះអញ្ចឹង ?

CHANBOKEO.COM

- ហ៊ឺ!.. ចេះតែទ្រាំៗទៅ ប្អូនស្រីអើយ! ធ្វើម៉េចយើងក្រខ្វះខាត
ត្រូវតែបង្ខំចិត្តលេបគ្រួសលេបថ្មបន្តិចហើយ ។

រោងធ្វើការនិមួយៗ ហប់ណាស់ គ្មានខ្យល់អាកាសផ្លាស់ប្តូរ ឋរិបូណ៌
អោយសមនឹងចំនួនមនុស្សធ្វើការទេ ។ នៅរសៀលថ្ងៃ ដដែលនោះ
ស្រាប់តែនាងឃើញកម្មករស្រីម្នាក់ដើរយំចេញពីបន្ទប់ ការិយាល័យរបស់មេចំណាត់ការ
រួចដើរកាត់កន្លែងនាងកំពុងឈរ បញ្ជាម៉ាស៊ីនដាំឡេវ ។ រាសីឃើញហើយ ក៏ឃាត់សួរថា ៖

- មានរឿងអ្វីហ្នឹងបងស្រី ? អាពួកក្នុងការិយាល័យវាប្រមាថអ្វី ដល់បងហ្នែស ?

នារីនោះងើបមុខឡើងហើយស្រដីទាំងទឹកភ្នែកថា ៖

- ម្តាយបងស្លាប់នៅឯស្រុក គ្រាន់តែសុំច្បាប់បីថ្ងៃ ទៅធ្វើបុណ្យ ក៏គេមិនអោយឈប់
ថែមទាំងជេរប្រមាថខ្ញុំថា ទោះបីជាខ្ញុំឈប់ទៅ
ធ្វើបុណ្យ ក៏ម៉ែខ្ញុំមិនអាចរស់មកវិញបានដែរ ដូច្នេះត្រូវធ្វើការ ទៀត ។ បើមិនធ្វើទេ
គេរើសមនុស្សថ្មីចូលជំនួស នោះពេលបង មកវិញ បងអត់ការធ្វើទៀតហើយ ។ ប្អូនស្រីអើយ!
បងឈឺចិត្ត
ណាស់ ដែលបងមិនអាចទៅបូជាសពម្តាយរបស់បងបាន!

ថាហើយ នារីនោះដើរយំសស្រាក់សំដៅទីធ្វើការរបស់នាងវិញ បាត់ទៅ ។ រាសីជ្រួញចិញ្ចើម
គិតក្នុងចិត្តថា ៖

- យើងទើបចូលធ្វើការមួយថ្ងៃ ប្រទះឃើញហេតុការណ៍ប៉ុនហ្នឹង ទៅហើយ ។
ចុះបើធ្វើរាប់ខែរាប់ឆ្នាំទៅ តើយើងឃើញអ្វីខ្លះទៀត ទៅហ្ន៎ ?

រាសីលួចនឹកអាណិតកម្មករទាំងនោះណាស់ មើលទៅគេម្នាក់ៗ ខំប្រឹងធ្វើការមិនហ៊ានអែអង់
ឬសូម្បីយកពេលប្រាំនាទីញញឹមដាក់ មិត្តធ្វើការជិតខ្លួននោះក៏គ្មានដែរ ។ មើលចុះ
ទឹកមុខរបស់គេបាន បង្ហាញនូវការប្រឹងព្យាយាមដោយញើសជិតដាម ប៉ុន្តែគេបែរជាមិន
បានទទួលក្តីស្រណោះអាណិតពីថៅកែរបស់គេឡើយ ព្រោះថៅកែ
គិតតែពីរឿងលុយចំណេញតែម្យ៉ាងប៉ុណ្ណោះ ។ ឯរឿងមនុស្សធម៌ ទុកកៀនជញ្ជាំង
គ្មាននរណាយកមកវិភាគវែកញែកប្រើការទេ ។

ព្រលប់នោះ រាសីធ្វើការលើសដល់ទៅជាងបីម៉ោងត្រូវដើរមក ផ្ទះវិញទាំងយប់ម្នាក់ឯង ។
កំពុងតែដើរឈ្ងោកៗ ស្រាប់តែនាង ចាប់ភ្លឹកថា
ហាក់ដូចជាមានស្រមោលមនុស្សដើរតាមនាងពីក្រោយ ភ្លិបភ្លែតៗ ។ ធិតាបែរក្រោយរកមើល

CHANBOKEO.COM

ស្រមោលនោះក៏បាត់ទៅ វិញ ។ ដោយនឹកទៅដល់សុវត្ថិភាពរបស់ខ្លួន នាងក៏ដើរគេចយ៉ាង លឿនតាមផ្លូវផ្សេង ក្រវិកក្រវក់ទំរាំដល់ផ្ទះ ស្រាប់តែឃើញរក្សា និងសយនាកំពុងអង្គុយតម្កង់រៀបអាហារចាំនាង ៖

- ស្លាប់ហើយ! អ្នកទាំងពីរមិនទាន់បរិភោគអាហារទេ?
- នៅទេបង! ខ្ញុំខំទៅចាំផ្លូវបងជាងពីរម៉ោងមិនឃើញ ក៏ដើរត្រឡប់មកវិញជួបនឹងបងសយនាទើបនឹងជិះម៉ូតូមកដល់ដែរ ។ ខ្ញុំក៏នាំគាត់មកផ្ទះយើងតែម្តងទៅ ។

រាសីក៏រៀបរបចាប់អាហារបរិភោគ បន្តិចមកនាងក៏លួចចោលកន្ទុយភ្នែកមើលសយនាភ្លៀកៗ ។

- រាសីមានការអ្វី បានជាលួចមើលមុខបងមិនឈប់?

សយនាសួរ ។ រាសីក៏ឆ្លើយវិញថា ៖

- អំបាញមិញនេះ ល្បងមានលួចដើរតាមរាសីទេ?
- បងហ្នឹងហ្ន៎ស ដើរតាមរាសី? មិនមែនទេ! បងមកដល់ទីនេះនិយាយលេងជាមួយរក្សាជាងមួយម៉ោងហើយ!
- តែ... ខ្ញុំបានឃើញមានស្រមោលមនុស្សដើរតាមក្រោយ ពេលខ្ញុំ ចេញពីរោងចក្រមកមែនណា៎!
- ពុទ្ធោ! បើស្រមោលនោះជាបងវិញ ចាំបាច់ដើរតាមធ្វើលិបលធ្វើអីកាលបើយើងស្គាល់គ្នាស្រាប់ទៅហើយ ។ ផ្ទុយទៅវិញ បងច្បាស់ជាសប្បាយចិត្ត ស្លាប់ហើយបើសិនបានដើរជាមួយរាសី ព្រោះប្អូនមានសំដីប្លែកៗមានរសជាតិ គួរអោយចង់ស្តាប់ណាស់ ។
- ចេះតែថាហើយ...ល្បងឯងនេះ ។
- បងសយនា មិនមែនល្បងសយនាទេ ។ រាសីស្តីហៅបងអោយ ដឹងប្រុស ដឹងស្រី ផងមើល៍!
- យី! រករឿងច្រើន តិចគេឈប់និយាយរកឥឡូវហ្នឹង!

សយនាទុចដឹក់ លួចញញឹម កាលបើឃើញរាសីឆ្លើយវិញទាំង ក្រហមថ្ពាល់ គួរអោយថ្នាក់ថ្នមអង្អែល ។ មែនហើយ! ថ្វីបើនាង ស្លៀកពាក់សាមញ្ញ និយាយស្តីឬកពាសាមញ្ញ ប៉ុន្តែគេហាក់ដូចជា ចាប់អារម្មណ៍ពីរូបនាងអ្វីម្ល៉េះទេ ជាពិសេសទៅទៀតនោះពេល នាងខឹងមុខក្រហមម្តងៗ ថ្ពាល់នាងឡើងពណ៌ក្រហមទុំ គួរអោយចង់បបោសថ្ងៃថើបអង្អែលក្រៃលែង ។

CHANBOKEO.COM

យប់បន្តិច សយនាក៏ត្រឡប់ទៅវិញ ។

- ល្បងចតម៉ូតូនៅឯណា ? (រាសីសួរ)
- គឺធ្វើគេងមាត់ច្រកចូល អស់នល់ទៅប្រាំរយឯណោះ ។
- ស្លាប់ហើយ អស់ថ្លៃបាយមួយពេលស្រេច ។
- អោយតែបងបានមកបាយជាមួយរាសីនិងរក្សា អស់ប៉ុនហ្នឹង បងរត់ម៉ូតូបានសងគ្រប់មិនជំពាក់គេទេណា៎ ។

សយនាញញឹមដាក់រាសី ហើយក៏ធ្វើដំណើរចេញទៅ ។

រាត្រីនោះ រាសីគេងគិតម្នាក់ឯង...

- តើគេជានរណា ? ហេតុអ្វីគេមកទីនេះញឹកញាប់ម្ល៉េះ ? គេពេញ ចិត្តរូបយើងហ្ន៎ស ? មិនសមទេ ព្រោះយើងមិនមានលក្ខណៈទន់ ភ្លន់ គួរឲ្យបុរសចាប់ភ្លឹកសោះណាជីវភាពក៏យ៉ាប់យ៉ឺនផង ។ ចុះ ស្រមោលមនុស្សលួចដើរតាមយើងនោះជានរណាដែរ ? រីឯកសារ ១០សន្លឹកនោះជាអ្វី ?ឬក៏ជិនហ្វូកំពុងឲ្យគេតាមដានយើង ?

រំពេចនោះ នាងក៏នឹកដល់ប្អូនៗ ៖

- រស្មី! រដ្ឋា! ពេលនេះ ប្អូនសុខទុក្ខយ៉ាងណាហើយ ? បងសូមបន់ស្រន់អោយប្អូនបានចាកផុតនៅគ្រោះអាក្រក់ក្នុងជីវិតទាំងឡាយ ផង ! សូមអោយយើងបានជួបគ្នាឆាប់ៗវិញ កុំខាន ។

oooooooooooooooo

ooooo

o

CHANBOKEO . COM

# វគ្គទី៨
# ឆ្កែទាល់ច្រក

រាសីបានចូលធ្វើការពីរថ្ងៃហើយ ។ ថ្វីបើនឿយហត់បន្តិច តែ នាងមិនដែលរអ៊ូមួយម៉ាត់ចេញពីមាត់ទេ ត្បិតនឹកថា ចង់សន្សំប្រាក់ អោយប្អូនប្រុសទៅរៀន សង្ឃឹមថ្ងៃមួយផុតជីវិតក្រីក្របែបនេះ ទៀត ។ ថ្ងៃនេះ នាងបានផ្ដាំអោយរក្សាឲ្យមកអង្គុយចាំនាងនៅមុខ រោងចក្រពេលនាងចេញធ្វើការ ព្រោះមិនចង់ដើរទៅផ្ទះតែម្នាក់ឯង ខ្លាចមានគេលបដើរតាមពីក្រោយដូចថ្ងៃមុនទៀត ។

ថ្ងៃនេះ អាកាសក្ដៅហប់ខុសធម្មតា សមនឹងលាមកធូលីហុយពី សំពត់ក្រណាត់កាត់ដេរ ថែមចំហាយមនុស្សធ្វើការច្រើនរយនាក់ ក្នុងរោងតែមួយទៀត កម្មការិនីបីបួននាក់ត្រូវដួលដោយខ្យល់គអស់ ជាច្រើននាក់ ។ នៅព្រលប់មុននឹងចេញមកផ្ទះ ស្រាប់តែគេមាន ចាប់កម្មការិនីអោយតម្រង់ជួរឆែកឆេរខ្លួនខុសធម្មតា ។

- មានរឿងអ្វីហ្នឹង បងសុផា ? (រាសីសួរ)
- គឺពួកការិយាល័យសង្ស័យថា មានកម្មករលួចឥវ៉ាន់ក្នុងរោងចក្រ ហើយ បានជាគេចាប់ឆែកខ្លួនយ៉ាងនេះ ។
- ហើយចុះ ហេតុអ្វីគេឆែកតែស្រីៗអញ្ចឹងបង ?
- បងមិនដឹងដូចតែគ្នាហ្នឹង ប្អូនស្រីអើយ !
- តើគេធ្វើបែបនេះ ញឹកញាប់ទេ ?
- គឺ តាមតែគេនឹកឃើញទេ ជាពិសេសបំផុត ពេលនាយចំណាត់ ការខ្មែរឈ្មោះសារៈ នោះចុះមកពិនិត្យការងារម្ដងណា គឺគេចូលចិត្ត ចាប់ស្រីៗឆែកខ្លួនណាស់ ។
- តើមួយណាទៅឈ្មោះសារៈនោះ ?

CHANBOKEO.COM

- គឺនរណាដែលមានមាឌសាច់ដុំធំៗ ហើយមានពុកមាត់ថ្លាមខ្លា សងខាង ភ្នែកធំៗមុខកាចៗ...
រាសីប៉ុកពោះភិបៗ កាលបើដល់វេននាងត្រូវដើរចូលទៅក្នុង
បន្ទប់តាមក្រោយកម្មករនារីបន្តកន្ទុយគ្នា ។ នៅក្នុងបន្ទប់មួយដែល
មានបុរសមាឌធំសង្ហាម្នាក់វ័យប្រហែល២៨ឆ្នាំ ទឹកមុខមាំមិនញញឹម សោះ...
រាសីគិតថាប្រហែលបុរសនោះហើយជាសារៈ នាយចំណាត់ ការរង ។ នៅក្បែរនោះ
មានបុរសឆ្មាំតម្រួតជាច្រើននាក់ តែគ្មាន ស្រីៗទេ ក្រៅតែពីកម្មការិនីរោងចក្រទាំងឡាយនោះ ។
រំពេចនោះ នាងប្រទះឃើញនារីម្នាក់លុតជង្គង់ទ្រហោរយំអង្វរថា ៖
- សូមមេត្តាកុំដោះសម្លៀកបំពាក់ខ្ញុំអី! ខ្ញុំមិនបានលួចអ្វីពីរោង ចក្រទេ ។
រួចហើយ ពីរបីនាក់ទៀតក៏រើបំរះ ហើយយំបន្តបន្ទាប់គ្នា ប៉ុន្តែ ពពួកឆ្មាំនោះមិនប្រណីទេ
បែរជាប្រើកម្លាំងបាយទះតប់ទាញអូស ហែកអាវសំពត់របស់នាងទាំងនោះ
អោយរបូតចេញស្ទើរតែរលីង អស់ពីខ្លួន ។ ទ្រាំបញ្ឈរភ្នែកមើលមិនបាន រាសីក៏ស្រែកឡើងថា ៖
- តើពួកកម្មករយើងប្រព្រឹត្តបទឧក្រិដ្ឋអ្វីខ្លះ ទើបយើងត្រូវទទួល ទោសបែបនេះគ្រប់គ្នា ?
បើលោកសង្ស័យថានរណាជាចោរ ហេតុ អ្វីក៏មិនចាប់ម្នាក់នោះធ្វើទោសទៅ ?
ហេតុអ្វីក៏ចាប់ធ្វើទណ្ឌកម្មប៉ាត ណាប៉ាតណីអញ្ចឹង ? នេះជាការរំលោភសិទ្ធិស្ត្រីឲ្យច្បាស់ក្រឡែត!
ស្រាប់តែបុរសមាឌធំជាមេកោយនោះ បើកភ្នែកធំៗឡើង រួច ហើយគំហកអោយនារីយើងថា
៖
- ចុះនាងជានរណាដែរ ហ៊ានមកស្រែកខ្វាងៗដាក់យើងដូច្នេះ ? ចង់មានការធ្វើទេ ?
ឬក៏ចង់អត់បាយងាប់ ?
- ជានរណាមិនសំខាន់ទេ ហើយក៏គ្មាននរណាចង់អត់បាយងាប់ ដែរ ។ ប៉ុន្តែអ្វីដែលសំខាន់នោះ
គឺបើយើងកើតជាមនុស្សហើយ តើមានបេះដូង មានចិត្តថ្លើមឬទេ ? បើមានបេះដូងមានចិត្តថ្លើម
ហើយ តើមានដែលគិតទេ ថាខ្លួនក៏ធ្លាប់មានកំណើតពីមនុស្ស ស្រី ?
រួចហើយតើមានដែលគិតទេថានឹងគិតផ្តល់តម្លៃសីលធម៌ដល់ ស្រីភេទវិញ
កាលបើស្រីភេទធ្លាប់អោយកំណើតដល់រូបអ្នក ?
ផាំង! បុរសនោះយារដៃទះកំភ្លៀងនាងយ៉ាងខ្លាំងធ្វើអោយធរី ដួលប្រូសទៅដីអុកគូថទឹស
ឈាមច្រមុះ ឈាមមាត់មួយរំពេច ។
- យើ! ហ៊ានជេរម៉ែយើងផងឬនាងច្រមក់ ? (នាយសារៈចំណាត់ ការរង គំហកខ្លាំងៗ)

CHANBOKEO.COM

តែរាសីមិនខ្លាចទេ ។ នាងប្រឹងក្រោកឈរវិញយ៉ាងរហ័ស រួច
ហើយឆ្លើយវិញដោយឥតខ្លាចរអារថា ៖
- នរណាគេអីក៏ល្ងិតល្ងង់ម្ល៉េះ គិតថាខ្ញុំជេរម្ដាយគេ ? ការពិតខ្ញុំ
កំពុងការពារកេរ្តិ៍ឈ្មោះរបស់ម្ដាយគេទេតើ ដែលគាត់កំពុងតែអង្គុយ រងភាពអាមាស
ដោយកូនប្រុសរបស់គាត់មិនបានទុកមុខមាត់ឲ្យ ម្ដាយ...ពោលគឺគេបានប្រព្រឹត្តបំពានលើមនុស្ស
ដែលមានភេទដូច ម្ដាយរបស់ខ្លួន ដោយឥតអាមាស!!
ផាំង! រាសីត្រូវកំភ្លៀងជាលើកទីពីរ វិលខ្វាល់ដួលទៅដីប្រួស
ជាថ្មីម្ដងទៀត ។
- ហ៊ានប្រដៅយើងផងហ្ន៎ស នាងល្អ ? ឋាន:ត្រឹមកម្មករ គ្មាន សិទ្ធិធ្វើជាម៉ែយើង
ស្រែកជេរយើងទាំងព្រហើនដូច្នេះឡើយ ។
ស្រាប់តែរាសីក្រោកឡើងជាលើកទីបី ហើយសើចកខឹកឡើង
ហាក់មិនបានឈឺចាប់នឹងការទះកំភ្លៀងនោះទេ ថែមទាំងស្រដី
ចំអកអោយនាយសារ:នោះបន្ថែមទៀតផងថា ៖
- ឋាន:ជាកម្មករ គ្មានសិទ្ធិស្ដីអោយចៅហ្វាយនាយមែន ។ ប៉ុន្តែអ្វី ដែលលោកកំពុងប្រព្រឹត្តនេះ
វាទាក់ទងនឹងសីលធម៌ទៅវិញតើហ៎
កាលបើការចេះដឹងខាងផ្នែកសីលធម៌របស់លោកធ្លាក់ចុះទាបហើយ
នរណាក៏អាចធ្វើជាម៉ែជាឪរបស់លោកបានដែរ ដើម្បីជួយណែនាំ ឲ្យបានដឹងខ្លួនខ្លះ
ថាលោកកំពុងប្រព្រឹត្តមិនគប្បីទៅលើនារីភេទ ។
ថ្វីបើលោកបានប្រើកម្លាំងបាយយកឈ្នះខ្ញុំបានពិតមែន តែលោកក៏ កំពុងតែចាញ់ខ្ញុំដែរ
គឺចាញ់ទាំងស្រុងនូវតម្លៃសីលធម៌និងតម្លៃនៃ ការគ្រប់គ្រងមនុស្សដោយមិនបាច់ប្រើហឹង្សា ។
កាលបើលោកជា បុរសមាឌធំដល់ម្លឹង ប៉ុន្តែបែរជាគ្មានសមត្ថភាពអាចយកឈ្នះខ្ញុំ បាន
ដោយមិនបាច់ប្រើកម្លាំងបាយ បានន័យថាលោកជាមនុស្សទន់ ខ្សោយអន់បំផុត ។
បើលោកពិតជាគ្រាន់បើមែន លោកត្រូវបង្ហាញ
មកថាលោកនឹងអាចយកឈ្នះខ្ញុំបានដោយមិនបាច់ប្រើហឹង្សា ដើម្បី
អោយនរណាៗនៅក្នុងរោងចក្រនេះ នឹកស្ងើចសរសើររូបលោក ដោយខានមិនបាន ។ ប៉ុន្តែ
ត្រង់ដែលលោកយកហឹង្សាមកប្រើ បំពានលើរូបកាយស្ត្រីភេទនេះ

CHANBOKEO.COM

តើគួរខ្ញុំយកទៅចុះនៅទំព័រទីមួយ នៃកាសែតពត៌មានជាតិ ដាក់ចំណងជើងថាម៉េចដែរ ដើម្បីឲ្យសក្តិ សមឋានៈរបស់លោក នៅក្នុងរោងចក្រជិនហួនេះ ?

រាសីស្រស់នីយ៉ាងក្លាហានដោយមិនខ្លាចចិត្តនរណាឡើយ ។ រីឯបុរសចំណាត់ការវិញ ក៏ខឹងសម្បារញ័រខ្លួន រហូតដល់រកនឹកពាក្យ ឆ្លើយមួយម៉ាត់តបមកនារីវិញលែងបាន ។ សូម្បីតែពួកឆ្មាំតម្រួត អង្គរក្សឬកម្មករនារីដែលឈរតម្រង់ជួរទីនោះ ក៏សម្លឹងមុខអ្នកទាំង ពីរដោយឥតពព្រិចភ្នែកដែរ ព្រោះគេមិនដែលឃើញចៅហ្វាយនាយត្រូវមាត់កូនចៅឡើងស្លឹកមុខដូច្នេះ ពីមុនមកសោះ ។

នេះជាលើកទីមួយហើយ ដែលពួកគេឃើញនារីកម្មករ តមាត់ យ៉ាងរឹងត្អឹងប្រឆាំងនាយចំណាត់ការដ៏កំណាចមួយរូបនោះ ។

- យើស ! មាត់បានណាស់ ! នេះ ពិតជាមិនខ្លាចអស់ការធ្វើទេ នាងល្អ ? (បុរសនោះគំហក)

- ចេះតែសម្លុតកម្មករ រកដកហូតការងារតែប៉ុណ្ណឹងទេ ហ្អែស លោកនាយចំណាត់ការ ? ចុះលោកវិញ មានដែលគិតទេ ថាលោក ក៏អាចអស់ការធ្វើដូចគ្នាដែរ កាលបើលោកធ្វើការខ្ជីខ្ជារំលោភសិទ្ធិ កម្មករបែបនេះ ? ចុះបើកម្មករដើរចេញអស់ពីរោងចក្រ ព្រោះគេ មិនសប្បាយចិត្តនឹងរបៀបចាត់ចែងគ្រប់គ្រងការនៅទីនេះ តើលោកមានមុខមាត់អីទៅជួបថៅកែ ? មើលទៅនាយជិនហួម៉ៅស្មិត យ៉ាងនេះលោកប្រហែលជាមិនអាចនៅអង្គុយកៅអីនៅទីនេះបាន យូរទេដឹង លោកសារៈ ?

- នាងនិយាយពីជិនហួ... នាងស្គាល់ជិនហួស៊ីនឹងគេដែរ ?

- ថីមិនស្គាល់ ! ជិនហួធ្លាប់ទាំងដើរទៅមកផ្ទះខ្ញុំថ្មីៗនេះផង ! បើ មិនជឿ សួរពូម្នាក់នេះទៅ ។ គាត់ក៏ធ្លាប់ជូនដំណើរជិនហួទៅផ្ទះខ្ញុំ ដែរ ។ សូម្បីតែជិនហួ មិនដែលហ៊ានយារដៃទះខ្ញុំផងចុះលោក ? លោកជានរណា ថ្លើមធំ ហ៊ានទះកំភ្លៀងខ្ញុំដល់ទៅពីរដៃ ? នេះលោកមិនខ្មាស់បរទេសខ្លះទេ ដែលយារដៃទះកំភ្លៀងជាតិខ្មែរគ្នា ឯងដើម្បីផ្គាប់ចិត្តថៅកែបរទេស ? ឬក៏លោកកំពុងតែពុល អំណាចជានាយចំណាត់ការរងលែងស្គាល់កូនចៅជាតិខ្មែរដូចគ្នា ទៅហើយ មែនទេ ?... មែនទេ ?

សារៈឆ្លើយលែងរួច ។ បន្តិចមក គេក៏បែរទៅនាយសៀក ៖

- ជិនហួទៅផ្ទះនាងនេះមែនឬនាយសៀក ? (នាយសារៈសួរ)

- មែនហើយទាន ! (នាយសៀកឆ្លើយ)

- តើជិនហួទៅធ្វើអ្វី ?

CHANBOKEO.COM

- គឺទៅរកឯកសារ១០សន្លឹកនោះ ។

- ឯកសារ១០សន្លឹក ?

សារៈ លាន់មាត់ហើយបែរមករាសីវិញសួរថា ៖

- ចុះនាងមកទាក់ទងអ្វីរឿងឯកសារ១០សន្លឹកនោះផង ?

រាសីងាកមុខចេញធ្វើព្រងើយ យកដៃដូតឈាមដែលហូរចេញ ពីមាត់ពីច្រមុះហើយក៏ឆ្លើយធ្វើហីថា ៖

- ជាការងាររវាងខ្ញុំនិងជិនហួ រឿងអីដែលខ្ញុំត្រូវប្រាប់លោកដែរ ?

- នាងដឹងពីឯកសារនោះមែនទេ ?

- ចុះលោកចង់ដឹងធ្វើអ្វី ?

ឃើញនារីនិយាយវិលវង់មិនព្រមប្រាប់ គេក៏បន្ទន់សំដី ៖

- ល្អើយចុះ ! យើងមិនបាច់ឆែកខ្លួននាងក៏បាន តែនាងត្រូវតែ ប្រាប់យើងអំពីឯកសារ១០សន្លឹកនោះសិន ។

- បើសិនមិនឆែក កុំឆែកទាំងអស់គ្នាទៅ ។ មើលហ្ន៎ ! ស្រីៗទាំង នេះគេធ្វើការពេញមួយថ្ងៃ ហេវបាយអស់កម្លាំងណាស់ អោយមក ឈរចាំឥតប្រយោជន៍ជាមួយកិច្ចការរបស់លោក ទីនេះទៀត មិន បានទេ សុំឲ្យគេទៅផ្ទះសិនបានទេ ?

ដោយចង់ដឹងរឿងឯកសារ១០សន្លឹកនោះ សារៈក៏បញ្ជាអោយ គេព្រលែងស្រីកម្មករទាំងនោះ ចេញទៅផ្ទះតាមសម្រួលដោយមិន បាច់ឆែកឆេរខ្លួន ។
ភាពញញឹមរីករាយបានផុសឡើងមកលើផ្ទៃមុខ របស់នារីទាំងឡាយនោះគ្រប់ៗគ្នា កាលបើគេឃើញរាសីយកខ្លួន នាងមកតវ៉ាការពារសិទ្ធិអោយពួកគេ ។ ទាំងអស់គ្នាដើរចេញទៅ ដោយលួចសម្លឹងមករាសី ក្នុងក្រសៃភ្នែកមួយដែលហាក់ដូចជាចង់ ប្រាប់នាងនូវពាក្យថា "អរគុណណាស់  មិត្តសម្លាញ់" ថ្វីបើគេមិន បាននិយាយអ្វីជាមួយរាសីក៏ដោយ ។

លុះឃើញពពួកកម្មការិនីចេញបាត់អស់ នាយចំណាត់ការមុខ កាចនោះស្រដីបន្តថា ៖

- ឯណា ប្រាប់យើងមកមើល៍ ថាឯកសារ១០សន្លឹកនោះ នៅឯណា ហើយនាងបានដឹងអ្វីខ្លះពីវាដែរឬទេ ?

- អូហ៍ ! នរណាទៅដឹងច្បាស់ដូចជិនហួម្ចាស់វានោះ ? ការពិត ខ្ញុំ គ្រាន់តែបានកាន់កាតាបប៉ុនហ្នឹង មានបានអានវាឯណា ? ធ្វើម៉េច នឹងខ្ញុំដឹងកើតទៅថាឯកសារនោះនិយាយពីស្អី ?

CHANBOKEO COM

- ពុទ្ធោអើយ! នេះគឺនាងបោកយើងតើហ៍?

- នរណាថា? គឺលោកតើហ៍ ប្រាជ្ញអន់ខ្លួនឯង ។

សារៈឮពាក្យប្រមាថ ក៏យារដៃបំរុងទះកំភ្លៀងនារីសាជាថ្មី តែ ត្រូវនាងគំហកតបវិញ ថា ៖

- ចេះប្រើកម្លាំងបាយតែម្យ៉ាងទេ មែនទេ? នេះតើហ៍ ជាសញ្ញា នៃមនុស្សអាប់ប្រាជ្ញ ដណ្តើមជ័យដោយអហឹង្សាមិនបាន ។ សូម្បី តែលើក្មេងស្រីដូចខ្ញុំម្នាក់ លោកប្រកួតមិនឈ្នះផង ចង់ទៅគ្រប់ គ្រងរោងចក្រទាំងមូលឯណាបានជោគជ័យដែរទៅ?

- មាត់បានណាស់ នាងល្អ! (សារៈគំហក)

- លោកដែរ... អីក៏ដៃបានម្ល៉េះ? ចូលចិត្តតែទះតប់មនុស្សដែល ទន់ខ្សោយជាងខ្លួន... តើថ្ងៃណាទៅទើបលោកមានប្រាជ្ញជាងនេះ យកឈ្នះគេដោយអហឹង្សា ពោលគឺមិនបាច់ប្រើកម្លាំងបាយនាំតែ ហត់អត់អំពើ? តើលោកនៅតែជាមនុស្សគ្រាន់បើដែរទេ បើសិន ដកកម្លាំងបាយចេញ? ចង់ប្រណាំងគ្នាជាមួយរាសីទេ ថាតើនរណា មួយគ្រាន់ជាង បើសិនយើងប្រកួតដោយប្រាជ្ញម្តង?

សារៈ ឈរញាក់ស្មៀកមុខពព្រើត ដោយកំហឹង ព្រោះចាញ់ សំដីក្មេងស្រី ។ រាសីស្រដីហើយក៏ដើរចេញទៅ ។ នាយសៀក ឃើញហើយ ក៏គំហកថា ៖

- ចង់ទៅណា? លោកនាយនិយាយជាមួយនាងមិនទាន់ចប់ទេ?

រាសីសើចក្អឹកហើយតបវិញថា ៖

- យ៉ាងម៉េច? ចង់នៅជជែកទាល់តែគាំងបេះដូងខ្យល់គរលំដួល ដូចស្រីៗប៉ុន្មាននាក់ពីថ្ងៃនោះមែនទេ ទើបអោយខ្ញុំទៅផ្ទះ?

នាយសៀកសម្លក់ភ្នែរ តែសារៈយកដៃគៀសហើយស្រដីថា ៖ - អោយនាងទៅចុះ មិនបាច់ឃាត់ទេ ។

រាសីក៏ដើរចេញទៅ ទុកឲ្យសារៈឈរខាំធ្មេញក្រឹតៗតែម្នាក់ឯង ត្បិតថ្ងៃនេះ គេបាក់មុខអស្ចារ្យ ដែលគេដេញប្រាជ្ញាក្មេងស្រីម្នាក់មិន ឈ្នះ ព្រោះនាងនិយាយត្រូវចំចំណុចខ្សោយរបស់សារៈពិតមែន ។ ការពិតនោះ បើនាយមិនប្រើកម្លាំងបាយវិញ តើអ្នកក្រោមបង្គាប់ ស្តាប់នាយដែរឬទេ? តើនាយមានលក្ខណៈសម្បត្តិអ្វីខ្លះដែលគួរឲ្យ អ្នកដទៃកោតសរសើរ ក្រៅពីកម្លាំងបាយ? ហេតុអ្វីក៏ ក្មេងស្រីតូច ច្រឡឹងម្នាក់ អាចប្រើសំដីយកឈ្នះលើរូបគេ យ៉ាងងាយដូច្នេះ? តើនាងជានរណា? ហេតុអ្វីមកធ្វើកម្មករទីនេះ? សារៈហាក់ដូចជា

CHANBOKEO.COM

ចាប់អារម្មណ៍លើមាណវីនោះតិចៗហើយ... គេសម្លឹងតាមរូបនាងពី ក្រោយធ្វើស្ងៀមស្ងាត់
រហូតដល់នាងបាត់ស្រមោលទៅ ។

នៅក្នុងបន្ទប់ជួល...

- បងរាសី! ហេតុអ្វីក៏មានរបួសធ្ងន់ធ្ងរយ៉ាងនេះ ?
- គឺ... រឿងវែងឆ្ងាយណាស់ រក្សា... តែបងសប្បាយចិត្តណាស់ ថ្វី
បើបងទទួលរងទណ្ឌកម្មដល់ម្លឹង ព្រោះបងបានយកដុំគ្រួសទៅញ៉ុក
មាត់អាពួកពូកែគម្រាមកំហែងកម្មករ អោយវាប្រឹងលេបម្តង ថា អារសជាតិជាមនុស្សចាញ់
វាមានអារម្មណ៍យ៉ាងម៉េចដែរ ។

រក្សាជួយជូតឈាមអោយបងស្រីហើយ ក៏រៀបបាយបរិភោគ
ស្រាប់តែនាងអើតអើមដកកសម្លឹងមើលតាមបង្អួចទៅក្រៅ ។

- មើលផ្លូវបងសយនាមែនទេ ?
- នរណាថា ? បងនឹករអើលខ្លួន ខ្លាចពួកមកពីរោងចក្រខានបង នៅផ្ទះយើងតើហ៎ ។

រក្សានៅស្ងៀមមិនហ៊ានសួរទៀត ។ ចៃដន្យ រាសីនិយាយបន្លប់ ទេ ។ ការពិត
នាងអើតរកមើលសយនាមែន តែមិនហ៊ានឆ្លើយ ទទួលខ្លួន ត្បិតនឹកខ្មាសប្អូនប្រុសរបស់នាង ។
ចៃដន្យ យប់នោះ សយនាមិនបានមកទទួលទានបាយល្ងាចជាមួយអ្នកទាំងពីរ ដូច
ដែលរាសីទន្ទឹងឡើយ ធ្វើអោយរាសីគេងរសាប់រសល់ទាល់ភ្លឺ...

ព្រឹកស្អែកឡើង...

- រក្សាចេញទៅណាដែរថ្ងៃនេះ ? (រាសីសួរ)
- ទៅរកការធ្វើជិតៗនេះណា៎បង ក្រែងលោដោះទាល់បានខ្លះ ទំរាំ ថ្ងៃចូលរៀន ។

រំពេចនោះ សូរសម្លេងគោះទ្វារលាន់ឡើង ។ រក្សាស្ទុះទៅបើក យ៉ាងលឿន ៖

- បងសយនា ? (រក្សាឧទានឡើង)

សយនាញញឹមពព្រាយដាក់អ្នកទាំងពីរហើយស្រដីថា ៖

- សូមទោស ដែលយប់មិញបងធ្វើការយប់ជ្រៅ មិនបានមក បរិភោគបាយជុំគ្នា ដូចរាល់ដង ។

រាសីបែរមុខចេញ ព្រោះមិនចង់អោយសយនាឃើញស្នាមជាំ លើផ្ទៃមុខរបស់នាង ។

- មានគេខឹងនឹងបងហើយ ដែលបងមិនមកកាលពីយប់មិញ ។

រក្សាលួចខ្សិបប្រាប់ហើយ ក៏ដើរគេចចេញទៅបាត់ ទុកឲ្យ
សយនានៅជជែកជាមួយបងស្រីតែពីរនាក់ ។

CHANBOKEO.COM

- រាសីខឹងនឹងបងមែនទេ ដែលបងខានមកពីយប់មិញ បានជាមិន ស្រដីរកបងសោះ ?

រាសីនៅស្ងៀម រៀបចំខ្លួនបំរុងដើរចេញទៅធ្វើការ ស្រាប់តែ សយនាឃើញមុខរបស់នាងមានស្នាមជាំខៀវ ក៏លាន់មាត់ ៖

- មានរឿងអ្វីហ្នឹង រាសីបានជា... ?

- ចាំអោយខ្ញុំរាសីស្លាប់សិនទៅ ចាំមកសួរសុខទុក្ខ (រាសីឆ្លើយកាត់ សំដីរបស់សយនា)

- ពុទ្ធោ! បើបងដឹងថា រាសីមានគ្រោះថ្នាក់ ម៉្លេះសមបងមករក ទាំងកណ្តាលយប់បាត់ទៅហើយ... តើនរណាគេទៅយកដៃជើងធំៗ របស់គេមកវាយដំរាសីយ៉ាងនេះ ?

- គឺពួកកាន់ការនៅក្នុងរោងចក្រជិនហួនោះអី ?

- រោងចក្រជិនហួ ? ប្អូនធ្វើអ្វីខុសនឹងវិន័យមែនទេ ?

រាសីជ្រួញចិញ្ចើមមួយស្របក់ក៏ឆ្លើយថា ៖

- គឺរាសីតវ៉ាប្រឆាំងនឹងការរំលោភសិទ្ធិរូបកាយរបស់កម្មការិនី ។

- ស្លាប់ហើយ! ទើបចូលធ្វើការពីរថ្ងៃ រាសីហ៊ានតវ៉ាគេ រហូត ដល់ត្រូវទទួលទណ្ឌកម្មបែបនេះផង ?

- បំណាច់នឹងទាល់ច្រក ទាល់តែបែរខាំពួកវាវិញខ្លះហើយ! រាសី មិនព្រមចុះចាញ់ពួកវាងាយៗទេ ថ្វីបើខ្ញុំនេះ មានតម្រិះ មានឋានៈ ត្រឹមកម្មករក៏ដោយ ក៏ខ្ញុំជាមនុស្ស មានសាច់មានឈាម មាន អារម្មណ៍ មានសតិប្រាជ្ញាស្មារតី... ខ្ញុំនឹងប្រើវាជួយខ្លួនឯងអោយ ដល់ទីបំផុត ។

កាលបើឮវាចានាងដូច្នោះ សយនាសម្លឹងមុខធិតាដោយក្រសែ ភ្នែកយ៉ាងមុត ទំនងហាក់ចង់នឹងដល់ជំរៅចិត្តនាងណាស់ ថានាង កំពុងគិតអ្វី ចង់ធ្វើអ្វីខ្លះក្នុងជីវិតរបស់នាង ។

- រាសី! យ៉ាងណាក៏គួរមើលកាលៈទេសៈផងណ៎! កុំអោយប្រទះ គ្រោះថ្នាក់មកលើរូបកាយច្រើនពេក ព្រោះខ្លួនជាស្រី... មិនអាច យកឈ្នះបុរសដោយកម្លាំងបាយបានទេ ។

- តែរាសីមិនបានដោះស្រាយបញ្ហាដោយអាងកម្លាំងបាយទេ! អ្នក ដែលកំពុងចាញ់ទេតើហ៎ ដែលចូលចិត្តយកកម្លាំងបាយមកតទល់ ស្ថានការណ៍ដែលខ្លួនកំពុងចាញ់ប្រៀប ។

- ទោះបីជាយ៉ាងណាក៏បងបារម្ភពីសុវត្ថិភាពរបស់រាសីណាស់!

CHANBOKEO .COM

- បងបារម្ភពីរាសី ? ក្នុងឋានៈអ្វីដែរ ? យើងមានជាប់សាច់ឈាម ឯណានឹងត្រូវបារម្ភពីគ្នាផង ?(រាសីគំហកអោយ)

ភ្លាមនោះ សយនាក៏ធ្លាក់ទឹកមុខភ្លាម រួចឆ្លើយវិញថា ៖

- មែនហើយ! បងភ្លេចខ្លួនទៅ ថាបងជាអ្នកក្រៅ មិនគួរមកហៃហៃស្អីពីរឿងផ្ទាល់ខ្លួនរបស់រាសីទេ ។ ឲ្យបងសូមទោសផងណា៎!

សយនាទម្លាក់មុខចុះ ហើយក៏ដើរចេញទៅ ។ រាសីញោចក្នុងចិត្តបន្តិចដែលនាងច្រឡំមាត់ស្តីអោយគេ ព្រោះនៅខឹងនឹងគេដែលមិនបានមកបរិភោគបាយជុំគ្នាកាលពីម្សិល ។ ម្យ៉ាងនាងក៏នៅខ្នក់ក្នុងចិត្តដែលមិនឃើញគេយកចិត្តនាងដូចរាល់ដង ។ ពេលនេះ គេ ដើរចេញទៅបាត់មិនព្រមយកចិត្តនាងទៀតហើយ ធ្វើអោយធីតារឹងរិតតែនឹកខឹងខ្នក់ខ្នាញ់ក្នុងចិត្តថែមទៀត ។

បន្តិចមក នាងក៏ចេញទៅធ្វើការ ។ ថ្ងៃនេះ ប្លែកណាស់ រាសីបានសង្កេតឃើញនារីសិចស៊ីសោភាម្នាក់បានបើករថយន្តមកដល់ រោងចក្រក្នុងឫកពាឆ្មើងឆ្មៃ ហើយចង្អុលស្តីងោកងាកដាក់ពពួក ទ្វារបាលទាំងឡាយនោះដោយមិនសំចៃមាត់សោះ ។

- បងសុផា! តើនារីប្រឹមប្រិយ៍ឆើតឆាយនោះជានរណាគេដែរ ?

រាសីសួរមិត្តនីរបស់នាង ។ សុផាបែរមើលឃើញហើយក៏ឆ្លើយ វិញថា ៖

- នាងហ្នឹងឈ្មោះសាវរី ជាសង្សាររបស់ជិនហួ ហើយត្រូវជាប្អូន ស្រីរបស់សារៈដែលជានាយចំណាត់ការរងនៅទីនេះ ។ ឮថាពួក គេមានណាស់ សុទ្ធតែកាន់ក្រុមហ៊ុនធំៗប្រាក់វាល់លានឯណោះ ។ ការពិត នាងនេះកាចដល់សូរហើយ លើសសារៈបងប្រុសនាងទៅទៀត ។ ការពិត នាងមិនដែលធ្វើការទេ គឺចេះតែត្រួតគេទាំង ទទឹងទិសតែម្យ៉ាងប៉ុនហ្នឹងឯង ។ ថ្ងៃនេះ បើសិននាងដើរមក បញ្ចេញរាងកាត់តាមរោងដេរមួយនេះ គេនឹងបញ្ចេញឫកអោយប្អូនបានឃើញមិនខានថា គេគឺជាទេពធិតាបិសាចតែម្នាក់គត់ គ្មានគូប្រជែងឡើយនៅភ្នំពេញនេះ ។

រាសីលួចសម្លឹងនាងយ៉ាងពិនិត្យពិច័យ ហើយនឹកក្នុងចិត្តថា ៖

- ហេតុអ្វីមនុស្សឫកពាអន់ៗបែបហ្នឹង បែរជាមានវាសនាដេក ពូក ចាយលុយវាល់លាន តែមនុស្សដែលស្រវាស្រទេញចង់រៀន ចង់សូត្រ ដូចយើង បែរជាគ្មានឱកាសទៅវិញ ? គិតទៅជីវិតនៅ លើលោកនេះអយុត្តិធម៌ណាស់! តើយើងត្រូវធ្វើយ៉ាងណា ដើម្បី

ជនះព្រហ្មលិខិត ដែលកំពុងតែឈរចាំសើចចំអកដល់ជីវិតរបស់ យើង ?
រាសីពិតជាមិនព្រមចុះចាញ់ដោយងាយៗឡើយ ។ យើង
មានអាយុមិនទាន់គ្រប់២០ឆ្នាំស្រួលបួលទេ... យើងពិតជានៅមាន ឱកាស... សំរាប់សាងអនាគត
យើងមិនព្រមរស់នៅលិចលង់ត្រឹម តែជាកម្មការិនីរហេមរហាមបែបនេះឡើយ ។

កំពុងតែឈ្ងោកគិតភាំងៗ ស្រាប់តែ... ខ្វាប់ៗ ៖

- អ៊ីយ៉ូយ !

រាសីលាន់មាត់ឡើង បែរមើលមនុស្សដែលយកបន្ទះម៉ែត្រមក វាយខ្នងនាងពីក្រោយ
ស្រាប់តែប្រទះនារីឆើតឆាយឈ្មោះសាវ៉ី អំបាញមិញនោះ ដែលកំពុងស្រែកវ៉ាវៗថា ៖

- ទីនេះជាកន្លែងធ្វើការ មិនមែនកន្លែងមកឈរងក់ទេ! ធ្វើការ ទ្រើកៗយ៉ាងនេះ
ត្រូវកាត់ប្រាក់ខែពាក់កណ្ដាលចោលទើបសម ។

រាសីឈឺណាស់ ចង់តែស្ទុះទៅវាយតបវិញអោយដឹងដៃគ្នាទៅ ហើយ តែសុផាយកដៃទប់
ហើយស្រដីតិចៗថា ៖

- ធ្វើការទៅ រាសី! កុំមាត់កុំកអី! ប្រយត្ន័រឿងតូចក្លាយជាធំ ដោយអាសារឥតការ ។

រាសីមិនបានហើបមាត់តបតមែនតែនាងសម្លក់សាវ៉ីវិញដោយ
មិនខ្លាចញញើតក្រសែភ្នែករបស់នារីគូកំណាន់ថៅកែរោងចក្រនោះ ឡើយ ។
ឃើញធិតាខមភ្នែកគ្រលួងដាក់វិញ សាវ៉ីក៏គំហកថា ៖

- នែ៎ ក្មេងព្រហើន! កុំវាយឫកព្រហើនដាក់យើងបែបនេះ តិចត្រូវម៉ាដំបងថែមទៀត ឥឡូវ!

ថៃដន្យ រាសីមិនបានខ្លាចរំពាត់នោះទេ ។ នាងនៅតែលួច
ចោលកន្ទុយភ្នែកសម្លក់សាវ៉ីដដែល ។ កាលបើបែរមកឃើញរាសី
មិនទទួលចុះញ៉មអំណាចរបស់នាង សាវ៉ីក៏បែរក្រោយ លើកយក
រំពាត់ម៉ែត្រចង្អុលមុខរាសីហើយស្រដីថា ៖

- យើ! ហ៊ានខមដាក់យើងផងឬមីច្រមក់ ?

ថាហើយ សាវ៉ីក៏យាររំពាត់វាយខ្វាប់លើខ្លួនរាសីជាលើកទីពីរ តែម្ដងនេះ
រាសីទ្រាំទប់កំហឹងលែងបានហើយ ។ នាងក៏ចាប់រំពាត់ កញ្ឆក់ពីដៃសាវ៉ីហើយទាញនាងគំហុក
ទៅមុខ ទៅក្រោយ រហូត ដល់សាវ៉ីរបូតដៃពីដំបងហើយភ្លាត់កែងចោទ ដួលគ្រេងចូលទៅ
ប្រឡោះម៉ាស៊ីនកាត់ក្រណាត់ពីគ្រឿង រិះតែម៉ាស៊ីនស៊ីដៃជើងអស់ ខ្លះ
ធ្វើអោយនារីឆើតឆាយភ័យផងខឹងសម្បារផង និយាយលែងឮ តែម្ដង ។

CHANBOKEO.COM

ឯរាសីវិញកញ្ឆក់រំពាត់ម៉ែត្រឈើនោះបានហើយ ក៏ស្រវា កាច់វាប្រសៗបោះចោលទៅដី រួចវាចាថា ៖

- ទោសរំលោភផ្គន្ទាគេ ថ្ងៃណាមួយបាបនោះនឹងវិលដល់ខ្លួនវិញជា មិនខាន... ពេលនោះ ទោះយំស្រែក ក៏ទេវតាជួយមិនបានដែរ ។

ភ្លាមនោះ សាវរីស្រែកយ៉េៗ ផ្អើលអស់ពពួកឆ្មាំរោងចក្រ រត់មកមើលឈូឆរ ៖

- មានការអ្វីអ្នកនាង ?
- គឺវានោះ វាវាយយើង! ចាត់ការវាអោយយើងភ្លាម!

សាវរីយកដៃចង្អុលមុខរាសី ។ ស្រាប់តែរាសីឆ្លើយវិញយ៉ាង លឿនឥតបង្អង់ថា ៖

- ស្លាប់ហើយ មិនដែលឃើញទេ ស្រីក្រមុំពេញវ័យ រូបស្រស់ ស្អាត តែបែរជាចេះកុហកសឿងម៉េះលោក ?

រាសីជញ្ឆក់មាត់ហើយគ្រវីក្បាលឡើង ព្រមទាំងស្រដីថែមថា ៖

- នេះជាគំរូយ៉ាងអាក្រក់បំផុតដល់កម្មករទីនេះ!! បើចៅហ្វាយ នាយចេះភូតកុហកដល់ម្លឹង តើគួរអោយកូនចៅរើសជាគំរូទេ ? ការពិត ខ្ញុំមិនបានវាយនរណាទេ គឺមានតែគេវាយខ្ញុំ ។
- នែ៎! គឺឯងហ្នឹងប្រើកម្លាំងបាយអោយយើងដួល បើមិនជឿទេ ចាប់ពួកកម្មករទីនេះអោយធ្វើសាក្សីមើល៍ថានរណាបានឃើញខ្លះ ?

ស្រាប់តែរាសីសើចកខឹកឡើង តបថា ៖

- ចៃដន្យ អ្នកធ្វើការទីនេះ ខ្លាចអំណាចអ្នកនាងដេញគេចោលពី រោងចក្រខានធ្វើការ ម្ល៉ោះហើយ គេត្រូវតែឆ្លើយកាន់ជើងអ្នកនាង ធ្វើអោយខ្ញុំនេះចាញ់ដោយអាសារឥតការ ។ ប៉ុន្តែបើចិត្តសឿងមែន យើងលេងក្បួនដោះអាវបង្ហាញសាច់វិញ...
- ដោះអាវបង្ហាញសាច់ មានអ្វីទាក់ទងនឹងរឿងនេះដែរទៅ ?

សាវរីស្រែកកាត់ ។

- ម៉េចក៏ថាមិនទាក់ទង ? (រាសីតប) បើយើងលេងក្បួនដោះអាវ បង្ហាញសាច់ នោះយើងនឹងបានដឹងថា នរណាជាអ្នករងគ្រោះត្រូវ គេវាយកន្ទួលសាច់ ហើយនរណាជាអ្នកវាយគេពិតប្រាកដ ? បើរក ឃើញថានរណាជាអ្នកភូតកុហក យើងទាំងអស់គ្នា ត្រូវចាប់គេនោះ កាត់អណ្តាតចោល កុំអោយគេរៀនភូតឆ្កួតៗដូចក្មេងតទៅទៀត ។
- ព្រហើន! (សាវរីស្រែកកាត់) នាងជាកម្មករ គ្មានសិទ្ធិមកតវ៉ា ស្មើជាមួយយើងជាចៅហ្វាយនាយទេ ។

CHANBOKEO.COM

រាសីច្រត់ចង្កេះធ្វើឫកព្រងើយហើយឆ្លើយថា ៖
- ថៃដន្យ អ្នកនាងមានឋានៈត្រឹមតែជាគូដណ្ដឹងរបស់ចៅហ្វាយ នាយ តែមិនទាន់បានធ្វើជាចៅហ្វាយនាយផ្លូវការឯណា ។ មិន ទៀងទេ ជិនហ្វូគេអាចដូរចិត្ត ទៅស្រឡាញ់ស្រីណាផ្សេងក៏ថាបាន ជាពិសេសពេលគេដឹងថា គេមានគូដណ្ដឹងដែលគ្មានមារយាទថ្លៃថ្នូរ បែបនេះប្រហែលជាគេដូរចិត្តទៅសម្លឹងនារីផ្សេងទៀតក៏មិនដឹង ។ ដូច្នេះ កុំទាន់ឃើញផ្ការលាន់ ក៏ត្រេកអរចាក់ទឹកពាងចោលអី... ណា មួយ ជិនហ្វូជាជនបរទេស មិនដឹងថាគេមានប្រពន្ធប៉ុន្មាន កូន ប៉ុន្មាននាក់នៅឯស្រុកទេ ដូច្នេះវាមិនទៀងដែរ ថាអ្នកនាងជានារីទី ប៉ុន្មានរបស់គេ ? កុំសូវវាយឫកធំដុំពេក ប្រយត្ន័ដល់ថ្ងៃគេដោះដៃ ព្រលែងចោល អ្នកនាងនឹងបាក់មុខខូងជ្រៅដូចបាតទន្លេសាបទៅ! ទាំងកម្មករប្រុសស្រី ទាំងឆ្មាំទាំងឡាយនៅទីនោះ បានឮ ដូច្នោះ អត់មិនបាន ក៏នាំគ្នាសើចហោរគិលឡើង ។
- ពួកឯងសើចអី ? (សាវរីគំហក)

ទាំងអស់គ្នាក៏ស្ងាត់មាត់លែងហ៊ានសើច ។ រំពេចនោះស្រាប់តែ ជិនហ្វូបើកឡានចូលមកដល់ ។ ពពួកឆ្មាំក៏ស្ទុះស្ទ្រូស្រទៅទទួល បើកទ្វារជូនលោក យកចិត្តភ្លាម ។
- បងជិនហ្វូ!

សាវរីងាកមកសម្លក់រាសី ហើយក៏រត់ទៅចាប់ដៃជិនហ្វូភ្លាម ។ ពេលនោះ រាសីចាប់ភ្លឹកថាជិនហ្វូហាក់ដូចជាល្ងួច ចោលកន្ទុយភ្នែក មើលនាងដែរ ទំនងចាប់ភ្លឹកថា នាងកំពុងតែមានរឿងជាមួយ សាវរី គូកំណាន់ចិត្តរបស់គេ ។ ថៃដន្យ គេមិនបានធ្វើមាត់អ្វីទេ បែរជាដើរឡើងទៅលើអាគារការិយាល័យយ៉ាងលឿន ដោយមិន រវល់ធ្វើដឹងធ្វើឮចំពោះកិរិយាខ្ចិកខ្ចក់របស់សាវរី ដែលកំពុងទាម ទារការចាប់អារម្មណ៍ពីរូបគេ ដើម្បីដាក់ទោសរាសីនោះឡើយ ។
- រាសី! ប្អូនសំដីថ្លោសៗដាក់គេអញ្ចឹង មិនខ្លាចគេចាប់ខ្លួនយក ទៅធ្វើទណ្ឌកម្មទេហ៍ ?

នាងសុផាសួរ ។ ភ្លាមនោះ រាសីគ្រវីក្បាល ៖
- បងសុផាអើយ! ជីវិតរបស់ខ្ញុំវាសោះកក្រោះអស់រសជាតិតាំងពី យូរហើយ បានមកកំប្លែងលេងសើចនឹងពពួកអ្នកមានអោយពួកគេ គាំងអណ្ដាតកកឈាមខ្លះ ខ្ញុំដូចជាមានអារម្មណ៍គ្រាន់បើបន្តិច ។
- ហើយចុះប្អូនមិនខ្លាចគេដេញអោយឈប់ធ្វើការទេហីអីហ្នឹង ?

CHANBOKEO.COM

រាសីញញឹមហើយសើចខឹកៗ ឆ្លើយថា ៖

- ពួកវាមានចំណុចខ្សោយមួយ ដែលគេមិនអាចយកឈ្នះខ្ញុំបាន ដោយកម្លាំងបាយ ។ ដូច្នេះ គេនឹងទ្រាំអោយខ្ញុំត្បូកស្ទុំមួយស្របក់ ទៀត ដើម្បីរកមធ្យោបាយយកឈ្នះខ្ញុំសាជាថ្មីវិញ សូម្បីតែជិនហួ ក៏មិនហ៊ានក្អកជាមួយខ្ញុំចំមុខទៀតដែរ ហោចណាស់ខ្ញុំនឹងបានរស់ មួយពេល ទំរាំអស់ការធ្វើ ។

រំពេចនោះ ស្នូរនាឡិការោទិ៍ឡើងជាសញ្ញាបញ្ចប់វេន ។ ស្រីៗ កម្មករជាច្រើនដើរមកទះស្មារាសី សំដែងអំណររបស់គេ ៖

- មីអូនឯងក្លាហានណាស់ ! បើកុំតែបានឯង កុំអីគេចាប់សំរាតខោ អាវពួកយើងនែកគ្មានសល់ទេ ។

- នាងតូចពូកែមែន ! ហ៊ានតបតរហូតនាងឆ្កួតស់នោះវាបាត់មាត់ !

- ប្អូនស្រីអើយ ! អរគុណណាស់ដែលឯងក្រោកឈរបាន ថែមទាំង អាចជួយការពារយើងទាំងអស់គ្នាផង ។

- ថ្ងៃក្រោយបងបោះឆ្នោតអោយឯងធ្វើជាប្រធានកម្មករទីនេះហើយ

ពពួកកម្មការិនីមកលួចខ្សិបលើកទឹកចិត្តនារីម្តងមួយៗ... ធ្វើឲ្យ ឆវីយើងមានមោទនភាពក្រៃលែង ចំពោះអំពើល្អដែលនាងបានធ្វើ ដើម្បីពួកនារីកម្មកររងគ្រោះទាំងនោះ ។

បន្តិចមក មាណវីក៏ដើរត្រឡប់មកដល់ផ្ទះវិញ ដោយមានទិញ បាយពីកញ្ចប់មកផង ។ ពេលនោះ រក្សាមិនទាន់មកដល់ផ្ទះនៅ ឡើយទេ ស្រាប់តែមាននារីម្នាក់មកគោះទ្វារបន្ទប់របស់នាង ។ ធិតាដើបឡើងទៅបើកទ្វារ ស្រាប់តែប្រទះសាវរីជ័សិចស៊ីឆើតឆាយ ឈរច្រត់ចង្កេះនៅមាត់ទ្វារបន្ទប់របស់នាង ។

- អ្នកនាងសាវរី ?

- មែន គឺយើង ! នាយសៀកប្រាប់ថានាងរស់នៅទីនេះ ទើបយើង ចង់មកមើលថាតើមនុស្សសំដីជា ដូចនាងមានការរស់នៅយ៉ាងម៉េច ដែរ ។ ការពិត មានទៅខ្មេះឯណា ? ជួលផ្ទះគេតូចប៉ុនសំបកក្ដាម ផ្លែចូលដេកមិនទាំងផុតកន្ទុយផង ។

CHANBOKEO.COM

- ដើ! ផ្ទះតូច ផ្ទះធំ វាមិនសំខាន់ទេ សំខាន់តែថាមនុស្សខ្លះមាន ផ្ទះធំ មានលុយចាក់ក្រាលថ្នល់ មានមាសស្រោបខ្លួន តែមាន មារយាទឬកពារអន់ៗ មិនបានស្មើនឹងឆ្កែកំបែកក្បាល នោះទើបគួរឲ្យស្រណោះអនិច្ចាបំផុត!
- យ៉ស! ហ៊ានប្រមាថយើងថាជាឆ្កែផងហ្ន៎ស?
- ហើយចុះទៅខ្លាចស្អី? បើមិនមែនជាឆ្កែទេ ហេតុអ្វីក៏បក់កន្ទុយ ដើរហិតក្លិនមកដល់ទីនេះ? ក្រែងដឹងហើយតើហ៎ ថាកន្លែងនេះ មានក្លិនអ្នកក្រស្អុយៗ ប៉ុន្តែ នៅតែបក់កន្ទុយដើរតាម ទាំងឈ្មោល ទាំងញី ទាំងចៅកែនិងស្រីរបស់ចៅកែ...!
- នែ៎! និយាយឲ្យមើលមុខមើលក្រោយផង! យើងមិនមែនជា ស្រីរបស់នរណាទេ នាងល្ងង់!
- អូហ៍ មិនមែនទេ? ហេតុអ្វីក៏តែងខ្លួនដូចស្រីរកស៊ីបែបហ្នឹង? ស្លាប់ហើយ! ស្លៀកខ្លីៗ ពាក់អាវវាលក បញ្ចេញនេះនោះ ហើយ មកដើរតត្រុកៗម្ដុំនេះទៀត តើអោយអ្នកស្រុកគេគិតយ៉ាងណាទៅ វិញហ្ន៎?

ដោយទប់ចិត្តនឹងពាក្យចំអករបស់រាសីមិនបាន សាវរីក៏យក កាបូបដៃរបស់នាងវាយក្បាលរាសីផស! តែមានរួចខ្លួនឯណា! រាសីខឹងណាស់ ក៏ចាប់ដៃអូសសាវរី ច្រានផ្ទាប់នឹងជញ្ជាំងផ្ទះរបស់ នាងហើយស្រដីថា ៖
- អ្នកនាងរករឿងខ្ញុំនៅកន្លែងធ្វើការមិនអស់ចិត្ត មករករឿងដល់ ផ្ទះខ្ញុំទៀតហ្ន៎ស? ម៉េច អាងខ្លួនអ្នកមាន មានលុយមានអំណាចឬ បានជាចង់មកវាតទីដល់ទីនេះ? គួរអោយស្ដាយ អ្នកនាងគិតខុស ហើយ! ទីនេះមិនមែនសំបុកស្វាឲ្យគេធ្វើបាបស្រេចនឹងចិត្តទេ!

ភ្លាមនោះសាវរីក៏ស្ទុះមកប្រវាយប្រតប់រាសីហើយស្រដីថា ៖
- គឺព្រោះតែនាងចេញមុខទៅទាក់ទាញជិនហួ ឲ្យគេមករកនាងទី នេះនោះអី ។ ដឹងទេ ថាគេជាគូកំណាន់របស់យើង? នាងកុំកាត់ មុខយើងអោយសោះ ពុំនោះសោត យើងមិនអោយនាងរួចខ្លួនទេ ព្រោះយើងស្អប់នរណា ដែលចូលចិត្តតាំងខ្លួនជាស្រីស្នេហ៍ពិសេស របស់ជិនហួ ។
- ពុទ្ធោអើយ អ្នកនាង! ហេតុអ្វីក៏លង់ស្នេហ៍ រហូតដល់អស់ការ ពិចារណាយ៉ាងនេះ? ខ្ញុំនេះឬជាស្រីស្នេហ៍របស់ជិនហួ? បើពិត ដូច្នោះមែន តើខ្ញុំចាំបាច់ទៅធ្វើការនៅរោងចក្រធ្វើអ្វី? ទុកឲ្យ ជិនហួហុចប្រាក់ចិញ្ចឹម ដេកស្ងៀមស្រណុកស្រួលខ្លួនវិញ មិន ប្រសើរជាងទេហ៍?
- នរណាទៅដឹងល្បិចស្រីមាយានោះ? អាពួកអ្នកក្រ ស្អីក៏ហ៊ានធ្វើ ដែរ អោយតែបានលុយ! (សាវរីគំហក)

CHANBOKEO.COM

- ហើយចុះអាពួកអ្នកមាននោះ វាមិនធ្វើអ្វីៗដើម្បីលុយទេឬអី ?
រួចចុះអ្នកនាងដែលតាមទាក់ទងជិនហ្វាឡើងស្អិតនោះ មិនដោយ សារឃើញលុយ
ឃើញទ្រព្យរបស់ជិនហ្វាទេហ្ន៎ស ? ហើយបើ ជិនហ្វាមិនមែនជាថៅកែសំបូរលុយវិញ
តើអ្នកនាងបក់កន្ទុយរត់ តាមគេដូច្នេះទេ ? ការពិត ពពួកស្រីអ្នកមានខ្លះៗប្រឹងតែងខ្លួន
តែងប្រាណ បញ្ចេញកាយសឹងតែអាក្រាត ដើរទាក់ប្រុស រកលុយ ស្រោបខ្លួន
មិនខុសអ្វីពីស្រីស្នេហ៍ក្រីក្រលក់ខ្លួនដើម្បីប្រាក់នោះ ប៉ុន្មានឡើយ... មើលចុះ ? តើវាគ្រាន់បើអី
ជាងគ្នាប៉ុន្មានទៅ ?
- នែ៎ នាងមើលងាយយើងជ្រុលពេកហើយ!
ផាំង! សាវរីយកដៃទះកំភ្លៀងរាសី ។ ចៃដន្យ នារីយើងមិន
ទុកអោយគេវាយនាងបានស្រួលៗទេ ។ ធិតាក៏ចាប់កដៃរបស់សាវរី
បានហើយ ក៏មួលបត់ទៅក្រោយយ៉ាងរហ័ស ។
- មនុស្សដូចអ្នកនាង ទាល់តែលេងថ្នាំខ្លាំងខ្លះទើបនឹងរសជាតិ!
រាសីក៏ចាប់មួលដៃសាវរីទៅក្រោយទាំងពីរហើយដោះអាវក្រៅ របស់នាងយកមកចង
តែសាវរីនៅតែស្រែកឡូងៗជេរនាង មិន ព្រមឈប់ឡើយ ។
រាសីទ្រាំមិនបានក៏ស្ទុះយកកូនកន្សែងពោះគោ មកមូរញ៉ុកមាត់សាវរីភ្លាម ។ រំពេចនោះ
រក្សាក៏មកដល់ផ្ទះ ៖
- បងរាសី! ចាប់បងស្រីនេះមកពីណា ?
- គឺជាចោរដែលចូលលួចទ្រព្យយើងនៅទីនេះ ។
- បងចង់យកគេទៅប្រគល់អោយប៉ូលីសមែនទេ ?
- អត់ទេ! នរណាគេឆោត យកអោយប៉ូលីសនោះ ? ពួកប៉ូលីស សព្វថ្ងៃខ្លះស៊ីសំណូកណាស់
មិនចូលចិត្តដាក់គុកចោរទេ ។ ឲ្យតែ ស៊ីកលុយ ពួកគេព្រលែងចោរវិញទាំងអស់
សូម្បីតែចោរដែលធ្លាប់ សម្លាប់មនុស្សមានភស្តុតាងហើយក៏ដោយ ។ ប្អូនដឹងទេ លុយអាច
បង្វិលផែនដីសុវណ្ណភូមិអោយវិលបានប៉ុន្មានជុំក៏បានដែរ ? អ្នកក្រ
ដូចជាយើងដេកតែពីចាញ់ទៅ ។ ដូច្នេះ បងមិនយកគេទៅអោយ
ប៉ូលីសទេក្រែងស្ត្រីមួយរូបនោះវាបកត្រឡប់ចាប់បងដាក់គុកវិញ ។
បងចង់អោយគេទទួលទោសបែបថ្មីម្តង សង្ឃឹមថា គេនឹងរាងចាល មួយជីវិត
លែងប្រព្រឹត្តអាក្រក់លើមនុស្សដូចគ្នា តទៅទៀត ។

- អញ្ចឹង បងគិតយ៉ាងម៉េចវិញទៅ ?

ពិតមែនតែសាវរីត្រូវរាសីចងដៃចងជើង តែនារីនៅស្តាប់ឮ មើលឃើញទាំងអស់នូវអ្វីៗសព្វយ៉ាងដែលរក្សានិងរាសីសន្ទនា ។

ឃើញដូច្នោះ រាសីក៏យកទឹក យកសាប៊ូមកលាងក្រែមម្សៅចេញពី ផ្ទៃមុខរបស់សាវរី ហើយទាញកន្ត្រៃកាត់សក់នាងខ្ទោកៗតែម្តង ។ សាវរីបើកភ្នែកធំៗ ខំរើបំរះយ៉ាងខ្លាំង តែមិនបានការឡើយ ។ ចំណែករក្សានៅអង្គុយមើលបងស្រី ស្ញៀមស្ងាត់ ព្រោះជឿក្នុងចិត្តជាក់ថាសាវរីជាស្រីចោរពិតមែន ។ បន្តិចមក រាសីយកថ្នាំម្សៅជា ច្រើនកញ្ចប់ មានតាំងពីថ្នាំលាបកមរមាស់រហូតដល់ថ្នាំទាស់សរសៃ ខ្វី រួមទាំងថ្នាំបញ្ចុះចម្រុះបួនដប់មុខ យកចាក់ចូលគ្នាហើយលាយ ស្រា ស ថែមទឹកតែ លាយទឹកពាង រួចហើយក៏ចាប់ច្របាច់ច្រមុះសាវរីបង្ខំក ៖

- ស្លាប់ហើយ! គិតធ្វើអ្វីហ្នឹង បងរាសី ?
- នេះគឺថ្នាំសម្រកសាច់ អោយស្គម ដើម្បីអោយគេដឹងថា អ្នកក្រ ស្គមហើយហេវនោះមានអារម្មណ៍យ៉ាងម៉េចដែរ ។

នាងក៏ច្របាច់ច្រមុះសាវរីបង្ខំកភ្លាម តែសាវរីគ្រវីក្បាលខ្វាល់ ធ្វើអោយជាតិថ្នាំកំពប់រាជពាសពេញផ្ទៃមុខអស់ ។ ប៉ុន្តែ ទោះបីជា ខំរើយ៉ាងណា ក៏មិនឈ្នះដៃរាសីកៀបជាន់កខ្ទប់ច្រមុះនាងដែរ ។ សាវរីដង្ហក់ខ្យល់ខក់ៗ លេបថ្នាំនោះអស់ពីរបីក្អឹកទៅ ។ ចំណែក រាសីវិញមិនព្រមលាងថ្នាំដែលនៅប្រឡាក់លើផ្ទៃមុខនារីចេញឡើយ បែរជាទុកអោយម្សៅនោះកកនៅលើមុខយ៉ាងក្រវេមក្រវ៉ាម តាម ដំណើរអញ្ចឹងទៅ ។ បន្តិចមក នាងក៏ទាញស៊ីរ៉ាំងចាក់ថ្នាំចាស់មួយ ចេញមក គឺជាស៊ីរ៉ាំងដែលនាងទិញកាលពីថ្ងៃមុន ដើម្បីចាក់ថ្នាំខ្លួន ឯងពេលនាងមិនស្រួលខ្លួន ។ ភ្លាមនោះ រាសីហូតយកក្រដាសមួយសន្លឹកចេញមក ។

- ចេះអានអក្សរមែនទេ អ្នកនាង ? មើលនេះ ជាលទ្ធផលនៃការជោះឈាមរបស់បងប្អូនយើង ។ គឺយើងមានជាប់រោគអេដស៍ទាំង ពីរនាក់ ។ យើងគិតថា ចង់ចែកពូជវា អោយអ្នកនាងជួយចិញ្ចឹម ខ្លះ ព្រោះអីអ្នកនាងជាអ្នកមាន មានលុយច្រើនណាស់ ដូច្នេះសូម មេត្តាជួយ ចិញ្ចឹមវាអោយធំធាត់បន្តិចណា៎! ។

រាសីលាតក្រដាសនោះដាក់នៅមុខសាវរីដែលអង្គុយជាប់ចំណង

CHANBOKEO.COM

ទាំងដៃទាំងជើង ផ្ទេកជញ្ជាំង ។ គ្រាន់តែឃើញលទ្ធផលលើផ្ទាំង ក្រដាសនោះកាលណា សាវីរបើកភ្នែកធំៗតែម្តង ។ បន្តិចមក រាសី ក៏ដោតស៊ីរាំងបូមឈាមពីរក្បា ប្រហែលជាកន្លះសេសេ យកទៅ ចាក់បញ្ចូលអោយសាវីរភ្លាម ។ គ្រាន់តែម្ជុលដោតសាច់ សាវីរក៏ស្រែកវ៉ាសឡើង ហើយក៏សន្លប់បាត់មាត់តែម្តង ។

ពេលនោះ សាវីរលែងជានារីស្រស់ស្អាតសិចស៊ីទៀតហើយ... នាងគ្រាន់តែជានារីមុខមាត់សាមញ្ញម្នាក់ មានសក់ខ្លីរខិញរខុញ មុខ លឿងៗស្លេកៗ មិនគួរស្នេហ៍ឡើយ ។ បន្តិចមក រាសីក៏ដោះខោ អាវរបស់សាវីរចេញ ហើយច្រកខោអាវកញ្ចាស់ៗអោយវិញ រួច ក៏អូសសាវីរអោយគេងលើក្តារកៀនជញ្ជាំង ៖

- សូមទោសណាអ្នកនាង! ផ្ទះយើងមានមុងតែមួយ កន្ទេលតែ មួយ គ្មានចំណែកលើសចែកអ្នកនាងទេ ដូច្នេះ សូមនៅហាលមូស មួយយប់សិនទៅណា... បានចែកទានអោយមូសក្រីក្រស្គមៗអោយ វាស្គាល់ជាតិឆ្អែតម៉ាដៃ ប្រហែលជាបានបុណ្យច្រើនណាស់!

យប់នោះ សយនាមិនបានមកលេងជាមួយអ្នកទាំងពីរដូចរាល់ ថ្ងៃទេ ប៉ុន្តែក៏ល្អដែរ ព្រោះរាសីកំពុងរវល់ទទួលភ្ញៀវថ្មីផង ។

CHANBOKEO.COM

oooooooooooooooooooooo

ooooo

o

# វគ្គទី៥
## ខ្លាំងជួបខ្លាំង

រក្សាដើបតាំងពីព្រហាម ទៅជួយលក់កាហ្វេនៅតៀមមួយ ម្តុំៗ រោងចក្រនោះដែរ ។ នាយសុំគេធ្វើការបណ្តោះអាសន្នទំរាំសាលា បើកទ្វារចូលរៀន ។ ចំណែករាសីក្រោកឡើង ដាស់សាវរីថា ៖

- ចាប់ពីពេលនេះទៅ បងស្រីត្រូវធ្វើតាមខ្ញុំសព្វបែបយ៉ាង បើមិន ដូច្នេះទេ ខ្ញុំនឹងប្រកាសប្រាប់គេថា បងស្រីមានរោគអេដស៍ នោះ បងនឹងត្រូវរងការអាមាសក្នុងសង្គម ហើយជិនហ្វក៏នឹងដោះដៃ ចោលបងស្រីដែរ ។ ប៉ុន្តែបើបងស្រីធ្វើតាមខ្ញុំគ្រប់មួយខែ នោះខ្ញុំនឹងដោះលែងបងអោយទៅជួបជុំគ្រួសារវិញដោយសុវត្ថិភាព ។

- ហើយឯងក៏មិនរួចខ្លួនដែរ នាងច្រមក់! យើងនឹងប្តឹងគេអោយ ចាប់ឯងដាក់គុក ពីការដែលនាងបានចាប់ជំរត់ធ្វើបាបលើរូបកាយ របស់យើង ។

- ចេះភូតបង្កាច់ខ្ញុំអញ្ចឹងកើត បងស្រី ? បងដើរមករកខ្ញុំដល់ផ្ទះ កាលពីម្សិល អ្នកស្រុកអ្នកភូមិណាក៏គេឃើញដែរ ។ ម្យ៉ាងទៀត បងកុំលែងក្បួនវាត់កន្ទុយដាក់ខ្ញុំវិញអី ព្រោះខ្ញុំមិនអោយបងស្រី រំលោភលើសិទ្ធិអ្នកក្រដូចខ្ញុំនេះតាមតែទំនើងចិត្តដោយអាងអំណាច ទឹកប្រាក់របស់បងស្រីបាននោះឡើយ ចាំទុកផង!

បន្តិចមក រាសីក៏លើកកូនកញ្ចក់មួយដាក់ពីមុខសាវរី ៖

- នេះ មើលខ្លួនទៅ ស្រស់ទេ ? សាវរីពីម្សិលនោះបានវង្វេងទៅ ដើរលេងឋានផ្សេងម៉ាខែសិនហើយ នៅសល់តែក្រមុំអារី ដែលជា បងស្រីមិនគ្រប់ដប់របស់រាសីប៉ុណ្ណោះ ។ ថ្ងៃនេះ ខ្ញុំនាំបងទៅធ្វើ ការជាមួយខ្ញុំ

CHANBOKEO.COM

ហើយសុំចាំអោយច្បាស់ផង ថាកុំធ្វើមាត់ច្រើនពេក
ប្រយត្ន័ខានបានត្រឡប់ទៅផ្ទះវិញក្នុងរវាងមួយខែទៀត ។

សាវរីឈ្ងោកមើលរូបនាងនៅក្នុងកញ្ចក់ ស្រាប់តែស្រែកឡើង ភ្លាត់សម្លេងថា ៖

- ពុទ្ធោ ព្រះអើយ!

មែនហើយ! សាវរីបានក្រឡាខ្លួនពីនារីសិចស៊ីសោភា មកនារីម្នាក់ដែលមានសក់កញ្ជ្រតកញ្ជ្រតរខិញរខុញ មុខហើមស្គរ ស្លេកៗ លឿងៗ ថែមទាំងមានកន្ទួលអុជក្រហមពេញមុខ ដោយកំសួលអំណាចថ្នាំកញ្ចាប់មួយរយមុខរបស់រាសីកាលពីយប់មិញ ។ បែរទៅ សម្លៀកបំពាក់វិញ មិនបាច់មើលឡើយ គឺជាសម្លៀកដ៏រខេករខាក ដែលសាវរីធ្លាប់ខ្ពើមរអើមបំផុតក្នុងជីវិតរបស់នាង ។

- ឯណាខោអាវរបស់យើង ? (សាវរីគំហកសួរ)

- គឺខ្ញុំបានយកទៅសំដិលចោលនៅខាងក្រៅ ហើយមានគេខ្ចីយក ទៅបាត់តាំងពីយប់មិញម្ល៉េះ ។ ចំណែកកាបូបយួររបស់បងស្រីវិញ ក៏ដូចគ្នាដែរ ខ្ញុំបានរលាក់ចែកក្មេងៗម្តុំនេះអស់ហើយ មិនបាច់រក វាទៀតទេ ។ ចាប់ពីថ្ងៃនេះតទៅ បងស្រីនឹងរស់នៅជាមួយខ្ញុំជា របៀបសាមញ្ញ ដើម្បីអោយជីវិតរបស់បង បានស្គាល់រសជាតិថ្មីៗ ល្អៗ ខុសពីមុនច្រើនណាស់ ។

មុននឹងចេញដំណើរ រាសីបានចាក់ថ្នាំមួយម្ជុលលើដើមដៃរបស់ សាវរីម្តងទៀត ។

- នេះជាកំពូលថ្នាំញៀនម្យ៉ាងដែលនឹងធ្វើទុក្ខបងស្រីក្នុង២៤ម៉ោង ទៀត ។ បងស្រីមិនអាចរត់គេចទៅណាបានទេ ទាល់តែបងស្រីមក រកខ្ញុំវិញ ដើម្បីចាក់ម្ជុលទីពីររំងាប់វា ។ បើបងស្រីលេងល្បិចជា មួយខ្ញុំ បងស្រីនឹងបានឡើងទំព័រទីមួយក្នុងកាសែតប្រចាំប្រទេស យ៉ាងស្រស់អស្ចារ្យហើយ ព្រោះយប់មិញ ពេលបងស្រីដួលបាត់ ស្មារតី ខ្ញុំបានហៅពួកកាសែតមកថតរូបទុករួចហើយ ។ ហ៊ានតែ បងស្រីលេងល្បិច នោះបងនឹងស្គាល់ស្នាដៃរបស់ខ្ញុំវិញមិនខាន ។ ពេលនោះ មិនដឹងថា ស្រីអ្នកមានឬក៏ស្រីអ្នកក្រទេ ដែលជាមនុស្ស ត្រូវធ្លាក់នរកទាំងរស់ ?

សាវរីញោចមុខ ជ្រួញចិញ្ចើម តែក៏មិនអាចជួយខ្លួននាងបាន ព្រោះចាញ់ប្រាជ្ញក្មេងស្រីសាមញ្ញមួយរូបនោះ រកក្រឡាដោះខ្លួនមិន រួចសោះ ។ រាសីក៏ស្រាយចំណងអោយសាវរីដើរតាមសម្រួល ៖

CHANBOKEO.COM

- ចាំអោយច្បាស់! បងស្រីមានឈ្មោះថ្មីថា អារី ជាបងស្រីរបស់
រាសី...សូមរៀបខ្លួនអោយសមស្ថានការណ៍ ។ ប្អូនប្រុសរបស់ខ្ញុំបាន ចេញទៅក្រៅ
រៀបជើងព្រួលរួចហើយ ។ បើមានអ្វីកើតឡើងលើ រូបខ្ញុំ
នោះបងស្រីក៏នឹងបានល្បីឈ្មោះពេញប្រទេសដែរ ហើយ
ជិនហ្វូច្បាស់ជាសប្បាយចិត្តនឹងឮដំណឹងនេះក្រៃលែងតែម្តង ។

សាវរីខាំធ្មេញក្រឹតៗ តែមិនហ៊ានធ្វើអ្វីទេ ទំនងកំពុងគិតរកវិធី
តដៃនាងច្រមក់នោះវិញហើយ ។ ថៃដន្យ សាវរីមិនដែលប្រើខួរ
ក្បាលសំរាប់គិតអ្វីតាំងពីដើមមក ។ ពេលនេះ នាងទើបតែនឹក ឃើញចង់ចាប់វាមកប្រើវិញ
តើអោយវារត់ស្រួលដូចចិត្តយ៉ាងម៉េច នឹងកើត ? ទីបំផុត
សាវរីបានត្រឹមតែខាំមាត់ធ្វើតាមរាសីតែម្យ៉ាង
ប៉ុណ្ណោះ ។

បន្តិចមក រាសីនាំសាវរីដល់មាត់ទ្វាររោងចក្រ ។ ថៃដន្យ ថ្ងៃ នោះ
ជិនហ្វូចេញទៅក្រៅក្រុងបាត់ ។ ឯសារៈចេញទៅក្រៅរហូត ដល់រសៀលទើបមកវិញ ។
រាសីបានដៃ ក៏ប្រើប្រាជ្ញបញ្ចុះបញ្ចូល រហូតដល់នាយសៀកនិងពួកការិយាល័យ
អោយទទួលនាងអារីចូល ធ្វើការដោយគ្មាននរណាចាប់ភ្លឹកម្នាក់ឡើយ ថានាងអារីនោះជាក្រមុំ
សាវរីដ៏សិចស៊ីមួយរូបនោះ ព្រោះថ្ងៃនេះ នាងបានប្រែក្រឡាទៅជា ធិតាជនបទមុខហើមស្តូរ
សក់កន្ទ្រីងកន្ទ្រើងមើលមិនយល់ទៅ ហើយ ។ បន្តិចមក គេក៏នាំអារីទៅកាន់ម៉ាស៊ីនដាំឡេវមួយ
ក្បែរៗ រាសីដែរ ដើម្បីអោយរាសីជួយមើលជាភ្នែក ជាច្រមុះ ព្រោះអីរាសី បានប្រាប់គេថា
បងស្រីមានសតិភ័យច្រើនខុសគេបន្តិច ។

ការពិត សាវរីបានរើកញ្ជ្រោលពីរបីដងហើយ តែត្រូវរាសីត្រួត ស្ថានការណ៍បានមុនជានិច្ច ។
ពេលនេះ សាវរីឬនាងអារីបានក្លាយ ទៅជាឌាកិនីជាប់ជុចរបស់រាសីហើយ ។ ថ្ងៃនោះ
នាយសៀកនិង ឆ្មាំតម្រួតប្លនដប់នាក់ទៀត ជាអ្នកដើរមើលខុសត្រូវរោងចក្រទាំង មូល
ព្រោះចៅហ្វាយធំទាំងពីរមិននៅ នៅតែពួកការិយាល័យតែ ប៉ុន្មាននាក់ ។
ប៉ុន្តែគេមិនបានចាប់ភ្លឹកគិតថាអារីនោះជាសាវរីឡើយ ព្រោះអារីនោះរខេករខាកមើលមិនបាន ។

សាវរីធ្វើការបានតែមួយស្របក់ ក៏បោកដុំក្រណាត់ព្រួសប្រស ទៅដី ហើយច្រត់ចង្កេះស្រែកថា
៖

- ទ៊ើយ! ការងាររបៀបនេះ អាណាធ្វើកើតលោកអើយ!

CHANBOKEO.COM

- នែ៎ នាងអារី! ទីនេះរោងចក្រណា៎! មិនមែនផ្ទះរបស់នាងទេ

ឆ្មាំបុរសម្នាក់ស្រែកវ៉ាងពីចម្ងាយ ហើយក៏ដើរមកជិត រួចស្រដី ទៅសាវរីថា ៖

- ឆាប់រើសឡើងរៀបវិញភ្លាម ឬក៏ចង់ត្រូវរំពាត់ខ្លះទើបធ្វើការ ? នែ៎! រៀនមើលគេមើលឯងផងវើយ! គេធ្វើរាប់ឆ្នាំមកហើយ មិន ទាំងរអ៊ូផង ចុះនាងស្ទីដែរ មកវាយឫកមើលតែថៅកែគេយ៉ាងនេះ តិចអត់មិនបានឥឡូវហ្នឹង!...

សាវរីសម្លក់នាយឆ្មាំ បំរុងនឹងតមាត់ទៅហើយ ស្រាប់តែរាសី គ្រហែមឡើងសម្លុតស្មារតីសាវរីភ្លាម ។ នាងទុចដឹក់លៃងហ៊ានមាត់ ក រួចក៏អោនឈ្ងោកធ្វើវិញទាំងទើសទាល់ ។ ទំរាំធ្វើការដល់ថ្ងៃត្រង់ សាវរីមុខស្លេកលើសមុនជិតដប់ដង ព្រោះក្រពះរបស់នាង គ្មាន គុយទាវព្រឹកទ្រាប់បាតសាលា ។ រាសីបានទិញបាយស្រូបឆាតៅហ៊ូ ជាមួយសណ្តែកបណ្តុះអត់មានសាច់ អោយនាងអារីមួយចាន ៖

- នេះ! ខ្ញុំចេញលុយអោយប្រាំរយរៀលសិន ។ ចាំដល់បើកប្រាក់ ខែ ចាំសងខ្ញុំវិញចុះ ។

រសជាតិបាយស្រូបប្លែកណាស់ ។ សាវរីលេបសឹងមិនចូល តែ នាងត្រូវតែទ្រាំលេប ព្រោះឃ្លានដល់កំណត់ហើយ ។ បើមិន លេបទេ នាងច្បាស់ជាខ្យល់គស្លាប់ទាំងថ្ងៃមិនខាន ។ មិនទាន់ បរិភោគបាយអស់ផង រាសីអូសដៃនាងចូលទៅវិញ ៖

- ដល់ម៉ោងធ្វើការវិញហើយបងស្រី! បើលេបមិនទាន់អស់ ចាក់ចោលទៅ ចាំល្ងាចចាំបរិភោគបន្ថែម ។

រសៀលនោះ សាវរីធ្វើការទាំងល្វិតល្វៃបំផុត ព្រោះសាច់ដុំដៃ ជើងរបស់នាងមិនដែលប្រើការរបៀបនេះយូរហើយ ។ នាងញ័រដៃ ញ័រជើងតតះដូចមនុស្សញៀនថ្នាំ ។ ឃើញដូច្នោះ រាសីដើរមកជិត ហើយគម្រាមបន្ថែមទៀតថា ៖

- ថ្នាំញៀនវាធ្វើទុក្ខហើយ ល្ងាចនេះ ត្រូវតែចាក់ម៉ម្ហូលទៀតដើម្បី អោយបាត់ញ័រ កុំគេចខ្លួនទៅណាអោយសោះ ប្រយត្ន័លើសដើម!

បន្តិចមក ស្រាប់តែនាយសារៈមកដល់ ដោយមាននាំថៅកែ ម្នាក់មកជាមួយផង ។ រាសីឃើញបុរសចំណាស់នោះភ្លាមក៏លាន់ មាត់ឡើងថា ៖

- ថៅកែខាំង ? គាត់មកធ្វើអ្វីទីនេះដែរ ? ហើយចុះរស្មី ប្អូនស្រី របស់យើងនោះ គេយកទៅលាក់ទុកនៅឯណា ?

សាវរីឃើញសារៈ នឹកអរភើត ខំរត់ចេញទៅរកនាយ យ៉ាង លឿន ហើយស្រែកថា ៖

CHANBOKEO.COM

- បងសារៈ ! បងសារៈ!

សារៈងាកឃើញនារីរខេករខាកចម្លែកម្នាក់ មុខហើមៗស្លេកៗ សក់ក្បាលរខិញរខុញក្នុងសម្លៀកកម្មករហៅគេថាបងៗ ក៏ជ្រួញ ចិញ្ចើមហើយគំហកថា៖

- នែ៎ នាង! នេះម៉ោងធ្វើការ មិនមែនម៉ោងញ៉ែបុរសទេ! ឆាប់ ត្រឡប់ទៅធ្វើការវិញទៅឮហើយនៅ ?

ថាហើយ គេក៏នាំថៅកែឌាំងឡើងទៅអាគារការិយាល័យបាត់ ទៅ ។ សាវរីស្ទុះរត់តាមពីក្រោយ តែត្រូវពួកឆ្មាំយកដំបងស្ទាក់ ៖

- នែ៎! ឡប់ទេហ៎្អសនាង ? ហេតុអ្វីមានកិរិយាមិនគប្បីទីនេះ ?

តែសាវរីបែរជាគំហកអោយនាយវិញថា ៖

- នែ៎ នាយឆ្មាំ! យើងត្រូវការជួបបងសារៈ ឯងមកចេះដឹងស្អី ដែរហ្អឹង ?

កាលបើសំដីកោងកាចរបស់នាង នាយឆ្មាំនោះមិនបានទុកមុខ អោយទេ គេក៏យកដំបងបុកស្មាសាវរីអស់ម៉ាទំហឹងដៃ ៖

- ចង់ថយដោយខ្លួនឯង ឬក៏ចង់អោយយើងប្រើកម្លាំងបាយ ?

ត្រូវមួយដំបង សាវរីមុខស្លេក ថយទៅវិញទាំងមុខក្រញ៉ូវ ព្រោះចាញ់ច្រាបមិនដឹងថាត្រូវធ្វើយ៉ាងណា ដើម្បីអោយបានទៅជួប ដោយសារៈជាបងប្រុស ។ ឯរាសីវិញ បែរជាលួចឈរញញឹមតែ ម្នាក់ឯង ៖

- សាវរីអើយ! ពេលនេះ ដឹងហើយឬនៅ ថាអាពួកឆ្មាំរោងចក្រនោះវាប្រើកម្លាំងបាយគម្រាមកម្មករក្នុងរោងចក្របែបណាខ្លះ ?

រសៀលបន្តិច សាវរីក៏ឆោឡោជាថ្មីម្តងទៀត ៖

- អិយ៉ូយ! ធ្វើការយ៉ាងនេះ មិនអោយសំរាកខ្លះទេហីអី! យើង ឈរគាំងជើងជិតងាប់ហើយវ៉ើយ!!

កម្មកររោងចក្រនៅម្តុំៗនោះបែរមើលគ្រប់គ្នាតែម្តង ។ស្រាប់តែឆ្មាំម្នាក់រលាស់រំពាត់វាត់ខ្វាប់ៗ ៖

- នែ៎នាង! បើមិនចង់ធ្វើការទេ ទៅដេកផ្ទះទៅ! បើយើងឮនាង ស្រែកតែមួយម៉ាត់ទៀត នាងនឹងស៊ីរំពាត់ពីរបីខ្វាប់មិនខាន ។

CHANBOKEO.COM

សាវរីភ្ញាក់ព្រើត នៅស្ងៀមលែងហ៊ានស្រែក ។ រំពេចនោះ ស្រាប់តែសារៈចេញពីការិយាល័យរបស់គេ ដើរកាត់ទីធ្លាមុខរោង ដេរលេខប្រាំ ដែលសាវរីនិងរាសីធ្វើការ ។

- បងសារៈ (សាវរីរត់រឹងទៅរក) ជួយអារីផង! បងសារៈ!

សារៈភ្ញាក់ព្រើត ដែលស្រីរូបអាក្រក់ មុខហើមស្តូរ រត់មកចាប់ ដៃហៅនាយថាបងៗដោយសម្លេងក្ងួរៗ សាជាថ្មីទៀត នៅចំពោះ មុខកម្មកររាប់រយ ធ្វើអោយគេនឹករអៀសខ្លួនណាស់ ។ នរៈក៏ កន្ត្រាក់ដៃសាវរីចេញ ក្នុងកិរិយាខ្ពើមរអើម ហើយស្រែកថា ៖

- នាយសៀក! នៅឯណា ? ចាត់ការនាងឆ្កួតនេះបន្តិចមើល៍!

គេក៏ប្រច្រានឆាងចេញ ហើយដើរសំដៅរថយន្ត ស្រាប់តែ សាវរីទៅអួសដៃសាថ្មី ៖

- បងសារៈ! នេះអារីណា៎! និយាយគ្នាបន្តិចមើល៍!

- នែ៎! ថាកុំប៉ះយើង ប្រឡាក់ខោអាវយើងអស់ហើយ យីអើរ៉ុ!

សារៈច្រានសាវរីយ៉ាងអស់ទំហឹងរហូតដល់នាងដួលអុកគូថទៅ ដីទឹសនៅចំពោះមុខកម្មករទាំងឡាយ ធ្វើអោយ មាណវីនឹកអាមាស នោះសែនអាមាសណាស់ ដែលសារៈលេងដៃធ្ងន់ដាក់នាងដូច្នេះ ។ មាណវីក៏ស្ទុះទៅអោបជើងសារៈ ហើយលាត់ជើងខោនាយឡើង កញ្ឆក់បានកូនកាំភ្លើងខ្លីមួយដែលនាយបង្កប់នៅកស្បែកជើង លើក ឡើងភ្ជង់សារៈភ្លាម ៖

- បងសារៈ ហ៊ានធ្វើបាបអារីដល់ថ្នាក់ហ្នឹងផងហ្ស៎ស ? ខ្ញុំមិនឲ្យ បងរួចខ្លួនងាយៗទេ កុំច្រឡំ!

ផាំង! សាវរីភ្លាត់កៃ បញ្ជូនគ្រាប់សំណឲ្យហៅទៅទំលុះជើង ស្តាំរបស់នាយសារៈភ្លាមមួយរំពេច ។ សាវរីភ្ញាក់ស្រឡាំងកាំងត្បិត នាងគ្មានចេតនាបាញ់បងប្រុសទេ ។ ការពិត នាងគ្រាន់តែចង់គំរាម អោយបងប្រុសស្តាប់នាងប៉ុនហ្នឹង នឹងអាលគេបានជួយដោះនាងពី ក្រញាំដៃល្បិចរបស់រាសី ។ ពេលនោះ ពពួកឆ្មាំក៏រត់ស្រ៊ូស្រមក យ៉ាងលឿន តែដោយខ្លាចគ្រាប់សំណក្នុងដៃសាវរី ទាំងអស់គ្នាក៏ ទុចង៉ក់ជំហានមិនហ៊ានចូលជិត ។ សារៈដួលទ្រោបខ្លួនទៅម្ខាង បើ កុំបាននាយសៀកទប់ទាន់ កុំអីដេកដីននៀលដីលេង មួយស្របក់ ហើយ ។ រីឯរាសីវិញ កាលបើក្រឡេកឃើញសារៈត្រូវប្អូនស្រីបាញ់ ត្រូវមួយគ្រាប់ នាងក៏លួចសើចចំអកនៅក្នុងចិត្ត តែម្នាក់ឯងថា ៖

CHANBOKEO.COM

- សមមុខអ្នកហើយ! នេះហើយ កម្មពៀរដែលនាយទះកំភ្លៀង
យើងបែកមាត់បែកច្រមុះឆ្លាយឈាមថ្ងៃមុន! ឥឡូវ យើងសុំសង អ្នកវិញហើយ!
ចូររៀនស្គាល់ថ្នាំខ្លាំងខ្លះទៅ ។ ពេលនេះ ប្អូនស្រី
របស់អ្នកកំពុងទ្រាំទ្រនឹងភាពក្រីក្រលំបាកមិនបាន ទើបដើបតដៃ លោកវិញយ៉ាងដូច្នេះ!
ចូរទទួលយកអំពើបាបរបស់ខ្លួនទៅ!

រំពេចនោះ ស្រាប់តែមានកងប៉ូលីសក្រុងមកដល់យ៉ាងច្រើន
ដូចស្រមោច ឡោមពទ្ធ័រោងចក្រនោះយ៉ាងចម្លែក ។
- មានរឿងអ្វីហ្នឹង នាយសៀក? (សារៈសួរ)
- មិនដឹងទេ លោកនាយ! (នាយសៀកឆ្លើយ)

សាវីរីនឹកភ័យក្រោយ បោះកាំភ្លើងចោល ធ្វើឡេឡា ។ រាសី
ឈរសម្លក់សាវីរីសឹងជ្រុះគ្រាប់ភ្នែក ដែលមាណវីម្នាក់នោះធ្វើឲ្យ ខូចគម្រោងការរបស់នាងអស់ ។
ក្នុងឱកាសដែលគេម្នាក់ៗកំពុង ជ្រួលច្របល់រឿងពួកប៉ូលីសមកឡោមពទ្ធ័ សាវីរីក៏រត់គេចខ្លួនបាត់
ទៅ ។ ភ្លាមនោះ រាសីបានឃើញនាយប៉ូលីសកាន់ដិការឆែកឆេរមក ហុចអោយសារៈ
ដែលកំពុងមានរបួសឈាមលើកំភួនជើងស្តាំ ។
ឯនាយប៉ូលីសជាច្រើនទៀតក៏ចាប់ឡើងទៅឆែកឆេរការិយាល័យ ។ ចំណែកប៉ូលីសមួយក្រុមទៀត
ក៏ចូលមកធ្វើអន្តរាគមន៍អោយពពួក កម្មករ ចេញទៅឈរនៅម្ខាង ដើម្បីអោយគេឆែកឆេរ ។

ភ្លាមនោះ រាសីបានប្រទះឃើញនាយកងប៉ូលីសមួយរូបនៅក្នុង
ចំណោមនាយប៉ូលីសមេបញ្ជាការពីរបីរូបទៀតនោះ មានមុខមាត់ ដូចសយនាបេះបិទតែម្តង ។
- បងសយនាជានាយកងប៉ូលីសទេតើហ៎? បងមិនមែនជាបុរស រត់ម៉ូតូឌុបឯណា...!

រាសីឧទានខ្សិបៗ តែក្នុងពោះម្នាក់ឯង ។ ភ្លាមនោះ នរៈដាក់ ភ្នែកមកចំនាង ដោយថៃដន្យ ។
កាលបើប្រទះក្រសៃភ្នែករបស់ នាយភ្លាម រាសីញញឹមឡើងដោយត្រេកអរ ព្រោះនាងកំពុងតែនឹក
រលឹករូបគេពន់ពេកណាស់ ។ ថៃដន្យ គេគ្រាន់តែញោចចិញ្ចើម បន្តិច
រួចហើយក៏បែរទៅធ្វើការបន្តទៀត ធ្វើហាក់ដូចមិនដឹង ឬមិនស្គាល់រាសីឡើយ ។
ធិតាខកចិត្តស្រឡេត នឹកខ្មាសតែក្នុងចិត្ត
ដែលនាយធ្វើពើមិនញញឹមត្រឡប់មករកនាងវិញសោះ ។ រាសីក៏
ទម្លាក់ទឹកមុខចុះ ចងចញ្ចើមមួយរំពេច ។

មួយម៉ោងក្រោយមក ប៉ូលីសក៏បំបែកជួរទៅ ដោយប្រមូល
យកសំណុំឯកសារទៅជាមួយជាច្រើនផង ។ ពេលនោះ កម្មករក៏ ដល់ម៉ោងត្រូវឈប់សំរាកដែរ ។
រាសីបែររកមើលសាវ៉ីរី មិនឃើញ ស្រមោលនាងសោះ ក៏ប្រហោងពោះធ្លុង ៖
- ស៊យហើយជាន់នេះ! ខូចការអស់រលីង រាសីអើយ!
រាសីដើរចងចញ្ចើមរហូតដល់ផ្ទះ រកនឹកមធ្យោបាយសំរាប់ដោះ ខ្លួនបន្តទៅទៀត
ក្រែងលោសាវ៉ីរីនាំកងទព័មកសងសឹកនាងវិញ ។ គ្រាន់តែនាងមកដល់ផ្ទះ
ស្រាប់តែភ្ញាក់ព្រើតដោយឃើញសាវ៉ីរីនៅ ទីនោះស្រេច
ដោយមានរក្សាជាអ្នកអង្គុយយាមមាត់ជណ្ដើរផង ៖
- រក្សា ? ហេតុអ្វីបងស្រីអារី មកដល់ទីនេះកើត ?
- គឺខ្ញុំនៅអង្គុយចាំបងឯមុខរោងចក្រ ស្រាប់តែឃើញគាត់រត់គេច ចេញមកទាំងភ្នែកសល្លក់
ក៏អូសនាំគាត់មកទីនេះតែម្ដងទៅ ។
រាសីដកដង្ហើមយូបន្ធូរទ្រូង ព្រោះល្បិចរបស់នាងមិនទាន់ដួរ ក្រឡា ។ បន្តិចមក
គេក៏ស្រាយបាយកញ្ចប់ដួសចែកគ្នាបរិភោគ ។
សាវ៉ីរីពបមាត់ទ្រង់ខ្ពើមរអើមសម្លម្ជូរដើមចេកលាយកូនត្រីចង្វារ ។
- បងស្រីអើយ! បើមិនចុកខ្លះទេ ប្រយ័ត្នតែសាកមុនអាយុទៅ ។ នេះហើយរសជាតិជីវិតអ្នកក្រ
រៀនភ្លក្សខ្លះទៅណា៎ ដើម្បីឲ្យដឹងថា អ្នកក្រធ្វើការយ៉ាប់ប៉ុនណា
ទំរាំបានលុយមកទិញបាយបែបហ្នឹង បរិភោគ ដូច្នេះកុំសូវកេងប្រវ័ញ្ចអ្នកក្រ
យកលុយទៅចាយខ្ជះខ្ជាយ ឥតប្រយោជន៍ពេក អាណិតអ្នកក្រខ្លះផង ឮហើយនៅ ?
ដោយទាល់ច្រក សាវ៉ីរីក៏ស្រវាស្លាបព្រា ទាញចានបាយភ្លាម
ម្យ៉ាងព្រោះខ្លាចរាសីនិងរក្សាពួយមុនអស់ ខានបរិភោគផង ។
តុក! តុក! តុក! សូរមនុស្សគោះទ្វារ ។
រាសីនិងរក្សាងើប មើលមុខគ្នា ៖
- ប្រហែលបងសយនាហើយ! (រក្សាពោល)
ឮឈ្មោះសយនា រាសីលួចបញ្ចេញស្នាមញញឹមតិចៗនៅលើផ្ទៃ មុខរបស់នាង ។
រក្សាក៏ស្ទុះទៅបើក ស្រាប់តែគេបើកភ្នែកធំៗត្បិត នោះមិនមែនជាសយនាឯណា
គឺជានាយសៀកនិងអង្គរក្សក្មេងមួយ រូបទៀតនៅឈរពីក្រោយ ។ រាសីឃើញហើយ
ក៏ស្ទុះក្រោកឈរ ទ្បើង យកខ្លួនពាំងមាត់ទ្វារ ៖

CHANBOKEO.COM

- ពូសៀកមករកពួកយើងទាំងព្រលប់មានការអ្វីដែរ ?
- គឺមកនាំខ្លួននាងអារីដែលបានបាញ់លោកសារៈកាលពីថ្ងៃ!
- ពូសៀកជាមេកងរបស់ឆ្មាំរោងចក្រ តែមិនមែនជាប៉ូលីសឯណា ដូច្នេះ
គ្មានសិទ្ធិចូលអុកឡុកផ្ទះអ្នកស្រុកណាទេ ។
- តែនាងអារីបានធ្វើអោយរបួសចៅហ្វាយនាយរបស់យើង!
- ហើយគេបង្គាប់ពូសៀក អោយមកតាមបងអារីអញ្ចឹងហ្អែស ?
- សួរច្រើនម្ល៉េះ ? ចៀសផ្លូវ!
- រឿងអីត្រូវចៀសផង ? នេះជាផ្ទះរបស់ខ្ញុំ!
យើញរាសីចចេស នាយសៀកក៏ចាប់កអាវនាងកញ្ឆក់ហើយ
បោះនាងទៅម្ខាងដួលប្រូសនៅមុខផ្ទះ ។ រក្សាឃើញដូច្នោះក៏ស្រែក ឡើងថា ៖
- ពួកឯងអាងស្អី មកធ្វើបាបបងស្រីយើងដូច្នេះ ?
រួចហើយរក្សាក៏ហក់ទៅតដៃនាយសៀក ស្រាប់តែត្រូវអង្គរក្ស ម្នាក់ទៀតយកដំបងរង ។
អ្នកទាំងពីរក៏ប្រវាយប្រតប់គ្នាឡើង ។ រីនាយសៀកក៏ហក់រឹងចូលក្នុងបន្ទប់រកស្រវាចាប់នាងអារី
តែក៏ត្រូវ រាសីលួចប៉ែងជើងដួលគ្រេងទៅម្ខាង ។ ខឹងណាស់ នាងសៀកដើប ឡើង
ស្ទុះរឹងទៅរកដាល់តប់រាសី តាមទំហំកំហឹងរបស់ខ្លួន ស្រាប់
តែមានដៃមួយមករងជំនួសហើយជើងមួយទៀត មកប៉ែងខ្លួននាយ
សៀកដួលភីងផ្កាប់មុខលើដីប្រឡាក់ស្រមក ។ រាសីស្ទុះដើបឡើង សម្លឹងមុខជននោះ
ស្រាប់តែបើកភ្នែកធំៗដោយក្តីត្រេកអរ ព្រោះ
នោះមិនមែននរណាក្រៅពីសយនាដែលធិតាកំពុងតែនឹករលឹកនោះ ឡើយ ។
បុរសយើងក៏ហក់រឹងទៅជួយរក្សា ហើយក៏ផ្តួលនាយឆ្មាំ ម្នាក់នោះទៅដីព្រួស
តែក្នុងមួយពព្រិចភ្នែក ។
- អ្នកទាំងពីរឆ្លងហួសព្រំដែនការងាររបស់ខ្លួនហើយ ។ កិច្ចការជា ឆ្មាំរោងចក្រ
ធ្វើនៅក្នុងរោងចក្រ កុំស្ពាយការងារចេញមកដល់ក្រៅ
រំខានអ្នកស្រុកដល់ផ្ទះរបស់គេបែបនេះទៀត! (វាសនាគំហក) យ៉ាងម៉េច ?
ខំធ្វើការយកចិត្តចៅហ្វាយបរទេស រហូតហ៊ានជិះក ខ្មែរដូចគ្នាហើយមែនទេ ?
នាយសៀកដើយសម្លឹងឃើញមុខវាសនាភ្លាម ក៏ឧទានថា ៖
- លោកវរសេនីយ ?

CHANBOKEO.COM

- មែនហើយ គឺយើង! យ៉ាងម៉េចដែរ ? ចង់តវ៉ាអ្វីទៀត ?

នាយសៀកក្រោកឡើងធ្វើអេះអុញ រួចហើយក៏នាំគូកនគេច ចេញទៅយ៉ាងរហ័សតែម្ដង ។ រាសីក៏ស្ទុះទៅលើករក្សាឡើង រួច ហើយក៏បែរញញឹមដាក់សយនាដោយដួងចិត្តសោមនស្សដែលនាយ បានចេញមុខមកជួយនាងនិងប្អូនទាន់ពេលវេលា ។ ចៃដន្យ នរៈ យើងបែរជាឈ្លោកមុខដើរចេញទៅវិញស្ងៀមស្ងាត់ មិនឃើញមាន វាចាអ្វីជាមួយនាងមួយម៉ាត់ទេ ប្រហែលជាគេនៅអាក់អន់ស្រពន់ ចិត្តហើយ ដែលកាលពីថ្ងៃមុន នាងបានគំហកអោយគេធ្ងន់ៗ ។ ឃើញបងស្រីធ្វើមុខទំនងខកចិត្ត រក្សាចាប់ភ្លឹកថាមានអ្វីខុសធម្មតា រវាងអ្នកទាំងពីរ ។ គេក៏គេចខ្លួនចូលទៅក្នុងផ្ទះបាត់ទៅ ទុកអោយ រាសីឈរធ្មឹងធ្មៃតែម្នាក់ឯង មិននិយាយស្ដី...

ការពិត រាសីចង់ហៅសយនាណាស់ តែនាងហារមាត់មិនរួច ត្បិតហាក់ដូចជានឹកខ្មាស់មាត់យ៉ាងណាមិនដឹង ។ ធម្មជាតិរបស់នាង គឺជាអ្នកបានមាត់បានក មិនចេះខ្លាចនរណាទេ តាំងពីដើមមក ប៉ុន្តែ ហេតុអ្វីពេលនេះ នាងបែរជាកកអណ្ដាតនិយាយមិនរួចទៅវិញ ?

បន្តិចមក នាងក៏ដាច់ចិត្តដើរចេញតាមច្រកតូចសំដៅទៅថ្នល់ ធំ តាមរកសយនាភ្លាម ។ មកដល់គល់ចាមរី ក្បែរមាត់ច្រកចូល រាសីបានឃើញស្រមោលបុរសនៅឈរអោបដៃ ផ្អែកខ្លួននឹងដើម ឈើធ្វើកិរិយាស្ងៀមស្ងាត់ ។ តាមផ្លូវនៅមានចរាចរនៅឡើយ ប៉ុន្តែ គ្មាននរណាគេចាប់ភ្លឹកនឹងវត្តមានបុរសម្នាក់ ដែលឈរស្ងៀមទីនោះ ទេ ។ គ្រាន់តែក្រឡេកឃើញស្រមោលនោះភ្លាម រាសីក៏ចំណាំបាន ថា នោះគឺជាសយនាប្រាកដណាស់ ។ នាងទុចដំណើរដ៏ក់ ឈរ ស្ងៀមយ៉ាងយូរ ។ ភ្លាមនោះ គេក៏បែរមុខមកចំនារីយើង ស្រាប់តែ គេភ្ញាក់ក្រញាង ត្បិតមិននឹកថានារីដើរតាមពីក្រោយរូបគេមក ។ គេក៏ធ្វើមុខញញឹមបន្តិច រួចស្រាប់តែទម្លាក់ទឹកមុខមកវិញយ៉ាង រហ័ស ហើយគេចមុខចេញពីនាងសាជាថ្មី ។

រាសីឈរចាំមួយស្របក់ហើយ នរៈនៅតែឈ្លោកមុខមិនស្រដី រកនាងដដែល ។ បន្តិចមក គេបែរខ្លួន ទំនងដូចជាបំរុងនឹងបោះ ជំហានចេញទៅ.. រាសីភ្ញាក់ព្រើត ញាប់ញ័រក្នុងដើមទ្រូងយ៉ាងណា មិនដឹងទេ ដែលឃើញសយនាបំរុងដើរគេចរូបនាងទៅទៀត ។ មាណវីក៏ដាច់ចិត្តឧទានហៅនរៈយើងថា ៖

- បងសយនា...!

CHANBOKEO.COM

ភ្លាមនោះ សយនាទុចដំណើរដ៏ក់តែម្តង ។ មែនហើយ! រាសី មិនដែលហៅគេថា បង ម្តងណាទេ ។ នាងទម្លាប់ហៅថាល្បងៗ ដូចប្រុសៗហៅគ្នាអញ្ចឹង ។ ពេលនេះ... នាងបែរជាប្រើពាក្យ បង យ៉ាងផ្អែមល្ហែម ធ្វើអោយនរៈចាប់ភ្លឹកភ្លាមតែម្តង ។ គេងើបមុខឡើងបែរក្រោយសម្លឹងភក្ត្រធិតា ។ ភាពញញឹមមួយបានលេចធ្លោមកលើផ្ទៃមុខរបស់នរៈដូចទេវតាជប់ដូច្នោះឯង ។ រាសីឃើញ ដូច្នេះក៏នឹករអៀសខ្លួនយ៉ាងណាមិនដឹងទេ ប៉ុន្តែខំកាត់ចិត្តធ្វើពើជា មិនញាប់ញ័រក្នុងចិត្ត ហើយតាំងចិត្តក្លាហានស្រដីទៅនរៈបន្តថា ៖

- បង មិនចូលលេងពួកយើងទេ ?

នរៈឈរសម្លឹងមុខរាសីយ៉ាងយូរ ទើបស្រដីសួរថា ៖

- ចុះរាសីវិញ មិនទើសទាល់នឹងវត្តមានរបស់បងទេហ៍ ?

រាសីគ្រវីក្បាល ហើយឆ្លើយថា ៖

- អត់ទេ... ហេតុអ្វីបងមកដល់ហើយ មិនចូលលេងអញ្ចឹង ?
- គឺ... មកពីបងខ្លាចចិត្ត...
- ខ្លាចធ្វើអី ?
- ខ្លាចធ្វើអោយរាសីខូចអារម្មណ៍...
- នរណាថា ? ការពិត រាសីពិតជាខូចអារម្មណ៍ប្រាកដណាស់ បើ សិនជាបងមកហើយ មិនចូលលេងពួកយើង ។

ពូដូច្នេះ សយនាសម្តែងនូវភាពរីករាយលើផ្ទៃមុខភ្លាម ៖

- ហើយចុះ រាសីញ៉ាំបាយហើយនៅ ?
- ចាស! នៅទេ!
- អញ្ចឹង មានអីចែកបងមួយចំណែកទេ ? បងកំពុងហេវណាស់!
- បើចំណីល្អៗ គ្មានទេ មានតែបាយស្រូបប៉ុណ្ណោះ បងយកទេ ?
- ឲ្យតែជាបាយបរិសុទ្ធដោយសទ្ធា បងមិនដែលប្រកែកឡើយ!

រាសីក៏ញញឹមដាក់នាយឡើងវិញជាថ្មី ។ បន្តិចមក អ្នកទាំងពីរ ក៏នាំគ្នាដើរត្រឡប់ក្រោយ ។ រំពេចនោះ ស្រាប់តែនរៈស្រដីថា ៖

- អោយបងសុំកាន់ដៃផងបានទេ រាសី ?

CHANBOKEO.COM

រាសីភ្ញាក់ព្រើត នឹកខ្មាសនរៈនៅក្នុងចិត្ត ក្តៅមុខក្តៅមាត់ ភាយៗតែម្តង ។ លុះឃើញឆវីនៅស្ងៀម គេក៏មិនហ៊ានចាប់ដៃ នាងកាន់ដែរ គ្រាន់តែដើរឈ្ងោកៗ តាមពីក្រោយរហូតដល់ផ្ទះ ។ នៅទីនោះ រក្សានិងសាវរីកំពុងតែអង្គុយលេបទឹកមាត់ក្អឹកៗ សម្លក់ចានបាយ រង់ចាំអ្នកទាំងពីរ ។ គ្រាន់តែក្រឡេកឃើញប្រុសកម្លោះ សាវរីបើកភ្នែកគ្រលួងឡើង ឈប់ទទួលទានអាហារភ្លាម ហើយក៏ ក្រោកគេចយកក្រមាទទូរមុខភ្លាម ត្បិតនឹកខ្មាសដែលខ្លួននាងមាន សោភ័ណពិបាកអោយបុរសឃើញពេក ។ សយនាលួចមើលនាង ហើយសួររាសីថា ៖

- គេជាបងស្រីរបស់អ្នកទាំងពីរ មែនទេ ?

រាសីបែរមើលសាវរីហើយងក់ក្បាល ៖

- បងស្រីជាកម្មកររោងចក្រដូចគ្នា អត់ផ្ទះជ្រក ក៏នាំគាត់មកជ្រកទី នេះបណ្តោះអាសន្នសិន ទំរាំគាត់រឹងដៃរឹងជើង ។

សយនាចាប់ស្លាបព្រាទំពារបណ្តើរ ពិភាល់ក្នុងចិត្តបណ្តើរ ។ មួយសន្ទុះធំក្រោយមក ក្រោយពីបាយរួច គេក៏លាម្ចាស់ផ្ទះត្រឡប់ ទៅវិញ ។ ពេលប៉ុនោះ រាសីមានអារម្មណ៍រីករាយក្នុងចិត្តណាស់ ក៏នឹកភ្ជក់ដើរជូនបុរសយើងដល់ថ្នល់ធំ ។

- អរគុណរាសី ចំពោះបាយពិសេសមួយពេលនេះ (នរៈវាចា)

- គ្រាន់តែជាបាយដួសសម្លដួសរយទេតើហ៎ មានអ្វីពិសេសទៅ ?

- ម៉េចក៏ថាមិនពិសេសកើត ? គឺបាយនោះមានលាយមន្តស្នេហ៍ យ៉ាងផ្អែមត្រជាក់ដល់បេះដូងរបស់បងតែម្តង ។

- និយាយតែផ្តាស !

- បងនិយាយពិតមែនណា៎ ! មិនផ្តាសទេ ។

- បើបងសយនានិយាយរបៀបនេះ ខ្ញុំទៅផ្ទះវិញហើយ ។

អៀនណាស់ ធិតាក៏ដើរបកក្រោយវិញយ៉ាងលឿន ទុកឲ្យនរៈ ឈរញញឹមពីក្រោយដោយដួងចិត្តរំភើបកាលបើបានដឹងថា មាណវី ក៏មានចិត្តរំភើបចំពោះរូបគេមិនខុសគ្នានឹងអារម្មណ៍របស់គេចំពោះ នាងប៉ុន្មានដែរ ។ រំពេចនោះ រាសីនឹកឃើញអ្វីម្យ៉ាង ក៏បែររក សយនាដែលកំពុងឈរសម្លឹងរូបនាងពីក្រោយយ៉ាងភ្លន់ភ្លឹក...

- សុំពឹងមួយបានទេ បងសយនា ? (រាសីសួរ)

- រឿងអ្វីទៅ រាសី ?

CHIANBOKEO.COM

- គឺបងអារីនោះអី ? ថ្ងៃនេះ គាត់ប្រវាយប្រតប់គ្នា ជាមួយនាយ ចំណាត់ការនៅរោងចក្រ បានរាលកែកំភ្លើងត្រូវនាយចំណាត់ការ ឈ្មោះ សារ: ។ ពេលនេះ គាត់អត់ការធ្វើផង កំពុងបណ្តាច់ថ្នាំ ញៀនផង មានសតិស្មើរៗផង ហើយខ្ញុំនិងរក្សាក៏ត្រូវទៅធ្វើការ ដែរ តើខ្ញុំគួរតែរកមធ្យោបាយអី កុំអោយគេរករឿងគាត់បានទេ ? ម្យ៉ាង ខ្ញុំចង់អោយគាត់ត្រឡប់ចូលធ្វើការស្អែកនេះវិញផង ។

សយនាគិតមួយស្របក់ ក៏ងក់ក្បាល ៖

- អញ្ចឹង ព្រឹកស្អែកនេះ យើងជួបគ្នានៅមាត់ទ្វាររោងចក្រ មុន ពេលចូលធ្វើការ ។

ធិតាក៏លើកដៃបក់បោយលាមាណពត្រឡប់ក្រោយវិញ ។ ទាំង គូញញឹមដាក់គ្នាយ៉ាងផ្អែមល្ហែមមានន័យជាលើកដំបូង មិនខុសពីផ្កា ដែលកំពុងត្រូវទឹកសន្សើមអម្រិតនោះឡើយ ។

យប់នោះ រាសីបានចាប់ក្រឡុកសាវីបង្អុកថ្នាំផង ចាក់ថ្នាំផង តាមវិធីដដែលសាជាថ្មី ថ្មីបើសាវីខំរើបម្រះយ៉ាងណា ក៏មិនឈ្នះដៃ ក្រមុំជនបទដ៏រឹងមាំនោះបានឡើយ ។

ព្រហាមឡើង...

រាសីនាំសាវីមកដល់រោងចក្រ ស្រាប់តែជួបនាយសៀកនិង ពពួកដៃជើង កំពុងឈរអោបដៃ ទំនងរង់ចាំវត្តមានរបស់នាងនិង សាវីដូច្នេះឯង ។

- អីយ៉ា ស្រីល្អ ? ដើរចូលមកអោយយើងជរះដោយខ្លួនឯងដូច្នេះ ប្រសើរហើយ ។

- នែ៎ ពូសៀក! ខ្ញុំមិនមែនជាអ្នកបង្ករឿងទេ កុំលេងម៉ៅ!

រាសីឆ្លើយ ហើយដើរចូលទៅក្នុងរោងធ្វើការបាត់ទៅ ទុកឲ្យ សាវីនៅដោះទ័លដោយខ្លួនឯង ។ ស្រាប់តែសាវីស្រដីថា ៖

- នាយសៀក! ឯងមើលយើងមិនស្គាល់យើងទេ ? នេះជាសាវី ប្អូនស្រីរបស់បងសារ: កូនចៅកែសារាយណា៎!

- ហា៎សៗ! (នាយសៀកនិងកូនចៅសើចលាន់ឡើង) មុខសំគិះ បែបហ្នឹងហ្ន៎ស ជាអ្នកនាងសាវី ? ដេកយល់សប្តិភ្ញាក់បីដងទៀត ក៏មិនអាចទៅរួចដែរ ។ អ្នកនាងសាវីបានចេញបរទេស ជាមួយ លោកជិនហួបាត់ទៅហើយ ។ មុខដូចនាង ត្រឹមតែជាកម្មកររោង ចក្រនោះ ដូចជាខ្ពស់ពេកផងសំរាប់នាងនោះ នាងចំកួតអើយ!

ឮពាក្យចំអកនេះ សាវីខឹងណាស់ ក៏យារដៃទះកំភ្លៀងនាយ សៀក តែត្រូវនាយចាប់ជាប់ ហើយគ្រវីនាងច្រានថយក្រោយដួល ប្រូសទៅដីភ្លាម ហើយស្រដីថា ៖

CHANBOKEO.COM

- នាងបាញ់លោកសារៈម្សិលមិញ យើងមិនទាន់ចាប់ដាក់ទោស ផង ពេលនេះ
ចង់មករកថែមថ្នាំខ្លាំងថែមទៀតឬអ្វី ?

- អាហ្ហ៊ឹម ! (សម្លេងគ្រហែមមួយលាន់ឡើង)

នាយសៀកដើបបែរមើល ស្រាប់តែឃើញមេកងប៉ូលីសបីបួន រូបមកដល់ទីនោះ ។ នាយភ្ញាក់ក្រញាងដូចគេចាប់គ្រវែង ៖

- មានការអ្វីឬ លោកអធិការ ?

- យើងបានពាក្យបណ្ដឹងពីកម្មករថា មានការរំលោភបំពានសិទ្ធិ នារីភេទនៅក្នុងរោងចក្រនេះ ទើបយើងយកដីការមកស៊ើបអង្កេត ឥឡូវនេះ យើងបានប្រទះស្ថានការណ៍មួយដោយ ផ្ទាល់ភ្នែកមួយ ហើយ មានអ្វីដោះសារទេ ?

នាយសៀកខាំធ្មេញក្រឹត ដកដៃវិញយ៉ាងរហ័ស ៖

- ផ្ញើទុកម៉ាពេលសិនចុះ ! (នាយសៀកគំហកខ្សឹបៗដាក់សាវី)

សាវីងាកក្រោយភ្លែត ក៏ស្គាល់ភ្លាមថា នោះគឺជាលោកអធិការ សយនាដែលនាងបានជួបកាលពីម្សិលនៅផ្ទះរាសី ។ មើលចុះ ! ថ្ងៃនេះ គេសង្ហាណាស់ កាលបើគេស្ថិតនៅក្នុងឯកសណ្ឋានជានាយ កងប៉ូលីស ។ កាលពីម្សិលមិញ សាវីមិនសូវជាចាប់អារម្មណ៍លើ រូបគេប៉ុន្មានទេ តែថ្ងៃនេះ នាងហាក់ដូចជាមានអារម្មណ៍ថា បុរស ម្នាក់នេះមានស្នេហ៍ជាងជិនហ្វូងសង្ហារបស់នាងនោះ ឆ្ងាយណាស់ ។

អធិការសយនាបែរទៅសាវីហើយស្រដីថា ៖

- សូមអ្នកនាងត្រឡប់ទៅធ្វើការតាមកន្លែងរបស់ខ្លួនវិញចុះ ។

- នាងទៅមិនទាន់បានទេ លោកអធិការ ? (នាយសៀកឃាត់)
លោកត្រូវតែចាប់ចងឃាត់ឃុំខ្លួននាងម្នាក់ផង ។

- អូហ៍ ហេតុអ្វីទៅ លោកឆ្មាំ ?

- គឺមកពីនាងបានលើកកាំភ្លើងបាញ់លោកសារៈអោយរបួសកាលពី ម្សិល
ហើយលួចរត់គេចខ្លួនទៅនោះអី !

- ប៉ុន្តែ លោកសារៈមិនទាន់ដាក់ពាក្យបណ្ដឹងទេ ដូច្នេះយើងមិន អាចឃាត់ខ្លួននាងបានឡើយ ។
សូមទោសផងណា៎ !

នាយសៀកធ្វើមុខស្មឿក ទំនងខកចិត្តកាលបើប៉ូលីសមិនព្រម ធ្វើតាមពាក្យនាយ ។ សាវីសម្លឹងមុខនរៈ ហើយក៏ដើរចេញទៅ ។ នៅទីមួយ មិនឆ្ងាយពីនោះប៉ុន្មាន

CHANBOKEO.COM

រាសីលួចឈរសម្លឹងឃើញគ្រប់ ស្ថានការណ៍
ថែមទាំងលួចនឹកឃ្នាន់ខ្នាញ់នឹងក្រសែភ្នែករបស់សាវរី
ដែលសម្លឹងនាយអធិការមិនពព្រិចនោះដល់ស្ងួរហើយ ។

ព្រឹកនេះ រាសីមិនឃើញជិនហួ ឬសារៈចូលមកការិយាល័យ ទេ ។ រីឯនាយសៀក ជាមេកោយទ្វារបាល និងកងតម្រួតសន្តិសុខ ប្រចាំរោងចក្រវិញ ក៏ហាក់ដូចជាពង្រញដៃជើង មិនសូវជារពឹស វាត់នាយវាត់អាយដូចរាល់ថ្ងៃដែរ ។ បន្តិចមក ពពួកកងប៉ូលីសក៏ នាំគ្នាចេញទៅវិញ ។ ឃើញក្រុមប៉ូលីសចេញបាត់ នាយសៀកបាន ដៃក៏ស្រែកវ៉ាងៗ ថា ៖

- ឪ៊ុយ អាពួកមាត់វែងមាត់ខ្លី! យើងមិនអោយឯងរួចខ្លួនងាយៗ ទេឪ៊ុយ! ចាំតែលោកជិនហួនិងលោកសារៈត្រឡប់មកវិញ ពួកឯង នឹងបានដឹងសខ្មៅហើយ ។ កុំស្មានថាពួកឯងស្គាល់ក្រុមប៉ូលីសអស់ ហ្នឹងហើយ អាចមកអង្រួនទីនេះ បានស្រេចតែចិត្តនោះឪ៊ុយ!!

កម្មកររោងចក្រទាំងប្រុសស្រី នៅក្នុងរោងការងារ លួចចោល កន្ទុយភ្នែកដាក់គ្នា ហើយញាក់មុខ តែមិនមាននរណានិយាយតបអ្វី នឹងនាយសៀកទេ ។ រាសីចោលកន្ទុយភ្នែកលួចមើលសាវរី ឃើញ នាងសម្តែងកិរិយាធុញថប់ក្នុងចិត្តក្រៃលែង ។ ថែមទៀត រាសីមិន ដែលនឹកចង់ធ្វើអន្តរាគមន៍ទេ ព្រោះកំពុងចង់អោយសាវរីរៀនភ្លក្ស រសជាតិជីវិតដោយផ្ទាល់ខ្លួនរបស់នាងតែម្តង ដោយមិនបាច់មាន នរណាពន្យល់ឲ្យនាងដឹងថា ជាតិជាអ្នកក្រ តើត្រូវពពួកអ្នកមាន និងពួកហែហមអ្នកមានទាំងនោះជិះជាន់ធ្វើបាបយ៉ាងណា ។

ពេលនេះ រាសីបែរសម្លឹងនាយសារៈនិងជិនហួដែលជាម៉ូយបន្ត បន្ទាប់តទៅទៀត ដែលនឹងត្រូវភ្លក្សរសជាតិជីវិតថ្មី ឆាប់ៗនេះ ។

oooooooooooooooo

ooooo

o

# វគ្គទី៦
## រាសីស្រីស្នាត

ពីរថ្ងៃកន្លងទៅនេះ សាវរីបានទទួលរសជាតិជីវិតដ៏ប្រៃល្វីងជូរចត់របស់កម្មការិនីរោងចក្រនោះ ពេញទំហឹងតែម្តង ។ ល្ងាចនេះឆវីយើងដើរសឹងតែមិនដល់ផ្ទះ ។ ណាមួយ រាសីបានធ្លាក់កៀប ស្ថានការណ៍មិនឲ្យសាវរីមានក្រឡាកម្រើករើរួចអីបន្តិច ។ ដែល គួរអោយខ្លាចបំផុតនោះគឺរូបភាពនិងឈ្មោះសាវរីត្រូវទៅនៅទំលើ ទំព័រទីមួយរបស់កាសែតប្រចាំប្រទេសដែលនឹងផ្សាយថានាងមាន មេរោគអេដស៍ជាប់ខ្លួន ។ ធិតាីលួចគិតចាក់ស្មុគ្រថា ៖

- ហេតុអ្វីមីច្រមក់កូនអ្នកជនបទម្នាក់នេះ វាមានប្រាជ្ញជាងយើង ដូច្នេះ ?
ហេតុអ្វីយើងរកនឹកមធ្យោបាយ តដៃវាវិញមិនរួចសោះ ?
ម៉េចក៏រាសីយើងធ្លាក់ត្រដាបដល់ថ្នាក់ហ្នឹងផង ? តើវានឹងព្រលែង យើងវិញនៅថ្ងៃណា ?
ហើយបើសិនជាយើងរត់រួចខ្លួនមកវិញ តើ យើងត្រូវធ្វើយ៉ាងណាដើម្បីសងសឹកចំពោះការដែលនាងធ្វើអំពើ រហេមរហាមលើយើងដោយមិនអោយបាក់មុខខ្លួនយើងដែលមក ធ្លាក់ក្នុងកណ្តាប់ដៃរបស់វាអោយវាញាក់យើងជាតួស្វាលេងសើច ?

កាលដើម សាវរីចូលចិត្តដើរបាត់ៗឃើញៗតាមតែទំនើងចិត្ត តាំងតែពីយូរមកហើយ ត្បិតអាងមានលុយចាយមិនអស់ ណាអាង ខ្លួនជាកូនស្រីពៅ ធ្វើអ្វីតាមតែទំនើងចិត្តគ្មាននរណាមានសិទ្ធិ ហើបមាត់ប្រដៅ ម្ល៉ោះហើយការបាត់ខ្លួនរបស់នាង ប៉ុន្មានថ្ងៃនេះមិនបានអង្រួនចិត្តនរណាអោយគេនឹកចាប់ភ្លឹក ចេញមុខតាមរក នាងទេ ។ ម្យ៉ាងទៀតជិនហ្បូជាសង្សាររបស់នាង បានចេញទៅ ស្រុកក្រៅពីរថ្ងៃ ។ គេរាល់គ្នាក៏គិតច្រឡំស្មានថា

CHANBOKEO.COM

នាងចេញទៅ ជាមួយជិនហួដែរ ។ នោះប្រហែលមកពីរាសីរបស់នាង កំពុងតែ
អណ្តែតចុះត្រដាបពិតមែនទេនឹង ?

នៅព្រឹកបន្ទាប់...

សាវរីបានស្រកភ្នែកជញ្ជីងស្ទើរតែអស់រលីងពីខ្លួន ។ មុខមាត់
របស់នាងប្រែរជាស្លេកស្លាំងមើលមិនយល់ ត្រូវនឹងអត់ក្រែមម្សៅ ជួយយោងទៀត
មើលទៅយ៉ាប់ជាងនារីអ្នកក្រស្រាប់ ដល់ទៅរាប់ សិបដងឯណោះ ។
ចំណែកដៃជើងវិញរញីរញ៉ូរមិនខុសពីដូនចាស់ ឡើយ រហូតកាន់ចានស្លាបព្រាស្ទើរតែមិនជាប់ ។
ពេលនេះ ទោះបី ចង់តដៃរាសី ក៏សាវរីលើកដៃលែងរួចដែរ ។ នេះហើយជីវិតរបស់
កម្មការិនីក្រីក្រ! គឺវាទន់អស់ដៃជើងដូច្នេះឯង កាលបើធ្វើការហួស
កម្លាំងហើយបរិភោគមិនគ្រប់ ។ តើសាវរីនឹងយល់ហើយ ខ្លាចរាង ចាលជីវិតបែបនេះឬទេ ?
ឬក៏នាងនៅតែប្រឹងខំរកនឹកមធ្យោបាយ កម្លៅណាមួយ មកសងសឹករាសីវិញដដែល ?

រាសីនិងរក្សាមិនដែលបរិភោគអាហារពេលព្រឹកឡើយ ព្រោះ គេមិនសូវមានប្រាក់ចាយវាយ
ដូច្នេះ ព្រឹកនេះ សាវរីក៏ត្រូវអត់ ពោះទទេដូចគ្នា គ្មានអ្វីបន្តិចទ្រាប់បាតសាលាសោះ ។
នៅក្នុងរោង ការងារ សាវរីធ្វើការបណ្តើរ កួរពោះហេវបាយបណ្តើរ ញ័រដៃ
ញ័រជើងដាំខ្សែវខុសបណ្តើរ ជួលកាលរហូតដល់ម៉ាស៊ីនគប់ត្រូវដៃ ឈឺស្លេកមុខបណ្តើរក៏មានដែរ ។
នោះហើយជារសជាតិពិត នៃជីវិត កម្មកររោងចក្រ ។ សាវរីអើយ ទ្រាំៗតាមកម្មទៅ!!

សំណាងល្អ នៅថ្ងៃដដែលនោះ ពួកការិយាល័យរោងចក្របាន ឲ្យកម្មករឈប់ធ្វើការកន្លះថ្ងៃ
មកជួយរៀបចំពិធីជប់លៀងដ៏ធំមួយ ទទួលសមាជិកគ្រួសារនិងមិត្តភក្តិរបស់ជិនហួ
ដែលត្រូវចុះមក មើលដំណើរការណ៍រោងចក្រកាត់ដេររបស់គេ នៅស្រុកខ្មែរនេះ ។
ពួកគេក៏បានរៀបចំវេទិកាទទួលយ៉ាងអឹកធឹក ថែមទាំងមានចាត់
ចែងកម្មករស្រីប្រុសប្អូនដប់នាក់ចូលទៅតុបតែងខ្លួនឲ្យស្រស់ស្អាត សង្ហា
ដើម្បីចេញមុខជូនកម្រងផ្កាដល់ភ្ញៀវកិត្តិយសទាំងនោះទៀត ផង ។
សាវរីមានកិរិយាច្រាស់ច្រាល់ណាស់ ព្រោះនោះគឺជាវេលាដ៏ វិសេសបំផុត
សំរាប់នាងបង្ហាញមុខមាត់ និងរាងសិចស៊ីរបស់ខ្លួន ទន្ទឹមនឹងជិនហួ ។ ចង្រៃអើ
អ្នកទាំងឡាយនៅក្នុងរោងចក្រជិនហួ
បែរជាស្គាល់ឆវីត្រឹមតែសាវរីកម្មការិនីដាំខ្សែវអាវតែប៉ុនហ្នឹង ។ តើ
នាងត្រូវធ្វើដូចម្តេចនឹងអោយគេចាប់អារម្មណ៍មកលើរូបនាង ?

រំពេចនោះ សាវរីបែរមើលជុំវិញខ្លួន ស្រាប់តែបាត់រាសីទៅខាង ណាមិនដឹង ។ សាវរីធូរទ្រូងខ្សាក ខំរកនឹកវិធីសំរាប់បង្ហាញខ្លួន នាងជាសាវរីដូចដើមវិញ ។

នៅក្នុងបន្ទប់ទឹកស្រី សាវរីខំយកសាប៊ូដុសលាងជំរះនូវជាតិថ្នាំ ដែលជិតជាប់លើស្បែកមុខ ។ គ្រោះមិនល្អ សាប៊ូនោះបានធ្វើឲ្យ ស្បែកមុខនាងក្រហាយដូចត្រូវម្ទេស រោលមុខហើមស្តុរ រិតតែពិបាកមើលលើសដើមទៅទៀត ។ សាវរីក៏រត់គេចចេញមកក្រៅ ដើរលបៗចូលការិយាល័យ លួចកាបូបរបស់ស្រីម្នាក់ បំរុងឆែក យកក្រែមម្សៅរបស់គេមកលាប ស្រាប់តែ... ផាំង! សាវរីត្រូវបាត

ដៃមួយ ទះកំភ្លៀងនាងវិលខ្វាល់ដួលផ្ទប់ទៅហ្នឹងជញ្ជាំង ៖

- យើ! មានដៃមានជើងផងហ្នឹងនាងល្អ ?

សាវរីបែរមើល ឃើញជានារីមួយរូបអាយុស្របាលនាងដែរ ជាអ្នកធ្វើការនៅក្នុងការិយាល័យរោងចក្រនោះ ។ នារីនោះក៏លើកដៃចង្អុលមុខសាវរីហើយដៀលបន្ថែមថា ៖

- មុខចោរយ៉ាងនេះ រោងចក្រមិនស្វាគមន៍ឡើយ ។

ភ្លាមនោះ ឆ្មាំតម្រួតរោងចក្រពីរនាក់បានមកដល់មាត់ទ្វារ ៖

- មានរឿងអ្វីអ្នកនាងណារេន ?

នារីនោះក៏ស្រែកឡើងថា ៖

- សូមចាត់ការនារីម្នាក់នេះផង! ថ្ងៃនេះ លួចចូលការិយាល័យ មានដៃមានជើង ត្រូវអោយថ្នាំខ្លាំងធីកខ្លះ!

សាវរីរឹងខ្លួនស្ដូក ដែលនាងត្រូវធ្លាក់ខ្លួនជាចោរ ហើយត្រូវគេ ចាប់បាន មិនដឹងថា នាងនឹងទទួលទោសបែបណាឡើយ ។ បន្តិច មក សាវរីត្រូវគេចងមាត់ចងដៃទុកមួយកន្លែង ទំរាំកម្មវិធីចប់ នឹង អាលមកចាត់ការនាងវិញ ។

នៅលើវេទិកាដែលទើបនឹងរៀបចំហើយកណ្ដាលទីធ្លារោងចក្រ ជិនហួមានមុខមាត់ញញឹមស្រស់ណាស់ ។ គេកាន់ក្បាលយោនសព្ទ វាចាឡើងទៅកាន់កម្មកររាប់រយរាប់ពាន់នោះថា ៖

- អរគុណណាស់ដែលអ្នកទាំងអស់មកចូលរួមជូនពរយើងថ្ងៃនេះ! ពេលនេះ ខ្ញុំសូមបង្ហាញនូវសមាជិកគ្រួសាររបស់ខ្ញុំមកពីស្រុកចិន..

ពេលនេះ នាយសារៈផុសចេញពីខាងណាមកមិនដឹង ក៏បាន មកដល់ចូលរួមពិធីទីនោះដែរ ដោយមានកាន់ឈើច្រត់ទប់ខ្លួនផង មើលទៅរបួសនៅលើជើងរបស់នាយពីគ្រាប់កាំភ្លើងម្សិលមិញ មិន ជាធំដុំប៉ុន្មានទេ ព្រោះគេនៅអាចដើរបានដោយខ្លួនឯង ។ ចំណែក នាយសៀកវិញឃើញរត់ ហោចុះ ហោឡើង ផ្គាប់ផ្គុននាយសារៈផង ផ្គាប់ផ្គុនជិនហ្វួផង ហើយក៏ខំយកចិត្តក្រមុំការិយាល័យស្អាតៗពីរបី នាក់ដែលឈរក្បែរនោះទៀតផង ។

រំពេចនោះ នារី១០នាក់ក្នុងសម្លៀកប្រពៃណីខ្មែរល្អស្អះ បាន មកដល់មុខវេទិកាជាមួយនឹងថាសកម្រងផ្កាម្លិះដ៏ស្រស់ស្អាតបំផុត... គ្រាន់តែក្រឡេកឃើញនារីដែលឈរមុខគេ មានកេសាខ្មៅរលើប វែងអន្លាយ ទឹកមុខញញឹមស្រស់បំព្រង កំពុងកាន់កម្រងផ្កា ដើរ ពើងទ្រូងយ៉ាងក្លាហាន ឡើងមកលើវេទិកាសំដៅមករកខ្លួន ជិនហ្វួ ក៏បើកភ្នែកធំៗ សម្លឹងទៅមាណវីវិញមិនព្រិចឡើយ ។ គេចំណាំ បានថា គេហាក់ដូចជាធ្លាប់ឃើញធិតានៅកន្លែងណាមួយ តែគេរក នឹកមិនឃើញសោះ ។ ភ្លាមនោះ នារីក៏ញញឹមដាក់ជិនហ្វួ ហើយក៏ លើកកម្រងផ្កាជូនថៅកែ ម្ចាស់រោងចក្រ ព្រមទាំងស្រដីថា ៖

- សូមស្វាគមន៍លោកជិនហ្វួ!

ជិនហ្វួលួចនឹករំភើបក្នុងចិត្តតែម្នាក់ឯង ដែលខ្លួនបានទទួល កម្រងផ្កាយ៉ាងស្រស់ស្អាតពីនារីដ៏សែនសោភាម្នាក់ ។ គេតាមមើល នាងមិនដាច់ពីក្រសែភ្នែក ថ្វីបើនាងបានដើរត្រលប់ចុះពីវេទិកា ទៅវិញបន្ទាប់ពីសូរទះដៃដ៏រំពងនោះហើយក៏ដោយ ។ ព្រមពេល ជាមួយគ្នានោះដែរ នាយសារៈក៏កាច់កបែរសម្លឹងនារីសោភាមួយ រូបនេះ មិនដាក់ពីភ្នែកដូចគ្នា ថែមទាំងលួចជ្រួញចិញ្ចើម រួចហើយ លួចញញឹមបន្តិចៗផង ។ ជាពិសេសទៅទៀត នរណាៗដែលនៅ ទីនោះ ក៏លួចកេះគ្នា ខ្សិបសួរលាន់ៗថា ៖

- តើនាងជានរណា ? ហេតុអ្វីយើងមិនដែលឃើញមុខហ្នឹង ពីមុន មក អញ្ចឹង ?

ថៃដន្យ ពេលធិតាយើងដើរមកដល់មុខកម្មការិនីឈ្មោះសុផា នាងក៏ញញឹមឡើងហើយស្រដីថា ៖

- កុំមើលមុខខ្ញុំពេកមើល៍ បងសុផា! នេះ គ្នាឯងតើហ៍!

ស្រាប់តែសុផាលាន់មាត់ សើចខឹកៗឡើង ៖

- ពុទ្ធោ រាសីទេហ៍ ? ស្លាប់ហើយ មើលកុំឲ្យតែស្គាល់អីបន្តិច! នេះបងស្មានថាជានារីថ្មីពិសេសរបស់ជិនហ្វួទេតើហ៍ មិនដឹងថាជា គ្នាឯងឯណា ព្រះអើយ!

CHANBOKEO.COM

សុផាក៏ស្រវាអោបរាសីដោយក្តីភ្ញាក់ផ្អើលផង ដោយការរីករាយ ផងដែលមិត្តរបស់ខ្លួន បានក្លាយជានារីដ៏ស្រស់ស្អាតសោភាមួយរូប នៅឈរមុខគេបង្អស់ក្នុងជួរនារីជំរើសទាំង១០រូបនោះ ។

បន្តិចមក នារីផ្សេងៗទៀត ក៏ដើរឡើងមកបំពាក់កម្រងផ្កា ម្តងមួយៗ ជូនដល់សាច់ញាតិរបស់ជនហ្មដែលទើបនឹងមកដល់ ។ រាសីឃើញកម្មវិធីរបស់គេនោះ អឺកធឹកណាស់ ។ គេចំណាយលុយ មិនតិចទេ គ្រាន់តែតុបតែងលំអតម្រូវចិត្តថៅកែរោងចក្រ ។ នាង លួចគិតអណោចក្នុងចិត្តតែម្នាក់ឯង៖

- នាគ្រាមួយ បងប្អូនយើងឈឺ រកតែប្រាក់ទិញថ្នាំឲ្យផឹកមិនបាន ទិញបាយលៀងក្រពះអោយបានពីរពេលមិនដែលគ្រប់ ប៉ុន្តែ នៅ ឯនេះវិញ គេសំបូររហូតដល់សល់លុយខ្ជះខ្ជាយចំណាយរាប់ពាន់ ដុល្លារ សំរាប់តែបំពេញមុខគ្រួសារគេតែមួយពេល... ហ៊ឺ! គិតទៅ ពិភពលោកអយុត្តិធម៌ណាស់ ? អ្នកមានគិតរកផ្លូវកេងប្រវ័ញ្ចអ្នក ក្រសព្វបែបយ៉ាង ដើម្បីឲ្យបានដុល្លារ ទោះបីជាត្រូវដើរផ្លូវងងិត ខ្លះ ផ្លូវអមនុស្សធម៌ខ្លះ អសីលធម៌ខ្លះក៏ដោយ ក៏គេនៅតែធ្វើ ដើម្បីអោយបានចំណេញដុល្លារច្រើនៗ នឹងអាលបានយកមកចាយ វាយខ្ជះខ្ជាយបែបនេះ តើនេះហើយឬសុភមង្គលរបស់គេ ? តើជា សុភមង្គលអីទៅ កាលបើអ្នកឈរទះដៃនៅចំពោះមុខគេទាំងឡាយ នោះសុទ្ធតែជាកម្មករដែលបង្ខំរញើសឈាមសព្វបែបយ៉ាង បង្ខំរ អស់សូម្បីតែកិត្តិយសជាមនុស្ស ឲ្យគេវាយ គេសម្លុត គេចាប់ សំរាតឆែកឆេរស្រេចតែនឹងចិត្ត ដើម្បីដូរប្រាក់លាបក្រពះនោះ ?

កម្មវិធីចប់ហើយ គេគ្រប់គ្នាបំបែកជួររៀបចំត្រឡប់ទៅផ្ទះ ។ រាសីផ្លាស់សម្លៀកហើយក៏ចេញដើររកសាវរី តែមិនប្រទះសោះ ៖

- ពុទ្ធោអើយ! លួចរត់បាត់ម្តងទៀតហើយទេដឹង ? ហ៊ឺ! ពេល នេះ តើនាងបំរុងគិតមកតដៃយើងវិញឬយ៉ាងណាដែរហ្ន៎ ?

កំពុងតែឈ្ងោកដើរចេញមួយៗចេញទៅ ស្រាប់តែ...

- អេហ៍ នាង!

រាសីឮសូរសម្លេងហៅក៏ងាកមើលឃើញនាយសៀកបក់ដៃ ៖

- ឮហៅខ្ញុំហ្ន៎ស ?

- អឺ! មកនេះ! មានការនិយាយគ្នាបន្តិច!

រាសីដើរចូលតាមនាយសៀកទៅក្នុងបន្ទប់ការិយាល័យនៅជាន់ ទីមួយ ស្រាប់តែប្រទះនឹងសាវ៉ីដែលត្រូវគេចងមាត់ ចងដៃជើង ឃុំទុកនៅក្នុងការិយាល័យ ។

- អារីបងស្រីឯង លបចូលការិយាល័យ លួចកាបូបលុយអ្នកធ្វើការ ហើយត្រូវគេតាមទាន់ ។ ពេលនេះ យើងបណ្តេញនាងអោយឈប់ ធ្វើការហើយ ។ ថែមទៀត នាងនៅជំពាក់ប្រាក់របស់រោងចក្រចំនួន ២០ដុល្លារសំរាប់ថ្លៃឯកសណ្ឋានកម្មករ ។ ដូច្នេះ រាសីត្រូវរកលុយ មកសងយើងសិន ទើបយើងអាចដោះលែងអារីបងស្រីរបស់នាង អោយទៅផ្ទះវិញបាន ។

រាសីបែរមើលទៅសាវ៉ីដែលកំពុងជាប់ចំណងមាត់ និងចំណង ជើងដៃ ក៏ឆ្លើយវិញថា ៖

- ពូសៀកអ្ហា៎! ពេលនេះ សក់អ្នកណា ក្បាលអ្នកហ្នឹងហើយ ។ នរណាជាអ្នកលួច អ្នកហ្នឹងជាអ្នករកសង ។ រឿងអីបានជាបង អារី ជាអ្នកលួច តែបែរជាចាប់ខ្ញុំឲ្យសងទៅវិញ ? ខ្ញុំហាក់ដូចជាមិន យល់សោះ!
- ហ្ន៎ក! ក្រែងឯងជាបងប្អូននឹងគ្នា មិនមែនទេ ?
- ចា៎ស! គឺបងប្អូនរួមកិច្ចការ តែដុល្លារដោយខ្លួនទេ ពូអើយ!

កំពុងតែនិយាយគ្នា ស្រាប់តែជិនហួចុះពីជាន់លើមកដល់ ។ គ្រាន់តែក្រឡេកឃើញរាសីភ្លាម ជិនហួធ្វើមុខស្រឡាំងកាំង ។ មួយ ស្របក់មក ទើបគេស្រដីថា ៖

- នារីដែលបំពាក់កម្រងផ្កាអោយខ្ញុំលើវេទិកាអំបាញមិញនេះ ជា នាងមែនទេ ?

រាសីញាក់ស្មាហើយឆ្លើយថា ៖

- បើជារាសីមែន នោះវាយ៉ាងម៉េចទៅ លោកជិនហួ ?

ជិនហួញញឹម រួចហើយបែរទៅមើលនាយសៀក និងឆ្មាំពីរ នាក់ដែលឈរទីនោះ រួចស្រាប់តែដាក់ភ្នែកទៅឃើញសាវ៉ីដែល កំពុងរើបំរះក្នុងចំណងមាត់ ចំណងដៃជើង ។

- មានរឿងអ្វីហ្នឹង នាយសៀក ? (ជិនហួសួរ)
- នាងក្រមុំនេះចូលការិយាល័យលួចឥវ៉ាន់ទេ លោកជិនហួ ។ បើមានការអ្វីទៀត លោកអញ្ជើញទៅចុះ ចំណែកនាងម្នាក់នេះ ទុកអោយនាយសៀកខ្ញុំ ចាត់ការវិញ ។

ឮដូច្នោះ ជិនហួក៏បែរមករាសីហើយស្រដីថា ៖

- យើងនិយាយគ្នាពីរបីម៉ាត់បានទេ រាសី ?

CHANBOKEO.COM

- មានការអ្វីសំខាន់ឬ លោកជិនហួ ?

- គឺ... (ជិនហួបែរមើលជុំវិញខ្លួនរួចអូសដៃរាសីចេញទៅក្រៅ)

- អេហ៍ នាំខ្ញុំទៅណា ? ខ្ញុំត្រូវនាំបងអារីទៅផ្ទះសិន មិនអាចបណ្តោយអោយនៅទីនេះម្នាក់ឯងទេ ។ មើលហ្ន៎! ឆ្មាំបុរសមាឌធំៗណាស់ ។ គេអាចធ្វើទោសបងអារីយ៉ាងណាក៏បានដែរ ។

ជិនហួគិតមួយស្របក់ក៏និយាយថា ៖

- បើខ្ញុំអោយគេលែងនាងអារីទៅវិញ តើរាសីអាចចេញទៅក្រៅ និយាយគ្នាជាមួយខ្ញុំបន្តិចបានទេ ?

រាសីបើកភ្នែកធ្វើឡឹងឡង់ រួចហើយអេះក្បាល ៖

- ពុទ្ធោអើយ លោកជិនហួ! គឺមិនសមទេនឹង ដែល... ?

- មិនអីទេ អោយតែនាងថាព្រមទៅ!

- ចាំស្អែក ចាំរាសីឆ្លើយបានទេ ?

ជិនហួធ្វើមុខស្ងួតកាលបើឮចម្លើយដូច្នោះ ។ ចំណែកសាវរីវិញ ឮជិនហួសុំណាត់ជាមួយរាសីក៏រើបំរះ ទន្ទ្រាំជើងខ្លាំងៗ លាន់សូរ ក្នុងក្តាំងមួយរំពេច ។ ជិនហួឃើញដូច្នេះក៏ជ្រួញចិញ្ចើមហើយបែរ ប្រាប់នាយសៀកថា ៖

- យើងខ្ពើមនារីណាដែលមារយាទព្រហើនដូច្នេះ ដល់សូរហើយ!

នាយសៀកលែងនាងនោះអោយទៅផ្ទះទៅ ថ្លង់ណាស់!

ថាហើយ ជិនហួក៏ងាកមករាសីហើយស្រដីជាចុងក្រោយថា ៖

- ស្អែក រាសីមកជួបខ្ញុំនៅការិយាល័យបន្តិចណា៎!

រួចហើយ នរៈក៏ហក់ចូលរថយន្តបរចេញទៅ ។ បន្តិចមក នាយសៀកក៏ស្រាយចំណងអោយអារី រួចស្រដីថា ៖

- នាងសំណាងបានរួចខ្លួនពីរដងហើយ តែកុំស្មានអោយសោះថា បានរួចខ្លួន ជាលើកទីបី ។

សាវរីនឹកខ្លាញ់ណាស់ តែក៏ខ្វះសមត្ថភាពជួយខ្លួនឯងបាន ម្ល៉េះហើយត្រូវបង្ខំចិត្តដើរចេញទៅពីក្រោយរាសី ដោយមិនហ៊ានហើបមាត់អីមួយម៉ាត់ដាក់នាយសៀកសោះឡើយ ។ ប៉ុន្តែនាងតាមសម្លក់ រាសីមិនឈប់ទេ ព្រោះជិនហួផ្តល់ការចាប់អារម្មណ៍ចំពោះរាសីខុស ប្លែកធម្មតា ។

CHANBOKEO.COM

រាសីទំនងដូចជាយល់អត្ថន័យក្រសែភ្នែករបស់សាវីរី ដែលតាមសម្លក់នាង ធិតាក៏ញាក់ស្មារាំចាថា ៖

- ខ្ញុំមិនបានតែងខ្លួនសិចស៊ីមកចោលឬកអោយគេញ៉ែទេ កុំច្រឡំ!
តែបើគេដើរមកញ៉ែខ្ញុំដល់កន្លែង ខ្ញុំក៏ចេះតែទ្រាំតាមដំណើរទៅ មិនដឹងធ្វើយ៉ាងម៉េចទេ...
ប្រុសសង្ហាហើយមានទ្រព្យយ៉ាងហ្នឹង នរណាទៅទ្រាំបានលោកអើយ... ម្យ៉ាងទៀត
រវាងមនុស្សពីរនាក់ ដែលមានសោភណ្ឌធម្មជាតិ និងអ្នកដែលមានសោភ័ណសិប្បនិមិត្ត មិនដឹងថា
មួយណាមានមន្តស្នេហ៍ជាងមួយណាទេហ្ន៎ ?

ស្រដីចំអករួចហើយ រាសីដើរចេញទៅយ៉ាងព្រងើយ ទុកឲ្យ
សាវីរីដើរចេញពីក្រោយខាំធ្មេញឃ្នាន់ខ្នាញ់ ព្រោះរកវិធីតបតរាសី មិនបាន ។ នៅមុខរោងចក្រ
អ្នកទាំងពីរក៏បានប្រទះនឹងរក្សាដែល ឈរចាំគេទីនោះស្រេច ។ គេក៏នាំគ្នាដើរត្រសងចេញទៅ ។

- រាសី!

រាសីភ្ញាក់ព្រើតបែរក្រោយ ឃើញសារៈកំពុងឈរផ្អែកនឹងរថ យន្ត សម្លឹងមកនាង
ព្រមទាំងដោយក្រសែភ្នែក យ៉ាងមុតថ្លា ។

- ចាស! (រាសីឆ្លើយ)
- សុំពេលជជែកគ្នាបន្តិចបានទេ ?

រាសីខ្លាចនាយចាប់ថ្នាក់រូបរាងសាវីរីបាន ក៏តឿនរក្សាថា ៖

- ប្អូននាំបងអាវីទៅផ្ទះមុនទៅ បន្តិចបងទៅតាមក្រោយណា៎!

រក្សាក៏អូសសាវីរី ដែលកំពុងធ្វើកិរិយាឆ្លេឆ្លាៗ ចេញទៅយ៉ាង រហ័ស ។ ចៃដន្យ
សារៈធ្វើកិរិយាហាក់មិនរវល់នឹងសាវីរីដែលទើប នឹងរាលកែត្រូវជើងគេ ថ្មីៗនោះទេ ។
មាណពបែរជាផ្តោតអារម្មណ៍ ទៅលើរាសីរបស់យើងឯណោះទៅវិញ ។

- មានការអ្វីទៅលោកសារៈ ? (រាសីសួរ)
- ចេញទៅនិយាយគ្នានៅក្រៅបានទេរាសី ? ទីនេះ ថ្លង់អ៊ូអរ ពិបាកស្តាប់គ្នាណាស់ ។

រាសីសម្លឹងមុខសារៈ ហើយស្រដីថា ៖

- មិនចង់ទៅទេ ព្រោះមិនដឹងថា លោកមានបំណងល្អឬអាក្រក់...
- ក្រែងនាងជាមនុស្សក្លាហានម្នាក់ មិនមែនទេ ?
- មែន! បើសិនយើងប្រយុទ្ធតតួ ដោយកម្លាំងប្រាជ្ញ! ! ប៉ុន្តែ...
ចំពោះល្បិចអកុសលនិងការប្រើកម្លាំងបាយ ខ្ញុំមិនចូលចិត្តលេងជា មួយទេ

CHANBOKEO . COM

ជាពិសេសជាមួយអ្នកមានលុយមានអំណាចជាងខ្ញុំ ព្រោះ គេមានដៃវែងជើងវែងជាង ហើយច្រើនទៀតផង ។ ជនអត្តខាត់ ដូចខ្ញុំទៅធ្វើអ្វីដើម្បីឈ្នះគេកើត ?

- ចុះបើខ្ញុំឈប់ប្រើកម្លាំងបាយ ហើយសូមល្បងប្រាជ្ញជាមួយនាង ម្តងវិញ តើព្រមចូលសង្វៀនទេ ?

- ប្រាជ្ញដោយភាពបរិសុទ្ធ ឬប្រាជ្ញក្នុងការប្រើកលល្បិចទុច្ចរិត ?

- គឺដោយគ្មានភាពទុច្ចរិតលាយឡំទេ រាសី !

- ច្បាស់ហើយ ប្អូនស ?

- មែនហើយ !

- តើធ្វើម៉េចអោយរាសីជឿបានទៅថាលោកមិនលេងល្បិច ?

រំពេចនោះ រថយន្តថ្មីស្រឡាងមួយបានបរកាត់ទីនេះ ហើយមក ឈប់ដីក់នៅក្បែរសារៈ ។ បុរសដែលជិះខាងក្រោយទំនងជាថៅកែ

ក៏បង្អួតកញ្ចក់ចុះ ហើយអើតមុខមកនិយាយនឹងសារៈថា ៖

- អឺ សារៈ ! ល្ងាចនេះ ជួបគ្នានៅកន្លែងដដែល ម៉ោង៧ !

រាសីភ្ញាក់ក្រញាងព្រោះនោះជាថៅកែខាំងដែលជំរត់រស្មីប្អូនស្រី របស់នាងកាលពីប៉ុន្មានខែមុន ។ ថៅកែខាំងមិនបានចាប់ភ្លឹកនឹង វត្តមានរបស់រាសីទេ ឬក៏គាត់មិនចាំមុខនាងផងក៏មិនដឹង ។ ភ្លាម នោះ រថយន្តក៏បរនាំថៅកែខាំងចេញទៅវិញ ។ គ្រាន់តែឃើញមុខ បុរសចំណាស់នោះភ្លាម រាសីមានអារម្មណ៍ហាក់ដូចជាចង់តាមដាន គាត់នោះណាស់ ដើម្បីតាមសួរដំណឹងប្អូនស្រីរបស់នាង ។ ធិតាក៏ បែរមើលសារៈ ហើយស្រដីថា ៖

- នេះ បើខ្ញុំសុំអោយលោកសារៈ ណែនាំថៅកែចំណាស់មួយរូប នោះឲ្យខ្ញុំស្គាល់ផង តើបានដែរទេ ?

ស្រាប់តែសារៈភ្ញាក់ក្រញាង ៖

- ហេតុអ្វីទៅ ?

- គ្រាន់តែចង់ស្គាល់ផង មិនបានទេ ?

- បាន ! ប៉ុន្តែទាល់តែនាងសុខចិត្តទៅជាមួយខ្ញុំពេលនេះ !

រាសីឈ្ងោកមើលសម្លៀកបំពាក់ជាកម្មកររោងចក្រហើយឆ្លើយ វិញថា ៖

- ក្នុងសំបករូបរាងបែបនេះ បានទេ ?

CHANBOKEO.COM

សារៈសម្លឹងមុខនាងដោយក្រសៃភ្នែកយ៉ាងមុតមួយស្របក់មក ក៏វាចាឡើងថា ៖

- ក៏បាន!

មាណវីក៏ដើរវាងទៅម្ខាង បំរុងបើកទ្វារឡើងឡានទៅហើយ ស្រាប់តែនាងដាក់ភ្នែកទៅម្ខាងថ្នល់ ឃើញសយនាឈរយួរបាយ មួយកញ្ចប់ ក្នុងសម្លៀកស៊ីវិល សម្លឹងមករកនាង មិនដឹងថាគេបាន មកឈរវេរ៉េវង់ចាំទីនោះតាំងពីអង្កាល់ទេ ។ ភ្លាមនោះ សារៈហៅ ៖

- ឆាប់ឡើងឡានមករាសី!

រាសីនៅអេះអុញរារែក ទំនងហាក់ដូចខ្លាចចិត្តសយនា ប៉ុន្តែ ចិត្តមួយទៀត ចង់ទៅតាមរកចៅកែខាំង ដើម្បីស៊ើបដំណឹងពីរស្មី ទីបំផុត នាងត្រូវតែសំរេចចិត្តទុកអោយសយនាឈរចាំនាងនៅ ម្ខាងថ្នល់ឯណោះទាំងខកចិត្ត រួចហើយក៏ឈ្ងោកមុខ ដាក់ខ្លួនអង្គុយ ចុះ ក្បែរសារៈក្នុងរថយន្តទាំងកិរិយាទើសទាល់ ។

រថយន្តបរទៅមុខគ្រឿនៗ រាសីលួចងាកក្រោយឃើញសយនា នៅឈរធ្មឹងទីនោះដដែល... ពេលនោះ រាសីលែងមានអារម្មណ៍ល្អ តែម្ដង ។ មួយស្របក់ក្រោយមក រថយន្តបាននាំអ្នកទាំងពីរមក ដល់មុខភោជនីយដ្ឋានយ៉ាងទំនើបមួយ ដែលមានវង់ភ្លេងសម័យ ប្រគំកំដរ និងនារីឡង់សេទទួលហៃហាមពិសេស ។ រាសីក៏ចុះពី ឡាន ទាញមួកកន្តិបទម្លាក់ចុះអោយលិចមុខបន្តិច ទំនងមិនចង់ អោយនរណាស្គាល់មុខនាងច្បាស់ឡើយ ។

រំពេចនោះ នារីឡង់សេមួយហ្វូងរត់មកទទួលសារៈ សំដែង អាការៈស្និទ្ធស្នាល ទំនងហាក់ដូចជាសារៈជាម៉ូយសំខាន់ប្រចាំកន្លែង របស់គេអញ្ចឹង ។ ព្រមពេលជាមួយគ្នានោះដែរ រាសីសង្កេតឃើញ ថាមនុស្សម្នាទាំងឡាយ ទាំងភ្ញៀវ ទាំងនារីឡង់សេ ទាំងអ្នកទទួល ភ្ញៀវដាក់តុ សុទ្ធតែឈរសម្លឹងរាសីអោយភ្នែរ មិនដាក់ភ្នែក ត្បិត គេនឹកឆ្ងល់ឃើញសារៈបណ្ដើរដៃគូ មានរូបរាងប្រុសមិនប្រុស ស្រី មិនស្រីមកជាមួយ ជាពិសេសទៅទៀតនោះ គឺដៃគូរបស់សារៈ ស្ថិតនៅក្នុងសម្លៀកជាកម្មកររោងចក្រតែម្ដង ។

ភ្លាមនោះ រាសីបានឮស្រីឡង់សេជជែកគ្នា ថា ៖

- អឺយ៉ា! ពេលនេះ លោកសារៈដូររសជាតិហើយតើហ៎!

- មកពីគាត់ជាមនុស្សកាច ទើបស្រីស្អាតៗរត់ចោលគាត់អស់!

- អឺហ៎ តាមពិតមកពីគាត់មិនទាន់ជួបដៃគូត្រូវចិត្តតើហ៎!

CHIANBOKEO.COM

- ប្រហែលជាគាត់មិនចូលចិត្តស្រីៗទេ ទើបស្រវាខ្មើយជាគ្នា...
- ប្រហែលជារកដៃគូល្អមិនបាននោះអី ? ចាស់៣០ប្លាយទៅហើយ
រើសដៃគូអីរើស រើសចុះរើសឡើង ចំខ្មើយ... ហាស់ៗហាំ!
- មកពីគេខិលខូចពេក ទើបនារីល្អគេគេចខ្លួនអស់នោះអី... ហ្នឹង ហើយរាសីប្រុសសិយណាំ!
តែសារៈបែរជាអង្គុយធ្វើមិនដឹងមិនឮ ចំពោះការពិចារណា
របស់នារីឡង់សេទាំងនោះទៅវិញ ។
- ញុំស្រាទេ រាសី ? (សារៈសួរ)
- មិនទេ! (រាសីគ្រវីក្បាល) កុំបបួលក្មេងអោយរៀនអកស្រាអី
ព្រោះនោះជាកិរិយាមិនថ្លៃថ្នូរទាល់តែសោះ ជាពិសេស កាលបើ យើងជាមនុស្សចាស់ពេញវ័យ
គួរណាស់តែប្រើគំនិតរបស់ខ្លួនបំភ្លឺ ជាផ្លូវ អោយក្មេងដើរផ្លូវល្អ ប្រសើរជាជាង ។
សារៈភ្ញាក់ព្រើត ត្បិតត្រូវមួយផ្លែធាំង តាំងពីចាប់បើកឆាក ។ គេធ្វើមុខស្មើ
ហើយក៏ងាកបញ្ជាម្ហូប ៖
- យកទឹកផ្លែឈើពីរ និងអាហារពីរមុខមក!
អ្នកបំរើងក់ក្បាលរួចដើរចេញទៅ ។ រាសីងកកវេភ្នែកចុះឡើង ទំនងរកមើលនរណាម្នាក់ ។
- ប្លែកភ្នែកណាស់មែនទេ រាសី បានដូចជាមានកិរិយាអើតអើមៗ ផ្ទើលៗ ដូច្នេះ ?
- មែនហើយ! (រាសីឆ្លើយ) ព្រោះខ្ញុំកំពុងនឹកគិតអនិច្ចាជីវិតនារី ឡង់សេទាំងនោះ.. មើលចុះ
ភ្ញៀវទីនេះភាគច្រើនជាបុរសចាស់ៗ ក្បាលទំពែកតែបែរជាមកប្រកៀកប្រកើយពពួកស្រីក្មេងៗ
មិនដឹង ជាប្តីនរណាគេ ឪពុកនរណាគេទេ ដែលលួចមកមានកិរិយាប្រព្រឹត្ត
នៅខាងក្រៅផ្ទះគ្មានថ្លៃថ្នូរអីបន្តិច ។ ចំណែកអ្នកបំរើវិញ ហេតុតែ ចង់បានប្រាក់ ក៏ខំត្រដរញញឹម
បំរើផ្គាប់ចិត្តអស់លោកចាស់ៗ ទាំង នោះ... ហើយខ្ញុំក៏នឹកគិតសង្ឃឹមថា
លោកសារៈមិនមែនជាបុរស
ម្នាក់ ក្នុងចំណោមបុរសព្រើលទាំងនោះឡើយ ។
ភ្លាមនោះ សារៈឈ្លក់ទឹកសឹងដាច់ខ្យល់ កាលបើត្រូវរាសី ឌឺដងមួយខ្លាយនោះ ។
គេបើកភ្នែកមូលក្រឡង់ ហើយតបថា ៖
- តែបើគេនោះមិនទាន់មានប្រពន្ធកូននៅឡើយ ការមករកកន្លែង សប្បាយៗអញ្ជឹងខ្លះៗ
វាមានទោទាស់អី..ព្រោះយើងមិនបានសាវ៉ា ចោលប្រពន្ធកូនឯណា ? (សារៈនិយាយ)

CHANBOKEO.COM

- ម៉េចក៏ថាមិនទាស់នោះ លោកសារៈ? ប្រុសម្នាក់ ប្រើលុយទិញ កិត្តិយស
ពពួកស្រីៗក្រីក្រជាច្រើននាក់មកជាន់ឈ្លី ។ ទំរាំគេមាន ប្រពន្ធ
តើចំនួនស្រីដែលគេបានឆ្លងកាត់មកនោះមានប៉ុន្មាននាក់ទៅ ដែលត្រូវក្លាយទៅជានារីរងគ្រោះ?
ឯភាពរងគ្រោះរបស់នាងគឺ មិនមែនត្រឹមតែពេលបំរើចំណង់តណ្ហារបស់បុរសបច្ចុប្បន្ននេះទេ ។
នៅនាអនាគត បុរសណាៗដទៃទៀត ក៏ស្ដោះទឹកមាត់ខ្ពើមរូបនាង
មិនព្រមទទួលយកនាងជាគូជីវិតដែរ ព្រោះសំអាងថាប្រវត្តិរបស់ នាងមិនល្អស្អាត...
ហើយចុះបុរសវិញ ដែលប្រព្រឹត្តមិនល្អស្អាត ម៉េចក៏គេភ្លេចទាញកញ្ឆក់ឆ្លុះខ្លួនឯងទៅវិញ?
តើបុរសទាំងនោះជា មនុស្ស ឬគ្រាន់តែជាជាតិតិរច្ឆាននៅក្នុងស្រោមមនុស្ស? បើគេជា
មនុស្សមែន ហេតុអ្វីក៏គ្មានចិត្ត គ្មានសតិ គ្មានអារម្មណ៍ យល់ដឹង អំពីអំពើមិនគប្បីរបស់ខ្លួន?
មានតែសត្វប៉ុណ្ណោះ ដែលគ្មានសតិ នឹងយល់ដឹងខុសត្រូវ ។
ជាតិជាមនុស្សគួរណាស់តែអាចញែកខ្លួន ចេញពីជាតិសត្វតិរច្ឆានអោយផុតស្រឡះ!...
មិនគួរណាពាក់ស្រោម មនុស្ស ហើយស្លាយធាតុតិរច្ឆានតាមខ្លួនទេ... គឺវាគួរអោយអាមាស
ណាស់!

សារៈទាល់ច្រកម្ដងទៀតហើយ ។ គេរកនឹកហើបមាត់តបទៅ នារីវិញមិនរួចសោះ
ព្រោះឆវីចាប់សារៈចំចំណុចខ្សោយរបស់គេ ។
មួយសន្ទុះធំក្រោយមក គេក៏ស្រដីថា ៖

- ជួនកាល នារីគេយល់ថា នោះជាមុខរបររបស់គេ ទើបគេមិន ខ្វល់ពីភាពថ្លៃថ្នូរ ។
គេគិតតែធ្វើយ៉ាងណាអោយតែបានលុយ...!
- ហើយចុះបុរសវិញនោះ មានភាពថ្លៃថ្នូរត្រឹមណាដែរ កាលបើ ឃើញនារីដើរខុសផ្លូវហើយ
មិនជួយទាញគ្នាអោយល្អមកវិញ បែរ ជានាំគ្នាយកកម្លាំងឥទ្ធិពលដុល្លារ
ជាន់ពន្លិចជីវិតរបស់នារីក្រីក្រ បន្ថែមអោយកាន់តែលិចលង់ថែមទៀតនោះ?

ហ៊ឺ! និយាយយូរៗទៅ សារៈរិតតែណែនទ្រូងឡើង ព្រោះរក
នឹកឆ្លើយតបនឹងមាណវីមិនបានសោះ ។ គេនៅស្ងៀមសម្លឹងមុខ មាណវី
លួចពិចារណាក្នុងចិត្តតែម្នាក់ឯងថា ៖

- មើលទៅនាងនៅក្មេងណាស់ ហើយជាក្មេងមកពីតាមខេត្តផង
ហេតុអ្វីនាងមានប្រាជ្ញាមាំមួនម្ល៉េះ? តើនាងរៀនដល់ណា? មាន ការអប់រំដល់ណាដែរ?
ហេតុអ្វីក៏នឹងការរាក់ជ្រៅក្នុងជីវិតម្ល៉េះ?

CHANBOKEO.COM

មែនហើយ! ការពិត រាសីស្អប់សង្គមរបៀបៗអ្វីដែលនាងបាន ឃើញនៅពេលនេះណាស់ ។ មើលចុះ! នៅតុឆ្ងាយៗពីនាង ខណ្ឌ័ បាំងដោយផើងផ្កាធំៗ ជាពិសេសនៅកន្លែងដែលមានពន្លឺភ្លើង ក្រហមព្រឹមៗ រាសីឃើញបុរសចាស់ៗ ខ្លះចាស់ជាងឪពុកនាង ទៅទៀត កំពុងអង្គុយអង្អែលស្រីក្មេង អោយនាងលើកកែវស្រា បង្អកខ្លួន ហើយក៏បំពងសំណើចលាន់ក្អាកក្អាយ ភ្លេចអស់ប្រពន្ធ កូន ។ ប្រហែលជាជីវិតបែបអញ្ចឹងទេនឹង ដែលនាំអោយឪពុកនាង វង្វេងចោលគ្រួសារ ចម្លងអេដស៍អោយប្រពន្ធ បង្កហឹង្សាវាយធ្វើបាបប្រពន្ធ ហើយបង្កើនភាពក្ដៅក្រហាយក្នុងចិត្តកូនគ្រប់គ្នា ?

រាសីអង្គុយទីនោះកាន់តែយូរ កាន់តែនឹកស្អប់ឪពុកនាងខ្លាំងឡើងជាលំដាប់ថ្វីបើគាត់បានចែកស្ថានទៅហើយក៏ដោយ ។ ចៃដន្យ រាសីមិនទាន់បានអហោសិកម្មដល់គាត់នៅឡើយទេ ។ មិនដឹងថ្ងៃណានាងត្រៀមចិត្តអហោសិកម្មអោយឪពុកនាងបានទេ ត្បិតអីនៅ រៀងរាល់មុននឹងបិទភ្នែកនិទ្រា រាសីនៅតែឮសម្រែកយំស្រែក របស់ម្ដាយនាងដែលត្រូវឪពុកនាងទះតប់ បន្ទាប់ពីគាត់ត្រឡប់មក ពីដើរលេងផឹកស្រាមានស្រី ។ លុយកាក់ដែលម្ដាយនាងរកស៊ីលក់ដូរបានមក សន្សំទុកគ្រាន់នឹងអោយកូនរៀន បានត្រូវឪពុកនាង យកទៅចែកចាយឲ្យមីនាងរបស់គាត់រៀងរាល់ថ្ងៃ ។ ថ្ងៃណាក៏នាង ឃើញម្ដាយស្រក់ទឹកភ្នែក ថ្ងៃណាក៏ឃើញឪពុកនាងវាយដំធ្វើបាប ម្ដាយរបស់នាង ថ្ងៃណាក៏នាងត្រូវរំពាត់ ដោយយកខ្លួនទៅរងជួស ម្ដាយ... នេះឬកិរិយាដ៏ល្អប្រពៃរបស់លោកឪពុកមានគុណចំពោះ កូន ? តើកិរិយារបៀបនេះ កូនៗគួរគិតយ៉ាងណាចំពោះឪពុកវិញ ដែរ ? ឬក៏សំអាងថាគាត់ជាអ្នកមានគុណហើយ អាចវាយទាត់ធាក់ សម្លាប់អារ ក កូនប្រពន្ធបានស្រេចតែអំពើចិត្ត ដោយមិនឲ្យកូន ដើបតវ៉ាអីមួយម៉ាត់ ?

ឃើញរាសីនៅស្ងៀមស្ងាត់ សារៈកពោលសួរថា ៖

- នាងរៀនដល់ណាដែរ រាសី ?
- ចាស! ដល់ថ្នាក់ទី១២ តែមិនបានប្រលងបញ្ចប់ទេ ព្រោះឈប់ រៀនដើម្បីផ្ទះជួយមើលម៉ែនិងប្អូនឈឺ ។
- ចុះគេទាំងពីរយ៉ាងណាហើយ ?
- ទទួលមរណភាពអស់ហើយ...
- អូហ៍! ឲ្យខ្ញុំសូមចូលរួមសោកស្ដាយផង រាសី!

CHANBOKEO.COM

- ចាស! មិនអីទេ! ខ្ញុំឈប់កាន់ទុក្ខយូរហើយ ។

- ចុះនាងមានបងប្អូនឯទៀតដែរទេ?

- មានប្អូនបួននាក់ ម្នាក់នៅរៀន ម្នាក់ចាញ់បោកចៅកែមុខខ្លាញ់រងើម ម្នាក់នៅបំរើជាកូនសិស្សវត្ត ហើយខ្ញុំធ្វើការរោងចក្រ ។

សារៈសម្លឹងនាងដោយក្រសែភ្នែកចម្លែក ដែលគេបានឃើញនារីក្រីក្រម្នាក់ប្រកាន់ខ្ជាប់នៅមោទនភាពរបស់ខ្លួនយ៉ាងរឹងមាំ មិន ព្រមបណ្តោយអោយភាពក្រីក្រទាញនាងធ្លាក់ចុះក្នុងសង្គមភក់ជ្រាំ អបលក្ខណ៍ ។ គេលួចកោតសរសើរនាងតិចៗនៅក្នុងចិត្ត ៖

- ញុំាអាហារនេះបន្តិចទៅរាសី ក្រែងលោឆ្ងាញ់មាត់ ។

រាសីងើបមុខឡើងសម្លឹងសារៈ ហើយវាចាតបថា ៖

- បើលោកពិតជារាប់អានរាសីជាញាតិ ជាមិត្ត ដោយស្មោះមែន សុំមេត្តាអនុញ្ញាត្តិអោយខ្ញុំខ្ចប់ម្ហូបនេះទៅផ្ទះវិញទៅ នោះខ្ញុំនឹងអាលបានចែករំលែកអោយប្អូនរបស់ខ្ញុំ ដែលគ្នាញុំាមិនដែលឆ្អែត ព្រោះ ខ្ញុំពុំមានសមត្ថភាពរកលុយទិញបាយអោយគេបរិភោគគ្រប់គ្រាន់ រៀងរាល់ថ្ងៃបានទេ ។

ពូវាចារបស់នាងដូច្នោះ គេហាក់ដូចជានឹករំជួលក្នុងចិត្តយ៉ាង ណាមិនដឹងទេ ។ នេះជាលើកទីមួយហើយ ដែលនារីសាមញ្ញម្នាក់អាចអង្រួនចិត្តរបស់គេអោយកក្រើកញាប់ញ័រដោយក្តីអាណិតអាសូរ បំផុត ។ ការពិតគេជាមនុស្សកាចរឹងត្អឹង មិនដែលចេះយោគយល់ នរណាម្តងឡើយ មិនថាបុរសឬស្ត្រីទេ ។ គេក៏ធ្លាប់ឆ្លងកាត់នារីយក មិនអស់ ហើយគេមិនដែលអង្វរនារីណាម្នាក់ទេ មានតែនាងៗអស់នោះមកតាមយកចិត្តទម្ងួចអង្វររូបគេ ។ ប្លែកអីតែរាសីមួយដែល មិនព្រមចុះញ៉មរូបនាយម្តងណាសូម្បីតែពេលគេប្រើកម្លាំងបាយ ដាក់នាងយ៉ាងខ្លាំងក៏ដោយ ។ ពេលនេះ គេបានស្គាល់នាងរិតតែច្បាស់... រាសីជានារីដ៏រឹងប៉ឹងម្នាក់គួរអោយកោតសរសើរ ថែមទាំង មានជំហរច្បាស់លាស់ក្នុងការនាំជីវិតរបស់នាងទៅកាន់អនាគត... នោះគឺការដើរក្នុងផ្លូវត្រូវ ផ្លូវសុចរិត ហើយថ្លៃថ្នូរ ។ ថ្វីបើនាង ជានារីក្រីក្រ ប៉ុន្តែ គុណសម្បត្តិរបស់នាងសំបូរលើសនារីៗអភិជនឯទៀតជាច្រើននៅភ្នំពេញនេះ ។ ពេលនេះ សារៈកាន់តែចាប់អារម្មណ៍លើរាសីកាន់តែជ្រាលជ្រៅឆ្ងាយទៅៗ នៅក្នុងជំរៅចិត្ត យ៉ាងចម្លែករកថាមិនត្រូវ...

CHANBOKEO.COM

នៅក្រោមពន្លឺភ្លើងក្រហមស្រទន់ សារៈឃើញធិតាដើបសម្លឹង តបមកនាយវិញដោយក្រសែភ្នែកភ្លឺថ្លាផ្លេកៗ បង្ហាញនូវភាពក្លា ហានរបស់នាង មិនព្រមចុះញ៉មឥទ្ធិពលសង្កម ដែលកំពុងគម្រាម ភាពក្រីក្ររបស់នាងឡើយ ។

- អេហ៍ សារៈ! ចាំពូយូរហើយមែនទេ ?

បុរសចាស់ម្នាក់ដើរចូលមកដល់ ឧទានហៅសារៈ ។

- អូហ៍ ពូខាំង! ខ្ញុំមកដល់ម៉ាស្របក់ហើយ ។ នេះ! ពូមកតែ ម្នាក់ឯងទេ ? ឯណាដៃគូ ?

- ទីនេះសំបូរអ្នកកំដរស្អាតៗណាស់ ចាំបាច់នាំមកពីក្រៅធ្វើអី ?

សារៈនៅស្ងៀម លួចងៀងភ្នែកមើលរាសី ដែលកំពុងអូស កៅអីបញ្ចៀសខ្លួនយ៉ាងឆ្ងាយពីថៅកែខាំង ។ លុះក្រឡេកឃើញ រាសីកាលណា ថៅកែខាំងលាន់មាត់សួរសារៈ ៖

- ឯងទៅនាំអាខ្ទើយនេះពីណាមក ? មុខមើលមិនបានសោះ!

- គឺ...ពីរោងចក្រជិនហួ! ថ្ងៃនេះ ខ្ញុំអផ្សុកពេក គ្មានគ្នាមកបាយ ជាមួយ ក៏បបួលគេមកលេងអោយបានជាគ្នាទៅ ។

- ស្លាប់ហើយ! ហើយម៉េចឯងមិនរកស្រីៗស្អាតៗទីនេះមកកំដរ វិញទៅ ? ទៅហៅមុខខ្ទើយមកតាមដូច្នេះ សប្បាយអីទៅវ៉ី ?

សារៈមិនឆ្លើយទេ ព្រោះដឹងថាថៅកែខាំងមិនបានមើលឃើញ សោភ័ណរបស់រាសីដូចនាយបានសម្លឹងឃើញនោះទេ ។ ប៉ុន្តែ នោះ ក៏ល្អដែរ ព្រោះនាយមិនបាច់ភ័យថាថៅកែខាំងរកមធ្យោបាយ ឆក់ រាសីកាត់មុខនាយផង ។ ភ្លាមនោះ គេបែរជាសួរវិញថា ៖

- ហើយចុះនាងរស្មីដ៏ស្រស់ស្អាត កូនធម៌របស់ពូនោះ ថ្ងៃនេះទៅណាហើយបានជាមិនឃើញមកតាមបំរើលោកប៉ាអញ្ចឹង ? រាល់ដង ឃើញតាមបំរើអោយស្អិតជាប់កែង!

- ថ្ងៃនេះវារករឿងអញពេក ទើបទះវាលេងពីបីដៃ រួចទុកវាចោល ហើយក៏មកបបួលឯងដើរលេងនេះអី ។ ទទួលឯងនាំអាខ្ទើយមក អញ្ចឹង ធ្វើអោយអញនេះអស់អារម្មណ៍រលីងធេង ។

រាសីភ្ញាក់ព្រើត ពេលបានឮប្រយោគថៅកែខាំងមួយឃ្លាអំបាញ មិញនេះ ។ ការពិត រស្មីចូលខ្លួនមកធ្វើជាស្រីបំរើកាមរបស់បុរស ចាស់នេះទេតើហ៍!

CHANBOKEO.COM

- ពុទ្ធោអើយ រស្មី! ពេលនេះ ប្អូនយ៉ាងណាទៅហើយ ? (រាសី លួចនឹកអាណិតប្អូននៅក្នុងចិត្តតែម្នាក់ឯង)

សារៈឃើញរាសីជ្រួញចិញ្ចើម ពេលឮថាថៅកែខាំងប្រើហឹង្សា លើនារីភេទ ក៏សម្រួលបរិយាកាសភ្លាម ៖

- យ៉ាងណាៗ សូមឮបន្ទូរដៃចំពោះគេខ្លះផង ព្រោះនារីមានភាព ទន់ភ្លន់គួរអោយស្រឡាញ់ណាស់ ។ បើសិនឮផ្តល់ឱកាសអោយគេ គេច្បាស់ជានឹងបង្ហាញនូវភាពទន់ភ្លន់ហើយស្រស់ស្អាតរបស់គេ ឲ្យ ឮត្រេកត្រអាលក្នុងដួងចិត្តជានិច្ច មិនលែងឡើយ ។

មែនហើយ! ពេលគេស្រដីប្រាប់ថៅកែខាំងនេះ អារម្មណ៍និង ចិត្តរបស់គេបានវិលដើរថយក្រោយ ទៅឃើញភាពទន់ភ្លន់ស្រស់ ស្អាតរបស់រាសី កាលពីថ្ងៃរសៀល ពេលមាណវីស្លៀកពាក់តុបតែង ខ្លួនក្នុងសម្លៀកបំពាក់ប្រពៃណីខ្មែរ ទម្លាក់សក់វែងអន្លាយខ្មៅរលើប សក្តិ សមនឹងទឹកមុខញញឹមថ្លាបំព្រង ព្រមនឹងភាពក្លាហានរបស់នាង...

គេនៅដក់អារម្មណ៍នឹងមិត្តភាពនោះមិនទាន់បាត់រំភើបស្រើបស្រាល នៅក្នុងចិត្តនៅឡើយទេ ។ ថែងន្យ គេត្រូវទទួលការខកចិត្តបន្តិច ដោយរូបគេមិនមែនជាបុរសដែលបាន ទទួលកម្រងផ្កាម្លិះពីរូប មាណវីផ្ទាល់ ។ បើសិនជាគេបានទទួលកម្រងផ្កាទៀត មិនដឹងថា បេះដូងរបស់គេ ញាប់ញ័ររន្ធត់យ៉ាងណាទៀតទៅ...

សារៈលួចចោលកន្ទុយភ្នែកដាក់នាងច្រើនដង តែធិតាហាក់ដូច ជាមានឫកពាធម្មតាៗ ដូចជាមិនចាប់អារម្មណ៍អំពីក្រសៃភ្នែករបស់ នាយយើងឡើយ ។ បន្តិចមក ថៅកែខាំងបានជួបបុរសចំណាស់ៗ ដែលជាថៅកែដូចគ្នា ។ គាត់ក៏បំបែកខ្លួនពីតុសារៈទៅ ទំនងដូចជា ទើសទាល់នឹងវត្តមានរបស់រាសីខ្មើយនោះហើយ ។

យប់បន្តិច រាសីក៏សុំខ្លួនអោយសារៈជូនត្រឡប់មកផ្ទះវិញ ។ តាមផ្លូវ នាងមិនបាននិយាយស្តីអ្វីជាមួយនាយទេ ។ ឯបុរសវិញក៏ រកនឹកចង់និយាយអ្វីជាមួយនាងមិនឃើញដែរ ព្រោះពេលណាគេ ហ៊ានហើបមួយម៉ាត់ រាសីផ្តល់យោបល់មួយម៉ាត់វិញ ស្កកសារៈអស់ កន្លះម៉ោង រកនឹកពាក្យតបលែងឃើញតែម្តង ។

- រាត្រីសួស្តី រាសី! ស្អែកយើងជួបគ្នាទៀតទេ ?

សារៈសួរពេលជូនរាសីដល់មាត់ច្រកចូលផ្ទះរបស់នាង ។

CHANBOKEO.COM

- មិនសន្យាទេ ។ ចាំរាសីគិតមើលសិន ។

ថាហើយ នាងក៏ដើបដើរចេញទៅ ។

- រាសី! (សារៈស្រែកហៅនាងម្តងទៀត)

ធិតាទុចង៉ក់ ហើយបែរក្រោយ ឃើញសារៈបើកទ្វាររថយន្ត ដើរចេញមករកនាង ហើយស្រដីថា ៖

- រាសី! អោយខ្ញុំសូមទោសផងណា៎... ចំពោះអ្វីដែលខ្ញុំប្រព្រឹត្តមិនល្អលើនាងកាលពីថ្ងៃមុន...

រាសីនៅស្ងៀមមិនឆ្លើយទេ ។ នាងសម្លឹងមុខសារៈមួយស្របក់ ក៏តបវិញថា ៖

- របួសកាយអាចជាបានក្នុងរយៈពេលយ៉ាងខ្លី ប៉ុន្តែការរបួសផ្លូវចិត្តតែងត្រូវការពេលវេលាយូរជាងនោះច្រើនផង...

- ប៉ុន្តែ... បើខ្ញុំសូមឱកាសកែឆ្នៃសម្ពន្ធ័របស់យើង... តើនាង អនុញ្ញាត្តដែរទេ ?... គឺខ្ញុំចង់មានន័យថា ទុកពេលអោយខ្ញុំបានធ្វើ ខ្លួនជាបុរសដែលគួរឲ្យអ្នកដទៃរំភើបចិត្ត ដោយមូលហេតុគុណធម៌ និងសីលធម៌ មិនមែនដោយអំណាចទឹកប្រាក់និងកម្លាំងបាយ...

- បើលោកចង់បានឱកាសពិតមែន... រាសីក៏នៅក្មេងដែរ គឺមានពេលគ្រប់គ្រាន់នឹងបានឃើញការកែប្រែរបស់លោក ។

សារៈញញឹមឡើង ដែលរាសីបើកភ្លើងខៀវឲ្យសញ្ញាដូច្នេះ ។ ពេលនោះ រាសីក៏បោះជំហានចេញទៅ ទុកអោយសារៈមើលតាម នាងពីក្រោយមិនដាក់ភ្នែករហូតដល់នាងបាត់ស្រមោលទៅក្នុងស្បៃ រាត្រីអន្ធការ ទើបដើរកាន់ច្រត់ទប់ខ្លួនចូលរថយន្តវិញ ។

រាសីដើរត្រឡប់ទៅផ្ទះយ៉ាងលឿនដូចហោះ ព្រោះពេលនោះ យប់ស្ងាត់បន្តិចហើយ ។ ភ្លាមនោះ នាងក៏ចាប់ភ្លឹកថាហាក់ដូចជា មានស្រមោលមួយលបលួចដើរតាមនាងទៀតហើយ ។ មាណវីនឹក ពិភាល់ក្នុងចិត្តណាស់ ក៏ងាករកមើលយ៉ាងរហ័ស តែនៅចាប់ម្ចាស់ស្រមោលនោះមិនបានដដែល មិនដឹងថាជានរណា ។ ភ្លាមនោះ នាងនឹករអើលក្នុងចិត្តយ៉ាងណាមិនដឹង ដែលនាងដើរយប់តែម្នាក់ ឯងគ្មានរក្សាមកចាំដើរកំដរជាគ្នា ។

លុះមកដល់មាត់ទ្វារផ្ទះ ស្រាប់តែធីឃើញបុរសម្នាក់នៅអង្គុយ

សំកុកមាត់ជណ្តើរមុខបន្ទប់របស់នាង ។

- បងសយនា ?

មែនហើយ! នោះគឺសយនាដែលនៅអង្គុយសំកុកចាំរាសី ។

- រាសី! អូនមកវិញហើយហ្អែស ?

គេសំដែងភាពញញឹមឡើង កាលបើឃើញវត្តមានរបស់រាសី នៅចំពោះមុខដោយសុខសប្បាយ ។

- បងពិសារបាយហើយហ្អែស ?

- នៅទេ ?

- ស្លាប់ហើយ! ហេតុអ្វីក៏នៅយប់ម្ល៉េះ ?

- ព្រោះបងនៅចាំបរិភោគជុំគ្នាជាមួយរាសីនោះអី ។

និតាឮដូច្នោះក៏ញញឹមឡើង ដោយសប្បាយចិត្តដែលគេយក ចិត្តទុកដាក់ចំពោះរូបនាង ។

- រាសីក៏ប្រឹងត្រឡប់អោយទាន់បង នឹងអាលបានទទួលទានជុំគ្នា ដែរហ្នឹងណា៎ ។

ថាហើយ នាងក៏ឡើងទៅលើផ្ទះ លាតកញ្ចប់អាហារដែលនាង ខ្ចប់យកមកពី ភោជនីយដ្ឋានចាប់ដាក់ចាន ។ សយនានៅអង្គុយ សម្លឹងមុខនិតាភ្លន់ភ្លឹក ហើយធ្វើកិរិយាអេះអុញហាក់ចង់សួរនាងពី នាយសារៈ តែក៏នឹកខ្លាចមិនសមរម្យ ក៏ទប់មាត់ទៅវិញ ។

- រក្សា! បងអារី! បរិភោគបាយទេ ? (រាសីសួរ)

- ពួកយើងបរិភោគរួចហើយ បងរាសី! អាហារចំណែករបស់បង នោះបងអារីគាត់ព្រលះអស់ហើយ សល់តែភាគដែលបងសយនា គាត់ចាប់ទុកទេ (រក្សាឆ្លើយ)

រាសីឮហើយញញឹមរួចលើកចានហុចអោយសយនា ៖

- នេះ ចំណែករបស់បង! ពិសារទៅ!

- រាសីទិញបាយនេះ យកមកធ្វើបងមែនទេ ? (នរៈសួរ)

- ចាំសអត់ទេ! គឺជាបាយដែលលោកសារៈទិញអោយ!

- អូហ៍ អញ្ចឹង អូនបរិភោគចុះ ព្រោះគេទិញសំរាប់អូន មិនមែនសំរាប់សយនាឯណា ។

រាសីងើបមុខឡើងសម្លឹងសយនាដែលធ្វើមុខស្ញើៗ ទំនងអន់ចិត្តដែលឃើញនាងចេញទៅក្រៅជាមួយនាយសារៈ ។ ឆវីក៏ញញឹម លួងចិត្តមាណពភ្លាម ៖

CHANBOKEO.COM

- អញ្ចឹង ខ្ញុំទុកម្ហូបនេះញ៉ាំព្រឹកស្អែកចុះ ។ ខ្ញុំញ៉ាំបាយដែលបង ចាប់ទុកនោះ ពីរនាក់បងក៏បានដែរ ។

សយនាញញឹមឡើងយ៉ាងគ្រហាញតែម្តង កាលបើរាសីនិយាយ ដូច្នោះ ។ ធិតាក៏ទាញស្លាបព្រាពីរមកហុចចែកគ្នាម្នាក់មួយ តែមិន រំលែកចានបាយទេ គឺសុខចិត្តបរិភោគចានតែមួយជាមួយគ្នា ៖

- ម៉ោះ! យើងញ៉ាំប្រណាំងគ្នាណា៎ បងសយនា! នរណាពូកែជាង អ្នកហ្នឹងឆ្អែតមុន! យ៉ាងម៉េចដែរបង ?

ប្រយោគមួយនេះ ដូចថ្នាំទិព្វមិនខុសសោះ ។ ភាពស្មុគស្មាញ ក្នុងចិត្តនរៈកាលពីពេលប៉ ក៏រលាយបាត់អស់រលីងពីបេះដូងរបស់ នរៈគ្មានសល់ នៅតែភាពភ្លឺថ្លាក្នុងចិត្តតែម្យ៉ាងប៉ុណ្ណោះ ។ អ្នកទាំង ពីរបរិភោគបាយបណ្តើរ លួចចោលភ្នែកញញឹមដាក់គ្នាបណ្តើរ... ថ្វីបើគេនៅបរិភោគស្ងៀមស្ងាត់ក៏ពិតមែន ប៉ុន្តែក្រសែភ្នែករបស់ អ្នកទាំងពីរដែលហោះហើរទៅមករកគ្នានោះ បានគួចនាំយកភាសា សម្ងាត់ក្នុងជំរៅបេះដូងរបស់គេ ទៅឱ្យប្រាប់គ្នាមិនអស់មិនហើយ សោះឡើយ...

យប់ជ្រៅបន្តិចហើយ...

- បងទៅវិញសិនហើយណា៎រាសី!

- ចា៎ស!

រាសីចេញជូនបុរសត្រឹមតែមាត់ជណ្តើរផ្ទះ ប៉ុណ្ណោះ ។

- រាសី! ឲ្យបងសុំផ្ញើអ្វីមួយ មុនបែកគ្នាយប់នេះបានទេ ?

- ផ្ទះខ្ញុំរខេករខាកណាស់បង មិនហ៊ានទទួលឥវ៉ាន់មានតម្លៃមកទុក ផ្តេសផ្តាសបានទេ (រាសីឆ្លើយ)

- តែ របស់មួយនោះ ចោរលួចមិនបានទេ ។

រាសីជ្រួញចិញ្ចើមទ្រង់ឆ្ងល់ ។ រំពេចនោះ គេដើរមកជិតនាង ហើយយកម្រាមចង្អុលដៃរបស់គេទៅផ្ទិតបបូរមាត់របស់ខ្លួនគេ រួច ហើយក៏យកទៅផ្ទិតលើបបូរមាត់របស់ស្រស់កល្យាណ បន្ទាប់មកគេ ក៏វាចាឡើងថា ៖

- សុំអោយបងបានគេងយល់សប្តិឃើញអូនយប់នេះផងណា៎!

ភ្លាមនោះរាសីនឹកខ្មាសក្នុងចិត្តណាស់ ។ នាងអៀនរឹងខ្លួនរហូត និយាយលែងចេញតែម្តង ។ សយនាញញឹមដាក់នាងជាចុងក្រោយ ហើយក៏ដើរចេញទៅ...

CHANBOKEO.COM

រាសីយកដៃស្ទាបបបូរមាត់ ស្រមៃយ័នឹកទៅដល់រសក្លិនសម្ពន្ធ័
និស្ស័យរវាងនាងនឹងនាយប៉ូលីសម្នាក់នោះ... ជារសជាតិជីវិតថ្មី
ដែលនាងទីបប្រទះដំបូងក្នុងជីវិត... តើពេលនេះ នាងត្រូវត្រៀម ខ្លួនរៀបកាយ
រៀបដំណើរជីវិតយ៉ាងណាតទៅទៀត ? នាងសម្លឹង តាមសយនាពីក្រោយ
បន្តិចមកក៏នឹកគិតទៅដល់សារៈ រួចដិនហ្ន... បន្តិចមកក៏គ្រវីក្បាល
ហើយក៏ដើរឡើងចូលទៅក្នុងផ្ទះ ទាំងដួងចិត្ត ច្របូកច្របល់
ត្បិតនាងមិនទាន់ស្គាល់ប្រវត្តិរបស់គេម្នាក់ណាបាន ច្បាស់នៅឡើយទេ...

*0000000000000000*

*00000*

*0*

CHANBOKEO . COM

# វគ្គទី៧
# គូប្រជែង

រក្សាដើបចេញទៅធ្វើការបាត់តាំងពីព្រលឹមស្រាង...

រាសីក្រោកឡើងហៅសាវ័រី ៖

- បងអារី! ចង់ទៅផ្ទះវិញទេ?
- នាងចង់លែងខ្ញុំវិញហើយឬ រាសី?
- គឺខ្ញុំឃើញបងស្រីដូចជាទុរន់ទុរាណាស់ ។ បើខ្ញុំទុកបងទីនេះតែ បីថ្ងៃទៀត ខ្ញុំច្បាស់ជាត្រូវដេញតុងទីនយកលុយធ្វើបុណ្យខ្មោចឲ្យ បងអារីឯងហើយ ។
- យី! និយាយអីចង្រៃម្ល៉េះ រាសី?
- មិនចង្រៃទេ! គឺការពិត ព្រោះបីថ្ងៃកន្លងមកនេះ បងធ្វើខ្លួនគួរ អោយវេទនាភ្នែកមែន! ឯឫកពាមារយាទវិញ យ៉ាប់ជាងជនក្រីក្រ រិតតែឆ្ងាយណាស់ទៅទៀត ។

សាវ័រីនៅស្ងៀម ត្បិតរាសីនិយាយត្រូវ ។

- ខ្ញុំមានផ្លូវពីរអោយបងជ្រើសរើស (រាសីនិយាយបន្ត) មួយគឺ នៅទីនេះបន្ត រហូតដល់គ្រប់មួយខែ ។ ពីរគឺទៅផ្ទះវិញ ប៉ុន្តែត្រូវ បិទមាត់រឿងអ្វីៗទាំងអស់ ហើយផ្លាស់ប្តូរឥរិយាបថផង ជាពិសេស ជាមួយកម្មកររោងចក្រជិនហួ ។ សូមមេត្តាយកបេះដូងមកមើល អ្នកក្រខ្លះ កុំប្រើតែប្រស្រីឥតមានវិញ្ញាណដូច្នេះទៀត ។ វាគួរឲ្យអាសូរណាស់ណា៎ ដែលបងមានភ្នែកតែពិការគំនិតមារយាទនោះ ។ ម្យ៉ាងទៀត សូមមេត្តាកុំវាត់កន្ទុយអោយខ្ញុំវិញអោយសោះ ។ អ្នក ក្រដូចខ្ញុំ បើសិនត្រូវស្លាប់វិញ គឺគ្មានអ្វីគួរអោយស្រណោះស្តាយ ឡើយ ព្រោះយើងគ្មានអ្វីនៅសល់ទេ ក្រៅពីជីវិតរបស់ខ្លួន ។ ប៉ុន្តែ ចំពោះអ្នកមានដូចបងស្រី... ទើបគួរអោយស្តាយ ព្រោះមិនបាន ចាយលុយដែលខ្លួនប្រឹងជីវិតពីអ្នកក្រនោះមក៍... សូមបងស្រីចាំឲ្យ ច្បាស់ផងថា

CHANBOKEO.COM

រាសីមិនបណ្តោយអោយនរណាដើរខ្សែលើបានងាយៗ ទេ ឮហើយនៅ ? ពេលនេះ
ខ្ញុំបានផ្ញើសំណុំរឿងរបស់យើងទៅ ពួកកាសែតអស់ហើយ បើមានផ្ទុះរឿងហេតុចម្លែកអ្វីនោះ
សូមកុំ ភ្លេចទៅមើលមុខដ៏ស្រស់ស្អាតរបស់បង នៅទំព័រទីមួយផងណា៎! នុ៎ះទ្វារ!
បងចេញទៅចុះ!

ស្រាប់តែ សាវរីបែរជាធ្វើកិរិយាអេះអុញ ។

- មានការអ្វីហ្នឹង ទើបបងស្រីមិនហ៊ានចេញទៅ ? (រាសីសួរ)
- ព្រោះគ្មានលុយធ្វើដំណើរទៅផ្ទះនោះអី!
- អូហ៎! ហើយម៉េចមិនទៅរោងចក្រជិនហួអោយគេជួយទៅ ?
- ទៅស្អី ? នរណាគេជឿថាយើងជា...
- ហៃ៎សៗ! ហ្នឹងបានថា... ធ្វើខ្លួនជាមនុស្សល្អមិនព្រមទេ បែរជា ធ្វើខ្លួនឥតមារយាទ
ចង់សត្រូវអោយជុំខ្លួនតែម្តង! លុះដល់មាន រឿងទាល់ច្រក រកញាតិពឹងមិនបានដូច្នេះឯង ។
ម៉េចដឹងខ្លួនហើយ នៅ បងអារី ថាភាពទាល់ច្រកនោះវាមានរសជាតិយ៉ាងម៉េចដែរ ?

សាវរីស្ងាត់មាត់ច្រៀប ដែលរាសីចាក់ចំចំណុចខ្សោយ ។ បន្តិច មក
រាសីក៏ដកលុយមួយពាន់រៀលហុចអោយ ៖

- នេ៎ះ គ្រប់ល្មមថ្លៃម៉ូតូឌុបហើយ ។ ខ្ញុំមិនទាន់បើកប្រាក់ខែនៅ ឡើយទេ
ដូច្នេះខ្ញុំក៏គ្មានច្រើនអោយបងខ្ចីដែរ ។ សង្ឃឹមថាបងអាច ទៅដល់ផ្ទះវិញដោយសុវត្ថិភាព ។

ថាហើយ រាសីជូនសាវរីរកម៉ូតូឌុប ស្រាប់តែរាសីកេះសាវរី បួញមាត់ប្រាប់ថា ៖

- នុ៎ះ! បុរសពាក់វ៉ែនតាខ្មៅ ស្ពាយកាម៉ារ៉ានៅក ហើយមានកាន់ សៀវភៅ កាន់ប៉ាកកានៅដៃ
ជាពួកកាសែតតាមស៊ើបការណ៍ពីបង ហើយ ។ ប្រយ័ត្នខ្លួនបន្តិចទៅណា៎ បងសម្លាញ់!

រាសីយកដៃទះខ្នងសាវរី ដែលកំពុងងាកបែរមើលដែរ ស្រាប់
តែនាងប្រទះបុរសនោះមែន ។ សាវរីពង្រួញខ្លួន ឡើងទំម៉ូតូឌុប ចេញទៅយ៉ាងលឿនតែម្តង
ក្នុងកិរិយាហាក់ដូចជាខ្លាចសកម្មភាព របស់បុរសវ៉ែនតាខ្មៅនោះណាស់ ។ លុះសាវរីចេញទៅផុត
រាសីក៏ ញញឹម លាន់មាត់ឡើងថា ៖

- រាសីភូតទេ បងសាវរីអើយ! ការពិត រាសីមិនដឹងផងថា បុរស
ពាក់វ៉ែនតាខ្មៅឈរត្រើយម្ខាងផ្លូវនោះជានរណាឡើយ គ្រាន់តែខ្ចី
យកមកប្រើបន្លាចបងម៉ាភ្លែតតែប៉ុណ្ណោះ ។

នាងសើចខឹកៗហើយ ក៏ដើរតម្រង់ទៅរោងចក្រជិនហួ ។

CHANBOKEO.COM

នៅក្នុងរោងដេរលេខប្រាំ...

រាសីកំពុងឈរបញ្ជាម៉ាស៊ីនដាំឡេវ ស្រាប់តែមានឆ្មាំម្នាក់ឈ្មោះ ម៉ាប់មកហៅ ៖

- រាសី! លោកជិនហួមានប្រសាសន៍ហៅអោយទៅជួបបន្តិច!
- មានការអីទៅពូម៉ាប់ ?
- មិនដឹងទេ!
- អញ្ចឹងរាសីមិនទៅទេ!
- យើ! ហ៊ានប្រកែកនឹងចៅហ្វាយផង ?
- ចុះបើខ្ញុំទៅ បាននរណាកាន់ម៉ាស៊ីននេះ ? ហើយបើខ្ញុំធ្វើការមិន គ្រប់តាមកុងត្រា ពួកការិយាល័យមិនកាត់ប្រាក់ខែខ្ញុំទៅហើយទេ ?
- តែលោកជិនហួបានបញ្ជាមក ដូច្នេះនាងត្រូវតែធ្វើតាម!
- ចុះពូទទួលបញ្ជាលោកជិនហួហើយ មានទៅប្រាប់ការិយាល័យ ហើយឬនៅ ថាអោយខ្ញុំឈប់ពីការងារទៅជួបលោកជិនហួ ដោយ គ្មានការបាត់បង់ប្រាក់ខែ ?
- នៅទេ!
- អញ្ចឹងទៅប្រាប់សិនទៅ ។

នាយម៉ាប់ទើសទាល់ក៏ដើរទៅវិញ ។ សុផាឃើញហើយ គ្រវី ក្បាលដាក់រាសី ៖

- កើតតែប្អូនចេះនឹកឃើញ ប្រើនាយហ្នឹងកើតហ្ន៎ ? ពីមុនៗមក ពួកកម្មករត្រូវគេកាត់ប្រាក់ខែទទេៗអស់ច្រើនដងហើយ ព្រោះតែ គេកោះហៅអោយទៅជួបអ្នកធំហើយស្រកស្រុតលទ្ធផលការងារ ។ - ហ៉ែសៗ! នេះរាសីស្មោះ! ខ្ញុំមិនអោយនរណាឆ្លៀតឱកាសដើរ ខ្សែលើរាសីបានឡើយ បងសុផាអើយ ។

បន្តិចមក នាយម៉ាប់ត្រឡប់មករកនាងទៀត ៖

- លោកជិនហួតឿនអោយនាងទៅជួបឥឡូវនេះ ។
- មិនទៅទេ! (រាសីឆ្លើយ)
- ហេតុអី ?
- កម្មករស្រីក្រមុំ ឲ្យទៅជួបចៅហ្វាយប្រុសសង្ហាតែពីរនាក់ក្នុង បន្ទប់យ៉ាងម៉េចកើត ? នោះ ជាការិយាល័យរបស់លោកនាយផង តើនរណាហ៊ានក្អករំខានទៅ បើសិនជាលោកចង់កេះកៀវកម្មករ ក្រមុំដូចខ្ញុំនេះ ?

CHANBOKEO.COM

រាសីនិយាយឮខ្លាំងៗ ធ្វើអោយកម្មករទីនោះ បានឮសឹងទាំង អស់គ្នា ។ នាយម៉ាប់ឆ្លើយវិញថា ៖

- មុខមាត់ដូចនាងអញ្ចឹង មិនធ្វើលោកជិនហ្វូមិនរំភើបចិត្តទេ ។
- ម៉េចក៏នឹងជួសជិនហ្វូកើត ? ពួកឯងមិនមែនជិនហ្វូឯណា ?

នាយឆ្មាំតបវិញលែងរួច ក៏ត្រឡប់ទៅវិញទាំងមុខស្មៀក បន្តិច មក នាយក៏ត្រឡប់មកវិញ ៖

- ជិនហ្វូថាអោយនាងទៅជួបជាប្រញាប់!
- មិនទេ!
- ទៅទៅណា៎! បើមិនអញ្ចឹង ពីត្រូវមាត់ទៀតហើយ ។
- ត្រូវខ្លះទៅ ទើបជីវិតមានរសជាតិ មិនអផ្សុកស្ងៀមស្ងាត់ពេក ។
- ពុទ្ធោ! ទៅទៅ ណា៎ មីនាង!
- មិនទៅទេ!
- នាងមិនគោរពចៅហ្វាយទេ ?
- គោរពចៅហ្វាយស្អី ? រាសីគោរពការងារជាជាង!

រំពេចនោះ មានសម្លេងមួយនិយាយកាត់ថា ៖

- ខ្ញុំក៏ចង់នឹងដែរថា ថាន:ជាម្ចាស់រោងចក្រ ហៅកម្មករម្នាក់អោយមកជួបនៅការិយាល័យមិនបាន តើដោយមូលហេតុអ្វីដែរ ?

ទាំងអស់គ្នាងាកទៅ ឃើញជិនហ្វូដើរចូលមក ។ រាសីធ្វើភ្នែក មូលក្រឡង់ ត្បិតមិននឹកស្មានថាជិនហ្វូដើរមករកនាងដល់រោងការ ងារដូច្នោះ ។ ការពិត នាងចង់លលេងបង្ក្រាបឆ្មាំឫកធំម្នាក់នោះ ទេតើហ៍ ។ កាលបើជិនហ្វូមកដល់ទីនោះទៅហើយ នាងក៏ធ្វើពើជា ញញឹមឡើង ៖

- ជំរាបសួរ លោកជិនហ្វូ!
- នាងអាចមានពេលអោយខ្ញុំមួយស្របក់បានទេ រាសី ?

រាសីញាក់ចិញ្ចើម ៖

- ចឹក៏មិនបាន តែរាសីមិនចង់បាត់បង់ប្រាក់ខែ ដោយសារផលិតផវាន់តាមកុងត្រាមិនគ្រប់ចំនួននោះទេ ។ បើសិនជាលោកជិនហ្វូ អាចប៉ូវអោយបាន រាសីទៅខ្លាចអីនឹងជួបលោក ?

CHANBOKEO.COM

ធិតានិយាយដូច្នោះ ព្រោះនាងដឹងហើយថាជិនហ្វូជាមនុស្សម៉ៅ ស្ទិត ។
ភ្លាមនោះជិនហ្វូក៏បែរទៅនាយឆ្មាំនោះ ៖
- ទៅប្រាប់ការិយាល័យទៅ ថា ជិនហ្វូនាំរាសីទៅនិយាយរឿងការ ងារនៅក្រៅ
មិនបានកាន់ម៉ាស៊ីនទេ ហើយសុំអោយគេរៀបប្រាក់ ខែបើកអោយនាងតាមធម្មតា ។

នាយឆ្មាំងក់ក្បាលហើយដើរចេញទៅ ។ ជិនហ្វូក៏នាំធិតាដើរ ត្រឡប់មកដល់រថយន្តរបស់គេ ។

- លោកបំរុងនាំខ្ញុំទៅណា ?
- ទៅក្រៅ ព្រោះជិនហ្វូមិនចូលចិត្តអោយកម្មករទីនេះ អើតអើម
ដកកចំហមាត់សម្លឹងជិនហ្វូនិងរាសីពេលយើងនិយាយគ្នាទេ ។
- តែរាសីមិនចង់ទៅទេ ។
- ម៉ាភ្លែតតើហ៎!
- ហ៊ឹ! មិនដឹងថា លោកជិនហ្វូនាំរាសីទៅណា ?
- ទៅកន្លែងល្អៗ !
- មិនមែនបោកយករាសីទៅបំពានរូបកាយទេណ៎ !

ជិនហ្វូបើកភ្នែកធំៗដែលនារីនិយាយស្ដីត្រង់ស្លុយដូច្នោះ ៖

- មិនទេ! ជាកន្លែងដែលរាសីពេញចិត្តនឹងទៅ ។
- កន្លែងណាដែរ ?
- ឡើងឡានសិនមក!

រាសីដាក់ខ្លួនចូលក្នុងឡាន អោយជិនហ្វូដឹកចេញទៅ ។ បន្តិច
មកក៏មកឈប់នៅហាងសំអាងនារីមួយ ៖

- នាំខ្ញុំមកទីនេះធ្វើអី ?
- គឺអោយគេសំអាងតុបតែងនាងឲ្យស្អាតនោះអី!
- អត់ទេ! រាសីមិនត្រូវការទេ ។
- ដើរជាមួយថៅកែ ទាល់តែរៀបខ្លួនអោយសមរម្យបន្តិចហើយ ។
- តែខ្ញុំមិនបានសុំខ្លួនមកដើរជាមួយថៅកែទេ ព្រោះវាហួសមាឌ ហួសសមត្ថភាពរបស់ខ្ញុំហើយ ។
- កុំប្រកែក! ទុកជាយ៉ាងណាក៏ខ្ញុំមិនអោយនាងស្លៀកពាក់រខេក
រខាកទៅបរិភោគបាយជាមួយខ្ញុំដែរ ។

CHANBOKEO.COM

ពូជីនហួថាទៅបរិភោគបាយ រាសីឯកឯងផ្ដើមយូបន្ទូរទ្រូង ។ ភ្លាមនោះនារីមួយរូបមកនាំរាសីចូលទៅសំអាងកាយ ។ មួយសន្ទុះ ធំក្រោយមក នាងក៏ចេញមកវិញ ។ ជីនហួដើបមើលមុខរាសី សម្លឹងនាងយ៉ាងភ្លន់ភ្លឹក ។ មែនហើយ! ធិតាយើងមានមុខមាត់ស្រស់ណាស់តើហ៍ សមនឹងរាងស្ដើងខ្ពស់ស្រឡះ លុះបានមកតុបតែងខ្លួនដោយក្រែមម្សៅនិងសម្លៀកល្អៗ សោភណ័របស់នាងក៏ អណ្ដែតឆ្ពោឡើងយ៉ាងត្រកាលមិនចាញ់តារាភាពយន្ដ វេតរតនា ឬ ចនចន្ទ័លក្ខិណានោះឡើយ ។ បន្តិចមកគេក៏នាំនាងសំដៅទៅ សាលប្រណិតមួយក្នុងសណ្ឋាគារផ្កាយប្រាំ ។

នៅទីនោះ នាងបានប្រទះឃើញពពួកពាណិជ្ជករមកជុំគ្នាកុះករ នៅសាលមួយដែលមានរៀបចំយ៉ាងប្រណិត សំរាប់ពពួកភ្ញៀវ អភិជន ដើម្បីជប់លៀងអាហារ ។ ជីនហួខ្សិបដាក់រាសីថា ៖

- នាងមិនបាច់និយាយអ្វីទេ គ្រាន់តែញញឹមដាក់ភ្ញៀវរបស់ខ្ញុំនោះ គ្រប់គ្រាន់ហើយ ធ្វើបានទេ?

រាសីងក់ក្បាល ។ នៅក្នុងចិត្ត ធិតាមានការភ្ញាក់ផ្អើលណាស់ចំពោះរាសីរបស់នាង ដែលកំពុងអណ្ដែតឡើងត្រដែត មកឃើញពិភពរស់នៅរបៀបពពួកអភិជន សំបូរដុល្លារចាក់ធារ ក្រាលផ្លូវ ថ្នល់ ។ ថ្ងៃនោះនាងរឹងខ្លួនណាស់ ត្បិតមិនធ្លាប់រៀបឥរិយាបថ របៀបពួកអ្នកមានម្ដងណាសោះក្នុងជីវិត ។ នាងបានលួចចោល កន្ទុយភ្នែកលួចមើលស្ត្រីឬនារីដទៃ ដែលមកបង្ហាញខ្លួនទីនោះដែរ ចង់ដឹងថាតើគេរៀបកិរិយា និយាយស្ដីចំពោះគ្នាយ៉ាងណា នឹងអាលរៀបឥរិយាបថរបស់នាងអោយចុះចំណោម ។ ថ្ងៃនោះជីនហួរវល់ ណាស់ តែគេក៏លួចញញឹមដាក់នាងមិនដាច់សោះ ទំនងហាក់ដុចជា រំភើបចិត្តដែលបានបណ្ដើរនារីមួយរូបក្បែរខ្លួនដែលមានសម្រស់ស្រស់សោភាមិនចាញ់នារីទាំងឡាយដែលនៅទីនោះឡើយ ។

រំពេចនោះ នាងក៏ឃើញថៅកែឌាំងនៅម្ដុំនោះដែរ ៖

- ពុទ្ធោអើយ! មនុស្សមារយាទអន់ៗដូច្នេះ ហេតុអ្វីក៏ក្លាយជា អភិជនអញ្ចឹងហ្ន៎? តើគេរកស៊ីអ្វី? ហេតុអ្វីក៏មានទ្រព្យដូចវែក ដំបូលចាក់?

ប៉ុន្តែនាងក៏ធូរពោះដែរ កាលបើដឹងថា នៅក្នុងចំណោមអភិជន នោះមានមនុស្សអន់ៗដូចថៅកែឌាំងមកចូលរួម ព្រោះនាងគិតថាហោចណាស់រូបនាងមានតម្លៃមានកិត្តិយស ផ្នែកសីលធម៌ខ្ពស់ជាង

ចៅកែខាំងដ៏សែនអប្រិយនោះដែរ ។ ថ្វីបើ ពេលនោះ ចៅកែខាំង បានស្លៀកពាក់ខោអាវមានតម្លៃយ៉ាងណាក៏ដោយ ក៏មិនអាចលាក់ មារយាទ និយាយឡូឡាខ្វាយទឹកមាត់របស់គាត់បានឡើយ ។

កាលបើក្រឡេកឃើញវត្តមានរាសីភ្លាម ចៅកែខាំងបើកភ្នែក ធំៗក្រលួង រត់មកចាប់ដៃជិនហ្វូរលាក់ ៖

- សួស្តីជិនហ្វូ! សុខសប្បាយទេ? ហើយចុះនេះ ពីណាគេដែរ? មុខដូចធ្លាប់ឃើញ ។

ចៅកែខាំងសួរជិនហ្វូផ្ទាច់ៗ រកតែជិនហ្វូឆ្លើយមិនចង់ទាន់ ។

- អូហ៍ នេះគឺ មិត្តរបស់ខ្ញុំ មកពីរោងចក្រជិនហ្វូ ។
- សួស្តីអ្នកនាង!

ចៅកែខាំងហុចដៃបំរុងចាប់ដៃជាមួយនាង តែរាសីបែរជាលើក ដៃសំពះតបទៅវិញ ៖

- ជំរាបសួរ ចា៎ស!

ចៅកែខកចិត្ត ដកដៃវិញ ឈរអេះអុញ តែក៏នៅធ្វើមុខខ្លាញ់ រដើម ចង់មករកញ៉ែរាសីដដែល ៖

- តើខ្ញុំមានដែលធ្លាប់ជួបនាងទេ? ព្រោះខ្ញុំមានអារម្មណ៍ថា យើង ធ្លាប់ជួបធ្លាប់ជួបគ្នានៅកន្លែងណាមួយពីមុនមក...

រាសីមិនឆ្លើយទេ បែរជាញញឹមឲ្យជិនហ្វូឆ្លើយជំនួស ។ នរៈ ហាក់ដូចជាយល់ក្រសែភ្នែករបស់នាង ក៏ឆ្លើយថា ៖

- ច្រឡំមនុស្សទេដឹង លោកខាំង! ព្រោះមិត្តខ្ញុំនៅធ្វើការរោងចក្រ ស៊ីងគ្មានពេលគេងទៅហើយ តើមានពេលអីចេញទៅក្រៅ ស្គាល់ លោកនោះ?

ចៅកែខាំងញោចស្មា ដែលជិនហ្វូការពាររាសីមិនអោយគាត់ ញ៉ែបាន ។ ភ្លាមនោះ គាត់ក៏ត្រូវគេម្នាក់អូសទាញទៅម្ខាងនិយាយ រឿងអ្វីផ្សេង ក៏បែកពីជិនហ្វូទៅ ។ ប៉ុន្តែមុននឹងបែកទៅ ចៅកែ ខាំងបានសរសេរចំណារតូចមួយហុចអោយជិនហ្វូ ទើបដើរគេច ទៅម្ខាង ។ ឃើញរាសីឈរសម្លក់ចៅកែខាំង ជិនហ្វូស្រដីថា ៖

- កុំប្រកាន់អី! គាត់ហ្នឹងពុលបាយពុលសម្លបែបហ្នឹង តាំងពីយូរ ហើយ មិនសូវមានមនុស្សល្អ ចូលចិត្តគាត់ប៉ុន្មានទេ ប៉ុន្តែគាត់ជា បុរសដែលពូកែខាងល្បិចរកស៊ី ទើបគេចេះតែនាំគ្នារាប់លេងទៅ កុំអោយខូចការងារជំនួញ ។

CHANBOKEO.COM

មើលទៅជិនហ្វូ និយាយដូចជាស្តាប់គ្នាបាន ខុសតែនាយជា មនុស្សម៉ៅស្និតបន្តិច ។ រាសីលាចិញ្ចើមមកវិញហើយតបថា ៖

- មិនអីទេ ជិនហ្វូ! ខ្ញុំមិនបានចាប់អារម្មណ៍អ្វីពីបុរសហ្នឹងទេ ។

ភ្លាមនោះ រាសីឃើញសារៈដើរចូលមកដល់តុដែលនាងនិងជិន ហ្វូអង្គុយ ។ គ្រាន់តែដាក់ភ្នែកចំធិតាយើងភ្លាម សារៈបើកភ្នែកធំៗ ទំនងភ្ញាក់ផ្អើល ដែលជិនហ្វូនាំនាងមកចូលរួមពិធីជួបជុំពាណិជ្ជករ អភិជននោះ ។ ម្យ៉ាង គេក៏ធ្វើទឹកមុខ ទំនងដូចជាឃ្នាន់ខ្នាញ់ក្នុង ចិត្តដែលជិនហ្វូបានកាត់មុខរបស់នាយ នាំខ្លួននារីដែលគេកំពុងតែ ចាប់អារម្មណ៍ មកបណ្តើរបង្អួតនាយវិញ ។

- សួស្តី សារៈ! ថ្ងៃនេះ មិនមានដៃគូមកជាមួយទេ? (ជិនហ្វូ ស្រដីរកសារៈ)
- សួស្តី ជិនហ្វូ! ខ្ញុំគ្មានដៃគូទេ ព្រោះគេរវល់ជាប់មានភ្ញៀវ ។

សារៈនិយាយផង លួចដៀងកន្ទុយភ្នែកទៅរាសីផង តែឆរីបែរ ជាធ្វើមិនដឹង ទុកឲ្យជិនហ្វូនិងសារៈប្រើកែវភ្នែកប្រយុទ្ធគ្នា ជំនួស វិញ ។ ការពិត ជិនហ្វូក៏ហាក់ដូចជាមិនសប្បាយចិត្តប៉ុន្មានដែរដែល សារៈចោលភ្នែកដាក់រាសីភ្លៀកៗមិនដាច់សោះ ។ គេជ្រួញចិញ្ចើម នឹកភ្នកចង់ដើបនាំរាសីគេចពីពិធីជប់លៀងនោះទៅហើយ ស្រាប់ តែមានបុរសពីរនាក់ដើរចូលមកដល់សាលប្រជុំ ក្នុងសម្លៀកស៊ីវិល យ៉ាងសង្ហា ។ ជិនហ្វូឃើញហើយក៏ធ្វើមុខស្រឡាំងកាំង ទំនងភ្ញាក់ ផ្អើល រួចហើយក៏កេះសារៈ សួរថា ៖

- សារៈ! បើខ្ញុំចាំមិនខុសទេ ពីរនាក់នោះគឺវរសេនីយសយនា និង វរសេនីយធូម៉ាន ដៃគូរបស់គេ ។

សារៈបែរមើលតាម ក៏លាន់មាត់ថា ៖

- មែនហើយ! គេមកបង្កប់ខ្លួនស៊ើបការណ៍រឿងអ្វីទេដឹង?
- ឬក៏គេមានមុខជំនួញ ត្រូវមកជួបជុំប្រជុំនៅទីនេះដែរ?

ជិនហ្វូសួរវិញ ។ សារៈគ្រវីក្បាល ៖

- ខ្ញុំមិនដឹងទេ! ប៉ុន្តែ ជិនហ្វូទៅខ្វល់ខ្វាយធ្វើអ្វី កាលបើយើងមិន បានរកស៊ីទុច្ចរិតអីផងនោះ?

ពេលនោះ ស្រាប់តែបុរសពីរនាក់នោះដាក់ភ្នែកមកចំជិនហ្វូ សារៈ និងរាសី ។ រាសីដើបមុខឡើងក៏ប្រទះនឹងក្រសៃភ្នែកសយនា ដែលសម្លឹងរូបនាងពីចម្ងាយដោយក្រសៃភ្នែកយ៉ាងមុត ធ្វើអោយ

CHANBOKEO.COM

នាងមានអារម្មណ៍ចម្លែកក្នុងខ្លួនយ៉ាងណាមិនដឹង ។ ភ្លាមនោះស្រាប់តែសយនានាំគូកនមកដល់តុរបស់នាង ៖

- សួស្តី លោកជិនហ្វូ! សួស្តី លោកសារ:!

បុរសទាំងបួនក៏ចាប់ដៃគ្នា ។ រាសីសង្កេតឃើញថា ម្តងនេះ បុរសទាំងអស់នោះមានកិរិយាប្រកបដោយពិរុទ្ធរៀងៗខ្លួន ប៉ុន្តែ គ្មាននរណានិយាយអ្វីសួរអ្វីតទៅទៀតទេ ក្រៅតែពីលួចសម្លឹងគ្នា ដោយកន្ទុយភ្នែកតែម្យ៉ាងប៉ុណ្ណោះ ។ មានកាល កន្ទុយភ្នែកទាំងនោះបានរត់មកដល់នាងទៀតផង ។ ប៉ុន្តែ រាសីធ្វើពើជាមិនដឹងអ្វី ហើយក៏អង្គុយធ្វើជាមិនចាប់ភ្លឹកនឹងវត្តមានរបស់អធិការពីររូប ក្នុង សម្លៀកស៊ីវិលនោះឡើយ ។

កម្មវិធីប្រជុំក៏ចាប់ផ្តើម ។ បន្ទាប់មក អ្នកបំរើក៏លើកអាហារមក ដល់ ។ ប៉ុន្តែ ភ្ញៀវដែលនៅអង្គុយតុរបស់នាងគ្រប់គ្នាមិនមានឮ ជជែកសើចក្អាកក្អាយដូចជាតុងទៃសោះ ឃើញតែគេនៅស្ងៀមៗ ធ្វើមុខញញឹមស្ងួតដាក់គ្នាប៉ុណ្ណោះ ។ យូរៗម្តង រាសីលួចសម្លឹងទៅសយនា ឃើញនាយចោលភ្នែកតែលើជិនហ្វូនិងសារ: ប៉ុន្តែ គេមិន សូវជាសម្លឹងនាងឡើយ មិនដឹងថា គេកំពុងអន់ចិត្តដែលនាងមក ជាមួយជិនហ្វូ ឬក៏គេធ្វើពើព្រោះគេកំពុងផ្ចង់អារម្មណ៍របស់គេនៅ លើរឿងដទៃផ្សេងទៀត ។

កម្មវិធីចប់ហើយ គេក៏បំបែកជួរ ។ ជិនហ្វូក៏នាំរាសីដើរត្រឡប់ មករករថយន្តវិញយ៉ាងរហ័ស ទំនងមិនចង់អោយនរណាចោលភ្នែក សម្លឹងមាណវីច្រើនពេកទេ ។ រំពេចនោះ ៖

- បងជិនហ្វូ!

សម្លេងស្រីម្នាក់ស្រែកហៅ ។ ជិនហ្វូនិងរាសីបែរមើលទៅនាង ឃើញសាវរីដើរចូលមកក្នុងមុខមាត់ចម្លែក ថ្វីបើនាងខំតាក់តែងកាយអោយដូចដើមវិញយ៉ាងណាក៏ដោយ ។

- សាវរី មែនទេ?

ជិនហ្វូលាន់មាត់ ជ្រួញចិញ្ចើម ។

- មែនហើយ! បងនៅចាំសាវរីដែរមែនទេ?
- ហើយសាវរីកើតអីហ្នឹង បានជា... ?
- គឺមកពី...

CHANBOKEO.COM

សាវរីទុកដ៏ក់ ដោយឃើញក្រសៃភ្នែករាសីកំពុងសម្លក់នាងពី ក្រោយខ្នងជិនហ្វមក ។ នាងក៏ដូរប្រយោគវិញភ្លាមថា ៖

- ខ្ញុំប្រើម្សៅលាបមុខខុស ទើបឈឺខ្លួនប៉ុន្មានថ្ងៃ... សាវរីនឹកបង ណាស់! ថ្ងៃនេះមានពេលអោយអូនដែរទេ ?

ជិនហ្វបែរមើលរាសី រួចហើយបែរមើលសាវរី ស្រាប់តែបុរស ចំណាស់ម្នាក់ដើរចូលមកដល់ ។

- លោកសារាយ! ជំរាបសួរ!

- អឺ! សុខសប្បាយទេ ជិនហ្វ ?

ការពិតនោះ គឺលោកសារាយឪពុករបស់សារៈនិងសាវរីទេតើ!

- មានពេលបន្តិចទេ ? ប៉ាសុំជជែកជាមួយកូនប្អូនដប់នាទី ។

ជិនហ្វសម្តែងអាការៈទើសទាល់ តែដោយគេខ្លាចចិត្តលោក សារាយ គេក៏ត្រូវបង្ខំចិត្តស្រដីទៅរាសីថា ៖

- នាងត្រឡប់ទៅរោងចក្រមុនបានទេ ?

រាសីងក់ក្បាល ។ រំពេចនោះ សារៈដើរមកដល់ល្មម ។

- សារៈជួយជូនរាសីត្រឡប់ទៅរោងចក្រវិញផងណា៎! ខ្ញុំមានការ ជាមួយសាវរីនិងលោកសារាយបន្តិច (ជិនហ្វស្រដីតឹង)

សារៈញញួរញ្ចោះក៏ញញឹមភ្លាមតែម្តង ។

- មិនអីទេ បាទ! ចាំខ្ញុំជូនទៅ ។

សារៈក៏នាំរាសីចេញទៅ ។ សាវរីឃើញរាសីចេញផុតក៏ញញឹម ភ្លែតតែម្តង ។ ចៃដន្យ សារៈទើបតែដើរបានប៉ុន្មានជំហាន លោក សារាយស្រែកឃាត់ថា ៖

- ប៉ាក៏ចង់និយាយជាមួយកូនម៉ាភ្លែតដែរ សារៈ ។ ឯងចាត់អោយ អ្នកណាម្នាក់ជូននាងទៅវិញទៅ ។

រាសីយល់ភ្លាម ថាលោកសារាយមិនពេញចិត្តអោយកូនប្រុស របស់លោកជូននាងត្រឡប់ទៅរោងចក្រវិញ ព្រោះនាងមានឋានៈ ត្រឹមតែជាអ្នកធ្វើការកំប៉ិកកំប៉ុក មិនសមនឹងអោយមេកោយឌូចនរៈ មកបើកឡានជូននាងទេ ។ ធិតាក៏ញញឹមឡើង ៖

- មិនអីទេ! ខ្ញុំជិះម៉ូតូឌុបក៏បាន!

សារៈសម្លឹងមុខនាង ហើយសួរខ្សិបៗថា ៖

CHIANBOKEO.COM

- ច្បាស់ហើយឬ ថាមិនអី ? បើយល់ថា គ្មានសុវត្ថិភាព ខ្ញុំជូន នាងចុះ ។ រឿងជាមួយលោកប៉ា ទុកឲ្យខ្ញុំដោះស្រាយតាមក្រោយ ។

- ច្បាស់ហើយ! លោកទៅជួបលោកប៉ារបស់លោកចុះ ។

ថាហើយ រាសីក៏បោះជំហាន ដើរចេញពីវាលចំណតឡាន មុខ សណ្ឋាគារ ហើយក៏ចេញក្រៅបងរកម៉ូតូឌុប ។ សារៈនិងជិនហួ នៅតែតាមសម្លឹងតាមនាងភ្លៀកៗ រហូតដល់បាត់ពីបរិវេណរបស់ សណ្ឋាគារនោះទៅ ។

រាសីកំពុងតែឈរវេរាចាំម៉ូតូឌុប ស្រាប់តែមានបុរសម្នាក់ជិះម៉ូតូ មកដល់ឈប់ដឹក ចំពោះមុខមាណវី ហើយបន្លឺវាចាថា ៖

- សួស្តីធិតារូបស្រស់! ចង់អោយខ្ញុំជូនទៅណាទេបាទ ?

រាសីងាកមើល ស្រាប់តែប្រទះនឹងសយនាកំពុងញញឹមពព្រាយ ដាក់នាងយ៉ាងស្រស់ ៖

- បងសយនា ?

- នៅស្គាល់បងដែរ រាសី ? ស្មានថាបានដើរជាមួយកម្លោះមហា សេដ្ឋី ភ្លេចអ្នកក្រដូចបងបាត់ទៅហើយ ?

- និយាយតែផ្តាស! ខ្ញុំមកនេះ ដោយការបង្ខិតបង្ខំពីចៅហ្វាយ នាយទេ! កុំច្រឡំ!

- អូហ៎ បើអញ្ចឹង បងធូរពោះបន្តិច ព្រោះសមត្ថភាពដូចបង មិនមានអ្វីអាចប្រជែងនឹងបុរសពីរនាក់នោះបានឡើយ ។

- និយាយអីផ្តេសផ្តាសហ្នឹង បងសយនា ? បងនិយាយបែបនេះ រាសីឈប់និយាយរកបងហើយ ។

មាណវីក៏ដើរគេចប៉េវចេញទៅ ។ វាសនាក៏ញញឹមហើយឆ្លើយ វិញថា ៖

- បើមិនមែនដូចបងថា រាសីចាំបាច់គេចមុខពីបងធ្វើអី ?

- ព្រោះមិនចូលចិត្តមនុស្សដែលគិតអ្វីមិនថ្លៃថ្នូរ...!

- អញ្ចឹង បងឈប់គិតដូច្នេះហើយ! ម៉ោះ! ឡើងជិះម៉ូតូមក៏!

រាសីញញឹមហើយបែរក្រោយភ្លាម ។ ថែដន្យ ពេលនេះ នាង ស្លៀកសំពត់ មិនអាចឡើងច្រកកៀវបានទេ ដូច្នេះត្រូវឡើងអង្គុយ ចំហៀងខ្លួនវិញ ។ ដោយនាងមិនធ្លាប់ ធិតាក៏ស្រវាអោបចង្កេះ បុរសយ៉ាងលឿន ត្បិតខ្លាចធ្លាក់ពីម៉ូតូ ។ ឃើញដូច្នោះ សយនាមាន កម្លាំងចិត្តប្រឹសតែម្តង ដែលបាននារីស្រវាកាន់ចង្កេះរបស់គេ ។

តាមផ្លូវ...

CHANBOKEO.COM

- អំបាញមិញ នៅក្នុងសាលជប់លៀង រាសីមិនមានញញឹមអ្វីដាក់ បងបន្តិចសោះ!
- ចេះតែថាហើយ! មិននឹងជានរណាគេទេហ្ន៎ ធ្វើមុខអោយមាំដាក់ រាសីវិញនោះ?
ឃើញហើយគួរអោយខ្លាចចិត្តគេណាស់!
- មកពីឃើញរាសីអង្គុយជាមួយបុរសសង្ហា ទើបគេមិនហ៊ានលួច ញញឹមដាក់នោះអី!
- មិនហ៊ាន ឬក៏កំពុងលួចខ្ពក់ក្នុងចិត្ត?
- ពុទ្ធោ! អីក៏មើលចិត្តបងធ្លុះម្ល៉េះ?
- ទាយលេងទេតើហ៏! រាសីមិនមែនជាហោរឯណា?
- តែបើរាសីអាចមើលយល់ចិត្តបងធ្លុះធ្លាយ នោះបងប្រហែលជា
សប្បាយចិត្តជាងនេះទៅទៀត ។

រាសីនឹកអៀនខ្លួនណាស់ ដែលសយនានិយាយផ្ទៃផ្កាអោយនាង ដូច្នេះ ។ នាងក៏លួចយកម្រាមដៃខ្ចាំចង្កេះគេខ្ចាប់ ។ នរៈភ្ញាក់ព្រើត យកដៃចាប់យ៉ាងលឿន ។ ដៃនិងដៃប៉ះគ្នា ។ អ្នកទាំងពីរបាន ទទួលអារម្មណ៍ចម្លែក ភាយៗក្នុងបេះដូង តែរៀងៗខ្លួន ។ រាសី រលាស់ដកដៃមកវិញយ៉ាងរហ័ស ស្រាប់តែម៉ូតូយោលយោគលែង មានលំនឹង ។ នាងក៏ប្រញាប់ចាប់កាន់ចង្កេះរបស់នរៈទប់ខ្លួនវិញ យ៉ាងលឿន ស្រាប់តែនាងឮសូរសំណើចខឹកៗមួយចេញពីក្រអូម មាត់របស់មាណព ។ ការពិត នរៈលលេងជាមួយមាណវីយើង ទេតើ ។ រាសីខ្ពាញ់ណាស់ ក៏ស្រដីថា ៖
- ស្អប់មុខមនុស្សខូចដូចបងសយនានេះមែនទែនតែម្តង ។

មាត់និយាយថាស្អប់ តែមុខវិញលួចញញឹមម្នាក់ឯង ដែលបាន នរៈលលេងនឹងរូបនាងដូច្នោះ ព្រោះកិរិយារបស់គេហាក់ដូចជា បង្ហាញប្រាប់នាងថា មាណពយើងកំពុងតែចាប់អារម្មណ៍លើនាង កាន់តែច្រើនហើយ ។

បន្តិចមក សយនាក៏បាននាំរាសីមកដល់រោងចក្រ ។
- ល្ងាចនេះ បងមកទទួលអូនទៅក្រៅម្តង! ចាំបងណា៎ រាសី! កុំ ណាត់ជាមួយនរណាទៀត បានទេ?

រាសីញញឹមហើយឆ្លើយថា ៖
- មិនធានាទេ ។ នរណាមកមុន អ្នកហ្នឹងហើយ ។
- ប៉ុន្តែ បងសង្ឃឹមថា រាសីនឹងចាំបងមិនខាន!
- នរណាប្រាប់?

CHANBOKEO.COM

នរៈយកដៃស្ដាំរបស់គេមកដាក់លើទ្រូងរបស់នាយ ឆ្លើយថា ៖

- បេះដូងបងនេះអី !

រាសីឈរសម្លក់ទាំងឃ្នាន់ខ្នាញ់ ដែលគេចូលចិត្តលេងចាប់ចំណុចខ្សោយក្នុងចិត្តរបស់នាង ។ សយនាក៏ញញឹមដាក់នាងយ៉ាង ត្រកាល ហើយក៏បត់ម៉ូតូត្រឡប់ក្រោយ ចេញទៅ ។

0000000000000000

00000

0

CHANBOKEO . COM

# វគ្គទី៨
# រាសីអណ្តែត

CHANBOKEO.COM

ឃើញបងស្រីស្លៀកពាក់រៀបខ្លួនយ៉ាងប្លែក រក្សាក៏សួរ ៖

- មានបុរសមកទទួលបងទៀតហើយហ្អេស បងរាសី ?
- ម៉េចក៏ប្អូនដឹង ?
- ព្រោះពីរបីថ្ងៃនេះ ដូចជា... ហ៉ឺសៗ សង្ស័យតែកន្លង់មាសទាំងនោះកំពុងឈ្លក់ស្នេហ៍បងស្រីរបស់ខ្ញុំទេ ។
- និយាយតែផ្ដាស ! មនុស្សមាត់ឆៅដូចបង នរណាគេមកចាប់ អារម្មណ៍នោះ ?
- មានតែមនុស្សបាតសង្គមទេ ដែលមិនចាប់អារម្មណ៍លើបងនោះ តែបើគេជាមនុស្សស្គាល់តម្លៃសីលធម៌មនុស្សធម៌ ខ្ញុំថាគេមិនមានមើលរំលងបងស្រីខ្ញុំជាដាច់ខាត ។
- មិនបាច់លើកកំពស់បងដល់ថ្នាក់ហ្នឹងទេ ។ បងគ្រាន់តែជាកម្មករ រោងចក្រមួយរូប គ្មានតម្លៃអ្វីអោយនរណាសម្លឹងមើលឡើយ ។
- ដឹងអីថា... រក្សាចាំតែមើលទេ ។
- អឺ បើអញ្ចឹងចាំទៀតទៅ !

រំពេចនោះ រក្សាឃើញមនុស្សម្នាក់មកដល់មាត់ទ្វារ ៖

- បងរាសី ! មានភ្ញៀវមករកបងហើយ !

រាសីងាកក្រោយ ឃើញសយនាឈរញញឹមសម្លឹងមកធិតាដែល ទម្លាក់កេសារំសាយ ពាក់អាវសសំពត់បត់ សមជាសុភាពនារី មិន ឆើតឆាយដូចកាលពីព្រឹកមិញ មិនរខេករខាកដូចរាល់ថ្ងៃ ដែលនាង ស្លៀកពាក់ទៅធ្វើការ ។

- បងសយនា ! ភ្លឹកអីហ្នឹង ? (រាសីសួរ)

- អូហ៍ អត់អីទេ! គឺបងភ្លឹកមើលគេម្នាក់ដ៏ស្រស់ស្អាតនោះអី!
- កុំលេងអញ្ចឹងមើល៍! ឈប់ទៅជាមួយឥឡូវហ្នឹង!
- មែនណា៎! រាសីស្មៀកពាក់អញ្ចឹងទៅ ដូចអ្នកគ្រូដល់ហើយ...
- តែខ្ញុំគ្មានសំណាងបែបនេះទេបង!
- គ្មាននរណាអាចមើលអនាគតឃើញទេ រាសី! ថ្ងៃក្រោយអូន
អាចក្លាយជាសាស្ត្រាចារ្យម្នាក់ក៏មិនដឹង ។
- រាសីសូមបន់អោយមាត់បងទិព្វទៅចុះណា៎!

គេក៏ញញឹមដាក់គ្នាឡើង ។
- រក្សា! មើលផ្ទះផងណា៎! យប់បន្តិច បងមកវិញហើយ ។
- បាទ! ទៅដើរលេងអោយបានសប្បាយណា៎បង ។

រក្សាឈរលើកដៃបងស្រី ដែលកំពុងឡើងជិះម៉ូតូចេញទៅ ជាមួយសយនា ទាំងទឹកមុខញញឹម ។

មួយស្របក់ក្រោយមក សយនាបាននាំរាសីមកដល់ផ្ទះឈើសង់ខ្ពស់ពីដីមួយនៅខាងលិចពោធិចិនតុងបន្តិច ។
- នេះជាផ្ទះរបស់បង មែនទេ?
- គឺផ្ទះរបស់ម៉ាក់បងណា៎! ម៉ោះ! ចូលទៅក្នុងផ្ទះសិនមករាសី!

រាសីដើរតាមក្រោយសយនាឡើងទៅដល់លើផ្ទះ ស្រាប់តែ ៖
- ប៉ា!

ក្មេងស្រីម្នាក់អាយុប្រហែល៥ឆ្នាំ រត់មកអោបជើងមាណព ។ រាសីភ្ញាក់ក្រញាង ៖
- នេះ គេមានប្រពន្ធកូនហើយមែនទេ? (រាសីនឹកក្នុងចិត្ត ហើយហាក់ដូចជាមានអារម្មណ៍ស្រកស្រុតភាពរីករាយនៅក្នុងចិត្ត យ៉ាង ណាមិនដឹងទេសោះ)

សយនាញញឹមហើយលើកនាងពឡើង ៖
- ស្រីខួច ញ៉ាំបាយហើយនៅហ្នឹង?
- ញ៉ាំរួចហើយ!
- ហើយចុះម៉ាក់យាយនៅឯណា?
- ចា៎ស នៅក្នុងផ្ទះ!

នាងតូចក៏បម្រះចុះពីដៃសយនា រត់ចូលទៅក្នុងផ្ទះ ៖

CHANBOKEO.COM

- ម៉ាក់យាយ ! ប៉ាមកវិញហើយ ! នាំម៉ាក់មីងមកផង !

នៅក្នុងផ្ទះ រាសីប្រទះនឹងស្ត្រីមួយរូបចំណាស់ម្នាក់ វ័យ ប្រហែលជាងហាសិប កំពុងអង្គុយដេរអាវ ។

- រាសី ! នេះ ម៉ាក់របស់បង ! (សយនាណែនាំ)

- ជំរាបសួរលោកអ៊ំ ! (រាសីលើកដៃសំពះ)

- អឺ ! ថ្វាយព្រះ ! ម៉ោះ ! អង្គុយចុះមក កូន !

ស្ត្រីចំណាស់នោះដាក់អាវចុះ ហើយក៏ហៅរាសីអោយចូលទៅ អង្គុយលេងលើក្តារជើងជិតគាត់ ។ រាសីក៏ដាក់ខ្លួនអង្គុយចុះ ទាំង ញញើតញញើម ព្រោះខ្លួនជាស្រីចូលមកលេងផ្ទះបុរសម្នាក់ជាលើក ដំបូង មិនដឹងថាគ្រួសាររបស់គេនោះមានអារម្មណ៍យ៉ាងណាចំពោះ វត្តមានរបស់នាង ។

- នាងឈ្មោះរាសីនោះមែនទេ ? (ស្ត្រីចាស់សួរ)

រាសីភ្ញាក់ព្រើតឆ្លើយឡើងថា ៖

- ចា៎ស ! លោកអ៊ំ !

- អឺ ! សយនាវានិយាយពីនាងប៉ុន្មានថ្ងៃជាប់គ្នាហើយ ទើបអ៊ំប្រាប់ អោយគេនាំកូនមកលេងម្តង ដើម្បីអោយស្គាល់គ្នា ។

- អូហ៍ ! និយាយពីខ្ញុំរឿងអ្វីទៅ លោកអ៊ំ ?

- គ្មានអ្វីអាក្រក់ទេ គេគ្រាន់តែថា គេបានជួបមនុស្សល្អ ចង់ណែនាំ ឲ្យអ៊ំស្គាល់ ។

រាសីនៅស្ងៀម លួចសម្លឹងសយនាដែលនៅអង្គុយប្រលែងជា មួយស្រីខួចក្បែរនោះ ។ គេអង្គុយញញឹម មិនមាត់មិនកអ្វីទេ ទុក អោយនាងនិយាយជាមួយម្តាយរបស់គេតែពីរនាក់ ។

- អ៊ីនែ៎ ល្ងាចនេះ យើងបរិភោគបាយជុំគ្នាណា៎ ! ព្រោះអ៊ំនេះខាន ទទួលទានបាយល្ងាចជាមួយកូនសយនាច្រើនថ្ងៃមកហើយ ។

ឮដូច្នោះ រាសីក៏លួចចោលកន្ទុយភ្នែកដាក់សយនាភ្លាម ។ មែនហើយ ! ប៉ុន្មានថ្ងៃជាប់ៗគ្នាកន្លងមកនេះ សយនាតែងតែទៅ បរិភោគបាយនៅផ្ទះរបស់នាង សឹងមិនលោះថ្ងៃសោះ សូម្បីតែ អាហារនោះត្រឹមជាបាយសម្រូបលក់រយតាមផ្លូវក៏ដោយ ។ ឃើញ រាសីលួចសម្លឹងមើលមុខនាយ សយនាក៏ញញឹមតបវិញ ទំនងចង់ ប្រាប់ថា រាសីជាមនុស្សម្នាក់ដ៏សំខាន់ក្នុងដួងចិត្តរបស់គេ ព្រោះគេ បានលួចគេចបាយល្ងាចពីមួយម្តាយ ដើម្បីមាណវី ។

CHANBOKEO.COM

រាសីស្ទុះដើបទៅជួយរៀបចំអាហារជាមួយអ៊ីសាវិនម្ដាយរបស់ សយនា ។ ព្រលប់នោះ នាងបានទទួលទានបាយឆ្ងាញ់ហើយពេញ ពោះជាលើកដំបូង ក្នុងរយៈច្រើនឆ្នាំកន្លងមក ម្យ៉ាងដោយសារអ៊ី សាវិនហាក់ដូចជារួសរាយរាក់ទាក់រូបនាងផង ។ ចំណែកអាហារ ថ្ងៃនោះក៏ប្លែកមាត់ហើយឆ្ងាញ់ផង ។ តែលុះឃើញសយនាចេះតែ លួចតាមសម្លឹងនាងពេក ធិតាក៏រអៀសខ្លួនលែងហ៊ានចិតផ្លែឈើ បរិភោគលាងមាត់ ព្រោះខ្លាចនាយចំអន់ថា នាងបរិភោគច្រើនខុស ធម្មតា ។

នៅក្នុងបន្ទប់ទទួលភ្ញៀវ...

អ៊ីសាវិនក៏មានប្រសាសន៍ឡើងថា ៖

- សយនាគេធ្វើការយូរហើយ ប៉ុន្តែទើបតែឡើងសក្តិជាវរសេនិយ ពេលថ្មីៗនេះឯង.. នាងអើយ! វាត្រង់ស៊ូយូណាស់ មិនចេះលួចស៊ី សំណូកអីខ្លះទេ ធ្វើការធំតែមុខ តែគ្មានលុយគ្មានទ្រព្យអ្វីដូចគេ សោះ រកតែលុយ ទិញសាំងចាក់ម៉ូតូមិនគ្រប់ផង (អ៊ីសាវិនពោល)

- ម៉ាក់! កុំមានប្រសាសន៍អញ្ចឹងអី! រាសីគេមិនចង់ដឹងរឿងកូន ប្រុសរបស់ម៉ាក់របៀបហ្នឹងទេ ។

ភ្លាមនោះ អ៊ីសាវិនក៏ដូរប្រយោគ ហើយបែរមកសាកសួរប្រវត្តិ របស់នារីយើងវិញ ។ ធិតាក៏ឆ្លើយទៅវិញតាមដំណើរ ។ ពេលនោះ រាសីចាប់អារម្មណ៍ភ្លាមថា អ៊ីសាវិនកំពុងឈ្លេចជីវប្រវត្តិរបស់នាង ដើម្បីកូនប្រុសរបស់គាត់ ។ ធិតាបានតាំងចិត្តយ៉ាងក្លាហាន ហ៊ាន និយាយការពិតទាំងអស់ជំរាបគាត់ ដោយឥតមានលាក់លៀមអ្វី ឡើយ ។ គ្រាន់តែឮថាឪពុកម្ដាយរបស់នាង បានទទួលមរណភាព ដោយជំងឺអេដស៍ អ៊ីសាវិនប្រែទឹកមុខភ្លាមតែម្ដង ។ ចំណែកឯ វាសនាវិញបែរជារក្សាឥរិយាបថនឹងធម្មតា ។ ចៃដន្យរាសីមិនដែល ចូលចិត្តកុហកនរណា ដើម្បីស្វែងរកប្រយោជន៍ សម្រាប់ខ្លួននាង ឡើយ ហើយក៏មិនអាមាសនឹងអតីតកាលរបស់នាងដែរ ព្រោះនាង គិតថាខ្លួនមិនបានប្រព្រឹត្តនូវកំហុសស្មោគគ្រោកនោះទេ ។ គឺឪពុក នាងទេតើ ដែលប្រព្រឹត្តនូវក្ដីអាមាសទាំងនោះ ។  បើសិនណាជា អ៊ីសាវិនទទួលរាប់អានរូបនាងមិនបាន ធិតាក៏មិនស្រេកស្រុតកម្លាំង ចិត្តដែរ ព្រោះនាងបានត្រូវសង្គមច្រានចោលរហូតដល់ធ្លាប់ខ្លួន រួចទៅហើយ ។ អ្វីដែលនាងគិតពេលនេះ គឺ... ការបោះជំហានទៅ មុខ

CHANBOKEO.COM

ជនៈនូវការសើចយំរបស់សង្គម ដើម្បីបញ្ជាក់បង្ហាញថា អ្នក ដែលមានជំងឺអេដស៍ទាំងឡាយ មិនមែនសុទ្ធតែជាមនុស្សអាក្រក់ ប្រព្រឹត្តអាក្រក់ មារយាទអាក្រក់ទាំងអស់នោះទេ ។ ជួនកាល គេ ទាំងនោះគ្រាន់តែជាជនរងគ្រោះ ដោយបុព្វហេតុចៃដន្យប៉ុណ្ណោះ តួយ៉ាងរូបនាងជាដើម ។ នាងជាជនរងគ្រោះអំពីអំពើពាលកម្លៅ របស់ឪពុកនាងប៉ុណ្ណោះ ហេតុអ្វីសង្គមត្រូវស្អប់ខ្ពើមនាងផង កាល បើនាងមិនដែលប្រព្រឹត្តអំពើពាលម្តងណាសោះ ?

វេលាចុងក្រោយនៃការសំណេះសំណាល រាសីមានអារម្មណ៍ថា អឺសាវិនម្តាយសយនារន្ធត់ចិត្ត ហើយភ្ញាក់ផ្អើលណាស់ ចំពោះប្រវត្តិ អតិតកាលរបស់នាង មិនទាន់អាចទទួលយកបានឡើយ ។ នាង មិនហ៊ានរំខានចិត្តម្ចាស់ផ្ទះ ក៏សុំខ្លួនត្រឡប់មកផ្ទះវិញ ។

តាមផ្លូវ អ្នកទាំងពីរមិនបានជជែក សើចកក្អឹកដូចកាលពី ព្រលប់នោះឡើយ ។ លុះមកដល់មាត់ច្រកចូលផ្ទះរាសី...

- បងសយនា!
- បាទ!
- ហេតុអ្វីធ្វើមុខហាក់ដូចជាមិនរីករាយអ្វីសោះ ?

សយនាសម្លឹងមុខនារីមួយស្របក់ ក៏ឆ្លើយវិញថា ៖

- ហេតុអ្វីមនុស្សល្អដូចរាសី បែរប្រទះជីវិតអភព្វយ៉ាងនេះផង ?

រាសីរំជួលចិត្តភ្លាមតែម្តង កាលបើឮនរៈពោលដូច្នោះ ។

- រាសីកំពុងហែលឆ្លង ទៅរកភាពសំបូរសប្បាយវិញហើយតើហ៍ ព្រោះពេលនេះ ខ្ញុំមានការធ្វើជាប់លាប់ហើយ ។
- ប៉ុន្តែ អូនត្រូវតែឧស្សាហ៍ទៅពិនិត្យរោគម្តងម្កាលផងណា៎!

ពេលនោះ រាសីយល់ភ្លាមថានរៈចង់និយាយពីជំងឺអេដស៍ ។ នាងនៅស្ងៀមមិនហ៊ានឆ្លើយ ព្រោះមិនដឹងជាត្រូវឆ្លើយយ៉ាងណា ។

- បើបងនាំអូនទៅពេទ្យ អូនព្រមទៅទេ ? (សយនាសួរ)
- គឺ... ខ្ញុំគ្មានលុយទេបង!
- ចុះបើបងរកជំនួយបាន ?
- គឺ... ចាំដល់ពេលនោះ ចាំគិតទៅ ។
- តែកុំចាំយូរពេក ក្រែងហួសពេលព្យាបាលណា៎!

ឃើញនរៈហាក់ដូចជាយកចិត្តទុកដាក់នឹងរូបនាង រាសីញញឹម ឡើង ស្រដីថា ៖

CHANBOKEO.COM

- ទោះបីជាយ៉ាងណា រាសីមិនអោយមនុស្សដែលមានសមានចិត្ត ចំពោះរាសី ខកសង្ឃារបស់គេម្ដងណាឡើយ ។

សយនាញញឹម ហើយចាប់ដៃនាងកាន់យ៉ាងណែន ៖

- សង្ឃឹមថា រាសីនឹងមានអនាគតល្អហើយមានអាយុវែង ។

គ្រាន់តែបានទទួលកំដៅពីបាតដៃសយនា រាសីមានកម្លាំងចិត្ត ប្រឹសតែម្ដង ៖

- រាសីអាយុវែងណាស់ មិនទៅណាចោលបងងាយៗឡើយ ។

សយនាញញឹមទាំងទឹកភ្នែករលីងរលោង ទំនងហាក់ដូចជានឹក អាសូរធិតាយើង ដែលមានជីវិតអភព្វមកទទួលរងគ្រោះពីអំពើ កម្លៅរបស់ឪពុកនាង ។

- ស្អែក បងមកបរិភោគបាយជាមួយអូនទីនេះ ចាំបងផងណា៎!

រាសីញញឹមតបវិញ ។ បន្តិចមក សយនាក៏លើកដៃអង្អែល កេសានារីសំដែងក្ដីអាណិតស្រឡាញ់នៅក្នុងចិត្តរបស់គេ រួចហើយក៏ បញ្ឆេះម៉ូតូចេញទៅ ។

ថ្វីបើយប់នោះ រាសីបានប្រទះនូវភាពរំជើបរំជួលក្នុងចិត្តខ្លះៗ ក៏ដោយ ក៏រាសីតាំងចិត្តយ៉ាងរឹងមាំថា នាងមិនព្រមចុះចាញ់ព្រហ្ម លិខិតឡើយ ។ នាងនឹងតស៊ូរហូតគ្រាចុងក្រោយរបស់នាង ថាអ្នក ដែលរងគ្រោះដោយជំងឺអេដស៍ មិនមែនសុទ្ធតែជាជនកម្លៅចោល មៀតដូចសង្គមថ្កោលទោសនោះឡើយ ។ ពេញមួយរាត្រី រាសី គេងគងថ្ងាសគិត រៀបដំណើរជីវិតរបស់នាងសំរាប់ថ្ងៃស្អែកតទៅ ទៀត...

ព្រឹកឡើង...

នៅក្នុងរោងដេរលេខប្រាំ...

- ហេតុអ្វីគេនាំគ្នាសម្លឹងមុខខ្ញុំម្ល៉េះ បងសុផា ?

- គឺមកពីគេឃើញជិនហ្វួយកចិត្តប្អូននោះអី រាសី!

- គ្រាន់តែគេខ្ចីដៃប្រើម៉ាង៉ែទេ បង ព្រោះសង្សារគេមិននៅ ។

- ចុះបើគេខ្ចីដៃរហូតម៉ាជីវិតនោះ ប្អូនឯងគិតយ៉ាងណា ?

- ស្លាប់ហើយ រាសីមិនហ៊ានគិតទេ ។ ជិនហ្វួជនជាតិបរទេស ជា ថៅកែអ្នកមានយ៉ាងនេះ គេមិនមកមើលមនុស្សដូចខ្ញុំទេ ម្យ៉ាង ទៀត គេជាមនុស្សកំណាញ់ម៉ៅស្វិតយ៉ាងនេះ រាសីមិនហ៊ានលែង ចូលឡើយ ព្រោះខ្ញុំស្អប់មនុស្សកំណាញ់ម៉ៅស្វិតណាស់ ។

CHANBOKEO.COM

រំពេចនោះ ស្រាប់តែសុផាបិទមាត់ឈឹង ឈ្ងោកមុខចុះ រត់ធ្វើ ការញាប់ដៃញាប់ជើងភ្លាម ។ រាសីនឹកឆ្ងល់ក៏បែរមើលក្រោយស្រាប់ តែឃើញជិនហួមកឈរពីក្រោយខ្នងរបស់នាង លួចស្តាប់ការដេរដែក គ្នារបស់នាងនឹងសុផា តាំងពីអង្កាល់ណាមកមិនដឹង ។

- អស់អីនិយាយហើយនៅ ? បើអស់ហើយ ខ្ញុំត្រូវការនិយាយជា មួយនាង!
- អូហ៍! អ្វីទៀតហើយ ? (រាសីញាក់មុខ)
- ចេញទៅជជែកនៅក្រៅបានទេ ព្រោះខ្ញុំមិនចង់មានអ្នកទីបីនឹង ឮរឿងខ្ញុំជជែកជាមួយនាងទេ ។

រាសីធ្វើអេះអុញ ព្រោះនាងមិនចង់មានចំណងអ្វីពាក់ពន្ធ័នឹង ថៅកែក្មេងម្នាក់នេះទេ ។

- ម៉េចទៅឬមិនទៅ ?
- សុំមិនទៅបានទេ ?
- នេះ នាងចង់ប្រកែកនឹងថៅហ្វាយនាយផងហ្ន៎ស ?
- បើនិយាយរឿងការងារ ខ្ញុំចាំបាច់ត្រូវតែធ្វើតាមហើយ ប៉ុន្តែបើ ជជែករឿងផ្ទាល់ខ្លួន ខ្ញុំមានសិទ្ធិមិនទទួលសំណើរបស់លោក ។

ពេលនោះ ជិនហួចាញ់សំដីរបស់ស្រីក្មេងទៀតហើយ ។ គេអែ អង់មួយស្របក់ក៏ចាប់អូសដៃនាងរឹង ៖

- នែ៎! នាំខ្ញុំទៅណា ? ខ្ញុំមិនទៅទេ!
- មាត់ច្រើនពេក តិច!
- តិចច្រើនអី! ថាមិនទៅ គឺមិនទៅហើយ ។
- ចចេសផងហ្ន៎ស! តិចថាពិបាកត្រូវថ្នាំខ្លាំង!

ជិនហួស្រវាអូសដៃនាងរឹង ស្រាប់តែមានរថយន្តមួយចូលមក ដល់ នាំមនុស្សបីនាក់ចូលមកដល់ ។

- បងជិនហួ!

រាសីងាកមើលឃើញសាវរីចុះមករកជិនហួយ៉ាងរហ័ស ។ នាង ធូរទ្រូងខ្យាក ព្រោះនាងមិនបានរំភើបចិត្តនឹងថៅកែចិនមួយរូបនេះ ទេ មើលទៅគេដូចជាអាត្មានិយមណាស់ មិនទន់ភ្លន់ហើយមិនស្ងួរ ចេះយកចិត្តនារីទៀតផង ។ គេស្គាល់តែអារម្មណ៍របស់គេ ជាធំ ប៉ុណ្ណោះ ។ ថ្វីបើគេបានបន្ទន់ឥរិយាបថដាក់រាសីខ្លះ ប៉ុន្តែនារីយើង នៅតែមានអារម្មណ៍ថា គេវាយឫកឆ្មើងឆ្មៃដល់ស្ទូរហើយ ។

CHANBOKEO.COM

សាវ័រីអួសដៃជិនហ្វពីរាសីផង លួចសម្លក់នាងផង ។ មើលចុះ សូម្បីតែខំទៅខាត់ខ្លួន កាត់សក់ថៃមុខ មួយថ្ងៃមួយយប់មកហើយ សាវ័រីមិនទាន់ប្រែរូបប្រសើរជាងមុនប៉ុន្មានទេ នៅតែហើមមុខស្ដើង មើលមិនយល់ដដែល មិនសមជាសាវ័រីដែលគេធ្លាប់ស្គាល់ពីមុន មកនោះទេ ។ បន្តិចមក សាវ័រីក៏អូសដៃជិនហ្វគេចទៅបាត់ ។

ភ្លាមនោះ រាសីឃើញនាយសារៈនិងលោកសារាយជាឪពុក កំពុងចុះពីរថយន្ត ។ នាងក៏ឈ្ងោកមុខ ដើរគេចទៅធ្វើការវិញ ។

- ឈប់សិន! យើងចង់និយាយជាមួយនាង! (លោកសារាយមាន ប្រសាសន៍ឃាត់រាសី)

នាងទុចដ៏ក់ បែរក្រោយភ្លាម ។ កម្មករក្នុងរោងដេរលេខប្រាំ បែរមើលមកនាងដោយក្រសៃភ្នែកងឿងឆ្ងល់គ្រប់គ្នាថា ហេតុអ្វីក៏ មាណវីយើងបានទទួលការចាប់អារម្មណ៍ ពីពពួកក្បាលកំពូលរបស់ រោងចក្រគ្រប់គ្នា អញ្ចឹង ?

- ចាស ? លោកមានការប្រើខ្ញុំរឿងអ្វីមែនទេ ? (រាសីសួរ)

- ដើរមកតាមយើង មក់!

ឃើញទឹកមុខដ៏មាំរបស់លោកសារាយ ធិតានឹកភ័យជ្រួចក្នុង ពោះ មិនដឹងថា លោកហៅនាងទៅធ្វើអី ។ រាសីក៏បោះជំហានតាម ពីក្រោយលោកសារាយដោយមានសារៈដើរទប់ខ្លួននឹងឈើច្រត់តាម មកផង ។ លុះមកដល់បន្ទប់ការិយាល័យរបស់នាយសារៈ លោក សារាយក៏បញ្ជាអោយសារៈបិទទ្វារ ។ រាសីងាកមើលឆ្វេងស្ដាំ រួច ហើយក៏តាំងចិត្តក្លាហាន សួរថា ៖

- លោកចង់សួរខ្ញុំ ពីរឿងអ្វីមែនទេ ?

រាសីនឹកថា ប្រហែលជាលោកសារាយចង់សួរនាងពីរឿងសាវ័រី ហើយមើលទៅ ដែលនាងបានឃាំងទុកធ្វើបាបអស់ពីរបីថ្ងៃ ។

- គឺយើងចង់សួរនាងពីរឿងឯកសារ១០សន្លឹក!

មាណវីភ្ញាក់ព្រើតដែលលោកសួររឿងផ្សេង ។ ធវីក៏ឆ្លើយថា ៖

- ឯកសារ១០សន្លឹក ? ១០សន្លឹកស្អីទៅ ? ខ្ញុំមិនបានដឹងទេ!

លោកសារាយសម្លឹងមុខកូនប្រុស ។ សារៈឃើញក្រសៃភ្នែក ឪពុក ក៏បែរមើលនារីហើយវាចាថា ៖

- រាសី! ឯកសារ១០សន្លឹកនោះសំខាន់ណាស់ សំរាប់អាយុជីវិត របស់រោងចក្រនេះទាំងមូល ។ នាងដឹងទេ ថាបើរោងចក្រនេះរលំ ដួល តើកម្មករប៉ុន្មានពាន់នាក់នឹងអត់ការធ្វើ ?

ហើយក្រុមគ្រួសារ របស់កម្មករប៉ុន្មានពាន់ ដែលនឹងត្រូវទទួលរងគ្រោះដោយសារការ
រលំដួលរបស់រោងចក្រនេះដែរ ?

- រលំដួលរឿងអី ? ធ្វើអ្វីខុសច្បាប់មែនទេ ទើបរលំដួល កាលបើ
កម្មករខំធ្វើការវេទនាយ៉ាងហ្នឹង ? ឬក៏ចៅកែចាញ់ល្បែង ?

- នាងឆ្លាតណាស់តើ រាសី! ហ៊ានទាយស្ថានការណ៍រោងចក្រដោយ ត្រង់ៗយ៉ាងនេះ ។ ម៉េច ?
ពេលនេះ នាងអាចប្រាប់យើងបានទេ ថា ឯកសារ១០សន្លឹកនោះនៅឯណា ?

- ខ្ញុំជំរាបហើយតើហ៍ថា ខ្ញុំមិនដឹងទេ ។

- កុំប្រកែក! នៅថ្ងៃដែលជិនហួដើរចេញពីមន្ទីរប្រជុំមក គេមិន បានទៅឯណាទេ
ក្រៅតែពីទៅជួបសាវរី រួចហើយក៏មានគ្រោះថ្នាក់ ពេលនោះ
នាងក៏ជាមនុស្សតែម្នាក់ដែលបានមកជួយជិនហួ រួចក៏ បានជួយយូរសំពៀតធ្វើការនោះអោយគេ!

- តែជិនហួបាននាំពូសៀកនិងដៃជើងប្អូនដប់នាក់ ទៅឆែកផ្ទះខ្ញុំ ឃើញនឹងភ្នែកហើយតើហ៍
ថាខ្ញុំគ្មានរបស់នោះទេ ។

លោកសារាយអង្គុយសម្លឹងមុខធិតាមួយស្របក់ក៏ស្រដីថា ៖

- តើនាងចង់បានប្រាក់ប៉ុន្មានដែរ ?

- ប្រាក់ខែធ្វើការខាងអ្វីទៅ ?

- ថ្លៃពតិមានដែលជាប់ទាក់ទងនឹងឯកសារ១០សន្លឹកនោះ ។

- ស្លាប់ហើយ បើដេកចាំទទួលប្រាក់ហ្នឹងយកទិញបាយទទួលទាន នោះ
ខ្ញុំច្បាស់ជាត្រូវដាច់ក្រពះស្លាប់មិនខាន ព្រោះខ្ញុំមិនដឹងពិត មែន ថាឯកសារនោះនៅឯណា ។

លោកសារាយទះតុផាំង ៖

- កុហក!

- កុំប្រើកម្លាំងបាយអី ចាស ព្រោះវាមិនបានធ្វើអោយខ្ញុំព្រឺរអារអី បន្តិចឡើយ ។
កម្លាំងបាយជាមធ្យោបាយយកឈ្នះ របស់មនុស្ស អវិជ្ជា អាប់ប្រាជ្ញទាំងឡាយនោះទេតើហ៍ ។
ឬមួយក៏លោកចង់ សម្តែងថាលោកក៏ជាមនុស្សម្នាក់ ក្នុងចំណោមពួកកម្លៅអវិជ្ជាទាំង
ឡាយនោះដែរ ? (រាសីតបទៅវិញដោយឥតព្រឺរអារ)

- ព្រហើន! ឆាប់បិទមាត់!

- មិនបិទ!

- តើអ្វីទៅដែលអាចធ្វើអោយនាងបើកមាត់បាន ? (លោកសារាយ គំហក)

CHANBOKEO.COM

- គឺប្រហែលជាសីលធម៌និងការគោរពចំពោះភាពជាមនុស្សដូចគ្នា ទេដឹង លោកសារាយ!
- មាត់បានណាស់ នាងច្រមក់!

ទោះជាប្រឹងគំហកកំហែងរាសីយ៉ាងណា ក៏លោកសារាយមិន
បានទទួលជោគជ័យដូចបំណងដដែល ។ បន្តិចមក លោកក៏បន្ធូរ បរិយាកាសមកវិញ ៖

- ដឹងទេ ថា យើងនឹងជិនហួ ចូលហ៊ុនគ្នាម្នាក់ពាក់កណ្ដាល ដើម្បី បើករោងចក្រជិនហួនេះ ?
- អត់ដឹងទេ ចា៎ស!
- បើអញ្ចឹងដឹងអោយហើយទៅ ។ បើកាលណាភាគហ៊ុនណាមួយ
ត្រូវរលំដោយប្រការមិនគប្បីណាមួយ វាអាចធ្វើអោយរង្គោះរង្គើ រោងចក្រទាំងមូលបាន ។
- ជារឿងរបស់លោកតើហ៎! ទាក់ទងអីនឹងខ្ញុំផង ?
- តែក៏ជារឿងរបស់នាងដែរ ?
- ហេតុអ្វីទៅ ? ខ្ញុំគ្មានភាគហ៊ុននៅក្នុងនេះទេ ។
- ព្រោះនាងនឹងអត់ការធ្វើ!
- អត់កន្លែងមួយ នៅកន្លែងមួយទៀត ទៅខ្វះអី អោយតែមាន ចិត្តចង់ធ្វើការ ។
- ហ៊ឺយ! នាងអើយ! និយាយសាច់ការបន្តិចមើល៍!
- កំពុងសាច់ការហើយតើហ៎ លោកសារាយ ។
- ចុះបើយើងតម្លើងរូបនាងជាប្រធានកម្មករក្នុងរោងដេរលេខប្រាំ
តើនាងព្រមជួយយើងពីរឿងឯកសារ១០សន្លឹកនោះទេ ?
- ជាឯកសាររបស់លោកជិនហួ តើអោយខ្ញុំធ្វើម៉េចយកបានទៅ ?
- គឺប្រើប្រាជ្ញារបស់នាងនោះអី ?
- ហើយចុះម៉េចក៏លោកមិនព្រមប្រើសមត្ថភាពរបស់លោក ជាអ្នក
កាន់ភាគហ៊ុន៥០ភាគរយនោះវិញទៅ ? ខ្លាចអីហ្នឹង ?

លោកសារាយញាក់មុខ ៖

- បើយើងធ្វើកើត យើងធ្វើយូរណាស់ទៅហើយ មិនចាំបាច់ប្រើ នាងទេ ។

រាសីបែរមើលលោកសារាយ រួចហើយមើលសារៈ ទំនងចង់ ដឹងពីចិត្តថ្លើមរបស់គេ ។ ថ្ងៃមុន
នាងធ្លាប់ត្រូវពីរកំភ្លៀងយ៉ាងធ្ងន់ ពីសារៈ នៅឈឺមាត់មិនទាន់បាត់ផង
តើអោយនាងរំសាយចិត្តខឹង ដោយងាយយ៉ាងម៉េច គ្រាន់តែគេមកជប់លៀងបាយមួយពេល
ហើយប្រើពាក្យសូមទោសមួយម៉ាត់នោះ ? ដូចជាមិនងាយស្រួល ដល់ម្លឹងឡើយ ។

CHANBOKEO.COM

ចុះលោកសារាយវិញ ? គ្រាន់តែគេមានឋានៈ ជានាយកោយដ៏ឧត្ដុង្គឧត្ដមម្នាក់ សុខៗក៏ហៅនាងមកសម្លុត ដូច កូនក្មេងបៀមដៃ ស្មានថា ធិតាយើងខ្លាចការសម្លុតនោះណាស់ អញ្ជឹង ? មិនឡើយ... ចាំទុកទៅ! ធិតាយើងមិនតក់ស្លុតដូចអ្នក គិតទេ! រាសីមិនមែនជាមនុស្សឲ្យគេខាំនាងលេងស្រួលៗដែរ! ពួកគេត្រូវតែសងនាងគ្រប់គ្នា ជាពិសេសគឺនរណាដែលមានគំនិត មានកិរិយាមិនល្អមកលើនាង ។

- ទៅចាក់ទឹកផ្លែឈើទទួលនាងបន្ដិចទៅ សារៈ ។

លោកសារាយបញ្ជា ។ សារៈក៏ដើបប្រុយ ទៅយកមកយ៉ាង លឿន តែនាងគ្រវីក្បាល ៖

- អរគុណហើយ! ខ្ញុំមិនហ៊ានទម្លាប់ខ្លួនបរិភោគរបស់ល្អៗទេ ត្បិត ថ្ងៃក្រោយ បើឃ្លានបរិភោគ ខ្ញុំច្បាស់ជារកប្រាក់ទិញមិនបានទេ ។

លោកសារាយសម្លឹងមុខនារីដែលមានចិត្តរឹងត្អឹងមិនព្រមញញោច នឹងស្ថានការណ៍ជុំវិញខ្លួននាង ។ បន្ដិចមក លោកក៏ស្រដីថា ៖

- ចុះបើយើងដកសារៈចេញ ហើយដាក់នាងជានាយចំណាត់ការទី នេះជំនួសវិញ តើនាងយល់យ៉ាងណាដែរ ?

- ពុទ្ធោ! ខ្ញុំរៀនមិនចប់មធ្យមសិក្សាផង តើមានសមត្ថភាពអីនឹង កាន់ការត្រួតត្រាមនុស្សរាប់ពាន់នាក់នោះ ? អូហ៍... នែ៎! នែ៎ សូម សួរបន្ដិចបានទេ ? ថ្ងៃមុន កូនប្រុសរបស់លោកទះកំភ្លៀងខ្ញុំពីរដៃ មិនទាន់បាត់ឈឺមុខផង ហេតុអ្វីថ្ងៃនេះ លោកជាមកមកចាប់បង្ខំខ្ញុំ តម្លើងបុណ្យសក្ដិអញ្ជឹង ? រឿងនេះ គិតទៅចម្លែកណាស់! កូន ក្មេងដូចខ្ញុំនេះ ពិតជាតាមមិនទាន់ល្បិចកលរបស់លោកទ ។

សារៈភ្ញាក់ព្រើតដែលនាងស្រដីរ៉ូងរ៉ាំងប្រាប់ឪពុករបស់នាង ។ លោកសារាយក៏ភ្ញាក់ក្រញាងដូចគ្នាដែរ ។ លោកដោះវ៉ែនាតាសម្លឹង មុខសារៈ ៖

- កូនបានធ្វើដូច្នោះ មែនឬសារៈ ?

សារៈនៅស្ងៀម ឈ្ងោកមុខមិនស្ដី ។ រាសីឆ្លើយជួសភ្លាមថា ៖

- គឺមកពីកាលនោះ ខ្ញុំបានជំទាស់មិនអោយលោកសារៈចាប់សំរាត នារីកម្មករទាំងអស់នោះ ដែលជាប់សង្ស័យថាជាមនុស្សលួចឥវ៉ាន់ នៅក្នុងរោងចក្រ ។

- អីក៏ប្រព្រឹត្តដល់ម្លឹងផង សារៈ ? បើឯងភ្លើតភ្លើននឹងរូបកាយ អាក្រាតរបស់នារី ម៉េចមិនទៅរកនៅខាងក្រៅវិញទៅ ? ហេតុអ្វីក៏ បង្កអោយមានរឿងរ៉ាវដូច្នេះ

នៅក្នុងរោងចក្ររបស់យើងអញ្ចឹង ?
ឯងខ្វះមធ្យោបាយរកស្រីមកបំរើអារម្មណ៍របស់ខ្លួនណាស់មែនទេ ?

សារៈឈ្ងោកមុខនៅស្ងៀមដងដែល ។ មែនហើយ! ថ្ងៃនោះ គេ ផឹកស្រា
អានសៀវភៅទស្សនាវដ្តីអាក្រាត រួចហើយក៏ទប់អារម្មណ៍
មិនជាប់ទើបភ្លាត់ប្រើល្បិចព្រើលៗនោះ បំពាននារីកម្មករលេងៗ ទៅ
ព្រោះអាងតែរូបគេជាកូនចៅកែ គ្មាននរណាហ៊ាន អ៊ឺះ តបត នឹងគេវិញ ។ ពេលនេះ
គេត្រូវឪពុកស្តីអោយនៅចំពោះមុខនារី ក្មេងម្នាក់
ដែលបានជេររូបនាយយ៉ាងអស់ចិត្តកាលពីថ្ងៃមុន ។ គេ ហាក់ដូចជាមានអារម្មណ៍ថា
ខ្លួនកំពុងតែដើរជាន់កត្តិយសខ្លួនឯង អោយលិចជ្រាំ ដូចរាសីថាមែនហើយ ។

- សារៈ! ឯងមិនត្រឹមបំពានលើសិទ្ធិនិងភេទរបស់នារីទេ ឯង
ហ៊ានទាំងប្រើកម្លាំងបាយបំបិទមាត់អ្នកតវ៉ាទៀត ? ប៉ាសោកស្តាយ ខ្លាំងណាស់ដែលកូនរបស់ប៉ា
មានមារយាទអន់ៗយ៉ាងនេះ! ប៉ាខំ ទុកចិត្តកូនរបស់ប៉ាណាស់ដែលគេបានរៀនសូត្រខ្ពង់ខ្ពស់
នឹកថាវិជ្ជា នឹងជួយអោយគេក្លាយជាមនុស្សប្រសើរម្នាក់ ។ ថែងន្យ អ្វីដែលប៉ា
គិតនោះបែរជាខុស ។ កូនរបស់ប៉ាបែរជាពុលលុយពុលអំណាច ឆ្លៀតឱកាសក្រោយខ្នងប៉ា
ទៅប្រព្រឹត្តអំពើមិនគប្បី... សារៈ!ពេល នេះ តើអោយប៉ាយកមុខទៅទុកនៅឯណាទៅកូន ?

លោកសារាយខឹងពេក បែរមុខចេញទៅបង្ហួចខាំធ្មេញក្រឹតៗ រួចហើយក៏មានប្រសាសន៍បន្តថា
៖

- មកពីឯងធ្វើចំពោះកម្មករខ្មែរគ្នាឯងយ៉ាងនេះទេដឹង បានជានាយ
ជិនហួវាហ៊ានចាប់ផ្តើមើលងាយក្រុមគ្រួសាររបស់យើង រហូតមាន លួចលាក់ឯកសារផ្សេងៗ
មិនអោយយើងដឹង ? ពេលនេះ ជិនហួ ប្រហែលជាសប្បាយចិត្តណាស់
ដែលឯងចេះសម្លុតខ្មែរគ្នាឯងដើម្បី ប្រយោជន៍របស់គេ ។ ឯគេវិញ
បែរជាចាំតែកើបយកប្រយោជន៍ ស្រាប់ៗ ដោយមិនបាច់ខ្វល់នឹងទទួលពាក្យជេរពីកម្មករ ប៉ុន្តែ
អ្នកដែលកម្មករស្អប់បំផុតហើយជេរបំផុត គឺយើង! ចុះបើជិនហួ
ប្រមូលទ្រព្យរត់ត្រឡប់ទៅស្រុកគេវិញ តើនរណានៅទទួលកំស្ទួល កំហឹងរបស់កម្មករទាំងនោះ ?
មិនគឺជាយើងដែលរស់ឯស្រុកខ្មែរ នេះទេ ហ្អែស ?

សារៈអង្គុយឈ្ងោកគិតយ៉ាងយូរ ទើបងើបមុខឡើងស្រដីថា ៖

- កូនបានដឹងកំហុសនេះហើយ ហើយក៏កំពុងកែខ្លួនដែរ...

CHANBOKEO.COM

- មែនហ្មែ៎ស ? តើប៉ាគួរជឿសំដីកូនទេ ? តើអ្វីទៅដែលធ្វើអោយ ឯងនូវឬកមារយាទនេះ ?

សារៈលួចដៀងកន្ទុយភ្នែកទៅរាសី បន្ទាប់មកក៏វាចាថា ៖

- លោកប៉ា! រាសី...ជាមនុស្សដែលសក្តិសមបំផុតសំរាប់មុខនាទី
ជានាយចំណាត់ការទូទៅក្នុងរោងចក្រនេះ ជំនួសខ្ញុំហើយ ព្រោះ នាងជានារីម្នាក់ ឋានៈត្រឹមកម្មករ
តែបានទទួលទណ្ឌកម្មយ៉ាងធំណាំ ដើម្បីយកសិលធម៌មកដាស់តឿនសតិរបស់ខ្ញុំ
អោយភ្ញាក់រលឹក ។ សំដីរបស់គេមានអត្ថន័យជ្រាលជ្រៅ មិនខុសពីប្រសាសន៍លោកប៉ា
ប្រដៅខ្ញុំពេលនេះ មួយម៉ាត់ឡើយ ។

រាសីញោចមុខកាលបើឮសារៈនិយាយដូច្នោះ ។ តើគេនិយាយ ចេញពីដួងចិត្ត
ឬក៏គ្រាន់ជាល្បែងបោកប្រាសរបស់អ្នកធំៗ នៅទី នោះ ។ ទោះជាយ៉ាងណា
រាសីមិនព្រមចាញ់បោកងាយៗឡើយ ។

- យ៉ាងម៉េចដែររាសី! សារៈសុខចិត្តដើរចុះពីឋានៈរបស់គេហើយ ចុះនាងវិញ ?
ព្រមឡើងមកទេ ? (លោកសារាយពោល)

- មិនទេ!

- ម៉េចអញ្ចឹង ?

- បើនូវជាមួយនឹងឯកសារ១០សន្លឹកនោះ គឺខ្ញុំមិនទទួលយកឡើយ តែបើឲ្យខ្ញុំទទួលកិច្ចការនេះ
ដោយគ្មានចំណង នោះខ្ញុំនឹងចាប់ផ្តើម ពីនាទីនេះតទៅ ។

- ដូចជាមិនងាយដល់ម្លឹងទេ រាសី!

- បើអញ្ចឹង ខ្ញុំទៅវិញហើយ! ជំរាបលា!

រាសីក្រោកពីកៅអីរឹងយ៉ាងលឿន ។ លោកសារាយញាក់មុខ ដាក់កូនប្រុស ។
សារៈហក់ទៅបាំងមាត់ទ្វារឲ្យរាសីទុចដំណើរដ៏ក់ ។

- ចុះកុងត្រាថ្ងៃនេះទេហ៎ រាសី ? (លោកសារាយសួរ) សំរាប់ កិច្ច
ការជានាយកផ្នែកចំណាត់ការទូទៅ ?

រាសីងាកក្រោយញញឹមឡើង ៖

- បើកុងត្រាជ្រះស្រឡះពីឯកសារ១០សន្លឹក ខ្ញុំស៊ីញ៉េភ្លាម ។

លោកសារាយហុចសំណៅទៅរាសីភ្លាម ៖

- នេះ! អានហើយស៊ីញ៉េផង !

CHANBOKEO.COM

រាសីញញឹម ត្បិតនាងមានឱកាសល្អសំរាប់ធ្វើអ្វីមួយយ៉ាងប្រពៃ បំផុតក្នុងជីវិតរបស់នាង ។ ភ្លាមនោះមាលាវីក៏ទាញសំណៅកុងត្រា
មកបើកទំព័រអាន ម្ដងមួយសន្លឹកៗ...

ព្រលប់ថ្ងៃដដែល...

- បងរាសី សប្បាយចិត្តម្ល៉េះ ថ្ងៃនេះ ? បងសយនានាំបងទៅក្រៅ ទៀត មែនទេ ?
- អត់ទេ! គឺបងសប្បាយចិត្តផង ពិភាល់ចិត្តផង ព្រោះរាសីបង អណ្ដែតខ្ពស់លឿន ហួសការស្មានរបស់បង ។
- អូហ៍! បើរាសីអណ្ដែតឡើងខ្ពស់ទៅហើយ ពីភាល់រឿងអ្វីទៅ បងស្រីអើយ... ?
- ឆ្ងល់ ឆ្ងល់ ឆ្ងល់ ដែលសុខៗ គេចាប់បងអោយទៅធ្វើមេកោយ
- អ្ហ៎! មេកោយ ?
- មែនណា៎! ដល់ថ្នាក់ជានាយកចំណាត់ការទូទៅផង!
- ពិតជាប្លែកមែនហើយបង! ខ្ញុំថាយកល្អ បងកុំធ្វើធ្វើអី ប្រយត្ន័ ជាន់ដានចោរ ។
- បងក៏គិតដូច្នេះដែរ ។ ប៉ុន្តែ បងក៏ចង់ធ្វើជានាយកោយដូចគ្នា ព្រោះបងចង់ដូរស្ថានភាពក្នុងរោងចក្រ ។ បងអាណិតពពួកស្រីៗ កម្មករទាំងឡាយនោះណាស់ ។ គ្នាធ្វើការយ៉ាប់យ៉ឺនក្រៃលែង ។ ឯ ថៅកែវិញ ស្គាល់តែការប្រមូលផលតែម្យ៉ាង ដោយមិនគិតពីសុខ ទុក្ខរបស់ពួកកម្មករទាំងនោះទេ ។
- បើដូច្នេះ បងមានរឿងពីរយ៉ាងដែលបងត្រូវប្រឈមមុខ ។ ទីមួយគឺកែប្រែស្ថានភាពក្នុងរោងចក្រ... មិនដឹងថាសមាជិកអ្នកគ្រប់គ្រងទាំងឡាយគេចូលចិត្តការគ្រប់គ្រងបែបថ្មីរបស់បង ដែរឬអ្វី ។ ទីពីរ គឺការពារស្ថានការណ៍ទុច្ចរិត ។ បើអ្នកកាន់ការពីមុនមានពិរុទ្ធ នោះ បងច្បាស់ជាទទួលថ្នបាក់ជំនួសហើយ ជាពិសេស បើសិន រោងចក្រមានរឿងទាក់ទងនឹងបទឧក្រិដ្ឋខុសច្បាប់ ។
- អរគុណណាស់រក្សា! យោបល់នេះមានប្រយោជន៍អ្វីម្ល៉េះ ? បងនឹងត្រៀមខ្លួនសំរាប់ស្ថានការណ៍ទាំងនោះហើយ ។

ព្រលប់នោះ រាសីនៅអង្គុយតំអក់ច្រាស់ច្រាល់ៗ ចាំផ្លូវសយនា តែមិនឃើញស្រមោលរបស់គេឡើយ ។

- បងរាសី! នេះម៉ោង១០យប់ហើយណា៎! ពិសារបាយសិនទៅ!

- អត់ទេ! បងសយនាគាត់ថាមកពិសារបាយជាមួយយើង ។ បើ យើងញ៉ាំមុនទៅ ហាក់ដូចជាយើងមិនរាប់អានគាត់...
- យប់ជ្រៅប៉ុនហ្នឹងហើយ ខ្ញុំថា គាត់ច្បាស់ជាមិនមកទេ ។
- ណ្ហើយ! បងចាំគាត់ម៉ាស្របក់ទៀតចុះ!
- អញ្ចឹង ខ្ញុំចូលគេងមុនហើយណា៎!
- អឺ!

ព្រហាមឡើង...

រក្សាក្រោករៀបចំខ្លួនទៅធ្វើការដូចប្រក្រតី ស្រាប់តែឃើញ បាយដែលរាសីគ្របទុកពីល្ងាចនោះ នៅកន្លែងដដែល ។

- បងរាសីមិនពិសារបាយទេ យប់មិញ ?
- គឺបងចាំបងសយនាយូរពេកក៏ហួសពេលឃ្លាន ទើបបងចូល គេង ដោយមិនបានញ៉ាំ!
- ស្លាប់ហើយ! អញ្ចឹងបងពិសារពេលនេះទៅ ដើម្បីកុំអោយខ្យល់ គព្រោះអត់អាហារណា៎!
- បងដឹងហើយ ប្អូនសម្លាញ់!

រក្សាញញឹមដាក់បងស្រីហើយក៏ដើរចេញទៅ ។ រាសីក្រោក ឡើងអង្គុយសម្លឹងចានបាយដែលនាងបានគ្របទុករង់ចាំសយនាមក បរិភោគជុំគ្នា... ឥឡូវពេលវេលាណាត់ បានកន្លងហួសទៅហើយ... គេក៏មិនឃើញវិលមកដូចពាក្យដែលគេសន្យា... តើគេមានរឿង អី ? ឬក៏គេមិនអាចទទួលរូបនាងបាន ព្រោះក្រុមគ្រួសាររបស់ នាងកើតរោគអេដស៍ ? ឬក៏ម្ដាយគេឃាត់មិនអោយមក ? ឬក៏គេ មានបញ្ហាជីវិតអ្វីផ្សេងទៀត ? បញ្ហាការងារ ? បញ្ហាជាមួយម្ដាយ របស់ស្រីខួច ? ឱមែនហើយ! គេមានកូនស្រីមួយឈ្មោះស្រីខួច តើម្ដាយរបស់ស្រីខួចនៅឯណា ? ឬក៏សយនា... នៅមានជាប់ចំណងអតីតកាលរបស់គេ ហើយមកខ្ចីរូបនាងជាស្ពានចម្លងទុក្ខ ក្នុងបេះដូងបណ្ដោះអាសន្នមួយគ្រាតែប៉ុណ្ណោះ ?

រាសីគិតទៅគិតមក ក៏ចាប់ចានបាយជះវីងទៅក្នុងទឹកជ្រាំ រួច ហើយក៏បិទទ្វារផ្ទះចេញទៅ ដោយទឹកមុខម៉ឺងម៉ាត់ខុសធម្មតា ។

នៅការិយាល័យថ្មីរបស់នារីយើង...

CHANBOKEO.COM

រាសីបានទទួលឯកសណ្ឋានថ្មីយ៉ាងស្អាត ។ ពូសៀកបានជញ្ជូន ឯកសារជាច្រើនមកអោយនាង ពីក្រុមការិយាល័យជាន់ក្រោម ។ បន្តិចមក នាងក៏ដើរចុះទៅការិយាល័យខាងក្រោម ក៏ប្រទះនឹងស្រី ម្នាក់ឈរយំសសឹកក្នុងការិយាល័យ ៖

- មានរឿងអ្វីហ្នឹងបងណារេន ? (រាសីសួរនារីម្នាក់ដែលធ្វើការនៅ ការិយាល័យក្រោម)
- គឺគាត់សុំឈប់ទៅមើលកូនឈឺ តែការិយាល័យមិនហ៊ានអនុញ្ញាតិ អោយទេ ទាល់តែចាំថ្នាក់លើអនុញ្ញាត្តសិន ។

រំពេចនោះ រាសីព្រួពូសៀកសម្លុតស្រីម្នាក់នោះ ថា ៖

- នាងមិនមែនជាគ្រូពេទ្យទេ ទោះបីជាទៅមើល ក៏ព្យាបាលកូន មិនកើតដែរ ។ នាងគ្រាន់តែធ្វើលុយអោយអ្នកផ្ទះគេនាំទៅព្យាបាល ទៅ វាស្រេចទៅបាត់ហើយ ។ ចាំបាច់ទៅឈប់ធ្វើអី ?

រាសីព្រួស្ដោះ ក៏ស្រដីរឹងថា ៖

- ពូសៀក! ចៅហ្វាយណាមួយដែលបង្គាប់អោយពូនិយាយរបៀប នេះ ចំពោះអ្នកធ្វើការ ? ខ្ញុំចង់ស្គាល់មុខចៅហ្វាយដែលមិនព្រម បង្ហាត់បង្រៀនពីសីលធម៌នៅក្នុងការងារទៅពូសៀក ។
- គឺ... គឺ... (នាយសៀកឆ្លើយតតាក់តតុប)
- ជិនហួ ឬក៏សារៈ នឹងអាលខ្ញុំទៅសួរគេឥឡូវនេះ ។
- គឺ...គឺ...
- បើមិនឆ្លើយទេ ខ្ញុំអោយពូសំរាកការងារម៉ាដៃ ទៅសំរាន្តគិត ហើយព្រឹកស្អែក ត្រឡប់មកឆ្លើយតបខ្ញុំវិញ ។ បងណារេន! សូម កត់ផង កាត់ប្រាក់ខែពូសៀកម៉ាដៃ ។

ភ្លាមនោះ ទាំងអស់គ្នាក្នុងការិយាល័យ បើកភ្នែកមូលក្រឡង់ តែម្ដង ។ រាសីបែរមកស្រីកម្មករមួយរូបនោះ ៖

- ស្រុកបងនៅឯណា បងស្រី ?
- នៅកំពង់ស្ពឺ អ្នកនាង!
- ហើយ បងចង់ឈប់ប៉ុន្មានថ្ងៃដែរ ?
- តែម៉ាដៃទេ ព្រោះបងត្រូវការប្រាក់ មិនអាចសុំឈប់យូរបានទេ
- អញ្ចឹងបងទៅចុះ ។ ខានស្អែកមកធ្វើការវិញណ៎ាបង!

ស្រីនោះក៏ញញឹមឡើងទាំងទឹកភ្នែក រួចលើកដៃសំពះ ៖

CHANBOKEO.COM

- អរគុណណាស់ ចំពោះសន្ដានចិត្តរបស់អ្នកនាង!

បន្តិចមក ស្រីនោះក៏ដើរចេញទៅ ។ ពូសៀកខាំធ្មេញក្រឺតៗ ក្ដាប់ដៃនៅឈរស្ងៀម សម្លក់រាសីដោយភ្នែកឡើងក្រឡោតគួរឲ្យ ខ្លាច ។ រាសីបែរមកពូសៀកវិញ ក៏ប្រទះនឹងក្រសែភ្នែកនោះ ។ នាងក៏ស្លួររឹងឡើងថា ៖

- ខឹងនឹងអ្នកណាពូសៀក ? ខឹងនឹងខ្ញុំដេញពូអោយទៅផ្ទះ ឬក៏ ខឹងនឹងខ្លួនពូឯងដែលខ្វះសីលធម៌ចំពោះអ្នកធ្វើការដូចគ្នា ?

ពូសៀកនៅស្ងៀម លែងហ៊ានតប រួចក៏ដើរចេញទៅ ទុកឲ្យ អ្នកធ្វើការនៅក្នុងការិយាល័យទាំងប៉ុន្មាន លួចមើលគាត់ភ្លៀកៗ ។ រាសីក៏ដើរចេញទៅពិនិត្យតាមរោងដេរនិមួយៗ ។

នៅរសៀលថ្ងៃដដែល...

រាសីបានដើរទៅមើលឃ្លាំង ផ្ទុកកេសទំនិញដឹកចេញចូល ។ នាងឃើញការរៀបចំស្តុកទុកឥវ៉ាន់ ហាក់ដូចជាមានភាពមិនប្រក្រតី សោះ ។ នាងក៏បញ្ជាអោយនាយឆ្មាំឈ្មោះម៉ាប់នោះ អោយហៅពួក កម្មករមករើរុះរៀបចំអោយមានរបៀប ស្រាប់តែនាយម៉ាប់គ្រវី ក្បាលតតាត់ ស្រដីថា ៖

- លោកជិនហ្វបានផ្ដាំមិនអោយផ្លាស់ប្ដូរអ្វីនៅក្នុងឃ្លាំងនេះទេ លុះ ណាតែមានថៅកែឌាំងមករាប់ទទួលឥវ៉ាន់សិន ។

- ថៅកែឌាំង ? ហេតុអ្វីទាក់ទងនឹងថៅកែឌាំងផង ?

- ខ្ញុំមិនដឹងទេ រាសី! គ្រាន់តែដឹងថា ថៅកែឌាំងទទួលកុងត្រា ជួយខាងដឹកផលិតផលចេញចូលរបស់រោងចក្រជិនហ្វប៉ុនហ្នឹង ។

ថាហើយ នាយម៉ាប់ក៏ដើរចេញទៅ ។

រាសីបានដើរជុំវិញទីនោះ សង្កេតកិច្ចការមួយសន្ទុះធំទើបដើរ ចេញទៅវិញ ធ្វើកិច្ចការផ្សេងៗបន្តទៀត ។

oooooooooooooooooooo

ooooo

o

CHANBOKEO.COM

# វគ្គទី៩
# ចៅកែទុច្ចរិត

ពីរថ្ងៃកន្លងទៅ...

គួរអោយឆ្ងល់ណាស់ ពីរថ្ងៃដែលនាងចូលធ្វើការ ស្រាប់តែបាត់ មុខជិនហ្វូទៅណាមិនដឹង ឃើញតែសារៈដែលមកអើតនាងមួយដង មួយយាម ដើម្បីជួយណែនាំនាងក្នុងការគ្រប់គ្រងកិច្ចការ ។ ពេល នោះ នាងបានសង្កេតឃើញថា នរៈបានផ្លាស់ប្តូរឥរិយាបថរបស់គេ ចំពោះនាងនិងចំពោះអ្នកធ្វើការបន្តិចហើយ ។ មានកាលខ្លះមាណព ជ្រុលគំហកមាត់ធំដាក់អ្នកធ្វើការ តែក៏ប្រញាប់កែប្រែមកវិញដែរ មិនជាមានៈតឹងរ៉ឹងនិយាយស្តាប់គ្នាមិនបាននោះឡើយ ។ ម្យ៉ាង ទៀត គេក៏ហាក់ដូចជាផ្តល់កិត្តិយសដល់នាងជាងមុនច្រើន មើលទៅ ប្រហែលជាគេបានទៅគេងគិតពិចារណា ពីសំដីរបស់នាងច្រើន ហើយ ទើបគេហាក់ដូចជាទន់ភ្លន់ មិនសូវកាចឆ្មើងឆ្មៃដូចមុនៗ នោះឡើយ ។

ព្រមជាមួយគ្នានេះដែរ...

ពីរថ្ងៃកន្លងមកនេះ រាសីក៏មិនឃើញសយនាមកលេងនាងដូច រាល់ដងទេ មិនដឹងថាគេកំពុងគិតរឿងអ្វី...

- តើរាសីយើងកំពុងអណ្តែតឡើង ឬកំពុងតែដើរធ្លាក់ចុះទៅក្នុង កលល្បិចរបស់ពួកអ្នកមានទុច្ចរិត ? ហើយចុះបងសយនាវិញ ? តើគេមានរឿងអ្វីទៅ ? ហេតុអ្វីបានជាគេបាត់មុខមិនឃើញមក អើតយើងសោះ តាំងពីដឹងប្រវត្តិអតិតកាលរបស់យើងមក ?

ជួនកាលរាសីនឹកភ្នកចង់រកជិះម៉ូតូឌុបទៅសាកសួរសយនាដល់ ផ្ទះ ប៉ុន្តែ លុះគេងគិតច្រើនដងទៅ... នាងបែរជាមិនដាច់ចិត្ត ត្បិត មិនចង់អោយអ៊ីសាវិនម្តាយរបស់គេ

CHANBOKEO.COM

យល់ច្រឡំថា នាងកំពុងរត់ តាមចាប់តោងកូនប្រុសរបស់គាត់... គិតទៅគិតមក ធិតាក៏ដក ដង្ហើមបន្ធូរទ្រូងមួយចោល ហើយក៏សំរេចចិត្តយ៉ាងម៉ឺងម៉ាត់ថា ៖

- អ្នកដែលស្រឡាញ់ហើយបារម្ភពីរាសីបំផុតនោះ គឺរាសីខ្លួនឯងតែ ម្តង មិនមែននរណាទៀតឡើយ ។ រាសីនៅក្មេងហើយនៅមាន អនាគតវែងឆ្ងាយ មិនត្រូវជាប់ផុងកប់ភក់ត្រឹមបុរសម្នាក់នោះទេ ។ កាលបើគេនិងម្តាយរបស់គេមិនអាចទទួលរាសីបាន ដោយសារតែ ម្តាយឪពុករបស់យើងស្លាប់ដោយជំងឺអេដស៍ នោះក៏បណ្តោយឲ្យគេ ទៅចុះ ! រីឯរាសីវិញ ត្រូវរៀបដំណើរជីវិតថ្មី បន្តទៅមុខទៀត ។ កុំធ្វើខ្លួនជាមនុស្សទាល់ច្រកអី ! មិនខ្វះទេបុរសល្អ សំរាប់ឲ្យយើង ជ្រើសរើស ។ បើសិនជាជីវិតរបស់យើង ទទួលជោគជ័យវិញនោះ ច្បាស់ជាមានបុរសបោះដៃអោយយើងជ្រើសរាប់មិនអស់ទេ សូម្បី តែសារៈនិងជិនហ្វូ ក៏ប្រហែលជាស្មគ្រ័ចិត្តតម្រង់ជួរនឹងគេផងក៏មិន ដឹង ។ ម្យ៉ាងទៀត យើងក៏នៅក្មេងដែរ មិនទាន់គ្រប់វ័យ២០ឆ្នាំ ស្រួលប្រួលផង ហេតុម្តេចក៏យើងបិទផ្លូវជីវិតរបស់ខ្លួនត្រឹមតែបុរស ឈ្មោះសយនាម្នាក់នោះ ។ គេមានអាយុច្រើនជាងយើងដល់ទៅម៉ា មេឃម៉ាដី មិនខុសឡើយពីសារៈ ឬជិនហ្វូ ។ ហេតុដូចម្តេចបានជា យើងបណ្តោយអោយគេមកដឹកនាំចិត្ត ដឹកនាំអារម្មណ៍ ដឹកនាំផ្លូវ ជីវិតសំរាប់យើងផង ? ម៉េចក៏យើងមិនរៀនកាច់ចង្កូត ដឹកនាំជីវិត ដោយខ្លួនឯង ដោយមិនបាច់មានបុរសនៅឈរក្បែរ ? ថាមិនត្រូវ ទេ នៅថ្ងៃតទៅមុខទៀត យើងអាចបានជួបប្រទះនឹងបុរសក្មេងៗ ស្រករគ្នា មានសន្តានចិត្តមានសម្បទាប្រហាក់ប្រហែលគ្នានឹងយើង អាចអោយយើងមានពាំនាក់បង្វែរផ្លូវចិត្តទៅវិញទៅមក បានយ៉ាង កក់ក្តៅលើសនេះរាប់រយដងផងក៏មិនដឹង ។ ពេលនេះ យើងមិន ទាន់ស្គាល់សយនានោះច្បាស់ឯណា ? យើងទើបតែជួបស្គាល់គេ ប៉ុន្មានថ្ងៃនេះឯង ។ ហេតុអ្វីយើងត្រូវដាក់ចិត្ត ប្រាថ្នាស្លាប់រស់ជា មួយបុរសនេះផង ? មិនទេ ! យើងមិនត្រូវឲ្យវត្តមានរបស់គេ ចំនួនបួនដប់ថ្ងៃក្នុងជីវិតរបស់យើងមកដណ្តប់ដួងចិត្តនិងជីវិតរបស់ យើងអោយវង្វេងភ្លេចអនាគតខ្លួនឯងបានឡើយ.. យើងនឹងឈ្នះ ឈ្នះចិត្តនរណាៗទាំងអស់ដែលគិតអវិជ្ជមានមកលើយើង ។ យើង នឹងធ្វើ... យើងនឹងបង្ហាញ... អោយគេបានដឹងថារាសីស្វែងរក ឃើញអនាគតត្រចះ ដោយជំហរកម្លាំងកាយ កម្លាំងប្រាជ្ញ

CHANBOKEO.COM

និងការ តស៊ូព្យាយាមដោយដៃពីររបស់យើងផ្ទាល់ ។ យើងនៅក្មេងណាស់ ហេតុអ្វីចុះចាញ់ព្រហ្មលិខិតតាំងពីពេលនោះទៅហើយ ? យើងពិត ជាមិនព្រមចុះចាញ់ដោយងាយៗទេ ។ បើមិនតស៊ូ ច្បាស់ជាមិន ដឹងទេ ថានរណាជាអ្នកឈ្នះចុងក្រោយ...!!

រាសីក៏ឆ្មេចនិន្ទ្រាដោយការសម្រេចចិត្តយ៉ាងរឹងត្អឹងថាមិនអោយ មាននរណាម្នាក់មកបំបាក់កម្លាំងចិត្តរបស់នាងបានឡើយ ។ មាណវី ត្រូវតែជួយខ្លួនឯង ។ នាងត្រូវតែឈ្នះ ហើយឈ្នះក្នុងកិត្តិយស កេរ្តិ៍ឈ្មោះល្អប្រពៃទៀតផង ។

ព្រឹកឡើង...

នារីយើងក៏ដើបចេញទៅធ្វើការដោយទឹកចិត្តរឹងប៉ឹងក្លាហាន ។ នាងភ្លេចអស់រឿងពីថ្ងៃម្សិល ភ្លេចហើយថានាងមានអារម្មណ៍យ៉ាង ណាចំពោះសយនា ។ នាងចាំបានតែមួយមុខគឺ រាសីត្រូវតែបោះ ជំហានទៅមុខជួយខ្លួនឯង ដោយខ្លួនឯង ដើម្បីជាជំហររឹងប៉ឹង និងជាបង្អែកដ៏កក់ក្ដៅសំរាប់ប្អូនៗកំព្រា ។ ពេលនេះ បើនាងមិន ស្រវាស្រទេញទេ គ្មាននរណាអាចជួយនាងនិងប្អូនរបស់នាងបាន ឡើយ ។ ពេលនេះ កម្លាំងចិត្តដែលនាងបានទទួលច្រើនជាងគេ បំផុតនោះ គឺរក្សា ប្អូនប្រុសដ៏ល្អរបស់នាងដែលយល់សុខយល់ទុក្ខ របស់នាងជានិច្ច ។

ដោយសារកុងត្រាថ្មីរបស់រោងចក្រ ដែលបានផ្ដល់សិទ្ធិច្រើន យ៉ាងដល់នាង មាណវីមានលទ្ធភាពកែប្រែស្ថានភាពក្នុងរោងចក្រ បានយ៉ាងប្លែកៗ ជាពិសេស គឺការផ្លាស់ប្ដូរអោយមានដំណើរខ្យល់ ចេញចូលក្នុងរោងដេរ ដើម្បីកុំអោយកម្មករខ្យល់គញឹកញាប់ មាន ការសំអាតជាប្រក្រតីមុននឹងចេញទៅផ្ទះ មានការគោរពគ្នារវាង អ្នកធ្វើការភេទខុសគ្នា រវាងកូនចៅនិងកម្មករ ចៀសវាងការ ប្រើពាក្យអសុរសនិងការប្រើកម្លាំងបាយ ដោះស្រាយបញ្ហា និងការ អនុញ្ញាត្តអោយបុគ្គលិកឈប់ពីការងារ ដោយមានមូលហេតុសម ហេតុសមផល ។ ដោយសារតែហេតុនេះហើយ រាសីក៏បានទទួល ការគាំទ្រយ៉ាងខ្លាំងពីសំណាក់កម្មករដូចគ្នា ។

រាសីបានមកធ្វើការនៅការិយាល័យដូចប្រក្រតី...

នៅព្រលប់ថ្ងៃមួយ កម្មករទាំងឡាយក៏នាំគ្នាដើរចេញទៅផ្ទះ ម្ដងមួយៗរពុយៗ ។ ឯរាសីវិញរៀបចំឥវ៉ាន់ទុកដាក់ បំរុងចេញ ទៅផ្ទះវិញដែរ ស្រាប់តែ ៖

- នរណាអោយនាងមកធ្វើការទីនេះ រាសី ?

រាសីងើបមុខឡើងឃើញជិនហួយរច្រងក់នៅមាត់ទ្វារ ។

CHANBOKEO.COM

- គឺលោកសាវាយនិងលោកសារៈជាអ្នកជ្រើសរើសខ្ញុំយកមក ។
- ពីអង្កាល់ដែរ ? ហេតុអ្វីខ្ញុំមិនដឹង ? នាងត្រូវជាអ្វីហ្នឹងពួកគេ ដែរ ទើបគេហៅនាងចូលធ្វើការនៅការិយាល័យមួយនេះ ដោយ មិនពិគ្រោះជាមួយខ្ញុំសោះអញ្ចឹង ? ចុះសារៈគេទៅធ្វើការអ្វីវិញ ?
- សួរម្ដងមួយ លោកជិនហួ! សួរញាប់យ៉ាងនេះ ខ្ញុំឆ្លើយយ៉ាង ម៉េចទាន់ទៅ ? ការពិត ខ្ញុំមិនមានជាប់សាច់ញាតិអ្វីនឹងពួកគេទេ គឺខ្ញុំត្រូវគេបង្ខំអោយមកធ្វើការទីនេះ តាំងពីថ្ងៃដែលលោកចេញទៅ ប៉ុន្មានថ្ងៃមុនជាមួយសង្សាររបស់លោក ។ រឿងគេជំរាបលោកឬអត់ នោះជារឿងរវាងម្ចាស់ភាគហ៊ុនគ្រប់ផ្នែក មិនមានជាប់ទាក់ទងអ្វី នឹងអ្នកធ្វើការស៊ីប្រាក់ខែដូចខ្ញុំនេះទេ ។

ជិនហួជ្រួញចិញ្ចើមមួយស្របក់ ស្រាប់តែញញឹមឡើង ៖

- អញ្ចឹងក៏បានដែរ ។ ខ្ញុំមិនបាច់ចុះដើរទៅរោងដែរ ដើម្បីតាមរក នាងផង ។
- តាមរកខ្ញុំ ? រកធ្វើអ្វី ?
- រកគ្នាបរិភោគបាយថ្ងៃត្រង់ជាមួយ កុំអោយអផ្សុកពេក...
- ចុះអ្នកនាងសាវរីនោះ ?
- គេនោះហ្វ៊ស ?... កុំនិយាយពីគេអី!
- ម៉េចអញ្ចឹង ?
- គឺ...

មិនទាន់ចប់ប្រយោគផង ស្រាប់តែនាយម៉ាប់ឆ្មាំឃ្លាំងដើរមក ដល់មុខការិយាល័យរបស់វាសី ។

- មានការអីហ្នឹង ? (ជិនហួលាន់មាត់)
- គឺថៅកែខាំងនាំគ្នីគ្នាមកទទួលឥវ៉ាន់របស់គាត់ ហើយមានអ្វីត្រូវ យកមកជូនលោកជិនហួវិញផង (នាយម៉ាប់ខ្សិប)

ជិនហួធ្វើកិរិយាហាក់ដូចជាមានពិរុទ្ធ ថែមទាំងដើរចេញទៅ ជាមួយនាយម៉ាប់យ៉ាងលឿន ដោយពុំមានលាវាសីមួយម៉ាត់សោះ ។ មាណវីសម្លឹងតាមអ្នកទាំងពីរទាំងពិភាល់ ។ នាងលួចអើតមើល តាមស្លាបព្រិលបង្អួច ឃើញរថយន្តទ្រុងធំមួយកំពុងថយគូថចូល ឃ្លាំង មិនដឹងថាគេកំពុងទទួលឥវ៉ាន់ ឬថយចូលទម្លាក់ឥវ៉ាន់ទេ ។ រីឯអ្នកធ្វើការវិញ គេដេញចេញក្រៅ ទុកតែមនុស្សសំខាន់ៗពីរបី នាក់ ។ ភ្លាមនោះ នាងឃើញថៅកែខាំងដើរទៅចាប់ដៃជាមួយនឹង

CHANBOKEO.COM

ជិនហួ ដែលមានអង្គរក្សដើរតាមពីក្រោយពីរបីនាក់ ដូចជានាយ សៀកនិងនាយម៉ាប់ជាដើម ។ បន្តិចមក គេក៏នាំដើរចូល ទៅក្នុង ឃ្លាំង ។ រាសីនឹកក្នុងចិត្តថា ៖

- តើថៅកែឌាំងរកស៊ីអ្វីទៅ ? ថ្ងៃមុនឮថាបបួលស្មីប្អូនរបស់នាង ទៅបំរើហាងការ៉ាអូខេនៅបាត់ដំបង... ឥឡូវស្រាប់តែមកប្រទះនៅ ភ្នំពេញ ដើរក្រវែលពពួកពាណិជ្ជធំៗ ។ គួរអោយឆ្ងល់ណាស់ដល់ ហើយ! បើមើលមារយាទឫកពាសំបកក្រៅ ថៅកែឌាំងជាមនុស្ស បាតសង្គមបេះដាក់ ហេតុអ្វីក៏គាត់អាចជ្រៀតចូលទៅក្នុងរង្វង់ពពួក អភិជនខ្ពង់ខ្ពស់ថ្លៃថ្នូរកើត ? មើលទៅជិនហួឆ្មើងឆ្មៃរកទីបំផុតគ្មាន ទេ ។ ចំណែកលោកសារាយវិញ ក៏មិនមែនជាមនុស្សដែលអាច បន្ទាបខ្លួនមករាប់ថៅកែឌាំងជាមិត្តដែរ ។ ប៉ុន្តែ តើពួកគេស្គាល់គ្នារបៀបណា ? ក្នុងមុខការជំនួញបែបណាទៅ បើរោងចក្រជិនហួ ជារោងចក្រកាត់ដេរ ។ លោកសារាយជាម្ចាស់សណ្ឋាគារផ្កាយប្រាំ ប៉ុន្តែថៅកែឌាំងរកស៊ីខាងការ៉ាអូខេ តើទាក់ទងមុខជំនួញនឹងគ្នា យ៉ាងណាបើមើលទៅដូចជាគ្មានខ្សែណាស៊ីគ្នាសោះអញ្ជឹង ?

ពេលនោះ ស្រាប់តែនាងឃើញក្រុមប៉ូលីសមកដល់ឡើងខ្មៅ មីរ ពទ្ធ័ជុំវិញរោងចក្រទាំងផ្លូវមុខផ្លូវក្រោយ ។ បន្តិចមក គេក៏ ចាប់បណ្តេញកម្មករចេញពីរោងចក្រម្តងមួយៗ  រួចក្រុមប៉ូលីសក៏ បង្រាយគ្នាឡោមពទ្ធ័ឃ្លាំងស្តុកឥវាន់នោះ ។ ផាំង! ផាំង! ស្នូរ គ្រាប់កាំភ្លើងផ្ទុះឡើងក្នុងក្លាំង ។ រាសីភ្ញាក់ព្រើត មិនដឹងគិតដូច ម្តេច ក៏រត់ចុះជណ្តើរក្រោយគេចរកកន្លែងសន្តិសុខ ស្រាប់តែរត់ជល់វរសេនិយមួយរូប ដែលហក់មកដល់កន្លៀតនោះដែរ ៖

- លោកធូម៉ាន ? (រាសីឧទានខ្សិបៗតែម្នាក់ឯង) គេជាដៃគូរបស់ បងសយនា! តើពេលនេះគាត់មកទីនេះដែរទេ ?

វរសេនិយធូម៉ានមិននិយាយអ្វីជាមួយនាងទេ គ្រាន់តែបក់ដៃ អោយនាងដើរចេញទៅម្ខាងទៀត ដែលមានកងប៉ូលីសចាំទទួល នាង ។ ស្នូរកាំភ្លើងលាន់ឮឡើងមួយស្របក់ធំ ។ រាសីរត់ទៅពួន ក្រោយខ្នងក្រុមប៉ូលីស មិនអាចមើលឃើញព្រឹត្តការណ៍ទាំងនោះ ឡើយ ក្រៅពីឮសូរគ្រាប់កាំភ្លើងឆ្លើយឆ្លងគ្នាមួយស្របក់ធំ ទំរាំអស់ កំសួល ។ បន្តិចក្រោយមក ក្រុមប៉ូលីសក៏នាំគ្នាក្រោកឈរស្រ៊ូស្រ បង្ហាញខ្លួនឡើងមកវិញ ។ រាសីក៏ងើបឈរដែរ ស្រាប់តែប្រទះ ឃើញក្រុមប៉ូលីសបណ្តើរជិនហួក្នុងខ្នោះដៃ ព្រមទាំងមាននាយម៉ាប់

CHANBOKEO.COM

នាយសៀកជាប់ខ្នោះផងដែរ ។ នៅខាងក្រោយឯណោះ រាសីឃើញ ថៅកែខាំងដេកប៉ះជើងច្រងាងក្នុងថ្លុកឈាម ។

ភ្លាមនោះ វរសេនិយឆ្ទូម៉ានលើកដីការមួយឡើងបង្ហាញ ៖

- មានដីការតុលាការបញ្ជាឲ្យយើងឃាត់ខ្លួនលោក ដោយបទពិរុទ្ធ ដឹកទំនិញចេញចូលក្នុងប្រទេស និងក្រៅប្រទេសរបស់រោងចក្រ ជីនហ្វអិលធីឌីមានលាក់អាភៀននៅក្នុងកេស បន្លំជាមួយកេស ដាក់ឥវាន់ដែលដឹកចេញនាំ ចូលទាំងឡាយនោះ! សូមអញ្ជើញ!

រំពេចនោះ ស្រាប់តែវរសេនិយឆ្ទូម៉ានបែរមករាសី ហើយមាន ប្រសាសន៍ប្រាប់រាសីថា ៖

- ឯអ្នកនាងវិញ ក៏ត្រូវទៅអញ្ជើញទៅប៉ុស្តិ៍ប៉ូលីសដែរ!

- ខ្ញុំហ្នឹងទៅប៉ុស្តិ៍ប៉ូលីស ?

- មែនហើយ ?

- ចុះខ្ញុំទៅជាប់ជំពាក់អី ជាមួយរឿងរកស៊ីរត់ពន្ធអាភៀនរបស់ពួក គេនោះ ?

- ចាំអ្នកនាងទៅឆ្លើយការពារខ្លួននៅទីនោះចុះ ។

ថាហើយ វរសេនីយក៏ញោចមុខអោយប៉ូលីសពីររូបនាំខ្លួននាង ចេញទៅ ។ រាសីភ្ញាក់ព្រើត ស្រែកឡើងថា ៖

- នែ៎ បើចង់ចាប់ខ្លួនខ្ញុំ ត្រូវបង្ហាញដីការតុលាការសិន! បើគ្មានទេ លោកកំពុងតែរំលោភសិទ្ធិអ្នកស្រុកហើយ ។

វរសេនិយឆ្ទូម៉ានសម្លឹងមុខនាងដោយក្រសែភ្នែកយ៉ាងមុត រួច ហើយឆ្លើយថា ៖

- បើនាងជាមនុស្សបរិសុទ្ធពិតមែន ហេតុអ្វីខ្វះសេចក្តីក្លាហាននឹង បង្ហាញការពិត ?

មាណវីភ្ញាក់ព្រើត ងើបមុខភ្លាម ៖

- រាសីមិនដែលខ្លាចការពិតម្តងណាទេ!

- បើអញ្ជឹង សូមអញ្ជើញ ។

រាសីក៏ពើងទ្រូងឡើងដើរតាមក្រុមប៉ូលីសអោយគេហែហមនាង ឡើងឡានចេញទៅ ។ ពពួកកម្មកររោងចក្រដែលនៅសល់ទីនោះ នៅឡើយ ក៏រត់ឈូនរកូកហៅប្រាប់គ្នាឡើងថា ៖

- អ្នកនាងរាសីត្រូវប៉ូលីសនាំខ្លួនទៅហើយពួកយើង! មានរឿងអ្វី ហ្នឹង ? ហេតុអ្វីមនុស្សល្អដូចអ្នកនាងរាសីមកជាប់ជំពាក់ជាមួយនឹង រឿងឧក្រិដ្ឋរបស់ថៅកែផង ? ដូចជាមិនគួរអោយជឿសោះ! តោះ ពួកយើង ទៅតាមមើលស្ថានការណ៍!

នៅក្នុងបន្ទប់លោកឧត្តមសេនិយមួយរូបឈ្មោះសក្តា...

CHANBOKEO.COM

លោកសក្កាផ្ទាត់ឯកសារអានម្តងមួយសន្លឹក រួចហើយក៏មាន ប្រសាសន៍ឡើងថា ៖

- នាងឆ្លើយមក ថា ឯកសារដើម១០សន្លឹករបស់ជិនហ្វូនោះ នៅ ឯណាដែរ ? ១០សន្លឹកដែលប្អូនប្រុសរបស់នាងយកមកប្រគល់ឲ្យ ការិយាល័យប៉ូលីសនេះ ជាឯកសារចម្លងទេ ។

រាសីបែរមើលទៅលោកធូម៉ាន ដែលឈរនៅពីក្រោយខ្នងនាង ហើយឆ្លើយថា ៖

- តើលោករកឯកសារដើម១០សន្លឹកនោះធ្វើអី កាលបើលោកចាប់ បានភស្តុតាងទាំងកេស ពីរោងចក្រទៅហើយនោះ ?

- វាជាភស្តុតាងបញ្ជាក់ពីផែនការងងឹត រវាងជិនហ្វូនិងចៅកែឌាំង សំរាប់បង្ហាញតុលាការ នូវគំរោងការណ៍ទុច្ចរិតទាំងឡាយរបស់គេ នៅកន្លែងផ្សេងៗទៀត ក្នុងស្រុកខ្មែរនេះ ។

- តើខ្ញុំត្រូវការពារខ្លួនយ៉ាងណាទេ បើសិនជាពួកឧក្រិដ្ឋយល់ថាខ្ញុំ នោះលួចសំណៅដើមរបស់គេ ? តិចលោវាប្រើគ្នាវាមកសម្លេះខ្ញុំ និងប្អូនប្រុសរបស់ខ្ញុំចោល រួចហើយក៏យកសំណៅដើមនោះកំទេចចោលអស់ នៅមុនពេលឡើងតុលាការ មិនស្រេចទៅហើយទេ ?

- ដូច្នេះហើយទើបយើងចង់អោយនាងប្រគល់សំណៅដើមនោះឲ្យ ទៅក្រុមប៉ូលីសរក្សាវិញ នោះពួកឧក្រិដ្ឋមិនអាចព្យាបាទនាង តាម យកឯកសារដើមទាំងនោះទៅបំផ្លាញចោលផង ។

- ប៉ុន្តែ... (រាសីសម្លឹងមុខលោកសក្កា រួចហើយក៏បែរទៅរកលោក ធូម៉ាន បន្តិចមកក៏ពោលបន្ត) តើអោយខ្ញុំទុកចិត្តលោកម្តេចបាន ទៅ ថាប៉ូលីសដូចលោក ធ្វើការយុត្តិធម៌ត្រឹមត្រូវ ហើយក៏មិន មែនជាប៉ូលីសបណ្តាញរបស់ចោរឧក្រិដ្ឋទាំងនោះ ?

លោកឧត្តមសេនិយសម្លឹងមុខលោកធូម៉ាន បន្ទាប់មកក៏មាន ប្រសាសន៍ថា ៖

- តើនាងចង់អោយយើងបញ្ជាក់ចំពោះនាងយ៉ាងណា ដើម្បីអោយ នាងទុកចិត្ត ?

រាសីញញឹមឡើង ៖

- គឺ... លោកត្រូវបង្ហាញថា ជនឧក្រិដ្ឋទាំងនេះ នឹងត្រូវផ្តន្ទាទោស មិនមែនអោយរួចខ្លួនដើរសេរីស្តែកៗនេះទេ ។

ថាហើយនាងដើរចេញទៅ ស្រាប់តែ ភ្លាមនោះ ធិតាយើងក៏ ទុចដំណើរដ៏ក់បែរក្រោយហើយស្រដីទៅលោកឧត្តមសេនិយថា ៖

- អូហ៍! បើសិនណាជាលោកប្រែក្រឡិចក្រឡុចវិញ ឯកសារទាំង ឡាយនោះ ក៏នៅមានផ្លូវចេញមករកយុត្តិធម៌អោយជាតិខ្មែរបាន ដដែល ទោះបីជាលោកចង់ប្រើល្បិចយាយីខ្ញុំ និងប្អូនប្រុសខ្ញុំ ក៏ដោយ ។ ម្យ៉ាងទៀត ពួកយើងមិនខ្លាចស្លាប់ទេ ព្រោះបើយើង

CHANBOKEO.COM

មិនស្លាប់ដោយការយាយីរបស់ពួកទុច្ចរិត ក៏គង់នឹងស្លាប់ដោយរោគ អេដស៍ដែរ ។ ដូច្នេះមិនបាច់តាមយាយីខ្ញុំនាំតែខាតពេលអី ។ បើលោកជាក្រុមប៉ូលីសដែលកាន់យុត្តិធម៌ប្រាកដមែន ស្អែកនេះ យើងនឹងបាននឹងលទ្ធផលល្អជាមិនខាន ។

ថាហើយ នាងក៏ដើរចេញទៅ ទុកអោយលោកឧត្តមសេនិយ សក្តាគ្រវិក្បាលលាន់មាត់តាមពីក្រោយ ៖

- នារីម្នាក់នេះ ក្មេងតែខ្លួនទេ តែមានការប្រុងប្រយត្ន័ មាត់ក៏បាន ប្រាជ្ញាក៏មិនអន់ដែរ ស្តាយណាស់ ដែលនាងកើតជំងឺអេដស៍... កុំអី នាងប្រហែលជាមានអនាគតវែងឆ្ងាយមិនខាន... តើលោកយល់ដូច ខ្ញុំទេ លោកធូម៉ាន ?

លោកធូម៉ានញញឹមហើយងក់ក្បាល ។

រាសីដើរមកដល់មាត់ទ្វាររបង ស្រាប់តែលោកធូម៉ានដើរមក ទាន់នាងដែរ ៖

- មានពេលបន្តិចបន្តួចទេ អ្នកនាងតូច ?
- លោកធូម៉ាន មានការអ្វីនឹងខ្ញុំ មែនទេ ?
- មិនមែនទេ! តែមានអ្នកផ្សេងគេចង់ជួបនាង!
- នរណាទៅ ?
- ឡើងឡានមក!

រាសីហក់ឡើងឡានផ្លាញដោយឥតរួញរា ។

មកដល់មន្ទីរពេទ្យមួយ...

- លោកនាំខ្ញុំមកទីនេះធ្វើអី ?
- ទៅដល់ខាងក្នុងនឹងដឹងហើយ ។

រាសីក៏ដើរតាមលោកធូម៉ាន ចូលទៅក្នុងបន្ទប់អ្នកជំងឺមួយ ។ នៅទីនេះ នាងប្រទះឃើញបុរសម្នាក់ កំពុងគេងសំងំស្ងាត់ស្ងៀម លើគ្រែ ដោយមានបង្គោងសេរ៉ូមផង ៖

- បងសយនា ?

នាងបើកភ្នែកធំៗឡើង រួចហើយក៏បែរសួរលោកធូម៉ាន ៖

- គាត់មានរបួសដោយសាររឿងអ្វីហ្នឹង ?
- គេចេញប្រតិបត្តិការ កាលពីប៉ុន្មានថ្ងៃមុន បានតតាំងនឹងពពួក ឧក្រិដ្ឋរត់ពន្ធថ្នាំញៀន ទើបត្រូវរបួសយ៉ាងនេះ ។

លោកធូម៉ានមានប្រសាសន៍ហើយក៏លាចេញទៅ ។ រាសីនឹក រន្ធត់ក្នុងចិត្តណាស់ ដែលនាងយល់ច្រឡំអំពីសយនា ប៉ុន្មានថ្ងៃកន្លង ទៅ ។ នាងក៏យកដៃទៅស្ទាបនាយបន្ទើរៗ ស្រាប់តែនរៈបើកភ្នែក ឡើង ៖

- រាសី! (គេឧទានហៅនាងខ្សិបៗ កាលបើឃើញនាងភ្លាម)
- ចាស! គឺខ្ញុំ! បងបានស្រួលខ្លះទេហ៎?
- គឺ... គ្រាន់បើហើយ... មិនអីទេ...!
- រាសីទើបតែដឹងថ្ងៃនេះឯង... ថាបងគេងមន្ទីរពេទ្យ...!
- អោយបង... សុំទោសរាសីផង... ដែលបងមិនបានទៅជួបរាសី តាមដែលបងសន្យា...
- បងមានគ្រោះថ្នាក់យ៉ាងនេះ រាសីមិនខឹងនឹងបងទេ ។

ភ្លាមនោះ នរៈលូកដៃញ័រតម្រង់មករាសី ៖

- សុំកាន់ដៃបន្តិចបានទេហ៎? បងនឹករាសីណាស់!

ឮដូច្នេះ រាសីញោចចិញ្ចើមហើយរំជួលក្នុងចិត្តភ្លាម ។ ម្សិល មិញ នាងបានលាងស្រមោលរបស់នរៈពីដួងចិត្តទៅហើយ ប៉ុន្តែ ចៃដន្យអី នាងបែរមកចតភ្ជាប់រូបថ្មីរបស់គេក្នុងបេះដូងម្តងទៀត ដូច្នេះ? មាណវីហាក់ដូចជានឹកអាណិតដល់បុរសយើងណាស់ ដែល តែងតែយកចិត្តទុកដាក់ចំពោះនាង ហើយបង្ហាញនូវភាពទន់ភ្លន់ របស់គេមកលើរូបនាងជានិច្ច ។ ថ្វីបើពេលនេះ គេបានដឹងប្រវត្តិ របស់នាងហើយក៏ដោយ ក៏គេនៅតែបង្ហាញនូវទឹកចិត្តរបស់គេ ចំពោះនាងដដែលឥតប្រែប្រួល ។ រាសីក៏សំរេចចិត្តលើកដៃស្តាំ របស់នាងហុចអោយនរៈកាន់ក្តាប់យ៉ាងណែន ។ ភាពញញឹមមួយ បានអណ្តែតឆ្លោឡើង លើផ្ទៃដ៏ស្លេកស្លាំងរបស់មាណពយើងភ្លាម ។ គេបើកភ្នែកព្រឹមៗទំនងនៅអស់កម្លាំងនៅឡើយ តែគេខំញញឹម ដាក់នារីយើងមិនដាច់សោះឡើយ ទំនងហាក់ដូចជាគេរំភើបចិត្ត ណាស់ដែលធិតាអាចមកសួរសុខទុក្ខគេដល់មន្ទីរពេទ្យ ៖

- អរគុណណាស់ រាសី ដែលមកមើលបង!

រាសីញញឹមឡើង តែមិនមានឆ្លើយតបអ្វីទេ ។ ទាំងពីរនាក់ សម្លឹងមុខគ្នាទៅវិញទៅមកយ៉ាងយូរ... ត្បិតគេមិនដឹងថា គេត្រូវ ចាប់ផ្តើមនិយាយអ្វី ពីត្រង់ណា ប្រាប់គ្នាឡើយ ព្រោះទំហំនៃសេចក្តី នឹករបស់គេចំពោះគ្នាទៅវិញទៅមក

CHANBOKEO.COM

ព្រោះវាមានធំធេងពិបាក និងបរិយាយដោយពាក្យសំដីណាស់ ។ គេបានត្រឹមតែកាន់ដៃគ្នា រួច ហើយញញឹមដាក់គ្នាទៅវិញទៅមកតែម្យ៉ាងប៉ុណ្ណោះ...

យប់នដែល នៅក្នុងផ្ទះរបស់រាសី...

- ខ្ញុំភ័យសឹងដាច់ខ្យល់ បងអើយ! ពេលអ្នកស្រុកគេប្រាប់ថា បង ត្រូវប៉ូលីសនាំខ្លួនទៅ ។

- ថៃដន្យ រាសីបងអណ្តែតខ្ពស់ណាស់ មិនងាយធ្លាក់ដីត្រូវគេជាន់ ឈ្លីងាយៗទេ ។

- រក្សានឹងតើហ៎ ថាបងស្រីរបស់ខ្ញុំពូកែណាស់ ។

រំពេចនោះ រាសីក្រឡេកឃើញស្រមោលមួយលិបលក្បែរពាង ទឹកខាងក្រៅផ្ទះនាងទៀតហើយ ។ នាងក៏មិចភ្នែកស៊ីញ៉ូដាក់រក្សា ក៏នាំគ្នាប្រើល្បិច ។ រាសីក៏ដើបឡើងពើជាដើរយឺតៗ ចេញទៅផ្លូវ ធំ ។ ស្រមោលនោះ ក៏ដើរតាមពីក្រោយរាសីភ្លាម ។ រក្សាក៏ស្ទុះ ទៅស្ទាក់ម៉ែងមួយជើង ។ ស្រមោលនោះក៏ដួលឆ្មោលទៅដីព្រូស តែម្តង ។ រាសីបែរក្រោយយកពិលឈ្លូល ស្រាប់តែ ៖

- ព្រះអើយ! រក្សាឈប់វាយទៅ! នេះរដ្ឋា ប្អូនយើងទេ ។

រក្សាដកដៃស្ទុះថយក្រោយយ៉ាងរហ័ស រួចលាន់មាត់ថា ៖

- រដ្ឋាមែនតើហ៎! ហើយម៉េចជាប្អូនមកដល់ទីនេះ ?

រដ្ឋាក៏ស្ទុះក្រោកឡើង យកដៃបោសគូថខោហើយស្រដីថា ៖

- គឺខ្ញុំរត់តាមឡានដែលបងជិះមកភ្នំពេញ តាំងពីថ្ងៃបងចេញពី បាត់ដំបងមកម្ល៉េះ ?

- ពុទ្ធោ! ហើយម៉េចបានជាបងមិនឃើញឯងអញ្ចឹង ?

- ព្រោះខ្ញុំយកធ្យូងគូរមុខ ហើយទទូរក្រមាអង្គុយលើដំបូល ទើប បងមិនបានចាប់ភ្លឹក ។

- ហើយម៉េចក៏ឯងមិនមករកបង បែរជាលិបលៗដូច្នេះទៅវិញ ?

- គឺខ្ញុំខ្លាចបងស្តីបន្ទោសហើយចាប់ខ្ញុំអោយទៅនៅវត្តវិញ ។

- ចុះប៉ុន្មានថ្ងៃនេះ ឯងបានអីបរិភោគទៅ ?

- គឺ... ដើរសុំបាយដែលគេញុំាសល់...

រាសីឮដូច្នោះក៏នឹកអាណិតប្អូនជួចក្នុងពោះ រហូតរលីងរលោង ទឹកភ្នែក ។ នាងក៏ស្ទុះទៅជិត ស្រវាប្អូនអោបភ្លាម ៖

CHANBOKEO.COM

- រដ្ឋា!... ហេតុអ្វីត្រូវខ្លាចបងផង ? ការពិត បងមិនដែលខឹង ហើយស្អប់ប្អូនទេ ។ ដែលបងស្អប់នោះ គឺមារយាទមិនល្អរបស់ ប្អូនតើហ៏!... ម៉ោះ! ចូលទៅក្នុងផ្ទះ ។

រក្សាក៏រត់ត្រុយទៅទិញបាយពីមាត់ផ្លូវមកអោយរដ្ឋាភ្លាម ។

- ប៉ុន្មានថ្ងៃនេះ ប្អូនស្នាក់នៅឯណា ?

- នៅគេងតាមតូបលក់ឥវ៉ាន់ដែលគេរើឥវ៉ាន់អស់ទៅ ។ ខ្ញុំចង់មក ជួបបងច្រើនដងហើយ តែមិនហ៊ាន ។

រដ្ឋាបរិភោគបាយផង និយាយជាមួយបងៗផង ។

- ពីថ្ងៃនេះទៅ បងសុំអោយប្អូនផ្តាច់រឿងសេពគប់គ្រឿងញៀន បានទេ រដ្ឋា ? បងសន្យាថានឹងប្រឹងរកលុយចិញ្ចឹមប្អូនអោយបាន រៀនសូត្រនឹងគេ ។

រដ្ឋានៅស្ងៀម ។ មួយស្របក់មក... គេក៏ស្រដីថា ៖

- តាំងពីមកដល់ភ្នំពេញនេះ ខ្ញុំមិនដែលប្រព្រឹត្តទេ សូម្បីតែប្រទះ ពួកក្មេងៗដូចគ្នាគេប្រព្រឹត្តក៏ដោយ ។

- ហេតុអ្វីទៅ ដែលធ្វើអោយឯងផ្តាច់ចរិតនេះបាន ?

- គឺខ្ញុំស្រឡាញ់បង ចង់រស់នៅជួបជុំគ្នាដូចពីដើមវិញ... រស់នៅជា មួយពួកម៉ាកសប្បាយម្តងម្កាល តែវាយគ្នាសឹងរាល់ថ្ងៃ ឈឺខ្លួន ណាស់បង! រដ្ឋាទ្រាំអោយគេវាយមិនបានទេ ។

- ពេលនេះ ប្អូនយល់ហើយមែនទេ ថាការរស់នៅជួបជុំបងប្អូន វាកក់ក្តៅនៅក្នុងចិត្តប៉ុនណា ?

- បាទ! ខ្ញុំជឿហើយ ។

ទាំងបីនាក់ក៏ស្រវាអោបគ្នាឡើងសាជាថ្មី ដោយក្តីរំភើបចិត្តជាទី បំផុត ដែលគេទាំងបីនាក់បានជួបជុំគ្នាវិញ ។ ពេលនេះ នាទីបន្ត ទៅទៀត គឺគេទាំងបីត្រូវតាមរករស្មីអោយឃើញ ។

oooooooooooooooooooo

ooooo

o

CHANBOKEO.COM

# វគ្គទី១០
# វៃកមុខ

ថ្ងៃស្អែកឡើង...
- រង្គា! កុំប្រើក្រាសសិតសក់ ច្រាសដុះធ្មេញ កន្ត្រៃកាត់ក្រចក សេនកោសខ្យល់ ខោអាវសើម ឬកន្សែងជូតខ្លួន ឡូកឡំជាមួយ បងៗអីណា! ចាំបងនាំទៅទិញឥវ៉ាន់សំរាប់ប្អូនប្រើផ្សេងវិញ ។
- ម៉េចអញ្ចឹងបងរាសី ?
- ព្រោះយើងមិនចង់ចម្លងរោគអេដស៍ ឬរោគអីផ្សេងៗដូចជាជំងឺ ថ្លើមជាដើម ដែលឆ្លងដោយជាតិឈាម ឬដោយទឹកមាត់ តាម រយៈស្បែកចំហ ដូចជាកោសខ្យល់ ឬកាត់ក្រចកមុតស្បែក ឬក៏ សិតសក់ដាច់ស្បែកក្បាលជាដើម ។
- អញ្ចឹង បងមានទៅជោះឈាមហើយឬនៅ ?
- បងនិងរក្សាជោះហើយ នៅតែរង្គាទេ ដែលមិនទាន់ធ្វើ ។
- នៅភ្នំពេញនេះ មានអង្គការគេជួយពួកក្មេងរងគ្រោះ ដូចយើង ដែរឬទេបង ?
- បងថាប្រហែលជាមិនអត់ទេ ។ ចាំបងស៊ើបរកឃើញ បងនឹង យកប្អូនទៅជោះហើយ ។ យ៉ាងណាៗ បើយើងបាននឹងមុននោះ យើងនឹងមានឱកាសព្យាបាលវាទាន់ពេល ។

ថាហើយ នាងក៏ចេញទៅធ្វើការ ៖
- រង្គា! ថ្ងៃនេះ នៅចាំផ្ទះ កុំដើរលេងរហេតរហូត ឮហើយនៅ ? ពេលព្រលប់ទៅចាំទទួលបងផង នៅមាត់ទ្វាររោងចក្រ ព្រោះបង មិនចូលចិត្តដើរយប់ព្រលប់ម្នាក់ឯងទេ ។
- បាទ បង!

--------------------

តុក! តុក! តុក!

រាសីកំពុងអានរបាយការណ៍ពីការិយាល័យខាងក្រោម ។ កាល បើឮសូរគោះទ្វារ នាងក៏ងើបមុខឡើង ឃើញសារៈនៅឈរអោប ដៃផ្អែកគែមទ្វារញញឹមមករកនាង ។ ថ្ងៃនេះ គេមិនបានប្រើឈើ ច្រត់ទេ ជាសញ្ញាថា ជើងរបស់គេកំពុងជាសះស្បើយហើយ ។

- លោកសារៈ ?
- បាទ! គឺខ្ញុំ!
- លោកមិនមានជាប់ពិរុទ្ធអ្វីជាមួយនឹងជិនហ្វូទេ ?
- បើជាប់នោះ ធ្វើម៉េចនឹងមកឈរញញឹមនៅទីនេះកើត ?
- ឬក៏... មិនទាន់ដល់ពេល ?
- ពុទ្ធោ! ម៉េចក៏ដាក់ទំនាយខ្ញុំអញ្ចឹងរាសី ? ខំតែចិត្តល្អមកជួយ មើលសុខទុក្ខអ្នកចូលធ្វើការថ្មី តែគេបែរជាបន់អោយខ្ញុំជាប់ពិរុទ្ធ ទៅវិញ ?
- លោកចង់ថាអោយនរណា គេគេ ?
- នរណាដែលមានខ្លួន យកទៅ!

រាសីសម្លក់ ។ ការពិត ពេលនេះ នរៈបានកែប្រែឫកពាររបស់ គេច្រើនណាស់ ថ្វីបើនៅភ្លាត់ស្នៀតម្ដងម្កាលក៏ដោយ តែការផ្លាស់ ប្ដូររបស់គេមានភាពវិជ្ជមានគួរអោយកត់សំគាល់មែន ជាពិសេស ជាមួយនារីទូទៅក្នុងរោងចក្រ ។

- ហេតុអ្វីលោកបាត់ខ្លួនទៅចោលរោងចក្រ រួចបណ្ដែតបណ្ដោយឲ្យ ខ្ញុំទទួលខុសត្រូវតែម្នាក់ឯងដូច្នេះ ?
- នឹកសារៈមែនទេ បានខំរអ៊ូដល់ម្លឹង ? (សារៈសួរបញ្ច្រាសវិញ)
- នរណាថា ? ចុះលោកមិនបារម្ភថាខ្ញុំធ្វើការមិនល្អទេហ្ស៎ ?

សារៈគ្រវីក្បាល ឆ្លើយថា ៖

- អត់ទេ! សារៈទុកចិត្តរាសីទាំងស្រុងតែម្ដងហើយ ។
- ម៉េចក៏លោកមានជំនឿចិត្តដល់ម្លឹង ?
- មិនជឿលើខ្លួនខ្ញុំទេ គឺជឿលើមោទនភាពដ៏រឹងត្អឹងរបស់រាសី ទេតើ គឺរាសីជាមនុស្សដែលមិនព្រមចុះចាញ់អំពើខុសច្បាប់ ខុស វិន័យទេ ។ ម្យ៉ាងទៀត រាសីបានអួតអាងថាអាចយកឈ្នះខ្ញុំបាន ដោយកម្លាំងប្រាជ្ញរបស់នាងផ្ទាល់ ។ ពេលនេះ ខ្ញុំចង់ពិសោធន៍ មើលថាតើនាងធ្វើការបានឈ្នះខ្ញុំដែរឬទេ... ឬក៏បានតែមាត់ ?

CHANBOKEO.COM

រាសីនៅស្ងៀម សម្លឹងមុខសារៈមួយស្របក់ ទើបឆ្លើយថា ៖

- ក៏បាន! ខ្ញុំមិនខ្លាចនឹងពិសោធន៍អោយលោកឃើញទេ ។

សារៈឮដូច្នោះភ្លាម ក៏ញញឹមឡើងគ្រហាញតែម្តង ៖

- សារៈកំពុងរង់ចាំមើលហើយតើហ៎ ។

ភ្លាមនោះ សារៈដូរប្រយោគវិញ សួររាសីថា ៖

- អោយខ្ញុំជូនរាសីទៅតុលាការព្រឹកនេះទេ ?
- ហើយ... លោកសារៈមានពេលដែរ ?
- ក្រែងដើម្បីប្រយោជន៍ជីនហួតើហ៎ ម៉េចក៏ថាសារៈគ្មានពេល ?
- ព្រោះឃើញលោកបាត់ខ្លួនញឹកពេក ។
- ប្រចណ្ឌហ្ន៎ស ?
- ឆ្កួតហើយ! និយាយអីផ្ដេសផ្ដាសអញ្ចឹង ?

សារៈសើចខឹកៗដែលបានលលេងនឹងរាសី ៖

- និយាយលេងទេ! ការពិត ខ្ញុំអាល័យទៅជួយមើលកិច្ចការរបស់លោកប៉ានៅឯសណ្ឋាគារផ្កាយប្រាំឯណោះ ទើបមិនសូវមានពេល មកទីនេះ ។ ណាមួយខ្ញុំចង់ពិសោធន៍សមត្ថភាពរបស់រាសីដែរ!

មាណពស្រដីផង ចោលភ្នែកមន្តស្នេហ៍ដាក់រាសីផង ។ ធិតា ឃើញដូច្នោះ ក៏គ្រហែមឡើង ៖

- នេះ! កន្លែងធ្វើការចាស៎! សូមមានមេត្តារក្សាព្រំដែនបន្តិច ។
- បាទ! ចៅហ្វាយស្រី ។ អញ្ចឹង ខ្ញុំដើរទៅចាំនៅខាងក្រោមចុះ!

ថាហើយ គេក៏សើចញញឹមដាក់នាងម្តងទៀត ទើបចេញទៅ ។ រាសីយកដៃអេះក្បាលទ្រាំមិនបាន ក៏ញញឹមដែរ ៖

- ហ៊ឺ! យើងនេះជាមនុស្សរមាំងរមោក រកលេខដាក់គ្មានទេ ប៉ុន្តែហេតុអ្វីក៏បុរសទាំងនេះចូលចិត្តមកពង្រាយស្នេហ៍ដាក់យើងដូច្នេះ ? ដូចជាមិនយល់សោះតែម្តងហើយ!

នៅក្នុងសាលក្រមកាត់ក្តី...

មេធាវីចៅកៃខាំងឡើងបើកសវនា ៖

- ចៅកៃមានរបួសធ្ងន់ណាស់ មិនដឹងថានឹងដឹងខ្លួនពេលណាទេ...

CHANBOKEO.COM

ដូច្នេះសូមតុលាការលើកពេលពន្យារការកាត់ទោស ត្បិតកូនក្តីមិន ទាន់នឹងស្មារតីនឹងអាចមកការពារករណីរបស់ខ្លួនបាន ។

នៅក្នុងសាលកាត់ក្តី រាសីក្រឡេកឃើញជិនហួរអង្គុយជាមួយ មេធាវីបីនាក់ ជាតិចិនពីរនាក់ ជាតិខ្មែរម្នាក់ ។ ជិនហួក៏បានលួច ចោលកន្ទុយភ្នែកដាក់នាងជាច្រើនដងដែរ ទំនងហាក់ដូចជាកំពុង តែអង្វរចិត្តនាងអោយជួយស្រោចស្រង់រូបគេ ។ រាសីឃើញហើយ គិតក្នុងចិត្តថា ៖

- ជិនហួ! ថ្ងៃមុន យើងបានជួយលោកផុតគ្រោះថ្នាក់ ថែមទាំង បានជូនលោកទៅដាក់ពេទ្យព្យាបាលទៀតផង ។ តែលោកបែរជា សងយើងវិញ ដោយភាពគម្រោះគម្រើយចំអកឡកឡឺយចំពោះទឹក ចិត្តរបស់យើង ។ លោកបានយកប្រាក់បីដុល្លារ មកកាត់ថ្លៃសន្តាន ចិត្តមនុស្សពីរនាក់ដែលជួយសង្គ្រោះលោក ។ ឯការដែលលោក យករាសីចូលធ្វើការក្នុងរោងចក្រនោះ មិនមែនបានន័យថាលោក មានចិត្តល្អចំពោះរាសីដែរ ការពិតមកពីលោកអាមាសខ្លួនដែលចាប់ កំហុសរាសីមិនបាន ពេលនាំគ្នីគ្នាមកឈ្លានពានឆែកឆេរផ្ទះខ្ញុំរក ឯកសារ១០សន្លឹក ។ រីឯការដែលលោកនាំរាសីទៅចូលរួមពិធីជប់ លៀងនៅភោជនីយដ្ឋាន ព្រោះលោកចង់ទាក់ចិត្តរាសីឲ្យហើបមាត់ ពីរឿងឯកសារសម្ងាត់នោះ ។ យើងមិនទន់ចិត្តចាញ់បោកមន្តស្នេហ៍ បុរសបរទេសដ៏ឆ្មើងឆ្មៃដូចជាជិនហួទេ...កុំច្រឡំ! លោកមានល្បិច ជ្រៅណាស់! ភាពញញឹមលើផ្ទៃមុខរបស់លោកគ្រាន់តែជាវាំងនន បិទបាំងដួងចិត្តដ៏ឧក្រិដ្ឋរបស់លោកតែប៉ុណ្ណោះ ។ រាសីស្គាល់បេះ ដូងរបស់លោកដល់បាត... កុំយកភាពញញឹមសំបកក្រៅ មក ពង្រាយមន្តស្នេហ៍ដាក់រាសីអី...គ្មានថ្ងៃដែលរាសីភ្លេចខ្លួនធ្វើអ្វីដើម្បី មនុស្សឧក្រិដ្ឋឡើយ ។ ថ្ងៃនេះ លោកដឹងហើយឬនៅ ថាអារម្មណ៍ របស់អ្នកចាញ់ អ្នកទាល់ច្រកនោះវាយ៉ាងម៉េចដែរ ? ដល់ថ្ងៃហើយ ដែលលោកត្រូវសងរាសីវិញ!!

រាសីធ្វើជាមិនឃើញក្រសែភ្នែករបស់ជិនហួ ។ តុលាការក៏បន្ត សវនាការកាត់ក្តីតទៅទៀត ។ រំពេចនោះមេធាវីខាងក្រសួងប៉ូលីស បានហៅសុំរាសីជាសាក្សី ដើម្បីបង្ហាញសំណៅដើមទាំង១០សន្លឹក នោះជូនតុលាការ ។ រាសីភ្ញាក់ព្រើតដើបឡើងប្រគល់ស្រោមសំបុត្រ ផ្ទាំងធំមួយ

CHANBOKEO.COM

ជូនទៅមេធាវីដែលដើរមកទទួលសំណៅពីដៃនិតាផ្ទាល់ ជូនទៅលោកចៅក្រម ។ រំពេចនោះ ស្រាប់តែជិនហួបើកភ្នែកធំៗ
ហើយស្ទុះងើបឈរឡើងទះតុផាំង រួចស្រែកលាន់ខ្ទ័រថា ៖

- រាសី! គឺនាងមែនតើហ៎ ដែលលួចឯកសាររបស់យើង!

រួចហើយ នាយស្ទុះហោលោតឆ្លោះតុ ហក់មកដល់ចំពោះមុខ នារី រួចលូកដៃច្របាច់កនារីយ៉ាងអស់ទំហឹង ធ្វើអោយអ្នកដែល ក្នុងសាលក្រមភ្ញាក់ក្រញាង ។ រំពេចនោះ ពពួកអធិការប្រចាំ សាលក្រមក៏ស្ទុះមកធ្វើអន្តរាគមន៍យ៉ាងរហ័សដូចព្រួញ ។ ក្រោយពី បំបែកជិនហួបានហើយ គេក៏ដាក់ខ្នោះនាំខ្លួននាយត្រឡប់ទៅទីតាំងដើមនោះវិញ ។ ប៉ុន្តែ ជិនហួមិនព្រមសំងំមាត់ទេ ។ គេនៅតែ ស្រែករ៉ូងរ៉ាំងដដែលថា ៖

- យើងដឹងថានាងគឺជាចោរលួចរបស់នោះយូរមកហើយ គ្រាន់តែ យើងចាប់ភស្តុតាងមិនបាន!... កុំអីនាងមិនបានមកអង្គុយញញឹម មុខស្រស់ដូច្នេះទេ នាងចោរមុខស្រស់! នាងរមិលគុណណាស់! យើងខំធ្វើអំពើល្អលើនាង តែនាងបែរជាលូកថ្លើមយើង!!

- សូមស្ងៀមស្ងាត់លោកជិនហួ! នេះជាសាលក្រមតុលាការ! សូម រក្សាវិន័យផង! (លោកចៅក្រមមានប្រសាសន៍) បើអ្នកមិនអាច រក្សាអារម្មណ៍ស្ងប់ស្ងាត់បានទេ យើងនឹងបញ្ជូននាយទៅគុកវិញ ឥឡូវ ពីបទប្រើហិង្សា នៅចំពោះមុខតុលាការ ។

ប៉ូលីសមាឌធំៗពីររូបមកឈរក្រៀកជិនហួជាប់ ។ នាយយើង ក៏មិទមាត់ដូចគេចុកកាលបើឮដូច្នោះ ។ រាសីខឹងណាស់ ទប់ចិត្តមិន បាន ក៏ងើបឡើងសូមច្បាប់ពីចៅក្រម ដើម្បីឆ្លើយតបទៅជិនហួ វិញ ។ ឃើញឥរិយាបថដ៏មានវិន័យរបស់នាង លោកចៅក្រមក៏ងក់ ក្បាលអនុញ្ញាត្ត ។ រាសីក៏ងើបឈរឡើង វាចាយ៉ាងក្លាហានម៉ឺងម៉ាត់ ប្រកបដោយសតិនិងប្រាជ្ញទៅជិនហួ ព្រមជាមួយនឹងក្រសែភ្នែក ដ៏មុតរបស់នាង មិនចាញ់ផ្លែកាំបិតទើបសម្លៀងហើយ ៖

- លោកជិនហួថាខ្ញុំជាចោរក៏ថាបាន ព្រោះខ្ញុំបានយកឯកសារនោះ ពីកាតាបរបស់លោកពិតមែន ប៉ុន្តែកិរិយាខ្ញុំនោះ មិនមែនជាកិរិយា របស់ចោរទេ គឺជាកិរិយារបស់ពលរដ្ឋខ្មែរដ៏ល្អម្នាក់ ធ្វើឡើងដើម្បី ចាប់ចោរបរទេស ដែលចូលមកក្នុងដីខ្មែរ ធ្វើចោរកេងប្រវ័ញ្ច លើ ជាតិខ្មែរដើម្បីប្រយោជន៍របស់ខ្លួន ដោយអំពើប្រព្រឹត្តទុច្ចរិតបំពាន ច្បាប់ទាំងព្រហើន ។ ចំពោះការដែលលោកជេរខ្ញុំថា ជាជនរមិល គុណចំពោះគុណបំណាច់ជិនហួផ្តល់ការងារឲ្យធ្វើ ដើម្បីលៀងក្រពះ នោះ តើលោកមានដែលយកសតិប្រាជ្ញរបស់លោក មកវិភាគលើ

CHANBOKEO.COM

កិរិយានិងការប្រព្រឹត្តរបស់ខ្លួនលោកផ្ទាល់ដែរទេ ? ឬក៏ចេះត្រឹមតែ វិភាគអ្នកដទៃតែប៉ុណ្ណោះ ? មើលចុះ ! ជាតិខ្មែរមានគុណចំពោះ លោកយ៉ាងណា ដែលបានប្រគល់សិទ្ធិឲ្យលោកធ្វើការរកស៊ីមានបាន នៅស្រុកយើង តែលោកបែរជាអកតញ្ញូប្រព្រឹត្តទុច្ចរិតក្បត់ជាតិខ្មែរ ទៅវិញ ។ ពេលនេះ តើលោករមិលគុណចំពោះជាតិខ្មែរប៉ុនណា ? មើលទៅ ! មើលទៅ ! ឯកសារទាំង១០សន្លឹកនោះ វាមានស៊ីញ៉េ របស់លោកនិងថៅកែឌាំង យល់ព្រមលើគំរោងរត់ពន្ធគ្រឿងញៀន បន្លំក្នុងកេសឥវ៉ាន់របស់រោងចក្រ តាមរយៈច្រកណាខ្លះតាមព្រំដែន តាមផែ និងតាមជើងយន្តហោះនានា ដោយមានទាំងរាយឈ្មោះ មន្ត្រីធំៗដែលនៅពីក្រោយខ្នង ជាបង្អែកបាំងភ្នែកជាតិខ្មែរក្នុងការ រកស៊ីទុច្ចរិតនោះទៀតផង ។ ថៃដន្យ ខ្ញុំបានពង្រាយពត៌មានទាំងឡាយនោះតាមមណ្ឌលស្នងការប៉ូលីស ពាសពេញភ្នំពេញគ្រប់ ច្រកអស់ទៅហើយ ពិបាកនឹងអោយមន្ត្រីពុករលួយប៉ុន្មាននាក់នោះ គ្របបំបិទរឿងនេះឲ្យស្ងាត់បានណាស់ ។ វេលានេះ នៅចំពោះមុខ សាលក្រមទាំងមូល រាសីខ្ញុំសូមបង្ហាញនូវជំនឿជឿជាក់លើភាពយុត្តិធម៌របស់តុលាការជាតិខ្មែរ កាត់ទោសបុរសឈ្មោះជិនហ្ហួ និង បណ្តាញទាំងឡាយរបស់គេឲ្យសក្តិសមនឹងអំពើទុច្ចរិតទាំងឡាយ ដែលគេបានប្រព្រឹត្តទៅលើជាតិខ្មែរយើង ។ នាងខ្ញុំសូមបញ្ចប់ សាវនាដោយក្តីគោរពចំពោះក្រមតុលាការយ៉ាងខ្ពង់ខ្ពស់ ។

លោកចៅក្រម ក៏ដូចជាលោកឧត្តមសេនីយអគ្គស្នងការ ឬ សូម្បីតែជិនហ្ហួ មេធាវី អាវ៉ូកា និងនរណាៗ ទាំងអស់ដែលមាន វត្តមាននៅក្នុងសាលក្រមនោះ បើកភ្នែកធំៗដោយការភ្ញាក់ផ្អើលចំពោះការវិភាគវែកញែករបស់នារីយើងយ៉ាងល្អិតល្អន់ ។

ពេលនោះ ជិនហ្ហួបាត់មាត់ឈឹងតែម្តង ទុកអោយមេធាវីរបស់ គេធ្វើការជំនួសវិញ ។ នៅវេលាចុងក្រោយនៃសវនាការកាត់ទោស នោះ រាសីបានឃើញជិនហ្ហួឈ្ងោកមុខចុះ ហាក់ដូចជាកំពុងដឹងថា គេរកច្រកចេញលែងឃើញហើយ ។

សារៈនិងលោកសារាយ ក៏នៅអង្គុយស្តាប់ការកាត់ទោសនោះ ចប់ចុងចប់ដើម ។ ថៃដន្យ អ្នកទាំងពីរមិនមានជាប់ឈ្មោះនៅក្នុង បណ្តាញនោះទេ តែជាប់ទោសត្រង់ថា មិនបានពិនិត្យកិច្ចការក្នុង រោងចក្រអោយបានហ្មត់ចត់ បណ្តោយឲ្យគូវិនិយោទុនឆ្លៀតឱកាស បង្កនូវសកម្មភាពទុច្ចរិតនៅក្នុងរោងចក្របាន ។ ពួកគេក៏ត្រូវបាន តុលាការពិន័យទោសខ្លះដែរ តែមិនដល់ថ្នាក់ជាប់គុក ឬដកហូត សិទ្ធិមិនឲ្យបើករោងចក្រនោះទេ ។

រាសីដើរឈ្ងោកៗចេញមកក្រៅរបង ស្រាប់តែ ៖

CHANBOKEO.COM

- រាសី!

នាងដើបបែរក្រោយមើលម្ចាស់សម្លេង ក៏ប្រទះនឹងលោកសារាយឈរទន្ទឹមនឹងសារៈកូនប្រុសរបស់លោក ញញឹមដាក់នាង៖

- ចា៎ស ? លោកមានការអ្វីចង់និយាយជាមួយខ្ញុំមែនទេ ?
- មែនហើយ! នាងឡើងឡានតាមខ្ញុំមក៎!

រាសីភ្ញាក់ព្រើត នឹកភ័យក្តុកៗក្នុងចិត្ត នឹកថាប្រហែលជាលោកនាំនាងទៅនិយាយរឿងសាវរីកូនស្រីរបស់លោកហើយ ។ នាងក៏លូនចូលទៅក្នុងឡានធ្វើដំណើរចេញទៅជាមួយអ្នកទាំងពីរ ។

មកដល់ភោជនីយដ្ឋានទំនើបមួយ ក្នុងសណ្ឋាគារផ្កាយប្រាំ...

លោកសារាយនិងសារៈ បាននាំរាសីមកដល់តុមួយ ដែលមានសាវរីនៅអង្គុយចាំទីនោះស្រាប់ ។ នាងភ្ញាក់ព្រើត កាន់តែបុកពោះ ថែមទៀត ។ បន្តិចមក នាងក៏តាំងអារម្មណ៍បាននឹងនវិញ ហើយក៏ញញឹមធ្វើមិនដឹង ។

- នេះ សាវរី! កូនស្រីរបស់ខ្ញុំណា៎រាសី!

រាសីលើកដៃជំរាបសួរ ថែមទាំងឆ្លើយថា ៖

- យើងធ្លាប់ជួបគ្នារួចហើយ លោកសារាយ!

ថៃដន្យ សាវរីលើកនេះ ហាក់ដូចជាសុភាពដាក់រាសីជាងមុន ច្រើនយ៉ាងប្លែកតែម្តង ។ ភ្លាមនោះ លោកសារាយមានប្រសាសន៍បន្តថា ៖

- រាសី! ពេលនេះ ជិនហួត្រូវតុលាការដកសិទ្ធិចេញពីរោងចក្រ យើងហើយ ហើយសារៈត្រូវនៅធ្វើការនៅសណ្ឋាគារផ្កាយប្រាំញឹក ញាប់ មិនអាចទៅជួយកិច្ចការរបស់នាងបានដឹតដល់ ។ ដូច្នេះបើ សាវរីទៅជួយធ្វើការទីនោះជាមួយនាង តើនាងគិតយ៉ាងម៉េចដែរ ?

រាសីភ្ញាក់ព្រើតឆ្លើយវិញថា ៖

- រាសីជាបុគ្គលិកស៊ីប្រាក់ខែ គ្មានសិទ្ធិសំរេចរឿងដូច្នេះទេ ចា៎ស!
- ចុះបើខ្ញុំអោយសិទ្ធិនាងសំរេច ?

CHANBOKEO.COM

- បើដូច្នោះមែន ខ្ញុំគិតថា អ្នកនាងសាវរីមិនអាចចាប់ផ្ដើមធ្វើការ ក្នុងឋានៈជាមេកោយបានទេ ព្រោះមិនដែលហែលឆ្លងការពិសោធន៍ ក្នុងការងារនឿយហត់យ៉ាងនេះ ពិតជាមិនអាចយល់ស្ថានភាពការ ងារនិងអារម្មណ៍របស់អ្នកធ្វើការបានគ្រប់ជ្រុងជ្រោយ អាចជ្រុល រំលោភសិទ្ធិមាត់ធំមាត់តូចដាក់កម្មករទាំងឡាយ ដោយប្រការណា ដែលខ្លួនមាស់ចិត្ត ។

អ្នកទាំងបីនោះបើកភ្នែកមើលមុខគ្នា ដែលរាសីនិយាយចំៗ ដោយមិនខ្លាចចិត្ត ។

- ល្អណាស់ដែលនាងហ៊ាននិយាយត្រង់យ៉ាងនេះ! យើងចូលចិត្ត!

(លោកសារាយតប) អញ្ចឹង ខ្ញុំនឹងអោយនាងនាំសាវរីទៅធ្វើការ ជាមួយនាងចាប់ពីថ្ងៃនេះតែម្តង គឺខ្ញុំចាត់អោយរាសីធ្វើជាមេកោយ ហើយសាវរីជាអនុប្រធាន យ៉ាងម៉េចដែរ ?

ស្រាប់តែរាសីលាន់មាត់ទាំងភ្ញាក់ផ្អើលថា ៖

- អូហ៍ពុទ្ធោ! ហើយចុះម៉េចលោកទុកចិត្តរាសីដល់ម្លឹង ?

- អឺហ៍ រៀនទុកចិត្តនាងខ្លះៗអោយហើយទៅ ម្យ៉ាងដោយសារ នាងមានទេពកោសល្យខាងចាត់ចែង មានសន្តានចិត្ត មានគុណធម៌ ខ្ពស់ ម្យ៉ាងទៀតដោយសារនាងបានជួយជំរះសំអាតភាពទុច្ចរិតនៅ ក្នុងរោងចក្រ មិនឲ្យយើងរលំរលាយដោយសារការចូលភាគហ៊ុន ជាមួយមនុស្សខូច ។ ណាមួយ.. ថាមិនត្រូវទេ ទៅអនាគត យើង អាចជាប់សាច់ឈាមនឹងគ្នាយ៉ាងជិតដិតផងក៏មិនដឹង ។

លោកសារាយមានប្រសាសន៍ផង លួចដៀងកន្ទុយភ្នែកដាក់ សារៈផង ដែលអង្គុយញញឹមដាក់រាសីមិនដាច់សោះ ។ នារីយើង យល់អត្ថន័យភ្លាមតែម្តង ៖

- ថាមិនត្រូវដែរ ថាតើនរណាទៅហ្ន៎ មានសមត្ថភាពនិងលក្ខណៈ សម្បត្តិល្អគ្រប់គ្រាន់មកចូលខ្លួនអោយរាសីជ្រើសរើសនោះ ?

ធិតានិយាយអោយព្រងើយ ។ លោកសារាយសើចកក្អឹក តប ទៅនាងវិញថា ៖

- ប្រហែលជាគេនោះ កំពុងខុសខាត់គុណសម្បត្តិរបស់គេ អោយភ្លឺ ចាំងភ្នែករាសីមុនគេហើយ ក៏មិនដឹង ។

រាសីក៏សើចតាមដែរ ។ ទទួលក្រឡេកឃើញសាវរីនៅស្ងៀម មិននិយាយអ្វីតាមទម្លាប់របស់នាងដែលបានមាត់បានសំដី រាសីក៏ លើកដៃស្តាំឡើង ហើយស្រដីថា ៖

- រាសីសុំស្វាគមន៍បងស្រីជាគូកនការងារ!

សាវរីខ្លាចចាញ់ចិត្តក្មេងស្រីម្នាក់នោះ ក៏លូកដៃចាប់វិញ ៖

CHANBOKEO.COM

- ស្វាគមន៍អ្នកនាងប្រធានថ្មី! បើមានអ្វីខុសឆ្គង សូមអញ្ជើញជួយ ណែនាំផង តែសូមមេត្តាកុំប្រើកម្លាំងបាយទៀតអីណា៎!

រាសីបើកភ្នែកមូលក្រឡង់ នឹងភ្លាមថាសាវរីចង់សំដៅលើការ ដែលរាសីចាប់ប្រើកម្លាំងបង្ខំសាវរីកាលពីលើកមួយនោះ ។ នាង បែរជាញញឹមហើយឆ្លើយថា ៖

- ហ៉ែសៗ! អ្នកដែលប្រើកម្លាំងបាយ មានបីយ៉ាង មួយគឺពពួក អ្នកធំនិងអ្នកមាន ដែលគ្មានសតិប្រាជ្ញត្រួតត្រាអ្នកដទៃបាន ព្រោះ គេខ្វះគុណសម្បត្តិល្អ ទើបប្រើលុយនិងអំណាចកម្លាំងបាយជំនួស ។ ទីពីរគឺក្រុមឆ្កែទាល់ច្រកដែលត្រូវគេបំពាន តែមិនអាចតបតអ្វីបាន ក្រៅពីសងសឹកវិញដោយកម្លាំងបាយ ។ ទីបីគឺពពួកអវិជ្ជាទូទៅ ដែលគ្មានសតិប្រាជ្ញ នឹងស្វែងរកមធ្យោបាយអហិង្សា ដើម្បីដោះ ស្រាយបញ្ហា ។ ចំពោះរាសីវិញ មិនចូលចិត្តការប្រើកម្លាំងបាយទេ តែគេបង្ខំទៅទាល់ច្រក រាសីសូមតបដោយកម្លាំងបាយវិញហើយ ។

សាវរីធ្វើមុខស្មើ ទំនងដូចជាដឹងខ្លួន ៖

- អោយខ្ញុំសូមទោសផងណា៎ ដែលខ្ញុំធ្លាប់មានចរិតមិនល្អលើរាសី កាលពីមុន ។ ការពិត ខ្ញុំមិនអាចវាយតម្លៃមនុស្សដោយវណ្ណៈរបស់ គេ ពិតមែនហើយ ។ ជួនកាលគេមានវណ្ណៈត្រឹមជាអ្នកក្រីក្រមកពី ជនបទ ធ្វើការជាកម្មករសាមញ្ញ តែគេក៏អាចមានសីលធម៌និងគុណ សម្បត្តិអ្វីទៀតល្អខ្ពង់ខ្ពស់ប្រសើរជាអ្នកក្រុង ដែលមានវណ្ណៈខ្ពស់ៗ ទាំងឡាយនោះទៅទៀត ។ វណ្ណៈតែម្យ៉ាង មិនអាចឆ្លុះបញ្ចាំងឲ្យ ឃើញនូវតម្លៃពិតរបស់មនុស្សទេ ។ គឺស្ថិតនៅលើសន្តានចិត្តនិង ការប្រព្រឹត្តរបស់គេ ។ បើយើងខ្វះទាំងពីរយ៉ាងនេះហើយ... ហ៊ឺ...

សាវរីដកដង្ហើមធំ ទំនងស្តាយក្រោយចំពោះឥរិយាបថរបស់ ខ្លួនកាលពីអតីតកាល ។ រាសីក៏ស្រដីតបវិញថា ៖

- តែអ្វីក៏មិនប្រសើរជាជាងការដឹងខ្លួន និងការកែប្រែរបស់មនុស្ស ដែលធ្លាប់ធ្វើខុសទេ ។ បងស្រីដឹងទេ នរណាដែលដឹងខ្លួនថា ធ្លាប់ ធ្វើខុស ហើយបានរកផ្លូវកែប្រែខ្លួនឲ្យមកល្អវិញទាន់ពេល គេចាត់ ទុកមនុស្សនោះ ថាជាវិរបុរសណា៎!

ស្រាប់តែសារៈញញឹមភ្លែតតែម្តង ៖

- រួចវិរបុរសពិតៗនោះ គឺសារៈនេះហើយ ។

CHANBOKEO.COM

គេនិយាយផង យកដៃទះទ្រូងរបស់គេបន្តើរៗផង ធ្វើអោយ
អ្នកទាំងអស់គ្នាសើចលាន់ឡើង ។ បរិយាកាសក៏ប្រែធូរស្រាលមក វិញរវាងអ្នកទាំងបួន ។
សារៈបានប្រាប់រាសីថា គេបានដឹងថាអារី
នោះជាសាវរីតាំងតែពីនាងទាញកាំភ្លើងបាញ់នាយម្ល៉េះព្រោះមានតែ សាវរីទេ
ដែលដឹងថានាយលាក់កាំភ្លើងនៅកជើងស្តាំ តែគេក៏ភ្ញាក់ ផ្អើលដែលសុខៗ
សាវរីក្លាយទៅជាមនុស្សចម្លែក ទើបមិនហ៊ាន កកូរកកាយឲ្យល្អក់ទឹក
ត្បិតខ្លាចសាវរីកំពុងបន្លំខ្លួនស៊ើបការអ្វី ។ ថៃ្ងនេះកាលនោះគេមានរបួសស្រាល
ទើបមិនជាខឹងនឹងប្អូនស្រី ប៉ុន្មាន ។ ក្រោយមកសាវរីក៏បានមកសុំទោសនាយវិញដែរ ។
បរិភោគរួច សាវរីក៏បររថយន្តនាំរាសីទៅរោងចក្រវិញ ។
តាមផ្លូវ...
- បងស្រី! អោយរាសីសុំទោសបងដែរដែលខ្ញុំបានលេងធ្ងន់ដៃ បន្តិចដាក់បងស្រី ។
ចំពោះរឿងចាក់ថ្នាំញៀន និងចាក់ឈាមចម្លង អេដស៍ដល់បងនោះ
គឺខ្ញុំសម្លុតស្មារតីបងស្រីលេងទេ ។ ការពិតគឺ ខ្ញុំបានចាក់កាល់ស្យូមអោយបងតើហ៍ ។
ឯរក្សាប្អូនប្រុសខ្ញុំនោះក៏ គ្មានផ្ទុកមេរោគអេដស៍ដែរ ។ ចំណែកបណ្ណ័មន្ទីរពេទ្យដែលខ្ញុំ
បង្ហាញបងនោះជារបស់ម្តាយខ្ញុំ មិនមែនរបស់រក្សាឡើយ ។
អារីកាន់ចង្កូតឡានផង ញញឹមផង ៖
- មិនបាច់ប្រាប់ក៏បងបានដឹងរួចហើយដែរថា ប្អូនគ្រាន់តែសម្លុត បងលេងប៉ុនហ្នឹង
ត្បិតបងបានទៅពេទ្យដោះឈាមហើយ ។ ពេល នេះ
បងបានរំសាយរឿងទាំងនោះពីក្នុងចិត្តអស់ហើយ មិនបាន កាន់ទុកក្នុងចិត្តតទៅទៀតទេ ។
នេះបើកុំតែបានរាសីជួយដាស់ តឿនខ្លះៗ បងប្រហែលជាធ្លាក់អន្លង់ក្នុងល្បិចរបស់ជិនហ្វរហូត
ហើយ ។ វាគួរអោយខ្មាស់ណាស់ដែលបងបណ្តោយអោយគេប្រើដៃ បងឲ្យជាន់កខ្មែរគ្នាឯង
ដើម្បីប្រយោជន៍របស់គេ ។ ថៃ្ងនេះ បាន ប្អូនមកទាន់ពេល
ជួយសង្គ្រោះរោងចក្រនិងកេរ្តិ៍ឈ្មោះគ្រួសាររបស់ បង ។ ដូច្នេះ
គឺបងទេដែលត្រូវសូមទោសហើយអរគុណប្អូន!!
រាសីញញឹមឡើង ដែលដឹងថា សាវរីបានរំសាយចិត្តគំនិតជា សត្រូវនឹងនាងចោលអស់ ។
ធិតាក៏ញញឹមឡើង ៖
- អញ្ចឹង! រាសីសុំចាប់ដៃធ្វើជាមិត្តជាមួយបងវិញហើយណា៎!

CHANBOKEO.COM

- ចាស! យើងជាមិត្តល្អនឹងគ្នាចាប់តាំងពីថ្ងៃនេះតទៅ ។

មកដល់រោងចក្រ រាសីបានឃើញកម្មកររាប់រយរាប់ពាន់នៅ ឈររង់ចាំកណ្ដាលទីធ្លាអ៊ូអរ ថែមទាំងឃើញបដាសរសេរអក្សរធំៗ ថា " សូមស្វាគមន៍អ្នកនាងនាយក!" ព្រមជាមួយសម្រែកខ្លាំងៗ ថា "ជយោ រាសី! ជយោ ភាពសុចរិត! ជយោ សីលធម៌!"

កម្មករប្រុសស្រីមួយហ្វូងធំ បានមកជួយបើកទ្វារឡាន ទ្រខ្លួនរាសីឡើងអោយអណ្ដែតខ្ពស់លើអាកាស ហើយដង្ហែនាងឡើងដោយសំណើចក្អាកក្អាយពេញរោងចក្រ ។ មួយស្របក់ក្រោយមក ទើបពួកគេដាក់នាងចុះវិញ ។ ធិតាយើងរំភើបចិត្តរហូត ដល់ទៅ រលីងរលោងទឹកភ្នែកដោយមិនដឹងខ្លួន ៖

- ជំរាបបងប្អូនទាំងអស់ដែលជាកម្មករដូចគ្នា! យើងធ្វើការនៅទី នេះជាមួយគ្នា យើងជាបងប្អូនរួមការងារ យើងត្រូវតែជួយដោះ ស្រាយទុក្ខធុរៈគ្នា ហើយរាប់រកគ្នាដោយថ្លៃថ្នូរ ។ ការដែលយើងធ្វើ ការបានល្អ រោងចក្រក៏រីកចំរើន ។ កាលបើរោងចក្ររីកចំរើនល្អត លាស់ ថៅកែម្ចាស់រោងចក្រច្បាស់ជានឹងមានមោទនភាពចំពោះ សមត្ថភាពរបស់យើងរាល់គ្នា ។ កិច្ចការរបស់រាសីខ្ញុំនៅក្នុងរោង ចក្រនោះ គឺធ្វើយ៉ាងណាអោយថៅហ្វាយនាយទទួលសោមនស្ស ហើយរំភើបចិត្តចំពោះកម្មករទាំងឡាយ រួចហើយគេត្រូវតែត្រឡប់មកសម្ដែងនូវភាពសោមនស្ស និងការលើកទឹកចិត្តចំពោះអ្នកទាំង អស់ត្រឡប់វិញ មិនមែនគិតតែពីខាងប្រមូលតែម្យ៉ាង ដោយខ្វះការ លើកទឹកចិត្តចំពោះពួកយើងឡើយ ។ ជយោ កម្លាំងកម្មករ! បើគ្មានសាមគ្គីរវាងពួកយើងជាកម្មករ រោងចក្រច្បាស់ជាមិនអាចមានដំណើរការជោគជ័យគ្រប់គ្រាន់ឡើយ ។ ចាប់ពីថ្ងៃនេះតទៅ យើងនឹងវិវត្តន៍ទៅរកជោគជ័យទាំងអស់គ្នា ទាំងកម្មករ ទាំង ផលិតផល ទាំងចំណូលរបស់រោងចក្រ!... ជយោ សាមគ្គី!

ពពួកកម្មករក៏លើកដៃស្រែកជ័យឃោសយ៉ាងខ្ទរខ្ទារ ពេញផ្ទៃ រោងចក្រទាំងមូល ។ សាវរីឈរអោបដៃផ្អែករថយន្ត សម្លឹងស្ថានការណ៍ទីនោះ ហើយនឹកគិតក្នុងចិត្តថា ៖

- រាសីមកដល់ទីនេះដោយបាតដៃទទេ តែអាចសំរេចជំហានក្នុងជីវិតបានយ៉ាងខ្ពស់ដល់ថ្នាក់នេះ ចុះហេតុអ្វីយើងបែរជាធ្វើមិនបាន ដូចនាង ? គួរអោយអាមាសណាស់! ដូច្នេះ តើយើងត្រូវធ្វើយ៉ាង ណា ប្រព្រឹត្តយ៉ាងណា

CHANBOKEO.COM

ដើម្បីទិញប្រិយភាពនិងការស្រឡាញ់គោរព ពីអ្នកទាំងឡាយឲ្យបានប្រសើរដូច្នោះទៅ ?... មើលទៅ មិនដឹងជា យើងលំបាកយ៉ាងណាខ្លះហ្ន៎ ?

ធិតាឈរជ្រួញចិញ្ចើមគិតតែម្នាក់ឯង ដោយគ្មាននរណាម្នាក់អើពើនឹងវត្តមានរបស់នារីយើងឡើយ ។

oooooooooooooooooo

ooooo

o

CHANBOKEO . COM

# វគ្គទី១១

# អនាគតរាសី

ព្រឹកស្អែកឡើង ជាថ្ងៃដែលរាសីត្រូវបានសំរាកពីការងារ...

- រក្សា! រដ្ឋា! ថ្ងៃនេះ បងគិតថានាំប្អូនទៅផ្សារ ទិញ ខោអាវអោយប្អូនស្លៀកពាក់ទៅរៀន អោយបានសមរម្យបន្តិច ។

- មិនបាច់ទេ បង! (រក្សាប្រកែក) ខ្ញុំស្លៀកខោអាវចាស់ៗនេះ សិនក៏បានដែរ ទំរាំយើងធូរស្រាលជាងនេះ ។

- មែនហើយ បងរាសី (រដ្ឋានិយាយ) ខ្ញុំមិនខ្វល់រឿងស្លៀកពាក់ ទេ សុំអោយតែមានបាយគ្រប់គ្រាន់បានហើយ ។

រាសីអាណិតប្អូនខ្លោចចិត្តកាលបើឮគេនិយាយដូច្នេះ ។

- បើអញ្ចឹង យើងនាំគ្នាទៅផ្សារដើរទិញចំណីញ៉ាំអោយឆ្ងាញ់មាត់ ម្តង យ៉ាងម៉េចដែរ ?

- ជយោ! រដ្ឋាសុំញ៉ាំអោយឆ្អែតម្តង! (រដ្ឋាឧទានដោយត្រេកអរ)

បន្តិចមក អ្នកទាំងបីកក៏បិទទ្វារផ្ទះ នាំបងប្អូនដើរត្រសងចេញ តាមច្រកសំដៅទៅផ្លូវធំ ។ គ្រាន់តែមកដល់មាត់ផ្លូវកាលណា អ្នក ទាំងបីភ្ញាក់ព្រើត ដោយមានក្បួនហែមួយមកដល់ មានដាក់សញ្ញា ឈ្មោះសណ្ឋាគារផ្កាយប្រាំរបស់លោកសារាយ សញ្ញារបស់រោងចក្រ ជិនហ្វូអិលធីឌី ដែលបានផ្លាស់ឈ្មោះទៅជា រោងចក្រសាមគ្គី និង សញ្ញាស្នងការក្រសួងប៉ូលីស ព្រមទាំងមានពពួកកាសែត ក្រុម ប៉ូលីស បុគ្គលិកការងារ និងអ្នកស្រុកទាំងឡាយយ៉ាងគគ្រឹកគគ្រេង ចម្លែកភ្នែកណាស់ ។

រំពេចនោះ រាសីឃើញលោកឧត្តមសេនីយសក្តា ចុះពីរថយន្ត ប៉ូលីសដើរមកដល់ចំពោះមុខនាង ហើយមានប្រសាសន៍ថា ៖

- ដោយសារតែនាងចាប់ឯកសារ១០សន្លឹកនោះបញ្ជូនមកប៉ូលីស ទើបយើងអាចចាប់បានពាណិជ្ជឧក្រិដ្ឋជាច្រើននាក់ រួមទាំងមន្ត្រីពុក រលួយក្បាលកំពូលជាច្រើននាក់ទៀត.. ពេលនេះ ដើម្បីជាការតប ស្នងជូននាងវិញ យើងសូមជូនរង្វាន់ពិសេសមួយ ឲ្យនាងជ្រើស រើសដោយខ្លួនឯង ។

CHANBOKEO.COM

ពពួកកាសែតបានរត់ស្ទុះស្រទោមរោមនារីយើងជុំជិត រង់ចាំ ថតសម្លេងរបស់ធិតា ដែលនឹងឆ្លើយតបទៅលោកឧត្តមសេនិយ ។ រាសីបែរមើលទិដ្ឋភាពជុំវិញខ្លួន ហើយក៏សម្លឹងមុខប្អូនរបស់នាង ទាំងពីរនាក់ បន្ទាប់មក ក៏ស្រដីតបថា ៖

- បើសិនជានាងខ្ញុំមានលទ្ធភាពជ្រើសរើសបានមែននោះ នាងខ្ញុំ សុំឱកាសនិងលទ្ធភាពថ្មី ដើម្បីអោយបានចូលរៀនឡើងវិញ រហូត ដល់ចប់មហាវិទ្យាល័យ ។ មានតែការសិក្សាទេ ដែលអាចជួយឲ្យ ជីវិតខ្ញុំ រីកចំរើនល្អូតលាស់ជាងមុនដោយប្រសើរ ។ ម្យ៉ាងទៀត នាងខ្ញុំមានប្អូនស្រីម្នាក់ឈ្មោះរស្មី ដែលត្រូវថៅកែខ្មាំង ចាប់យក ទៅ ។ នាងខ្ញុំសូមអោយក្រសួងមានសមត្ថកិច្ច ជួយស្វែងរកនាង អោយបានត្រឡប់មកផ្ទះជួបជុំបងប្អូនវិញផង ។

ភ្លាមនោះ លោកឧត្តមសេនីយញញឹមឡើង រួចហើយបែរទៅ លោកធូម៉ានដែលនៅឈរជិតនោះ មិចភ្នែកជាសញ្ញា ។ លោក ធូម៉ានក៏បើកទ្វារឡានភ្លាម ។ នារីម្នាក់ដើរចុះពីរថយន្តក្នុងសភាព ទ្រុឌទ្រោមស្លេកស្លាំង ៖

- បងរាសី! (នាងហៅរាសីតិចៗ ទំនងខ្លាចចិត្ត)

- រស្មី ? ប្អូនស្រីរបស់បង! (រាសីលាន់មាត់ឡើង)

កាលបើយល់វត្តមានរស្មីភ្លាម ទាំងរាសី ទាំងរដ្ឋានិងរក្សាក៏នាំ គ្នារត់រឹងទៅស្រវាអោបនាង ដោយសេចក្តីនឹករលឹកនិងរំភើបចិត្ត ដែលនាងបានរួចពីកណ្តាប់ដៃថៅកែខ្មាំង ។ រស្មីស្រក់ទឹកភ្នែកតក់ៗ ដោយក្តីសោកស្តាយចំពោះកំហុសរបស់ខ្លួន រួចហើយស្រដីថា ៖

- ឲ្យរស្មីសុំទោសបងផង ដែលប្អូនមិនជឿតាមសំដីបង ទើបខ្លួន ត្រូវទទួលរងគ្រោះបែបនេះ ។ នេះបើកុំតែបានក្រុមប៉ូលីសទៅ បោសសំអាតកន្លែងដែលថៅកែខ្មាំងដែលឃុំឃាំងនារី ដើម្បីលក់សេវាបំរើកាមដល់ភ្ញៀវបរទេស កុំអីរស្មីមិនបានរួចខ្លួនមកវិញទេ!

រាសីអោបប្អូនហើយអង្អែលខ្នងនាងបន្តើរៗ ៖

- មានតែផ្ទះយើងទេ ដែលកក់ក្តៅ ព្រោះគ្មាននរណាគេធ្វើបាប ប្អូន ។ ថ្វីបើយើងក្រីក្របន្តិច តែប្អូននឹងមានសេចក្តីសុខ ចៀសផុត នូវការប្រមាថសព្វបែបយ៉ាងពីបុរសពាល ។

- ចា៎ស មែនហើយ! ពេលនេះ រស្មីដឹងហើយ ថាមានតែផ្ទះយើង ទេ ដែលផ្តល់សេចក្តីសុខចំពោះយើងលើសទីណាទាំងអស់ ។

CHANBOKEO.COM

ទាំងបួននាក់ក៏ស្រវាអោបគ្នាសាជាថ្មី ដោយក្ដីរីករាយជាលើក ដំបូងតាំងពីគេបែកគ្នាមក ។ មហាជនអនុជនទាំងឡាយដែលមាន វត្តមាននៅទីនោះ
ក៏ទះដៃហ៊ោរកញ្ជ្រៀវឡើងដើម្បីលើកទឹកចិត្ត បងប្អូនទាំងបួននាក់ ។ បន្តិចមក
លោកឧត្តមសេនីយសក្ដាក៏មាន
ប្រសាសន៍ឡើងថា ៖
- សំណើរបស់នាងត្រឹមត្រូវហើយសមរម្យណាស់ ។ ពួកយើង ស្មគ្រ័ជួយឧបត្ថម្ភរូបនាង រហូតដល់ត្រើយចុះ ។
ស្រាប់តែលោកសារាយ ដែលឈរស្ងៀមស្ងាត់នៅទីនោះយូរ ហើយ
ក៏មានប្រសាសន៍យ៉ាងរហ័សបន្ថែមថា ៖
- ថៃដន្យ រាសីជានាយចំណាត់ការរបស់រោងចក្រយើង ដូច្នេះសូម
មេត្តាជួយរៀបកាលវិភាគកម្មវិធីសិក្សា ដើម្បីអោយនាងអាចមក
ជួយលើកកម្លាំងចិត្តកម្មករនៅក្នុងរោងចក្រសាមគ្គីរបស់យើងផង!
លោកឧត្តមសេនីយសើចគ្រហាញកាលបើឮដូច្នោះ ៖
- ល្អើយចុះ! ខ្ញុំទុកអោយអ្នកទាំងពីរជជែកគ្នារឿងកាលវិភាគទៅ ចុះណា៎!
ខ្ញុំសូមដកខ្លួនថយហើយ ។
មហាជនអនុជនទាំងឡាយ ក៏ទះដៃសាទរនូវរង្វាន់ឧបត្ថម្ភដល់ រាសីសាជាថ្មី
យ៉ាងខ្ទៀវខ្ទារអឺងកង ។ បន្តិចមក ក្បួនទាំងមូលក៏ រំសាយទៅ ។ រាសីបាននាំប្អូនដើរលេងផ្សារ
ទិញអាហារបរិភោគ យ៉ាងឆ្អែតបំផុតក្នុងថ្ងៃនោះ ។ ថ្ងៃរសៀលបន្តិច ពួកគេក៏នាំគ្នាមក
ដល់មន្ទីរពេទ្យដើម្បីសួរសុខទុក្ខសយនា ។ នៅទីនោះ អ្នកទាំងបួន
បានប្រទះនឹងអ៊ីសាវិននិងស្រីខួច ព្រមទាំងសយនាដែលនៅអង្គុយ ញញឹមលើគ្រែអ្នកជំងឺ
ទំនងដូចជាបានធូរស្រាលវិញហើយ ។
- ជំរាបសួរលោកអ៊ី! ជំរាបសួរបងសយនា! សួស្ដីស្រីខួច!
សយនានិងអ៊ីសាវិនភ្ញាក់ក្រញាង កាលបើឃើញវត្តមានក្មេងៗ បួននាក់មកដល់ ។
រាសីក៏ណែនាំអោយស្គាល់ ស្រាប់តែសយនា ញញឹមឡើងស្រដីថា ៖
- បងស្គាល់ពួកគេអស់ហើយ រាសី!
- ម៉េចក៏បងសយនាដឹងកើត ?

CHANBOKEO.COM

- ព្រោះទូរទស្សន៍គេផ្សាយរឿងរាសីពីរថ្ងៃជាប់គ្នាហើយ តាំងពី រឿងនាយជិនហួរហូតដល់រឿងរាសីឡើងបុណ្យសក្តិនៅរោងចក្រ សាមគ្គី រឿងរាសីបានជួបជុំបងប្អូនវិញ និងបានរង្វាន់អាហារ រូបករណ៍សំរាប់ឧត្តមសិក្សាទៀតផង ។ ពេលនេះ រាសីអណ្តែតខ្ពស់លឿនជាងល្បឿនយន្តហោះទៅទៀត ។ ត្រឹមតែជិះម៉ូតចាស់ៗដូចសយនា ប្រហែលជាបោលតាមរាសីលែងទាន់ហើយ...

- ចេះតែថាហើយ បងសយនា! នោះគឺជាវាសនាថៃដន្យទេ ។

- វាសនាថៃដន្យ ក៏ផ្សំមកពីតម្លៃគុណសម្បត្តិរបស់បុគ្គលដែរ ។ បើបុគ្គលណាមួយខ្វះគុណសម្បត្តិល្អ ក៏វាសនាថៃដន្យ មិនអាចនាំគេអោយអណ្តែតខ្ពស់ស្មើនឹងរាសីពេលនេះបានឡើយ ។ អូហ៍ និយាយ អញ្ចឹងបងដូចជាឆ្ងល់ថាតើរាសីយកក្រដាសឯកសារ១០សន្លឹកនោះ ទៅទុកឯណាទើបជិនហួនាំគ្នីគ្នាទៅឆែកឆេរមិនឃើញអញ្ចឹង ?

- រឿងតូចៗប៉ុនហ្នឹងមានទៅពិបាកដោះស្រាយអី ។ ខ្ញុំបានផ្តិត ចម្លងច្រើនសន្លឹកឲ្យប្អូនរក្សាយកទៅប្រគល់អោយស្នងការប៉ូលីស គ្រប់ខណ្ឌគ្រប់មណ្ឌលក្នុងក្រុងដើម្បីអង្រួនការចាប់អារម្មណ៍ពីកង ប៉ូលីសគ្រប់ថ្នាក់ ។ ចំណែកឯសំណៅដើមវិញខ្ញុំបិទលាក់នៅពី ក្រោយក្រដាសរូបថតតួកុននិងអ្នកចំរៀងទាំងឡាយ ដែលបិទលើជញ្ជាំងនោះអី ។ ពួកវាឆោតណាស់ ប្រាជ្ញអន់ៗចាញ់រាសីជាកូន ក្មេងមិនសមជាថៅកែរោងចក្រអីបន្តិច ហ៉ៃសៗ !

រាសីសើចកក្អឹក កាលបើលេងល្បិចឆបោកឈ្នះថៅកែរោងចក្រទាំងមូលបាន ។ រំពេចនោះ ស្រីខួចរត់មកប្រឡែងជាមួយប្អូនៗ របស់រាសី ៖

- មីងៗ ពូៗ ចាំទៅលេងផ្ទះស្រីខួចណា៎! ស្រីខួចមានដើមដូងផ្លែចាំបេះចែកគ្នាញ៉ាំ ។

អ្នកទាំងអស់ញញឹមដាក់គ្នាឡើង ។ រាសីសង្កេតឃើញថា អ៊ី សាវិនក៏ហាក់ដូចជាបន្ធូរឥរិយាបថចំពោះមាណវីច្រើនណាស់ មិន ចង្អៀតចង្អល់ដូចថ្ងៃមុនឡើយ ។ គាត់សំណេះសំណាលគ្នាយ៉ាងរាក់ ទាក់ជាមួយនាងរហូតដល់ពេលនាងនាំប្អូនត្រឡប់ទៅផ្ទះវិញ ។

មកដល់មាត់ច្រកចូលមុខផ្ទះ ស្រាប់តែអ្នកទាំងអស់ប្រទះសារៈ ឈប់ឡានឈរចាំនៅទីនោះតាំងពីអង្កាល់មិនដឹង ។ រស្មីឃើញនាយភ្លាម ក៏ខិនខ្សិបដាក់បងស្រីថា ៖

CHANBOKEO.COM

- បងស្រីខ្ញុំដូចជាសម្ងួណាស់តើហ៎!

រាសីលូកដៃកេះប្អូន ហើយតបខ្សិបៗថា ៖

- គេមិនមែនសុទ្ធតែជាបុរសល្អគ្រប់គ្នាទេ ។ ប្រយត្ន័ខ្លួនខ្លះ ទើប ប្រសើរ ។ អ្វីដែលបុរសបានងាយ គេចោលវិញក៏ងាយដែរ ព្រោះ គេនឹងគិតថា របស់នោះគ្មានតម្លៃ ព្រោះគេដើររើសបានតាមផ្លូវ ដោយមិនបាច់ខំប្រឹងដើររក យល់ទេរស្មី ?

រស្មីនៅស្ងៀម មិនហ៊ានមាត់តទៅទៀត ។

- សួស្តីរាសី! ទំនេរទេ ? (សារៈសួរ)

- ទំនេរចាស! ទំនេរទាំងបួននាក់តែម្តង! បើសិនលោកអាចដឹក ដើរលេងទីក្រុងម៉ាជុំបាន ប្រហែលសប្បាយហើយយ៉ាង...!

សារៈបើកភ្នែកមូលក្រឡង់ ព្រោះគេចង់បបួលនាងតែម្នាក់ឯង ទេតើហ៎ ។ តែលុះឮរាសីពោលដូច្នោះ គេហាក់ដូចជាទើសទាល់ ក្នុងចិត្តបន្តិច ។ រាសីយល់អារម្មណ៍របស់នាយភ្លាម ក៏វាចាបន្តថា ៖

- ថៃដន្យ! បងប្អូនយើងទើបតែជួបជុំគ្នាថ្មីនេះឯង ។ លោកមិន ជួយអបអរការជួបជុំរបស់ពួកយើងទាំងបួននាក់ទេហ៎ ?

សារៈក៏ញញឹមឡើង ៖

- ក៏បាន! ម៉ោះ ឡើងឡានមក!

បន្តិចមក សារៈក៏បើកឡាននាំអ្នកទាំងបួនដល់មាត់ទន្លេមុខវាំង រួចហើយបរយឺតៗជុំវិញវត្តភ្នំ បើកឆ្ពោលទីក្រុងពីរបីជុំ ទើបសារៈ បើកឡើងស្ពានជ្រោយចង្វារឆ្លងទៅត្រើយម្ខាង ។ ពួកគេមិនដែល ឃើញទីក្រុងពេលយប់ទេ ។ កាលបើឃើញពន្លឺភ្លើងល្អព្រោងព្រាត គេទះដៃច្រៀងផងសើចផងយ៉ាងក្អាកក្អាយ ។ រីឯនាយសារៈដែល ធ្លាប់តែរឹងត្អឹង មិនសូវចេះសើចលេងនោះ ក៏ប្រែជាមានអារម្មណ៍ ថាខ្លួនគេហាក់ដូចជារីករាយនឹងភាពកក់ក្តៅរបស់ក្មេងកំព្រាទាំងបួន នាក់នោះណាស់ ។ បន្តិចមក សារៈបត់ចូលភោជនីយដ្ឋានទំនើប មួយ ។ ទាំងបួននាក់បងប្អូនមើលមុខគ្នា ។ រាសីក៏វាចាឡើងថា ៖

- សូមទៅកន្លែងផ្សេងបានទេ សប្បាយហើយ មានសេរីភាព មិនសូវពិបាកអោយពួកយើងរៀបខ្លួនផង ។

សារៈញញឹមមិនតបតទេ បែរជាថយឡានចេញទៅវិញ ។

នៅមុំមាត់ទន្លេ ក្បែររទេះលក់លតឆាមីឆាមួយ...

- នេះនែ៎! របស់ល្អ ដល់ហើយ! (រាសីស្រែកហៅបងប្អូន)

សារៈសម្លឹងមើលអ្នកទាំងបួនចាប់មីឆាចែកគ្នា ៖

- ម៉េចមិនទិញម្នាក់មួយចានញ៉ាំទៅ រាសី? (សារៈសួរ)

- មិនទេ ខ្លាចសល់! ទិញម្តងម៉ាចានចែកគ្នាញ៉ាំអស់សិន ចាំទិញ មួយទៀត ទើបវាមិនសល់ចោល ស្តាយលុយដែលខំធ្វើការបាន មកនោះណាស់ ។

- ប៉ុន្តែ ពេលនេះ ខ្ញុំជាអ្នកប៉ាវពួកនាងទេតើហ៎!

- បើដូច្នោះខ្ញុំរិតតែប្រយត្ន័ឡើង កុំអោយម្ចាស់សទ្ធាគេខកចិត្តដែល ឃើញយើងបរិភោគលោភលន់ហើយខ្ជីខ្ជា ដោយអាងតែខ្លួនមិន មែនជាអ្នកចេញលុយថ្លៃអាហារទាំងនេះ ។

សារៈកាន់ចង្កឹះចាប់មីរបណ្តើរលួចមើលរាសីបណ្តើរ ថែមទាំង នឹកគិតក្នុងចិត្តម្នាក់ឯង ៖

- នាងពូកែសំចៃណាស់ ធ្វើអ្វីមានរបៀបទៅតាមសមត្ថភាពរបស់ ខ្លួន មិនខ្ជះខ្ជាយ មិនលោភលន់ មិនរំភើបនឹងរបស់ដែលបុរស យកមកធ្វើជាធ្នាក់ពង្រាយស្នេហ៍ ។ នាងរស់នៅសាមញ្ញប៉ុន្តែនាង មានគំនិតខ្ពស់! ទៅថ្ងៃមុខ តើយើងអាចមានសមត្ថភាពធ្វើជាដៃគូ របស់នាងបានទេ? តើយើងត្រូវធ្វើយ៉ាងម៉េច ដើម្បីទាញភាព ជោគជ័យរបស់យើងអោយបានស្មើនាងបាន? គិតទៅ នាងជានារី ម្នាក់ដែលបុរសពិបាកនឹងរត់តាមហើយ ព្រោះនាងឈ្លាសវៃខុស នារីធម្មតា ។ យើងវិញក៏ត្រូវតែខំប្រឹងចាប់ពីថ្ងៃនេះទៅដែរ ដើម្បី កុំអោយចាញ់ល្បឿនរបស់ស្រីក្មេងមួយរូបនេះ ។ បើអោយចាញ់ បានមែន វាគួរអោយអាមាសណាស់ ព្រោះ នាងអាចប្រឹងចាប់តាំង ពីបាតដៃទទេរហូតដល់ជោគជ័យដោយខ្លួនឯង... ចំណែកយើង វិញបានចាប់ផ្តើមពីចំណុចខ្ពស់ជាងនាងឆ្ងាយ... បើសិននៅទីបញ្ចប់ យើងបែរជារត់ដល់ទីក្រោយនាង ច្បាស់ជាយើងលែងសល់មុខ សំរាប់អោយនាងមើលតទៅទៀតហើយ ។

សារៈពិចារណាមិនអស់មិនហើយពីរាសីយើង ព្រោះអីស្រីក្មេង ម្នាក់នេះមានគុណសម្បត្តិយ៉ាងខ្ពស់មួយ ដែលធ្វើអោយគេខ្លាចរអារ យ៉ាងខ្លាំង គឺប្រាជ្ញនិងការព្យាយាមដ៏មោះមុតរបស់នាង ។

CHANBOKEO.COM

បវេសនកាលសិស្សក៏បានចូលមកដល់...

នៅមុខអាគារមហាវិទ្យាល័យផ្នែកគ្រប់គ្រង រាសីពាក់អាវស សំពត់ខៀវ ក្រងសក់យ៉ាងមានរបៀប ឈរអោបសៀវភៅសម្លឹង ទៅដំបូលអាគារសាលា ទាំងដួងចិត្តរំភើបក្រៃលែង ៖

- ឱ! មហាវិទ្យាល័យអើយ! ពេលនេះ ខ្ញុំមានវាសនាខ្ពស់ បាន ប្រឡងជាប់ ចូលរៀនឧត្តមសិក្សាដូចបំណងហើយ..!

រាសីរលីងរលោងទឹកភ្នែកដោយក្តីរំភើបផង អាណិតខ្លួនផង ដែលឪពុកម្តាយរបស់នាងគ្មានឱកាស នឹងបានមកឃើញជោគជ័យ របស់នាងថ្ងៃនេះ ។ មាណវីសច្ចាខ្សិបៗទៅមេឃថា ៖

- ខ្ញុំនឹងខំរៀនលុះត្រាតែបានសំរេចជោគជ័យយ៉ាងប្រសើរ... ដើម្បី អនាគតខ្លួនឯង និងដើម្បីប្អូនៗជាទីស្រឡាញ់ទាំងបីនាក់ ។

ពេលនោះ នាងក៏ដើរឡើងទៅរកថ្នាក់រៀន ស្រាប់តែវ៉ាក់អើ នឹងបុរសមួយរូប ពាក់វ៉ែនតាស ដើរឡើងទៅជាន់លើដែរ ។ គេ សម្លឹងមុខនាងឡើងភ្លឹក បន្តិចមក ក៏ដើរឡើងហួសទៅ ។ មើល ទៅគេស្លៀកពាក់រៀបរយថ្លៃថ្នូរណាស់ ។ ឯភាពញញឹមនៅលើផ្ទៃ មុខរបស់គេ ក៏បានខាបយកចំណាប់អារម្មណ៍ពីធិតាយើងភ្លាមដែរ ។ នាងស្ទុះដើរឡើងទៅតាមក្រោយ ក្នុងចិត្តនឹកចង់ដឹងថា ហេតុអ្វីបាន ជាគេសម្លឹងមុខនាងដូច្នោះ ។

នៅក្នុងថ្នាក់រៀន...

រាសីនៅអង្គុយតុខាងគេ កៀនបង្អួច ។ រំពេចនោះសាស្ត្រាចារ្យ មួយរូបក៏បានបង្ហាញខ្លួនឡើង នៅម៉ោងដំបូង ។ រាសីភ្ញាក់ព្រើត ព្រោះសាស្ត្រាចារ្យនោះមិនមែនជានរណាក្រៅពីបុរសដែលនាងជួប អំបាញ់មិញនៅមាត់ជណ្តើរឡើងអាគារនោះឡើយ ។

- សួស្តី! ខ្ញុំឈ្មោះបូរិន្ទ ជាសាស្ត្រាចារ្យអនុបណ្ឌិត...

រាសីស្តាប់ការពន្យល់របស់សាស្ត្រាចារ្យផង លួចសង្កេតកិរិយា ឫកពាបុរសនោះផង ឃើញថាលោកគ្រូបូរិន្ទបានលួចចោលក្រសែ ភ្នែកតាមកញ្ចក់វ៉ែនតាមីញ៉ូបនោះមកលើរូបនាងជាញឹកញយ ។

ថ្ងៃត្រង់មកដល់... រាសីដើរចេញពីសាលា គិតថានឹងរកម៉ូតូ ឌុបជិះត្រឡប់ទៅវិញ ស្រាប់តែវ៉ាក់អីនឹងសាស្ត្រាចារ្យបូរិន្ទនៅមាត់

CHANBOKEO COM

ទ្វាររបងម្ដងទៀត ។

- យី! ជួបគ្នាទៀតហើយ អីក៏ចៃដន្យម្ល៉េះ ? (រាសីគិតក្នុងចិត្ត)

រំពេចនោះ គេញញឹមដាក់នាងយ៉ាងស្រស់ ហើយស្រដីថា ៖

- ស្អែកជួបគ្នាទៀតណា៎ រាសី!

- ចា៎ស លោកគ្រូ!

គេសម្លឹងនារីដោយកែវភ្នែកដ៏មានមន្តស្នេហ៍ ធ្វើនារីនឹកចម្លែកចិត្តតែម្ដង ។ បន្ទាប់មក បុរសក៏បោះជំហានចេញទៅ ។ ភ្លាមនោះបុរសមួយរូបកាន់បាច់ផ្កាមួយបាច់មកហុចចំពោះមុខស្រស់នារី ៖

- សូមជូនពរឲ្យនិស្សិតថ្មីរៀនបានជោគជ័យដល់ទីបញ្ចប់!

រាសីបែរភ្លែត សម្លឹងម្ចាស់បាច់ផ្កា ៖

- បងសយនា ? ជាសះស្បើយហើយហ្នឹង ? (ធិតាលាន់មាត់)

- ទោះមិនជាក៏ប្រឹងអោយជាដែរ ដើម្បីយកផ្កាមកស្វាគមន៍និស្សិត នារីដ៏សំខាន់ម្នាក់ដែលបានចូលរៀនមហាវិទ្យាល័យថ្ងៃដំបូង ។

រាសីញញឹមដាក់នរៈយ៉ាងប៉ប្រឹមព្រោះបានទទួលបាច់ផ្កាពីគេ ។

នៅក្រោមដើមក្ងោកមួយ សយនាកាច់នំបុ័ងដាក់សាច់ជាពីរ ចែករាសីបរិភោគម្នាក់មួយកំណាត់ ៖

- នេះ! ម្នាក់ពាក់កណ្ដាល! ឆ្អែតទេ ប៉ុនហ្នឹង ? ការពិត បងមានតែមួយហ្នឹងទេ ព្រោះពួកម៉ាកគេទិញអោយ ។ គេប្រាប់ថានំបុ័ង នេះឆ្ងាញ់ណាស់ ។ បងក៏នឹកភ្នកដល់រាសីភ្លាម ទើបជិះម៉ូតូយកមក ផ្ញើចែកគ្នាភ្លក្សរសជាតិទៅ មិនដឹងថាឆ្ងាញ់មែនឬយ៉ាងណាទេ ។

រាសីញញឹម ឆ្លើយថា ៖

- ទោះមិនឆ្ងាញ់ក៏ឆ្ងាញ់ដែរ ព្រោះជារបស់ដែលផ្ដិតភ្ជាប់នូវសន្ដានចិត្តដ៏ល្អរបស់បងដែលនឹកឃើញដល់រាសីក្រីក្រ!

ឮដូច្នោះសយនាក៏ញញឹមយ៉ាងស្រស់តែម្ដង រួចគេលើកទឹកផ្លែឈើមួយកំប៉ុងមកកាច់បើកគំរប ហុចទៅអោយមាណវី ៖

- នេះទឹក! រាសីញ៉ាំមុនទៅ! ទុកពាក់កណ្ដាលអោយបង!

រាសីសម្លឹងមុខនរៈ ៖

CHANBOKEO.COM

- បងញាំដែលមាត់រាសី មិនខ្លាចឆ្លងរោគទេ ?

- មិនខ្លាចទេ! (នរៈឆ្លើយទាំងញញឹមដដែល)

- ម៉េចបានជាមិនខ្លាច ?

- ព្រោះរាសីគ្មានជំងឺផ្ដេសផ្ដាសដូចអូនប្រាប់បងនោះឯណា ?

- ម៉េចក៏បងដឹង ?

- ព្រោះឃើញលទ្ធផលនៅលើបណ្ណ័ជោះឈាមរបស់អូន!

- អូហ៍! បងឯងចេះធ្វើចោរលួចមើលរបស់គេតាំងពីអង្កាល់ ?

- បន្លំធ្វើចោរខ្លះមិនបានទេ ? ធ្វើប៉ូលីសយូរហើយអផ្សុកណាស់ ។ ធ្វើចោរម្ដងទៅ ទើបជីវិតមានរសជាតិ... ការពិត គឺបងបានរៀន តាមក្បួនរាសី ចាប់ជិនហួនិងថៅកែឌាំងដាក់គុកនោះអី!

រាសីឮហើយ ក៏សើចកក្អឹកឡើង ។ ពេលនោះ នាងដាក់ភ្នែក ទៅអាវនិងមួកដែលនរៈកំពុងពាក់លើខ្លួន ក៏នឹកភ្នកដល់គេម្នាក់ ៖

- បងសយនា! បុរសដែលទៅអូសឡានថៅកែឌាំងពីក្នុងប្រឡាយ ទឹក នៅឯព្រៃកូនខ្លា បាត់ដំបង ប៉ុន្មានខែមុននេះ ជាបងមែនទេ ?

សយនាបើកភ្នែកក្រឡង់ ទំនងភ្ញាក់ផ្អើល ៖

- អូហ៍! រាសីចំណាំបងបានដែរមែនទេ ?

- នេះ មានន័យថាគឺបងមែនតើហ៍! ហើយបងទៅធ្វើការអ្វីជាមួយ ថៅកែឌាំង ? (រាសីជ្រួញចិញ្ចើម) កុំប្រាប់ខ្ញុំណា៎ ថាបងជាបណ្ដាញ របស់ពួកនោះ ?

- ជាបណ្ដាញមែន តែមិនមែនពួកថៅកែឌាំងទេ គឺបណ្ដាញប៉ូលីស ត្បិតកាលនោះ គាត់មានផែនការរត់ថ្នាំញៀនតាមច្រកប៉ៃលិន ។

- អញ្ចឹង បងស្គាល់រាសីតាំងពីពេលនោះម្ល៉េះ ?

- ហ្នឹងហើយ! បងចាំមុខនារីម្នាក់នោះច្បាស់ណាស់! គេស្រែកយំ ជេរថៅកែឌាំង រួចហើយដៀមដាមដាក់បងថា បើថ្ងៃណា អំបែង ដូចរូបគេអណ្ដែតឡើងក្លាយជាថៅកែ គេនឹងចាប់ពួកបងឲ្យធ្វើការ ឲ្យគេ មិនឲ្យទៅបំរើថៅកែទុច្ចរិតសំអុយនោះទៀតឡើយ ហើយ គេនឹងធ្វើឲ្យថៅកែទុច្ចរិតទាំងនោះ លោះព្រលឹងដោយស្នាដៃរបស់ គេទៀតផង ។

CHANBOKEO.COM

- ពុទ្ធោ! ចាំអោយគ្រប់ម៉ាត់តែម្ដងហ្ន៎!

- មែន! ពាក្យនោះមានន័យជិតជំរៅបេះដូងបងណាស់ ព្រោះបាន បង្ហាញនូវឧត្ដមគតិដ៏ខ្ពង់ខ្ពស់របស់នារីសាមញ្ញម្នាក់មួយរូប...

- អញ្ចឹង នៅថ្ងៃឧប្បត្តិហេតុនោះ បងកំពុងទៅស៊ើបការណ៍?

- គឺបងស៊ើបអង្កេតរឿងថៅកែឌាំងនិងជិនហួ ទទួលជួបអូនដោយ ចៃដន្យទាំងពីរលើក ។ ប្រហែលយើងជាគូព្រេងនឹងគ្នាទេដឹង ទើប ទេវតានាំផ្លូវអោយជួបគ្នារាល់ដងយ៉ាងនេះ?

- និយាយផ្ដាសតែម្ដង បងសយនា! ខ្ញុំជាក្មេងនៅរៀនទេណា៎! កុំ អាលនាំក្មេងបែកអារម្មណ៍ ខានរៀនខានសូត្រ ។

នរៈញញឹមនៅស្ងៀម ទំនងខ្លាចចិត្តនារី ។ រាសីក៏ស្រដីបន្ត ៖

- ហើយចុះបងវិញ? ជីវិតអតីតកាលរបស់បងយ៉ាងណាដែរ? រាសីមិនដែលឮបងនិយាយអីប្រាប់ខ្ញុំមួយម៉ាត់នៅឡើយទេ ។

- មានអីនិយាយទៅ បើបងគ្មានអតីតកាលនឹងនិយាយផងហ្នឹង!

- អូហ៍ ហើយចុះម៉ាក់ស្រីខួចនោះ?

- ប្រចណ្ឌបងហ្អែស?

- នរណាថា? បើមិនចង់ប្រាប់ទេ ក៏ហីទៅ ។

- នែ៎ កុំអាលដាក់ងរដាក់បងអី! ការពិត ម៉ាក់ស្រីខួចជាប្អូនស្រី របស់បងតើហ៍ ។ ប្ដីរបស់នាងមានស្រី រួចក៏មានទំនាស់នឹងប្រពន្ធ ទើបលែងលះគ្នាទៅ ។ ឯម៉ាក់ស្រីខួចបានស្លាប់ទៅតាំងពីសំរាល កូនបានមួយអាទិត្យម្ល៉េះ ។ ហេតុនេះ បងក៏ចិញ្ចឹមស្រីខួចជាកូនមក ព្រោះអាណិតគ្នា គ្មានម៉ាក់ប៉ាហៅនឹងគេ ។

- ពុទ្ធោ! គួរអោយអាណិតណាស់!

- មិនអីទេ! បើរាសីអាណិតនាងមែន ឧស្សាហ៍ទៅលេងនាងផង ទៅណា៎! បើសិនជាស្រីខួចមានម៉ាក់ចិត្តល្អៗដូចរាសី ប្រហែលជា គ្នាមានការកក់ក្ដៅក្នុងចិត្តមិនលែងឡើយ ។

- និយាយឌឺដងឲ្យរាសីទៀតហើយ បងនេះ!

- មិនបានឌឺដងទេ បងនិយាយពិតទេតើហ៍! មែនណា៎!

- យី! និយាយអញ្ចឹង មិនខ្លាចសង្សារបងប្រចណ្ឌទេ?

CHANBOKEO.COM

- មិនខ្លាចទេ!

- ព្រោះអីទៅ ?

- ព្រោះបងគ្មានសង្សារនឹងអោយប្រចណ្ឌនោះអី!

- ហ៊ឺ! តើរាសីគួរជឿដែរឬទេហ្ន៎ ?

- ជឿឬមិនជឿ រាសីយកប្រាជ្ញដ៏ឆ្លៀវឆ្លាតរបស់អូននោះ យកទៅ អង្កេតពិសោធន៍មើលទៅ ហើយចាំប្រាប់លទ្ធផលដល់បងផងណា៎!

អ្នកទាំងពីរក៏សម្លឹងមុខគ្នាឡើងសើចញញឹមសាជាថ្មី ដោយដួងចិត្តមានជំនឿលើគ្នាទៅវិញទៅមកយ៉ាងថ្លៃថ្នូរ ។ បន្តិចមក នរៈ ក៏ជិះម៉ូតូឌុបរាសីជូននាងទៅដល់ផ្ទះទើបគេត្រឡប់ទៅវិញ ។

ព្រលប់ថ្ងៃនដែល...

- បងរាសី! មានគេមកលេងបងនែ៎ក!

រាសីងាក់ភ្នែកទៅ ឃើញសារៈកាន់ឥវ៉ាន់មួយស្បោង ។

- ខ្ញុំទិញប្រដាប់ប្រដាសំរាប់សិក្សាមកផ្ញើ (សារៈនិយាយ)

រាសីស្ទុះក្រាលកន្ទេលជូនភ្ញៀវ ថែមទាំងស្រដីថា ៖

- អរគុណណាស់ដែលលោកសារៈស្គាល់ទុក្ខធុរៈរបស់ពួកយើង ។

- ជាបញ្ញើបន្តិចបន្តួចទេ ទៅគិតធ្វើអ្វី ។

- បើពិតជាគ្មានចំណងមែននោះ រាសីពិតជាសប្បាយចិត្តណាស់!

ល្ងាចនោះ សារៈនៅបរិភោគបាយជាមួយគ្រួសាររបស់រាសី ជា លើកដំបូង ។ ប្អូនៗរបស់រាសីលួចមើលកិរិយារបស់មាណវីគ្រប់គ្នា ប៉ុន្តែគ្មាននរណានិយាយអ្វី សួរអ្វីទេ រហូតដល់សារៈចេញទៅវិញ បាត់ ទើបនាំគ្នាចោមលលេងបងស្រីរបស់គេ ៖

- ពួកកន្លង់ហោះហើរក្រឡឹងបងស្រីយើង ព្រឹកល្ងាចតែម្តង!

- បងមិនបានត្រេកត្រអាលរំភើបនឹងមន្តស្នេហ៍របស់កន្លង់ទាំងនេះ ទេ រក្សា រស្មី រដ្ឋា! កុំរៀនភ្លើតភ្លើនតាមគេឲ្យសោះ ។ ធម្មតា ការមានមិត្តជាការប្រសើរ ប៉ុន្តែការរក្សាព្រំដែនរវាងមិត្តឲ្យ ឲ្យស្ថិត នៅក្នុងគន្លងសីលធម៌នោះ រឹងរឹតតែប្រពៃណាស់ទៅទៀត ។ នេះបងកំពុងតែនៅរៀនណា៎ មិនចង់គិតអ្វីឲ្យវែងឆ្ងាយជាងនេះទេ ចាំបងរៀនចប់ឧត្តមសិក្សាមានការធ្វើត្រឹមត្រូវសិន ។

CHANBOKEO.COM

- មកពីយើងឃើញបងទៅមកជិតដិតជាមួយបងសយនានិងលោក សារៈ ទើបចង់ដឹងចិត្តបងថា... (រស្មីទុចង៉ក់មិនហ៊ានបញ្ចប់វាចា)

រាសីញញឹមដាក់ប្អូនស្រី រួចហើយក៏ស្រដីពន្យល់នាងវិញថា ៖

- រស្មី! យើងគ្មានឪពុកម្ដាយចាស់ទុំនៅក្បែរ ជួយណែនាំយើងទេ មានតែខ្លួនយើងប៉ុណ្ណោះដែលត្រូវណែនាំខ្លួនឯងគ្រប់វេលា... ដូច្នេះ បើបុរសមានសមានចិត្តល្អលើយើង យើងក៏ទទួលយកដោយអំណរ ប៉ុន្តែមិនគួរគិតអ្វីវែងឆ្ងាយជាងនោះទេ ។ បងបានសច្ចានឹងខ្លួនឯង ហើយថាបើរៀនមិនទាន់ចប់ បងមិនគិតគូពីរឿង ជ្រើសរើសបុរស ឡើយ គ្រាន់តែរាប់អានគេត្រឹមតែជាមិត្តសិនចុះព្រោះបងស្រឡាញ់ ការសិក្សានិងស្រឡាញ់អនាគតរបស់ខ្លួនឯង ជាជាងយកចិត្តទៅ អាណិតបុរសដែលដើរតាមផ្គាប់ផ្គុនបង ។ រស្មីដឹងទេ? បុរសហ៊ាន លូកថ្លើមយើង ពេលណាដែលយើងបើកដៃឲ្យគេ ។ តែបើយើង រក្សាខ្លួនមធ្យ័ត គេពិតជាមិនហ៊ានបំពានយើងឡើយ ។ បងនៅ ក្មេង ពិតជាមានឱកាសដែលអាចជួបប្រទះបុរសល្អៗជា ច្រើន... បងនឹងសម្លឹងបុរសទាំងឡាយដោយប្រាជ្ញាស្មារតីភ្លឺថ្លា មើលគេឲ្យ គ្រប់ជ្រុងជ្រោយ មុនសំរេចចិត្តជ្រើសរើសនរណាម្នាក់ ជាគូជីវិត ។ ថ្វីបើបងសយនាបានបង្ហាញនូវសម្ពន្ធ័ភាពចំពោះបង យ៉ាងល្អគួរឲ្យ រំភើបចិត្ត តែបងទើបតែស្គាល់គេថ្មីៗ ដូច្នេះត្រូវទុកពេលមើលគេ ឲ្យបានយូរបន្តិចសិន ទើបដឹងច្បាស់ថាគេធ្វើពើជាល្អ ឬក៏គេជា មនុស្សល្អពិតប្រាកដមែន ។ បើគេគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ធ្វើជាគូជីវិតរបស់បងទេនោះ បងក៏នៅមានមិត្តល្អដទៃ ដែលបង អាចសម្លឹងតទៅទៀតបាន ពោលគឺបងមិនបណ្ដោយឲ្យជីវិតបង ទាល់ច្រកត្រឹមបុរសម្នាក់ ដែលគ្មានគុណសម្បត្តិគ្រប់គ្រាន់សំរាប់បង នោះឡើយ ។ កាលបើបងរក្សាកិត្តិយសខ្លួនឲ្យមានតម្លៃ បុរសក៏នឹង ខិតខំដុសខាត់គុណសម្បត្តិរបស់គេឲ្យចាំងភ្នែកបងដូចគ្នា ដើម្បីមក ប្រជែងយកចំណាប់អារម្មណ៍ពីបង... បើបងសយនាជាមនុស្សល្អ ពិតមែន គេប្រាកដជាផ្ដល់កម្លាំងចិត្តឲ្យបងរៀនសូត្រ ចប់ចុងចប់ ដើម ដោយមិនយកចំណងផ្លូវចិត្ត មករំខានការសិក្សារបស់បង ឡើយ ។ ឯលោកសារៈវិញ បងមិនលង់ល្បោយស្នេហ៍និងទឹកលុយ

CHANBOKEO.COM

របស់គេទេ ខ្លាចមានស្រីៗលេចមុខមក ប្រាប់ថាគេជាប្រពន្ធដើម ទីមួយ ទីពីរ ទីបីនោះ តើបងត្រូវគិតយ៉ាងណាទៅវិញ ? តើគួរ ខ្លាចទឹកអាស៊ីដដែរឬទេ ? ឯណាទៅកត្តិយសស្រីក្រមុំ ? រឿងនេះ សុទ្ធតែត្រូវការពេលវេលាសំរាប់ពិនិត្យវិភាគហ្មត់ចត់ណាស់! ជីវិត នារីមិនមែនជាកូនអុកទេ ដែលអាចលើកដាក់ទៅខាងណាក៏ស្រេច ចិត្តនោះ ។ កូនអុកគ្មានចិត្តគ្មានអារម្មណ៍ឡើយ តែយើងជាមនុស្ស មានចិត្តមានអារម្មណ៍ ។ បើសិនដើរធ្លាក់ផ្លូវខុស យើងនឹងឈឺ ខ្មាស ខឹង ខកចិត្ត តូចចិត្តបំផុត... ដូច្នេះ ជាស្រីហើយនៅក្មេង យើងត្រូវប្រយត្ន័មើលមុខមើលក្រោយ មុនបោះជំហានដើរ ។ កុំ អាងតែសំរស់មួយមុខ រួចស្រវាស្រទេញដើររកចាប់បុរសអ្នកមាន ឲ្យគេចិញ្ចឹមយើងឲ្យសោះ ព្រោះថា ពេលណាយើងស្មើយសម្ផស្ស បុរសនឹងបោះបង់យើងចោលហើយ រួចយើងនឹងតែលតោលអស់ កិត្តិយស អស់លំនឹង មិនដឹងជួយខ្លួនយ៉ាងណាក្រៅពីស្រែកជេរ ព្រហ្មលិខិតតែម្យ៉ាង រួចមកក៏ដើរស្វែងរកបុរសថ្មីមកធ្វើជាបង្អែក តទៅទៀត ។ តើយើងនៅមានកិត្តិយសអ្វី កាលបើយើងពឹងផ្អែក ជំហារបុរសដើម្បីរស់ ? បុរសនឹងយំសើចយើងអស់មួយជីវិត កាល បើគេឃើញយើងពុំមានជំហារឹងប៉ឹង ។ រស្មី! អូនបានហែលឆ្លង រួចហើយតើ ថាជីវិតជាអ្នករកស៊ីលក់សំរស់នោះ ជាស្ថានសួគ៌ឬក៏ ជាស្ថាននរក ? ឯបងវិញ បងមិនព្រមដើរផ្លូវដែលរសាត់ឆ្ងាយពី សីលធម៌ទេ ។ ទៅអនាគត បងនឹងបំភ្លឺភ្នែកគ្រប់គ្នាឲ្យគេទទួល ស្គាល់ថាកំទេចអំបែងដូចបង នេះអាចអណ្តែតយ៉ាងខ្ពស់យ៉ាងឆ្ងាយ ដោយកម្លាំងសមត្ថភាពរបស់បងផ្ទាល់តែម្តង ។ រីឯបុរសដែលនឹង មកឈរទន្ទឹមនែបជាគូជីវិតរបស់បង គឺជាមនុស្សដែលមាន សីលធម៌ ហើយទទួលស្គាល់តម្លៃមនុស្សភាពរបស់បងច្បាស់លាស់ ដោយមិនរើសអើងពីអតីតកាលរបស់បង មិនរើសអើងវណ្ណៈឬពូជ អំបូរក្រុមគ្រួសារបងឡើយ ជាពិសេសបំផុតនោះ គឺគេព្រមទទួល ស្គាល់ប្រាជ្ញា និងសមត្ថភាពរបស់នារីតែម្តង!

# **ចប់**

CHANBOKEO.COM

# វាចាចុងក្រោយ

- ស្លឹកឈើអាចជ្រុះឆ្ងាយគល់
- សំដីជាមាគ៌ា ប្រាជ្ញជាអាវុធ
- អតីតកាលមិនអាចវាស់តម្លៃមនុស្សបានពិតប្រាកដទេ ផ្ទុយទៅវិញ ការប្រព្រឹត្តរបស់គេនៅបច្ចុប្បន្ននេះជាកញ្ចក់ដ៏ប្រសើរសំរាប់ឆ្លុះបញ្ជាំង តម្លៃអនាគតរបស់បុគ្គលនោះ ។
- ការព្យាយាមដ៏មោះមុត តែងនាំមនុស្សទៅរកជោគជ័យ ។
- ការមានមិត្ត ជាការប្រសើរ ប៉ុន្តែ ការរក្សាព្រំដែនរវាងមិត្តឲ្យស្ថិត នៅក្នុងគន្លងសីលធម៌ នោះរឹងរឹតតែប្រពៃណាស់ទៅទៀត!
- ឪពុកដែលចម្លងអេដស៍ទៅប្រពន្ធកូន ឲ្យគេស្លាប់ដោយសារអំពើ ពាលកម្ទៅរបស់ខ្លួន តើគួរអោយកូនគិតថា លោកជាអ្នកមានគុណ ឬក៏ លោកជាឃាដករ ? តើគុណនឹងទោសអាចទូទាត់គ្នាបានទេ នៅក្នុង ករណីនេះ ?
- **មានតែមនុស្សកម្ទៅអវិជ្ជាទេ ដែលចូលចិត្តយកកម្លាំងបាយមក ជំនះស្ថានការណ៍ដែលខ្លួនកំពុងចាញ់ប្រៀប ។**
- សត្វតិរច្ឆានគ្មានសតិនឹងយល់ដឹងខុសត្រូវឡើយ ។ ជាតិជាមនុស្ស គួរណាស់តែអាចញែកខ្លួនចេញពីជាតិសត្វតិរច្ឆាន អោយផុតស្រឡះ ដោយកិរិតកំពស់សតិនិងប្រាជ្ញ ដឹងត្រូវ ដឹងខុស ដឹងកែ! !
- វណ្ណៈទ្រព្យធនតែម្យ៉ាង មិនអាចឆ្លុះបញ្ជាំងឲ្យឃើញនូវតម្លៃពិត របស់មនុស្សទេ តែត្រូវមើលសន្ដានចិត្តនិង ការប្រព្រឹត្តរបស់គេ ថែម ទៀតផង ។

អ្នកស្រីកែវចន្ទ័បូរណ៍

អ្នកនិពន្ធ

CHANBOKEO.COM